# មាតិកា

## ជំពូក១៖ ស្ថានភាពរួម


១- សេចក្តីសង្ខេប ៖ ... 1
២- សេចក្តីផ្តើម ... 4
៣- គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ... 5
៣.១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (Rectangular Strategy) ... 5
៣.២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ... 9
៣.៣- ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ ជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ .. 10
៣.៤- យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក ... 13
៤- កសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិ ... 14
៤.១-វិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ ... 14
៤.២-កំណើនផលិតផលកសិកម្មឆ្នាំ ២០១៣ ... 15
៤.៣-ការវិវឌ្ឍនៃផលិតកម្មកសិកម្មរយៈពេល៥ឆ្នាំ ... 18


## ជំពូក២៖ លទ្ធផលនិងទិសដៅ


៥-លទ្ធផលឆ្នាំ២០១៣-២០១៤និងទិសដៅឆ្នាំ២០១៤-២០១៥ តាមបណ្តាអនុវិស័យនានា ... 29
៥.១- ផលិតកម្មដំណាំស្រូវនិងដំណាំផ្សេងៗ (ឧបសម្ព័ន្ធទី១-១១) ... 29
៥.២- ការងារសេវាកម្មកសិកម្មរបស់អគ្គនាយកដ្ឋានកសិកម្ម ... 30
៥.២.១. លទ្ធផល ... 30
៥.២.២. វាយតម្លៃនិងសន្និដ្ឋាន ... 36
៥.២.៣. ទិសដៅនិងវិធានការ ... 36
៥.៣- ការងារស្រាវជ្រាវបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ... 38
៥.៣-១. លទ្ធផល ... 38
៥.៣-២. វាយតម្លៃនិងសំណើ ... 42
៥.៣-៣. វិធានការ ... 43
៥.៤- ការងារសេវាកម្មរបស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល (ឧបសម្ព័ន្ធទី១២-១៤) ... 44
៥.៤.១-លទ្ធផល ... 44
៥.៤.២. វាយតម្លៃនិងសន្និដ្ឋាន ... 55
៥.៤.៣-វិធានការ ... 56
៥.៥- ផលិតកម្មនិងសេវាកម្មដំណាំកៅស៊ូ (ឧបសម្ព័ន្ធទី១៥-១៧) ... 57
៥.៥.១- លទ្ធផល ... 57
៥.៥.២- វាយតម្លៃ ... 62
៥.៥.៣- វិធានការ និងទិសដៅ ... 63
៥.៦- លទ្ធផលការងាររុក្ខកម្ម ... 64

៥.៦.១-លទ្ធផល ... 64
៥.៦.២. វាយតម្លៃនិងសន្និដ្ឋាន ... 68
៥.៦.៣. ទិសដៅនិងវិធានការ ... 68
៥.៧- ការងារជលផល ( ឧបសម្ព័ន្ធទី១៩) ... 68
៥.៧.១- លទ្ធផល ... 68
៥.៧.២- វាយតម្លៃនិងសន្និដ្ឋាន ... 71
៥.៧.៣- ទិសដៅវិធានការ ... 72
៥.៨- ការងារសេវាកម្មនិងការគាំទ្រ ផ្សេងៗទៀត ... 73
៥.៨.១-ការងារគោលនយោបាយផែនការនិងវិនិយោគ ... 73
៥.៨.២-ការងារសហប្រតិបត្តិការអន្តរជាតិ ... 80
៥.៨.៣-ការងារកិច្ចការរដ្ឋបាល ... 84
៥.៨.៤-ការងារនីតិកម្មកសិកម្ម ... 85
៥.៨.៥-ការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង ... 88
៥.៨.៦- ការងារកសិ-ឧស្សាហកម្ម ... 91
៥.៨.៧- ការងារយេនឌ័រ ... 93
៥.៩-ធនធានមនុស្សនិងថវិកា ... 94
៥.៩.១ ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ... 94
៥.៩.២- ការអភិវឌ្ឍន៍ធនធានមនុស្សនៅតាមគ្រឹះស្ថានអប់រំ ... 96
៥.៩.៣- ការងារគណនេយ្យ-ហិរញ្ញវត្ថុ ... 103
៥.១០-កម្មវិធី និងគម្រោងជំនួយដោយដៃគូអភិវឌ្ឍន៍ ... 108
៥.១០.១ គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ... 108
៥.១០.២ គម្រោងជំនួយបច្ចេកទេស ADB-Grant . 0222-CAM/Component1: PFMRDs ... 109
៥.១០.៣ គម្រោងកម្មវិធីខ្សែសង្វាក់ផលិតកម្មកសិកម្មកម្ពុជា ... 109
៥.១០.៤ គម្រោងអភិវឌ្ឍន៍ជនបទតំបន់ទំនាបទន្លេសាប ... 110
៥.១០.៥ គម្រោងបន្សាំនឹងការប្រែប្រួលធាតុអាកាស និងពាណិជ្ជកម្មស្រូវ-អង្ករ ... 113

## ជំពូក៣៖ វាយតម្លៃនិងសន្និដ្ឋាន

៦-វាយតម្លៃរួម ... 114
៧-ទិសដៅរួម ... 116
៨. ការវាយតម្លៃនិងសន្និដ្ឋាន ... 118

# ជំពូក ១
# ស្ថានភាពរួម

## ១- សេចក្តីសង្ខេប ៖

ឆ្នាំ២០១៣ គឺជាឆ្នាំចុងក្រោយ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងក៏ជាឆ្នាំចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ មុតមាំ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

មកទល់ពេលនេះ ការងារបង្កបង្កើនផលរដូវវស្សានិងរដូវប្រាំង ត្រូវបានបញ្ចប់ការដាំដុះជាស្ថាពរ និងឈានដល់ពេលកំណត់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រារព្ធធ្វើសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៣-២០១៤ និងលើកទិសដៅសម្រាប់អនុវត្តឆ្នាំ២០១៤-២០១៥ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញអំពីសមិទ្ធផលដែលសម្រេចបានជាវិជ្ជមាន ក៏ដូចជាការប្រមូលផ្តុំនូវមតិយោបល់ ទស្សនៈទៅលើបញ្ហាប្រឈមទាំងឡាយ និងការវិភាគចែករំលែកលើបទពិសោធន៍ល្អៗ ជាពិសេសការផ្តល់អនុសាសន៍គន្លឹះដ៏មានតម្លៃរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដើម្បីជាត្រីវិស័យក្នុងការរៀបចំជាចក្ខុវិស័យ ជាយុទ្ធសាស្ត្រ និងលើកទិសដៅអនុវត្តបន្តនៅឆ្នាំបន្ទាប់ ឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា។

នារយៈពេលមួយឆ្នាំកន្លងមកនេះ បើទោះបីជាបានជួបប្រទះនូវគ្រោះទឹកជំនន់ធ្ងន់ធ្ងរជាបន្តបន្ទាប់ (ទន្លេមេគង្គនិងទឹកភ្លៀង) កង្វះខាតទឹកនៅពាក់កណ្តាលរដូវវស្សា និងសត្វល្អិត នៅក្នុងខេត្តមួយចំនួនមានខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កណ្តាល កោះកុង ក្រចេះ ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ មណ្ឌលគិរី សៀមរាប ស្ទឹងត្រែង រតនគិរី ស្វាយរៀង តាកែវ ឧត្តរមានជ័យ ប៉ៃលិន ព្រមទាំងរាជធានីភ្នំពេញ រួមទាំងឥទ្ធិពលបន្សល់ពីវិបត្តហិរញ្ញវត្ថុនិងសេដ្ឋកិច្ចពិភពលោក ដែលនៅមិនទាន់មានភាពប្រាកដប្រជានៅឡើយ តែក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំនិងតម្រង់ទិស ក៏ដូចជាវិធានការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែងធ្វើឱ្យផលិតកម្មកសិកម្ម នៅតែមានការកើនឡើងគួរឱ្យកត់សម្គាល់។ ជាក់ស្តែងស្រូវរដូវវស្សាឆ្នាំ២០១៣នេះ ពិតមែនតែមានភាពមិនប្រក្រតីនៃគ្រោះធម្មជាតិ ក៏ស្ថានភាពផលិតកម្មកសិកម្ម ជារួមមានកម្រិតល្អទូទាំងប្រទេស។ យើងបានដាំដុះស្រូវរដូវវស្សាលើផ្ទៃដីជិត២,៥៧លានហត ដែលមានទិន្នផលជាមធ្យមចំនួន២,៩២៥ត/ហត ដោយទទួលបរិមាណផលសរុបជាង ៧,២៧លានតោន និងស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤ លើផ្ទៃដីប្រមាណ៤៨៤ពាន់ហត ដែលមានទិន្នផលជាមធ្យម ៤,៣៨៣ត/ហត ដោយទទួលបានបរិមាណផលសរុបជិត២,១២លានតោន។ សរុបទាំងរដូវវស្សានិងរដូវប្រាំង យើងអនុវត្តបានលើផ្ទៃដីសរុប**៣,០៥២លានហត** ដោយទទួលបរិមាណផលសរុបប្រមាណ**៩,៣៩លានតោនស្រូវ** និងទិន្នផលមធ្យមប្រចាំឆ្នាំ**៣,១៦៣ត/ហត**។ ជារួមតុល្យភាពស្បៀងនៅសល់ប្រមាណ**៣,០៩លានតោនអង្ករ** គិតជាស្រូវជាង**៤,៨លានតោន** លើសឆ្នាំមុន៩៣ពាន់តោនស្រូវ និងខ្ពស់ជាងមធ្យមភាគ១០ឆ្នាំកន្លងមកប្រមាណ១,៣លានតោនអង្ករ ដែលនេះជាជោគជ័យមួយធំធេងរបស់កម្ពុជា។ ការពិសោធន៍ស្រាវជ្រាវដំណាំ ការស្វែងរកបច្ចេកទេសសមស្រប ដើម្បីយកទៅផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ក្នុងការធ្វើប្រពលវប្បកម្មដំណាំ កំពុងត្រូវបានដំណើរការយ៉ាងផុសផុល ពិសេសការអនុវត្តការងារពិសោធន៍ស្រាវជ្រាវលើដំណាំស្រូវយ៉ាងសកម្មនៅ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា តាមកសិដ្ឋានស្ថានីយ៍ មណ្ឌលអភិវឌ្ឍកសិកម្ម និងស្រែកសិករ មានជាអាទិ៍ ការពិសោធន៍ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការប្រើប្រាស់ជី ការពិសោធន៍ប្រៀបធៀបពូជ ការពិសោធន៍បន្សាំពូជ និងការពិសោធន៍អំពីវិធីសាស្ត្រដាំដុះដំណាំផ្សេងៗទៀត។ ការធ្វើបង្ហាញទិវាស្រែ និងការរៀបចំទស្សនៈកិច្ចសិក្សា ដោយមានកសិករចូលរួមត្រូវបានអនុវត្តយ៉ាងសកម្ម និងបានបញ្ចេញពូជស្រូវថ្មីមួយទៀតឈ្មោះ ដំណើប

ស្បៀមង្គលជូនកសិករប្រើប្រាស់។

ផ្លែផ្កាដែលលេចចេញពីការសម្រួចសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញផលិតកម្មស្រូវនិងនាំចេញអង្ករ បាននិងកំពុងរីកចម្រើនគួរឲ្យកត់សម្គាល់។

គួរកត់សម្គាល់ផងដែរថា ការនាំចេញអង្ករកម្ពុជាកំពុងស្ថិតនៅលើនិន្នាការកើនឡើងជាលំដាប់ ជាពិសេសនៅឆ្នាំ២០១៣ កន្លងមកនេះ អង្ករប្រមាណជាង ៣៧៨ ពាន់តោន ត្រូវបាននាំចេញទៅកាន់៦៦ប្រទេសរួចទៅហើយ។ ជាមោទនៈមួយទៀតគឺអង្ករពូជផ្ការំដួលត្រូវបានពិភពលោកទទួលស្គាល់ថាល្អជាងគេក្នុងពិភពលោកក្នុងឆ្នាំ២០១២និងឆ្នាំ២០១៣ជាប់ៗគ្នា។

ចំពោះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មសំខាន់ៗ ក៏មានការកើនឡើងលើសឆ្នាំមុន។ ជារួមឈានមកដល់ពេលបច្ចុប្បន្នការងារបង្កបង្កើនផលដំណាំឆ្នាំ២០១៣-២០១៤នេះ ទទួលបានផលល្អប្រសើរ។

ដោយឡែក ផលិតកម្មសត្វនៅកម្ពុជាជាពិសេស គោ ក្របី និងបក្សីមានការវិវត្តន៍គួរកត់សម្គាល់។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ ឃើញថាផលិតកម្មគោថយចុះប្រមាណ ៤,១៦% ក្របីថយចុះ ៥,៧៦%។ ការថយចុះនេះគឺ បណ្ដាលមកពីមួយផ្នែកធំ ដោយសារការប្រើប្រាស់គ្រឿងយន្តក្នុងផលិតកម្មកសិកម្មជំនួសឲ្យការប្រើប្រាស់កម្លាំងទូសទាញគោ ក្របី (នៅឆ្នាំ២០១៣ ការភ្ជួររាស់ដោយគោ ក្របីមានចំនួន០,៩៦លានហត ស្មើនឹង៣០% នៅខណៈដែលការភ្ជួររាស់ដោយត្រាក់ទ័រ-គោយន្តមានចំនួន២,៣១លានហត ស្មើនឹង៧០%)។ ការចិញ្ចឹមបក្សីពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣៥,៣% គឺពី២០,១៩លានក្បាល ដល់ ២៧,៣២លានក្បាល។

ចំពោះដំណាំអចិន្ត្រៃយ៍ដូចជា កៅស៊ូ ស្វាយចន្ទី ដំណាំឈើហូបផ្លែផ្សេងៗ និងចម្ការ។ល។ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ គួរកត់សម្គាល់ថា មកដល់ឆ្នាំ២០១៣ ផ្ទៃដីដាំដុះកៅស៊ូទូទាំងប្រទេសប្រមាណ០,៣៣លានហត គឺកើនឡើង១៧,៣% ប្រៀបធៀបទៅនឹងឆ្នាំ២០១២ ក្នុងនោះ ការអភិវឌ្ឍវិស័យកៅស៊ូគ្រួសារ មានការវិវឌ្ឍន៍តាមសន្ទុះមួយគួរឱ្យចាប់អារម្មណ៍។

ចំណែកឯវិស័យជលផល ការធ្វើនេសាទទឹកសាបបានកើនឡើង៣,៧%គឺពី៥០៩ពាន់តោននៅឆ្នាំ២០១២ ដល់ប្រមាណ៥២៨ពាន់តោននៅឆ្នាំ២០១៣ ហើយការធ្វើនេសាទសមុទ្រសម្រេចបាន១១០ពាន់តោន កើនលើសឆ្នាំមុន១១%។ ការអភិវឌ្ឍវារីវប្បកម្ម ដូចជាការចិញ្ចឹមត្រី បង្គា សម្រេចបាន៩ម៉ឺនតោន កើនលើសឆ្នាំមុន ២១,៦% និងសហគមន៍នេសាទមានចំនួន៥១៦សហគមន៍ត្រូវបានបង្កើត ក្នុងនោះ៣៦០សហគមន៍ បានចុះបញ្ជីទទួលស្គាល់ ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចហើយ។

ចំពោះការវិវឌ្ឍរីកចម្រើននៃវិស័យជលផល យើងអាចវាយតម្លៃជាជំហានដំបូងថា ការកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២របស់ **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** ដែលបានសម្រេចលុបឡូត៍នេសាទទាំងអស់ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល កំពុងបានផ្ដល់ផលជាវិជ្ជមានដល់ប្រជាពលរដ្ឋទូទាំងប្រទេស ពិសេសការកើនឡើងផលនេសាទតាមគ្រួសារ ដែលមានប្រជានេសាទប្រមាណ១,៥លាននាក់កំពុងចូលរួម។

ការពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើ និងច្បាប់ស្ដីពីជលផល កំពុងត្រូវបានយកចិត្តទុកដាក់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវគ្រប់រូបភាពនៃបទល្មើសផ្សេងៗ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ទន្ទឹមនឹងអនុវិស័យខាងលើ (ផលិតកម្មដំណាំស្រូវ ផលិតកម្ម និងបសុព្យាបាល ផលិតកម្មដំណាំកៅស៊ូ រុក្ខកម្ម ជលផល) ផ្នែកសេវាកម្ម និងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍ និងទិសដៅរបស់រាជរដ្ឋាភិបាលដូចជាការងារវិនិយោគសាធារណៈ ការរៀបចំគម្រោងសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការងារវិនិយោគផ្នែកឯកជនលើវិស័យកសិកម្មមានការកើនឡើង ការងារស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្មកាន់តែទូលំទូលាយ កិច្ចការសហប្រតិបត្តិការអន្តរជាតិកាន់តែល្អប្រសើរឡើង និងការរៀបចំលិខិតបទដ្ឋានច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ត្រូវបានធ្វើកាន់តែច្រើនផងដែរ។

តាមការរៀបរាប់ខាងលើ យើងអាចវាយតម្លៃបានថា បរិមាណផលិតកម្មស្រូវមានការកើនឡើង បើប្រៀបធៀបនឹងឆ្នាំកន្លងមក ជារួមការងារបង្កបង្កើនផលកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំកំពុងវិវឌ្ឍន៍ល្អប្រសើរ និងមានការចាប់អារម្មណ៍ខ្ពស់ពីប្រជាកសិកររបស់យើង។

ជារួមសមិទ្ធផល ដែលសម្រេចបានដូចក្នុងរបាយការណ៍លម្អិតនេះ គឺជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសស្រាក់សស្រាំរបស់ប្រជាពលរដ្ឋផងដែរ។

ជាសន្និដ្ឋាន កសិកម្មកម្ពុជាសម្រេចបាននូវលទ្ធផលល្អប្រសើរ ដោយសារការដាក់ចេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយនិងយុទ្ធសាស្ត្រ ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២និងទី៣ របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

## ២- សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្មនៅឡើយ ហើយមានប្រជាពលរដ្ឋប្រមាណ៨០%រស់នៅជនបទ ក្នុងនោះភាគច្រើនប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ក្នុងលក្ខខណ្ឌនៃដំណើរការវិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងចាត់ទុកថាកសិកម្ម គឺជាវិស័យមួយដែលមានអាទិភាពខ្ពស់នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេសជាតិ។

ដោយយោងលើសារៈសំខាន់ចាំបាច់របស់វិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវយុទ្ធសាស្រ្តនិងផែនការអភិវឌ្ឍន៍ជាតិ ដោយផ្តោតទៅលើការលើកស្ទួយវិស័យកសិកម្មនិងជនបទ ការកាត់បន្ថយភាពក្រីក្រឱ្យបានក្នុងកម្រិតមួយសមស្រប (ជាង១%ក្នុងមួយឆ្នាំ) តាមរយៈការបង្កើនផលិតភាពកសិកម្មធានានូវសន្តិសុខស្បៀង បង្កើតការងារ និងបង្កើនចំណូលប្រចាំគ្រួសារកសិករ ហើយដែលថ្មីៗកន្លងមកនេះ វិស័យនេះអាចធានាបាននូវអតិរេកនៃផលិតផលកសិកម្មបម្រើឱ្យការនាំចេញច្រើនទៀតផង។ យើងបានពិនិត្យឃើញថា កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាទាំងនេះបានឆ្លុះបញ្ចាំងតាមរយៈការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ២០០៩-២០១៣ ដែលត្រូវបានរៀបចំឡើង និងឆ្លើយតបនូវទិសដៅគោលនយោបាយយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ នៃរាជរដ្ឋាភិបាលកម្ពុជា។

ជាការពិតឆ្នាំ២០១៣ គឺជាឆ្នាំចុងក្រោយ នៃការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ និងជាឆ្នាំចាប់ផ្តើមអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃមោះមុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលក្នុងនោះការលើកស្ទួយវិស័យកសិកម្មគឺជាមុំមួយដ៏សំខាន់ សម្រាប់កំណើនសេដ្ឋកិច្ចជាតិ។ ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ការកែទម្រង់ដីធ្លីនិងគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព គឺជាមុខព្រួញស្នូលដើម្បីចូលរួមជំរុញសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំ និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជំនះដោះស្រាយបាននូវការលំបាកផ្សេងៗ ដែលរួមមានកត្តាអវិជ្ជមាននៃធម្មជាតិ ពិសេសគ្រោះទឹកជំនន់ទន្លេមេគង្គ ទឹកភ្លៀង និងកង្វះទឹកក្នុងរដូវវស្សាឆ្នាំ២០១៣ ដែលបានប៉ះពាល់បំផ្លិចបំផ្លាញផលដំណាំស្រូវ និងដំណាំផ្សេងៗប្រមាណជាង១៣០ពាន់ហត រួមនឹងមានជំនន់ទឹកភ្លៀងនៅតំបន់មួយចំនួនទៀត។ ស្ថិតក្នុងបរិបទនេះ វិស័យកសិកម្មសម្រេចបានកំណើនប្រមាណ១,៧%នាឆ្នាំ២០១៣ និងសង្ឃឹមថាវិស័យនេះអាចនឹងទទួលបានកំណើនល្អក្នុងឆ្នាំ២០១៤ និងក្នុងរយៈពេលមធ្យមខាងមុខ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំជំរុញផលិតកម្មកសិកម្មលើគ្រប់មុខព្រួញ ជាពិសេសការបង្កបង្កើនផលដំណាំជាយុទ្ធសាស្រ្តជាអាទិ៍ ដំណាំស្រូវ កៅស៊ូ និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដែលអាចឆ្លើយតបបានទៅនឹងតម្រូវការស្បៀងក្នុងស្រុក និងនៅសល់ស្បៀងសម្រាប់នាំចេញ ជាក់ស្តែងកម្ពុជាអាចនៅសល់ស្រូវជាង៤,៨លានតោន សម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្មអាហារក្នុងស្រុកនិងការនាំចេញ។ ទន្ទឹមនឹងការកែទម្រង់ផ្តាច់ព្រ័ត្រវិស័យជលផល ដែលដឹកនាំប្រកបដោយគតិបណ្ឌិតមុតស្រួចរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ស្ថិតក្នុងបរិយាកាសអំណោយផលនេះ ប្រជាពលរដ្ឋគ្រប់តំបន់និងទីប្រជុំជន បានខិតខំប្រកបមុខរបរយ៉ាងមមាញឹកប្រកបដោយលក្ខណៈប្រកួតប្រជែង ក្នុងបរិបទនៃពាណិជ្ជូបនីយកម្មកសិកម្ម ដែលធ្វើឱ្យវិស័យកសិកម្មកាន់តែមានសភាពសកម្ម និងមានសារៈសំខាន់ក្នុងជីវភាពសង្គម ក៏ដូចជាការគាំទ្រសេដ្ឋកិច្ចជាតិ ទន្ទឹមនឹងរាជរដ្ឋាភិបាលបាននិងកំពុងបង្កើនផ្តោតការយកចិត្តទុកដាក់ និងវិនិយោគកាន់តែខ្លាំងក្លាលើវិស័យកសិកម្មនេះ ដែលជាបុរេលក្ខខណ្ឌផ្តល់ការលើកទឹកចិត្ត និងទាក់ទាញការដាក់ទុនវិនិយោគកាន់តែធំឡើងជាលំដាប់ពីវិស័យឯកជនជាតិនិងអន្តរជាតិ។

កំណើនវិស័យកសិកម្មក្នុងឆ្នាំ២០១៣ បានមកពីការខិខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការបង្កើតបច្ចេកវិទ្យាថ្មីៗ ការផ្តល់សេវាកម្មគាំទ្រ និងការផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យា មានសភាពកាន់តែសកម្ម ចូលជ្រៅដល់មជ្ឈដ្ឋានប្រជាកសិក និងការរួមចំណែកឧបត្ថម្ភពីបណ្តាដៃគូអភិវឌ្ឍន៍របស់កម្ពុជាផងដែរ ជាពិសេសការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញប្បទានដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីចូលរួមជំរុញវិស័យនេះ។

ក្រោយពីរាជរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយស្តីពី ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ បរិមាណអង្ករនាំចេញផ្លូវការក្នុងឆ្នាំ២០១៣ បានកើនដល់ជាង៣៧៨ពាន់តោនទៅកាន់ប្រទេសចំនួន៦៦ និងអង្ករពូជស្រូវផ្ការំដួលត្រូវបានចាត់ទុកថាមានគុណភាពល្អជាងគេក្នុងពិភពលោក។ នេះជាការឆ្លុះបញ្ចាំងនូវការខិតខំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការសម្រេចសកម្មភាពអនុវត្តគោលនយោបាយ ទៅតាមចក្ខុវិស័យប្រក្សត្យរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។ ក្រៅពីអង្ករ ផលិតផល កៅស៊ូ ដំឡូងមី និងពោត បានឈរក្នុងលំដាប់នៃការនាំចេញ ដែលអាចសន្និដ្ឋានបានថាផលិតផលកសិកម្មសម្រាប់ការនាំចេញ របស់កម្ពុជាកំពុងលេចធ្លោនាពេលបច្ចុប្បន្ននេះ។

ជាការសន្និដ្ឋាន វិស័យកសិកម្មបច្ចុប្បន្ននេះ មានការអភិវឌ្ឍប្រកបដោយមោទនភាព ជាពិសេសផលិតកម្មកសិកម្មកម្ពុជានៅតែបន្តឈានចូលដល់ដំណាក់កាលល្អបំផុត ក្នុងប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា។

## ៣- គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.១-យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (Rectangular Strategy)

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្លាសវៃរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានកំណត់ការលើកកម្ពស់វិស័យកសិកម្ម សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ **គោលដៅជាយុទ្ធសាស្ត្រ ៤** និង **វិស័យអាទិភាព ៤** ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ។ គោលដៅជាយុទ្ធសាស្ត្រ ៤ របស់រាជរដ្ឋាភិបាលត្រូវបានកំណត់គឺ÷ (ទី១)ធានាឲ្យបាននូវកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និង ធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឲ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបាន អត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ (ទី២)បង្កើតការងារឲ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អ និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងការទាក់ទាញនិងជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគ ទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស (ទី៣)សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និង (ទី៤)បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាព៤ ដែលក្នុងនោះចំណុចអាទិភាពទី៣ មានពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម÷ “ការអភិវឌ្ឍនិងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម” តាមរយៈ(១)ការបង្កើនតម្លៃបន្ថែមនៃការផលិតនិងការនាំចេញអង្ករ ជាពិសេសការផ្តោតលើអង្ករក្រអូប អង្ករសរីរាង្គ និងកសិផលមានតម្លៃខ្ពស់ឯទៀត ដូចជាកៅស៊ូ ស្វាយចន្ទី ពោត សណ្តែក ល្ង ម្រេច ស្ករត្នោត ផ្លែឈើ កាហ្វេ បន្លែបង្ការនិងផ្កាជាដើម(២)ជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដែលទីផ្សារត្រូវការ ដូចជាសាច់ ត្រី ផលិតផលទឹកដោះគោ ជាដើម(៣)ការជំរុញការលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យកសិឧស្សាហកម្ម និង(៤)ការបង្កើនផលិតភាពទំនើបកម្មកសិកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម។

**ចក្កោណទី១. ការលើកស្ទួយវិស័យកសិកម្ម**

វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រម និងក្នុងវិសាលភាពនិងល្បឿនថ្មី ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម (បើកទូលាយ) ពោលគឺពឹងផ្អែកជាសំខាន់លើធនធានមានស្រាប់ (ធនធានដីនិងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណី ឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម (ស៊ីជម្រៅ) ពោលគឺ ពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី ការស្រាវជ្រាវ និងការអភិវឌ្ឍយន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វនិងវារីវប្បកម្មផង ដោយគិតគូរផងដែរអំពីភាពចាំបាច់ ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និងការធានាចីរភាពបរិស្ថាន និងធនធានធម្មជាតិ។ ទន្ទឹមនេះ ការបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្ម និងការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម នឹងជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាជួយបង្កើនចំណូលជូនកសិករ។

**មុំទី១. ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៥ គឺការខិតខំរក្សាកំណើនក្នុងវិស័យកសិកម្មឱ្យបានក្នុងរង្វង់ ៥%ក្នុងមួយឆ្នាំ ដោយបន្តលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**ទី១.** ការបន្តបង្កើនផលិតភាពស្រូវនិងដំណាំផ្សេងទៀត តាមរយៈការពង្រឹង ការពង្រីក និងការធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេស និងព័ត៌មានទីផ្សារកសិកម្ម ដោយជំរុញសេវាទាំងនោះ ឱ្យមានរចនាសម្ព័ន្ធទៅដល់មូលដ្ឋាន ហើយផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្ត និងដៃគូដែលមានការពាក់ព័ន្ធ ការលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍដើម្បីបង្កើនផលិតភាព និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការផលិតនិងប្រើប្រាស់ពូជដែលមានគុណភាព និងឆ្លើយតបនឹងតម្រូវការទីផ្សារ ការបន្តវិនិយោគនិងការធ្វើវិចារណកម្មការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ការកែលម្អប្រព័ន្ធប្រមូលនិងទុកដាក់កសិផល ការរៀបចំនិងកែសម្រួលក្របខណ្ឌគតិយុត្ត សម្រាប់ការគ្រប់គ្រងការផលិតពូជ ការនាំចូលធាតុចូលកសិកម្ម ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា ដីកសិកម្ម និងសហគមន៍ប្រើប្រាស់ទឹក ព្រមទាំងការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យកសិកម្ម។

**ទី២.** ការបន្តជំរុញពិពិធកម្ម តាមរយៈការលើកកម្ពស់ការស្រាវជ្រាវនិងអភិវឌ្ឍ ការផ្សព្វផ្សាយមុខដំណាំថ្មីៗ ដែលមានសក្តានុពលសម្រាប់ការដាំដុះនិងការនាំចេញ ការពង្រឹងបរិស្ថានអនុគ្រោះ សម្រាប់ទាក់ទាញការវិនិយោគឯកជនពិសេសក្នុងការស្រាវជ្រាវ ការផលិត ការចែកចាយ និងការកែច្នៃកសិផល ការបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធទាំងអស់ ក្នុងការផ្ទេរចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិទ្យាថ្មីៗដល់កសិករ និងការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម។

**ទី៣.** ការបន្តលើកកម្ពស់ពាណិជ្ជូបនីយកម្ម តាមរយៈការជំរុញការអនុវត្តច្បាប់និងគោលនយោបាយ ព្រមទាំងការពង្រឹងយន្តការស្ថាប័ន ដើម្បីជំរុញការធ្វើពាណិជ្ជកម្មនិងការនាំចេញកសិផល រួមមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីសហគមន៍កសិកម្ម ការលើកម្ពស់សមត្ថភាពកែច្នៃ ការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមបញ្ចូលនូវយន្តការច្រកចេញចូលតែមួយ ការពង្រឹងប្រព័ន្ធឡូជិស្ទីក ការលើកស្ទួយគុណភាពកសិផលឱ្យស្របតាមស្តង់ដារអន្តរជាតិ ការបង្កើនសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានតាមថ្លៃសមស្រប ការលើកស្ទួយភាពជាដៃគូរវាងកសិករនិងពាណិជ្ជករ ក៏ដូចជារវាងកសិឧស្សាហកម្មខ្នាតធំ និងកសិកម្មលក្ខណៈគ្រួសារ។

**មុំទី២. ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម**

រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់ជលផល ក្នុងគោលដៅបំពេញតម្រូវការអាហារូបត្ថម្ភ និងថែរក្សាធនធានមច្ឆជាតិឱ្យគង់វង្ស តាមរយៈការរៀបចំសហគមន៍នេសាទ ការអភិរក្សព្រៃលិចទឹក ការប្រយុទ្ធនឹងការនេសាទខុសច្បាប់ និងការបំផុសវារីវប្បកម្ម។

រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យជលផល ដោយលុបចោលទាំងស្រុង ហើយផ្តល់ជូនប្រជាជនធ្វើការនេសាទជាលក្ខណៈគ្រួសារ ទន្ទឹមនឹងការពង្រឹងនិងពង្រីកការរៀបចំសហគមន៍នេសាទ និងតំបន់អភិរក្សជលផល ព្រមទាំងបានអនុវត្តយ៉ាងសកម្មនូវវិធានការការពារព្រៃលិចទឹក ជាពិសេសនៅជុំវិញបឹងទន្លេសាប ដែលជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅ និងជាកន្លែងបន្តពូជរបស់មច្ឆជាតិជាច្រើនប្រភេទ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលនីតិកាលទី៥ មានគោលដៅជំរុញលើកកម្ពស់ចលនាចិញ្ចឹមសត្វនិងវារីវប្បកម្មឱ្យកាន់តែទូលាយថែមទៀត តាមរយៈការបង្កើតក្របខណ្ឌគោលនយោបាយ ដោយផ្អែកលើគោលការណ៍ខ្សែចង្វាក់តម្លៃ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍវិស័យទាំងនេះ ដោយគិតគូរផងដែរដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យនិងភូតគាមអនាម័យ ទន្ទឹមនឹងការអនុវត្តវិធានការមុតស្រួចនានា សំដៅធានារក្សាចីរភាពនៃធនធានជលផល ទាំងក្នុងដែនទឹកសាបនិងសមុទ្រ។

ឆ្លើយតបនឹងគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**ទី១.** ការបន្តជំរុញអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល២០១០-២០១៩សំដៅ បង្កើនផលិតផលត្រីដើម្បីធានាសេចក្តីត្រូវការរបស់ប្រជាជននិងទីផ្សារនាំចេញ ដោយផ្តោតជាសំខាន់លើសរសរស្តម្ភបីគឺ÷ (១)ជលផលទឹកសាបនិងសមុទ្រ (២)វារីវប្បកម្មទឹកសាបនិងសមុទ្រ និង (៣)ការកែច្នៃនិងពាណិជ្ជកម្ម។

**ទី២.** ការជំរុញរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការចិញ្ចឹមសត្វ។

**ទី៣.** ការជំរុញការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍលើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ ការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋាន ទាំងក្នុងវិស័យបសុសត្វ និងវារីវប្បកម្ម។

**ទី៤.** ការជំរុញអនុម័តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំស្ថាប័ន និងគ្រប់គ្រងវិស័យនេះ ក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារអនាម័យលើផលិតផលពីសត្វ ការពង្រឹងនិងជំរុញអនុវត្តវិធានការអនាម័យសត្វ ភូតគាមអនាម័យ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ក៏ដូចជាដើម្បីការពារសុខភាពសាធារណៈ។

**ទី៥.** ការជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ក្នុងទ្រង់ទ្រាយមធ្យមនិងធំ ដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន និងការរកទីផ្សារជូនកសិករ ការលើកទឹកចិត្តការវិនិយោគឯកជន ក្នុងការកែច្នៃផលិតផលសត្វ និងផលិតផលជលផល ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលពាណិជ្ជកម្មលើបសុសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងផលិតផលជលផល។

**មុំទី៣. កំណែទម្រង់ដីធ្លី ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម**

រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តកាន់តែសកម្ម និងស៊ីជម្រៅថែមទៀត នូវកំណែទម្រង់ដីធ្លី ដោយផ្តោតលើការពង្រឹងការគ្រប់គ្រង ការរៀបចំ ការប្រើប្រាស់ និងការបែងចែកដីធ្លី ដើម្បីរួមចំណែកធ្វើឱ្យសម្រេចគោលដៅជាតិ ក្នុងការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាននិងធនធានធម្មជាតិ និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ក្នុងបរិការណ៍នៃសេដ្ឋកិច្ចទីផ្សារ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពលើ÷

- ការបន្តជំរុញរៀបចំគោលនយោបាយដីធ្លីទូលំទូលាយ "សៀវភៅសដីធ្លី"
- ការជំរុញការរៀបចំច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម និងច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម
- ការបន្តជំរុញល្បឿននៃការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី
- ការបន្តជំរុញកសាងទិន្នន័យអំពីការគ្រប់គ្រងនិងនិងប្រើប្រាស់ដីធ្លី ដើម្បីជាមូលដ្ឋានច្បាស់លាស់ក្នុងការរៀបចំផែនការប្រើប្រាស់ និងបែងចែកដីធ្លីឱ្យបានត្រឹមត្រូវ ជាអាទិភាព ដីសម្រាប់កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ ជនបទ ទីក្រុង លំនៅដ្ឋាន និងតំបន់អភិរក្ស សំដៅធ្វើវិចារណកម្មនៃការប្រើប្រាស់ដី ចៀសវាងការប្រើប្រាស់ដី និងការបំប្លែងការប្រើប្រាស់ដីមិនចំសក្តានុពល។ ការយកចិត្តទុកដាក់ នឹងត្រូវផ្តោតទៅលើការបន្តជំរុញកិច្ចការស្រាវជ្រាវ និងការរៀបចំចំណាត់ថ្នាក់ដីទៅតាមប្រភេទមានសក្តានុពលអំណោយផលដល់ផលិតកម្មកសិកម្ម តាមតំបន់ភូមិសាស្ត្រនីមួយៗ

- ការបន្តធានាការគ្រប់គ្រង ការការពារនិងប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព ដើម្បីរក្សាចីរភាពបរិស្ថាន និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ព្រមទាំងការទប់ស្កាត់រាល់ការកាប់ទន្ទ្រានដីព្រៃ និងការចាត់វិធានការតឹងរឹងចំពោះបុគ្គល ដែលរំលោភកាន់កាប់ដីគ្រប់ប្រភេទដោយខុសច្បាប់ និងប្រមូលដីទុកមិនផលិត រួមទាំងការបន្តដកហូតមកវិញនូវសម្បទានដីសេដ្ឋកិច្ច ដែលក្រុមហ៊ុនមិនគោរពកិច្ចសន្យា និងបទដ្ឋានគតិយុត្តជាធរមាន ទន្ទឹមនឹងការឈប់ផ្តល់ថែមទៀតនូវសម្បទានដីសេដ្ឋកិច្ច។
- បន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីកសិកម្មជាលក្ខណៈគ្រួសារ និងការបន្តជួយប្រជាកសិករ ក្នុងការលើកកម្ពស់ផលិតភាពនៃការប្រើប្រាស់ដី។

**មុំទី៤. ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ បានផ្តោតលើការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ និងជលផល ដើម្បីធានាចីរភាពកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ តាមរយៈការជំរុញអនុវត្តកម្មវិធីព្រៃឈើសហគមន៍ ការត្រួតពិនិត្យតាមដានការធ្វើអាជីវកម្មព្រៃឈើ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងការអនុវត្តវិធានការម៉ឺងម៉ាត់ចំពោះបទល្មើសព្រៃឈើ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុង ការអនុវត្តស៊ីជម្រៅនូវកំណែទម្រង់ឡូតិ៍នេសាទនិងជលផល។

ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងនិងពង្រីកថែមទៀត នូវការគ្រប់គ្រងធនធានធម្មជាតិសំដៅរក្សាតុល្យភាពរវាងការអភិវឌ្ឍនិងការអភិរក្ស ពិសេសលើកកម្ពស់វិភាគទាននៃធនធានធម្មជាតិ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈ (១)ការធានាគម្របបៃតង ការអភិរក្សព្រៃឈើនិងសត្វព្រៃ (២)ការធានាចីរភាពនៃធនធានជលផល និង (៣)ការធានាចីរភាពប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាគុណភាពដី និងចីរភាពនៃប្រភពទឹក ដោយផ្តោតទៅលើការការពារជីវចម្រុះ តំបន់ដីសើម និងតំបន់ឆ្នេរ។ ផ្អែកលើអភិក្រមនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ÷

**(ទី១)**ការបន្តគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយចីរភាពនិងសមធម៌ ស្របតាម កម្មវិធីព្រៃឈើជាតិ ពិសេសតាមរយៈការពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ការកំណត់ព្រំប្រទល់ ចំណាត់ថ្នាក់និងការចុះបញ្ជីដែនព្រៃឈើ ការគ្រប់គ្រងនិងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនូវព្រៃឈើរដ្ឋនិងឯកជន ការអនុវត្តវិធានការលើកកម្ពស់ជីវភាព និងការចូលរួមរបស់សហគមន៍ដែលរស់នៅអាស្រ័យព្រៃឈើ ការលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងនិងអភិរក្ស ការកាត់បន្ថយនូវការបាត់បង់និងរេចរិលព្រៃឈើ ការបង្កើនការដាំនិងស្តារព្រៃឈើឡើងវិញ ការពង្រឹងកិច្ចអភិរក្សសត្វព្រៃ និងជម្រកសត្វព្រៃ ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការជំរុញការងារស្រាវជ្រាវនិងផ្សព្វផ្សាយ។

**(ទី២)**ការបន្តពង្រឹងការគ្រប់គ្រងនិងអភិរក្សធនធានជលផលប្រកបដោយចីរភាព ស្របតាម ក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ២០១០-២០១៩ និង សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយវិស័យជលផលជាតិ ពិសេសតាមរយៈការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទគ្រប់ប្រភេទ ជាអាទិ៍ ការពង្រឹងការគ្រប់គ្រងឧបករណ៍នេសាទ ការលុបបំបាត់ការនេសាទហួសកម្រិត ការពង្រឹងសមត្ថភាពសហគមន៍នេសាទ ក្នុងការគ្រប់គ្រង ប្រើប្រាស់ និងអភិរក្សធនធានជលផល ការការពារជីវចម្រុះនិងជម្រកវារីសត្វ ការគ្រប់គ្រងគុណភាពទឹកសាប និងសមុទ្រ ដោយកាត់បន្ថយសារជាតិពុលជាអតិបរមា ការថែទាំនិងជំរុញការដាំព្រៃលិចទឹកនិងព្រៃកោងកាង ការកំណត់ព្រំប្រទល់ព្រៃលិចទឹក និងតំបន់អភិរក្សជលផល ព្រមទាំងការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ។

**(ទី៣)**ការបន្តជំរុញអនុវត្តវិធានការនានា ដើម្បីរក្សាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី សំដៅធានាគុណភាពដីនិងទឹក រួមទាំងទឹកក្រោមដីផង សម្រាប់បម្រើឲ្យវិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការជំរុញការរៀបចំនិងអនុវត្តគោលនយោបាយ និងបទដ្ឋានគតិយុត្ត ព្រមទាំងផែនការសកម្មភាព និងកម្មវិធីនានាឲ្យមានប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចជា ឧទ្យានជាតិ ជម្រកសត្វព្រៃ តំបន់ការពារ តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់អភិរក្សជីវសាស្ត្រ តំបន់អភិរក្សធម្មជាតិ តំបន់ឧទ្យានសមុទ្រ ពិសេសពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

(ទី៤)ការបន្តជំរុញអនុវត្តកិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខណ្ឌគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ តាមរយៈការអនុវត្តក្របខណ្ឌគតិយុត្ត និងយន្តការសម្រាប់ការធ្វើពាណិជ្ជកម្មកាបូន ការពង្រឹងសមត្ថភាព ការរៀបចំ និងអនុវត្តវិធានការសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការសិក្សាពីលទ្ធភាពក្នុងការប្រើប្រាស់យន្តការហិរញ្ញប្បទានផ្នែកបរិស្ថាន ដូចជាការទូទាត់កម្រៃបរិស្ថាន និងមូលនិធិបរិស្ថាន ការពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ រួមទាំងជីវចម្រុះ តំបន់វាលទឹកភ្លៀងនិងតំបន់ដីសើម ព្រមទាំងការពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ៣.២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ កំពុងត្រូវបានរៀបចំ ដោយបានឆ្លុះបញ្ចាំង និងឆ្លើយតបនូវទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក៏កំពុងត្រូវបានរៀបចំធ្វើឱ្យមានសង្គតិភាពជាមួយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ សំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ និងពន្លឿនការកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់និងជំរុញការអភិវឌ្ឍកសិកម្ម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ បានកំណត់ចក្ខុវិស័យដើម្បីធានា "រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ធានាបាននូវភាពមានស្បៀងគ្រប់គ្រាន់និងប្រកបដោយសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋគ្រប់រូបតាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា តាមអភិក្រមនិងក្នុងវិសាលភាពនិងល្បឿនថ្មី សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព"។

ដើម្បីសម្រេចបាននូវទស្សនវិស័យនេះ សកម្មភាពគាំទ្រជាច្រើនត្រូវបានផ្តល់ រួមជាមួយនូវធាតុចូលសំខាន់ៗ សំដៅជំរុញដល់ការលូតលាស់សេដ្ឋកិច្ច ដូចជាការផ្តល់សេវាកម្មមានគុណភាពខ្ពស់ ដែលនាំដល់ការផ្គត់ផ្គង់ស្បៀងប្រកប ដោយសុវត្ថិភាព បង្កើនផលិតភាពកសិកម្មនិងតម្លៃបន្ថែម ដោយផ្អែកទៅលើមូលដ្ឋាននិរន្តរភាព និងប្រសិទ្ធភាពតម្លៃចំពោះវិស័យដែលពឹងផ្អែកលើផលិតកម្មកសិកម្ម នេសាទ និងរុក្ខាប្រមាញ់។

ទិសដៅគោលនយោបាយរួមនឹងត្រូវបានកំណត់សំដៅ "**<u>ជំរុញកំណើនកសិកម្មក្នុងរង្វង់៣-៥%ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារនិងគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព</u>**"។

ដើម្បីធ្វើឱ្យសម្រេចបានទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកម្មវិធីអាទិភាពសំខាន់ៗចំនួនប្រាំ ដែលជាផ្នែកមួយនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅពង្រឹងការអនុវត្តថវិកាតាមកម្មវិធី និងកម្មវិធីវិនិយោគសាធារណៈ ដោយរួមបញ្ចូលនូវប្រភពធនធានថវិកាខាងក្រៅផងដែរ។ កម្មវិធីទាំង៥គឺ÷ កម្មវិធីទី១÷ បង្កើនផលិតភាព ពិពិធកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម កម្មវិធីទី២÷ ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ កម្មវិធីទី៣÷ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស កម្មវិធីទី៤÷ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និង កម្មវិធីទី៥÷ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព។

#### *កម្មវិធីទី-១៖ បង្កើនផលិតភាព ពិពិធកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម*

**គោលបំណងកម្មវិធីទី១**÷ "ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម សំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ដីប្រកបដោយនិរន្តរភាព" ។

#### *កម្មវិធីទី-២៖ ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ*

**គោលបំណងកម្មវិធីទី-២**÷ "ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវនិងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់

សត្វ សាច់សត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ" ។

***កម្មវិធីទី-៣៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស***

**គោលបំណងកម្មវិធីទី-៣÷** "បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំនិងបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។

***កម្មវិធីទី-៤៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព***

**គោលបំណងកម្មវិធីទី៤÷** "បង្កើនការការពារធនធានជលផល បង្កើតតំបន់អភិរក្ស លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ធានាឱ្យបាននូវផ្ទៃនេសាទសម្រាប់សហគមន៍នេសាទ និងបង្កើនផលិតកម្មនេសាទ លើមូលដ្ឋានជំរុញវារីវប្បកម្មក្នុងរង្វង់១៥%ក្នុងមួយឆ្នាំ និងពង្រឹងសមត្ថភាព១០០សហគមន៍នេសាទជារៀងរាល់ឆ្នាំ" ។

***កម្មវិធីទី-៥៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព***

គោលបំណងកម្មវិធីទី៥÷ "បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឱ្យបានយ៉ាងតិច២៥.០០០ហ.តក្នុង១ឆ្នាំ បង្កើតព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃឱ្យបាន៥០.០០០ហ.តក្នុង១ឆ្នាំ និងសហគមន៍ព្រៃឈើឱ្យបាន៣២សហគមន៍ក្នុង១ឆ្នាំ" ។

ដើម្បីសម្រេចបាននូវទិសដៅនិងគោលបំណងគោលនយោបាយទាំងអស់ខាងលើ កិច្ចការជាច្រើននឹងត្រូវអនុវត្តនិងត្រូវសម្រេចឱ្យបាននាពេលខាងមុខ។ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងអនុវិស័យនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវខិតខំរៀបចំសកម្មភាពស្របតាមគោលបំណងនៃកម្មវិធីនីមួយៗ និងអនុវត្តឱ្យបានសកម្មនិងខ្លាំងក្លាថែមទៀតនូវបណ្តាសកម្មភាពទាំងអស់នោះ ដូចមាននឹងចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ នាពេលខាងមុខនេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្តេជ្ញាយ៉ាងមុតមាំ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ដើម្បីប្រែក្លាយផែនការសកម្មភាព ដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើនធនធានក្នុងស្រុក និងកៀងគរធនធានពីបណ្តាដៃគូអភិវឌ្ឍន៍នានា ក៏ដូចជាការធ្វើសមាហរណកម្មឱ្យតួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់ ។

## ៣.៣- ផែនការសកម្មភាព សម្រាប់អនុវត្តគោលនយោបាយ ជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ

ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ កន្លងទៅនេះ ដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ហើយដែលគ្រប់ភាគីដែលពាក់ព័ន្ធក្នុងកិច្ចការនេះ ត្រូវតែរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវទិសដៅធ្វើយ៉ាងណាឱ្យកម្ពុជាមានផលិតផលស្រូវ ដែលផលិតលើសប្រមាណជាង ៤លានតោន និងមានលទ្ធភាពនាំចេញអង្ករជាផ្លូវការជាង ១លានតោន នៅឆ្នាំ២០១៥ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំនូវផែនការសកម្មភាពលម្អិតរបស់ខ្លួន សំដៅឆ្លើយតបនិងសម្រេចបាននូវចំណុចទិសដៅគោលនយោបាយដែលបានកំណត់នេះ។ ឯកសារគោលនយោបាយស្តីពី ការជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ បានកំណត់ច្បាស់នូវចំណុចវិធានការគោលនយោបាយសំខាន់ៗ ទៅតាមដំណាក់កាលនីមួយៗគឺៈ (ទី១) វិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងផលិតកម្ម (ទី២) ពាក់ព័ន្ធនឹងការប្រមូលទិញនិងការកែច្នៃ (ទី៣) ពាក់ព័ន្ធនឹងប្រព័ន្ធសម្រួលការនាំចេញ និង (ទី៤) គឺវិធានការគោលនយោបាយដែលពាក់ព័ន្ធនឹងការស្វែងរកទីផ្សារ។

ដើម្បីឆ្លើយតបបាននូវទិសដៅគោលនយោបាយ ដែលបានដាក់ឱ្យអនុវត្តនេះ "ការបង្កើនផលិតភាព ពិសេសប្រពលវប្បកម្មដំណាំស្រូវនិងពិពិធកម្មរូបនីយកម្ម" គឺជាចំណុចគន្លឹះ ដែលនឹងត្រូវយកចិត្តទុកដាក់និងត្រូវផ្តោតទៅលើការបង្កើនសេវាកម្ម និងអន្តរាគមន៍នានា ដើម្បីជួយដល់ការបង្កើនផលិតផលស្រូវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ការបង្កើនការស្រាវជ្រាវ និងអភិវឌ្ឍ

ពូជស្រូវដែលស្របនឹងលក្ខណៈដី កត្តាអាកាសធាតុ និងពិសេសការកំណត់ប្រភេទពូជសំខាន់ៗ ស្របតាមតម្រូវការទីផ្សារចង់បាន។ល។ ម្យ៉ាងទៀត ការសម្របសម្រួលនិងគាំទ្រវិស័យឯកជនក្នុងការបង្កើនសមត្ថភាពម៉ាស៊ីនកែច្នៃ តម្រូវតាមស្តង់ដារទីផ្សារអន្តរជាតិ គឺជាការចាំបាច់ និងត្រូវតែគាំទ្រឱ្យបានខ្លាំងក្លា។

ការប្រមូលផ្តុំផលិតកម្ម ក៏ជាចំណុចគ្រឹះមួយសំខាន់ផងដែរ ពោលគឺសំដៅសម្រួលដល់ការផ្គត់ផ្គង់ និងប្រមូលទិញជាលក្ខណៈទ្រង់ទ្រាយធំតាមរយៈ "សហគមន៍កសិកម្ម ឬសហករណ៍កសិកម្ម"។ ដូចនេះ ទាមទារឲ្យមានការប្រមូលផ្តុំផលិតកម្មជាចាំបាច់ ហើយសហគមន៍កសិកម្មគឺជាមជ្ឈមណ្ឌលផលិតនិងផ្គត់ផ្គង់ដ៏សំខាន់នាពេលអនាគត។

ក្នុងន័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានតម្រង់ទិសនៃការធ្វើអន្តរាគមន៍ទៅរកការពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម ដើម្បីផលិតក្នុងទ្រង់ទ្រាយធំនាពេលខាងមុខ។ ម្យ៉ាងវិញទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានយកចិត្តទុកដាក់ខ្លាំងក្លាដល់ការគាំទ្រផ្នែកឯកជន ពិសេសបណ្តាក្រុមហ៊ុនដែលចូលរួមក្នុងការធ្វើផលិតកម្មកសិកម្មនៅកម្ពុជា ។

ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិត និងអ្នកប្រមូលទិញ តាមយន្តការ «ផលិតកម្មកសិកម្មតាមកិច្ចសន្យា» គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់ ក្នុងការសម្រេចបាននូវទិសដៅគោលនយោបាយនេះ។ ម្យ៉ាងវិញទៀត ការផ្តល់ព័ត៌មានអំពីទីផ្សារស្រូវអង្ករ ក៏ជាមធ្យោបាយដ៏សំខាន់មួយដើម្បីឱ្យកសិករ ពាណិជ្ជករ មានទំនាក់ទំនងគ្នាក្នុងពាណិជ្ជកម្មកសិកម្មនេះ។ លើសពីនេះទៀតនោះ ការសម្រួលពាណិជ្ជកម្ម និងការនាំចេញតាមរយៈសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការសម្រួលបែបបទលិខិតបទដ្ឋានក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាវិធានការចាំបាច់និងត្រូវពង្រឹងបន្ថែមទៀត។

ផ្អែកលើសារសំខាន់និងភាពចាំបាច់នៃឯកសារគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរៀបចំនូវផែនការសកម្មភាពរបស់ខ្លួនដោយបានលម្អិតនូវអ្វីដែលជាសកម្មភាព និងភារកិច្ចត្រូវអនុវត្ត និងបានដាក់ចុះជាសកម្មភាពជាក់ស្តែងនានាដល់អង្គភាពជំនាញដែលពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តវិធានការគោលនយោបាយនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ក្នុងឆ្នាំ២០១៣កន្លងទៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តនូវបណ្តាសកម្មភាពធំៗមួយចំនួន ដូចជា÷

**(ទ-១) វិធានការពាក់ពន្ធ័នឹងផលិតកម្មស្រូវៈ**

មកទល់នឹងពេលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់រួចហើយនូវប្រភេទពូជស្រូវសំខាន់ៗចំនួន១០ពូជ សម្រាប់ជំរុញផលិតកម្ម រួមមាន÷ ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន៣ពូជគឺ ពូជសែនពិដោរ ពូជជលសារ និងពូជ IR66 ពូជស្រូវកណ្តាលចំនួន៤ពូជៈ ពូជផ្ការំដួល ពូជផ្ការំដេង ពូជផ្ការមៀត និងពូជផ្កាច័ន្ទសែនសរ ពូជស្រូវធ្ងន់ចំនួន៣ពូជៈ ពូជរាំងជ័យ ពូជខា៤ និងពូជខា៦ ។ ការផ្សព្វផ្សាយពូជទាំង១០នេះ ត្រូវបានក្រសួងជំរុញឱ្យអនុវត្ត និងផលិតយ៉ាងខ្លាំងក្លា ពិសេសពូជដែលទីផ្សារត្រូវការ។

ក្រសួងបានធ្វើការសម្រួលនីតិវិធីនៃការនាំចូលពូជស្រូវ ជី ធាតុចូលកសិកម្មផ្សេងៗទៀត ជាមួយនឹងច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម ក៏ត្រូវបានអនុវត្ត។ ក្រសួងបានពង្រឹងនិងពង្រីកសមត្ថភាព CARDI ស្ថានីយ៍ពិសោធន៍ មណ្ឌលអភិវឌ្ឍន៍កសិកម្ម ក៏ដូចជាការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ពង្រីករចនាសម្ព័ន្ធផ្សព្វផ្សាយកសិកម្ម រៀបចំគម្រោងផែនការដើម្បីគាំទ្រការរៀបចំរចនាសម្ព័ន្ធ និងពង្រឹងតួនាទីរបស់អង្គការកសិករ ពិសេសការលើកកម្ពស់សមត្ថភាពរបស់កសិករនិងសហគមន៍កសិកម្មក្នុងការខ្ចី និងការប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវឥណទានពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។ ច្បាប់ស្តីពីសហគមន៍កសិកម្មត្រូវបានរៀបចំរួចរាល់ និងបានអនុម័តដាក់ឲ្យប្រើប្រាស់ដោយរដ្ឋសភា។

ការរៀបចំធ្វើចំណាត់ថ្នាក់តំបន់ប្រើប្រាស់ដីកំពុងត្រូវបានគិតគូរ និងស្វះស្វែងរកធនធានដើម្បីអនុវត្ត។ ច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម កំពុងដំណើរការរៀបចំកសាងយ៉ាងសកម្ម។ អនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបានអនុម័ត និងកំពុងរៀបចំអនុវត្ត។ ការរៀបចំធ្វើជំរឿនកសិកម្មកំពុងអនុវត្ត ដោយបានសហការជាមួយក្រសួងផែនការ ក្រោមជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍។

**(ទ-២) វិធានការពាក់ពន្ធ័នឹងការប្រមូលទិញនិងការកែច្នៃស្រូវៈ** ក្រសួងបានយកចិត្តទុកដាក់ដល់ការពង្រឹងសហគមន៍

កសិកម្ម ដោយបានផ្តោតលើសកម្មភាព÷ ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស ការផ្សារភ្ជាប់ទីផ្សារកសិផល ពង្រឹងសមត្ថភាពគ្រប់គ្រង និងកសាងពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដល់សហគមន៍កសិកម្ម។ ជាក់ស្តែង មកដល់ខែធ្នូ ឆ្នាំ២០១៣នេះ មានសហគមន៍កសិកម្មសរុបចំនួន៤៨៦សហគមន៍ត្រូវបានបង្កើតឡើង និងកំពុងពង្រឹងសមត្ថភាពគ្រប់គ្រង។

(ទ-៣) **វិធានការពាក់ព័ន្ធនឹងប្រព័ន្ធសម្រួលការនាំចេញអង្ករ:** ក្រសួងបានរៀបចំចងក្រងនិងផ្សព្វផ្សាយឯកសារស្តីពីនីតិវិធីនៃការនាំចេញទំនិញជាកម្មវត្ថុការត្រួតពិនិត្យភូតគាមអនាម័យ ស្វែងរកធនធានដើម្បីសិក្សាពីសមាសភាពចង្រៃលើអង្ករនៅក្នុងប្រទេសកម្ពុជា រៀបចំបញ្ជីឈ្មោះសមាសភាពចង្រៃ ដើម្បីឆ្លើយតបការតម្រូវរបស់ភាគីពាក់ព័ន្ធ រៀបចំចងក្រងនិងផ្សព្វផ្សាយអត្ថបទបច្ចេកទេសស្តីពីសមាសភាពចង្រៃលើអង្ករ រៀបចំតំបន់គ្មានសមាសភាពចង្រៃ សម្រាប់ផលិតកម្មដំណាំស្រូវ ដើម្បីនាំចេញទៅតាមតម្រូវការរបស់ប្រទេសនាំចូល ដោយផ្អែកលើស្តង់ដារអន្តរជាតិស្តីពីវិធានភូតគាមអនាម័យ ខិតខំពង្រឹងសមត្ថភាពបច្ចេកទេស ដើម្បីជំរុញការអនុវត្តការងារធ្វូបទកម្ម ហើយច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យកំពុងត្រូវបានរៀបចំ។ ក្រសួងបានចាត់មន្ត្រីជំនាញជាន់ខ្ពស់ ដើម្បីប្រចាំការនៅច្រកចេញចូលតែមួយសម្រាប់ធ្វើសេវាបំពេញបែបបទនាំអង្ករនូវក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រសួងបានរួមសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីកំណត់ស្តង់ដារគុណភាពអង្ករកម្ពុជាឲ្យស្របតាមស្តង់ដារអន្តរជាតិ ។

(ទ-៤) **វិធានការស្វែងរកទីផ្សារ:** ក្រសួងបានផ្សព្វផ្សាយព័ត៌មានតម្លៃស្រូវអង្ករក្នុងស្រុកនិងទីផ្សារអន្តរជាតិ តាមវិទ្យុ ទូរទស្សន៍ សារជាអក្សរ ព្រឹត្តិបត្រ គេហទំព័រព័ត៌មានទីផ្សារកសិកម្ម ធ្វើអង្កេតអំពីលំហូរពាណិជ្ជកម្ម និងចរាចរស្រូវ-អង្ករ និងវិភាគអំពីស្ថានការទីផ្សារតំបន់ និងអន្តរជាតិ ។

ការនាំចេញអង្ករផ្លូវការរបស់កម្ពុជាមាននិន្នាការវិវឌ្ឍគួរឱ្យកត់សម្គាល់ នាឆ្នាំ២០០៩ ការនាំចេញអង្ករឆ្លងកាត់ច្រកចេញចូលតែមួយមានត្រឹមតែ១២.៦១៣តោន និងបានកើនខ្លាំងចាប់ពីមានការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករកាលពីឆ្នាំ២០១០។ អង្ករនាំចេញផ្លូវការបានកើនពី១០៥.២៦០តោននាឆ្នាំ២០១០រហូតដល់៣៧៨.៨៥០តោន នាឆ្នាំ២០១៣នេះ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការនាំចេញអង្ករផ្លូវការនៅទាបជាងសូចនាករកំណត់ ក្នុងឯកសារគោលនយោបាយនៅឡើយ (ឆ្នាំ២០១៣ គ្រោងសម្រេចឱ្យបាន៥០០ពាន់តោន) ដែលកិច្ចការនេះទាមទារឱ្យមានការខិតខំបន្ថែមទៀត ដើម្បីសម្រេចបានដល់គោលដៅកំណត់។







*ប្រភព÷ ក្រុមការងារផ្នែកស្រូវ-អង្ករនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លេខាធិការច្រកចេញចូលតែមួយឆ្នាំ២០១៣*

សហព័ន្ធអ្នកនាំអង្ករចេញកម្ពុជាត្រូវបានបង្កើត និងប្រកាសទទួលស្គាល់នាខែកក្កដា ឆ្នាំ២០១២។ សហព័ន្ធនេះគឺជាដៃគូរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការនាំចេញអង្ករកម្ពុជា និងបានដាក់នៅក្នុងក្រុមការងារទី៩ ស្តីពីក្រុមការងារផ្នែកស្រូវអង្ករនៃវេទិការាជរដ្ឋាភិបាល ផ្នែកឯកជន។ កម្ពុជាមានភាពអនុគ្រោះពន្ធគយសម្រាប់ទីផ្សារនៅអឺរ៉ុប ដែលកត្តានេះបានធ្វើឱ្យកម្ពុជាមានឧត្តមភាពប្រៀបធៀបផ្នែកតម្លៃបើធៀបនឹងប្រទេសជិតខាង ក៏ប៉ុន្តែទីផ្សារសហគមន៍អឺរ៉ុប បានរឹតបន្តឹងផ្នែកស្តង់ដារអង្ករ អនាម័យនិងភូតគាមអនាម័យ (SPS) និងអង្ករដែលប្រើពូជ GMO។ ដូចនេះ ដើម្បីមានលទ្ធភាពនាំចូលទៅទីផ្សារអឺរ៉ុប កម្ពុជាត្រូវបំពេញលក្ខខណ្ឌឲ្យបានត្រឹមត្រូវនិងមានការធានាច្បាស់លាស់។

កង្វះខាតទុនសម្រាប់ប្រមូលទិញស្រូវនៅរដូវប្រមូលផលគឺជាបញ្ហាមួយគួរកត់សម្គាល់ ដែលកត្តានេះបានធ្វើឱ្យស្រូវកម្ពុជាហូរចេញទៅក្រៅ ជាពិសេសទៅវៀតណាមនិងថៃ។ ការខ្ចីទុនពីធនាគារក៏មានការលំបាក ដោយសារខ្វះទ្រព្យបញ្ចាំឬធានា ហើយចំនួននៅមានកម្រិតទាប ដែលកិច្ចការនេះនឹងត្រូវពិភាក្សាដើម្បីស្វែងរកដំណោះស្រាយ។

## ៣.៤- យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក

យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក មានទស្សនៈវិស័យ “ធានាឱ្យមានស្បៀងនិងទឹកគ្រប់គ្រាន់ មានសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូបភាពក្រីក្រត្រូវបានកាត់បន្ថយ រួមចំណែកក្នុងការលូតលាស់សេដ្ឋកិច្ចជាតិ (បង្កើនផលិតផលសរុបក្នុងស្រុកសម្រាប់ប្រជាជនម្នាក់ៗ) និងធានាឱ្យបាននូវចីរភាពធនធានធម្មជាតិ”។

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយន្តការដើម្បីគៀងគរជំនួយនិងធនធានសម្រាប់អនុវត្ត ជាពិសេសអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក តាមរយៈយន្តការសហប្រតិបត្តិការទ្វេភាគីពហុភាគី ជំនួយអភិវឌ្ឍន៍ផ្លូវការ និងយន្តការក្រុមការងារបច្ចេកទេសនានា។ ទស្សនវិស័យទិសដៅនិងកម្មវិធីរបស់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនិងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹកនេះ គឺសមស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីររបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ហើយក៏ស្របតាមដំណើរការវិវឌ្ឍ និងនិន្នាការប្រកួតប្រជែងនៅលើទីផ្សារនៅក្នុងតំបន់ និងលើសកលលោក និងតាមតម្រូវការសេដ្ឋកិច្ចទីផ្សារសេរី។ ប្រការទាំងអស់នេះហើយ ដែលធ្វើឱ្យដៃគូអភិវឌ្ឍន៍នានាមានការចូលរួមយ៉ាងពេញទំហឹងក្នុងការកសាងយុទ្ធសាស្ត្រនេះ បានផ្តល់ជំនួយទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់គាំទ្រសកម្មភាពទាំងឡាយ ដែលមានចែងក្នុងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹកនេះ។

ផ្អែកលើទស្សនវិស័យរយៈពេលវែង យុទ្ធសាស្ត្រនេះមានគោលដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ធានាបាននូវសន្តិសុខស្បៀង និងការលូតលាស់សេដ្ឋកិច្ច តាមរយៈការបង្កើននូវផលិតភាពនិងពិពិធកម្មកសិកម្ម បង្កើនការអភិវឌ្ឍនិងគ្រប់គ្រងធនធានទឹក។ ដើម្បីសម្រេចបាននូវគោលដៅនេះ យុទ្ធសាស្ត្របានកំណត់នូវកម្មវិធីសំខាន់ចំនួន៥គឺៈ ទី(១) កម្មវិធីគាំទ្រដល់ការពង្រឹងសមត្ថភាពនិងគ្រប់គ្រងស្ថាប័នសម្រាប់វិស័យកសិកម្មនិងទឹកៈ ទី(២) កម្មវិធីគាំទ្រសន្តិសុខស្បៀង ទី(៣) កម្មវិធីគាំទ្រកសិកម្មនិងកសិពាណិជ្ជកម្ម ទី(៤) កម្មវិធីគ្រប់គ្រងធនធានទឹក ការស្រោចស្រពនិងដីធ្លី ទី(៥) កម្មវិធីស្រាវជ្រាវ អប់រំនិងផ្សព្វផ្សាយសម្រាប់កសិកម្មនិងធនធានទឹក។

ដោយផ្អែកលើទិសដៅនេះ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹកនិងឧតុនិយមនាំមុខ និងដោយមានការសម្របសម្រួលគាំទ្រពីដៃគូអភិវឌ្ឍន៍ បានកំណត់រៀបចំកម្មវិធីទាំង៥រួចជាស្ថាពរ។ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ដោយមានការជួយឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍ បានពិនិត្យនិងរៀបចំធ្វើសុខុដុមនីយកម្មកម្មវិធីទាំង៥នេះ ក្នុងគោលបំណងដើម្បីកំណត់អាទិភាពកម្មវិធីទាំងអស់ឱ្យមានលក្ខណៈស្របគ្នាទាក់ទងគ្នានិងតាមលំដាប់។ ជាលទ្ធផលការធ្វើសុខុដុមនីយកម្មកម្មវិធីនេះកំណត់បាននូវផ្នែក (Component) ចំនួន ០៦ ដែលរួមមាន ផ្នែកទី១: គោលនយោបាយ និងបទប្បញ្ញត្តិ ផ្នែកទី២: ការកសាងសមត្ថភាព ស្ថាប័ននិងការអភិវឌ្ឍធនធានមនុស្ស ផ្នែកទី៣: ការស្រាវជ្រាវនិងការអប់រំ ផ្នែកទី៤: សន្តិសុខស្បៀង ផ្នែកទី៥: ការគ្រប់គ្រងធនធានទឹកនិងដីកសិកម្ម និងផ្នែកទី៦: កសិពាណិជ្ជកម្មនិងទីផ្សារ។

មកទល់ពេលនេះ សមាសភាពដឹកនាំនិងគ្រប់គ្រង នៃក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ត្រូវបានកែសម្រួលរួច។ សូចនាករសម្រាប់ការតាមដានរួមគ្នាក៏បានត្រូវរៀបចំ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្ត។ ក្រោយពីការដាក់ចេញនូវយុទ្ធសាស្ត្រ

ចតុកោណដំណាក់កាលទី៣ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៤-២០១៨ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក នឹងត្រូវពិចារណាក្នុងការរៀបចំ យុទ្ធសាស្ត្រកសិកម្មនិងទឹក សម្រាប់អនុវត្តបន្តរយៈពេល៥ឆ្នាំ (២០១៤-២០១៨) ដើម្បីឱ្យស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសភាពប្រទាក់ក្រឡាគ្នាជាមួយផែនការអភិវឌ្ឍន៍តាមវិស័យទាំង២ (កសិកម្មនិងទឹក)។

## ៤- កសិកម្មក្នុងកំណើនសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មមានសារៈសំខាន់បំផុត ក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ព្រោះវិស័យនេះអាចផ្តល់នូវប្រភពស្បៀងអាហារ សម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍផ្នែកកសិឧស្សាហកម្មនិងជាប្រភពចំណូលជាតិសំខាន់ ដែលទទួលបានពីការធ្វើផលិតកម្ម និងការនាំចេញផលិតផលកសិកម្មចូលទៅក្នុងទីផ្សារអន្តជាតិ។ នេះគឺជាចំណុចគន្លឹះចំបងបំផុតដែលអាចបញ្ជាក់បានថា វិស័យកសិកម្មមានតួនាទីក្នុងការជំរុញការរីកលូតលាស់ផ្នែកសេដ្ឋកិច្ច។

តម្រូវការផលិតផលកសិកម្មសម្រាប់អាស៊ីមានការកើនឡើងយ៉ាងឆាប់រហ័ស។ ការកើនឡើងនេះ គឺធ្វើឱ្យកើនឡើងតម្លៃចំណីអាហារ និងការព្រួយបារម្ភចំពោះសុវត្ថិភាពស្បៀងដែលកំពុងបន្តកើតមាន។ តម្លៃវត្ថុធាតុដើមសម្រាប់ការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ដូចជាជ័រកៅស៊ូ រំពឹងថានឹងកើនឡើង ស្របគ្នានឹងនិន្នាការកើនឡើងនៃតម្លៃប្រេងផងដែរ។ ស្ថានភាពសេដ្ឋកិច្ចដែលប្រែប្រួល និងស្ថានភាពនៃការផ្គត់ផ្គង់ចំណីអាហារ អាចបង្កើនតម្រូវការផលិតផលកសិកម្ម។ ដោយគិតគូរពីកត្តាទាំងអស់នេះ វិស័យកសិកម្មត្រូវបានព្យាករណ៍ថានឹងរក្សាបានការអនុវត្តល្អប្រសើរក្នុងឆ្នាំ២០១៤ និងក្នុងរយៈពេលមធ្យមខាងមុខ។ ការនាំចេញផលិតផលកសិកម្ម ពិសេសការនាំចេញអង្ករ ត្រូវបានវាយតម្លៃថាមានការកើនឡើងដោយសាររាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ដល់វិស័យនេះ ។

### ៤.១-វិស័យកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ

វិស័យកសិកម្មមិនត្រឹមតែបានចូលរួមចំណែក ឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺថែមទាំងបានចូលរួមចំណែកដ៏សំខាន់ក្នុងកិច្ចការសង្គម ក៏ដូចជាការចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ។ ពោលគឺវិស័យកសិកម្មអាចដោះស្រាយបាននូវការងារធ្វើរបស់ប្រជាជនរហូតដល់ប្រមាណជិត៧0% និងអាចចូលរួមមួយចំណែកធំដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើផលិតកម្មកសិកម្មនេះ។

ពិនិត្យជារួម អត្រាភាពក្រីក្របានធ្លាក់ចុះពី២៩,៩%ក្នុងឆ្នាំ២០០៨ មកត្រឹម២២,៩%ក្នុងឆ្នាំ២០០៩ ហើយអត្រានេះបានបន្តធ្លាក់ចុះដល់ ២១,១%ក្នុងឆ្នាំ២០១០ និង១៩,៨%ក្នុងឆ្នាំ២០១១ ដែលតាមការប៉ាន់ស្មានគឺកម្ពុជាអាចកាត់បន្ថយអត្រាភាពក្រីក្របានប្រមាណជាង១%ក្នុងមួយឆ្នាំសម្រាប់ឆ្នាំ២០១២ និង២០១៣។ បន្ថែមលើនេះ កម្ពុជាត្រូវបានវាយតម្លៃថាបានសម្រេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ទី១ លើផ្នែកកង្វះអាហារូបត្ថម្ភ ដែលអត្រាប្រេវ៉ាឡង់បានថយចុះពី៣៩,៩%នៅក្នុងចន្លោះឆ្នាំ១៩៩០-៩២ មកត្រឹមតែ១៧,១%ក្នុងចន្លោះឆ្នាំ២០១០-២០១២។

សន្តិភាព ការបង្រួបបង្រួមជាតិ និងស្ថេរភាពសង្គមគឺជាកត្តាគន្លឹះសម្រាប់ការកសាងប្រទេស ពិសេសការអភិវឌ្ឍវិស័យកសិកម្មនេះ។ គោលនយោបាយគាំទ្រដល់ការរីកលូតលាស់នៃវិស័យកសិកម្ម ក៏ជាកត្តាជំរុញមួយទៀតយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យនេះ ដែលធ្វើឱ្យសហគមន៍ដៃគូអភិវឌ្ឍន៍នានា យកចិត្តទុកដាក់ជួយគាំទ្រយ៉ាងខ្លាំងក្លា។ រាជរដ្ឋាភិបាលកម្ពុជា បានជំរុញការអនុវត្តពិពិធកម្ម និងប្រពលវប្បកម្ម ដើម្បីធានាឱ្យបាននូវនិរន្តភាពនៃកំណើនសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ធានាសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋទូទៅ។ ម្យ៉ាងវិញទៀត សក្តានុពលភាពសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ដូចជា កត្តាដីកសិកម្មដែលអាចពង្រីកផលិតកម្មកសិកម្ម លទ្ធភាពបង្កើនទិន្នផលដំណាំ ប្រភពធនធាន ទឹកនិងការស្រោចស្រព កម្លាំងពលកម្មកសិកម្ម។ល។ នឹងអាចរុញការរីកលូតលាស់សេដ្ឋកិច្ចជនបទ និងអាចធ្វើឱ្យមានការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនបន្ថែមទៀត។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយកចិត្តទុកដាក់ជំរុញផលិតភាពកសិកម្ម ដោយខិតខំពង្រឹងថែមទៀតនូវការងារស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម ឱ្យមានប្រសិទ្ធភាពសេវាកម្មគាំទ្រ ដូចជា ការអភិវឌ្ឍនូវទីផ្សារកសិកម្ម និងបទដ្ឋានគតិយុត្តនានា ក៏បានកែលម្អបំពេញបន្ថែមនិងកសាងថ្មី ដែលបានជួយឱ្យការងារដឹកនាំអនុវត្តសកម្មភាពនានា មានលក្ខណៈប្រសើរនិងមានប្រសិទ្ធភាព ។

## ៤.២-កំណើនផលិតផលកសិកម្មឆ្នាំ ២០១៣

### ៤.២.១- ការចូលរួមចំណែករបស់វិស័យសេដ្ឋកិច្ចសំខាន់ៗក្នុង GDP ឆ្នាំ ២០១៣ គិតតាមថ្លៃបច្ចុប្បន្ន (Constant Price)

វិស័យកសិកម្មបានចូលរួមចំណែកប្រហែល៣១,៦% (ថ្លៃបច្ចុប្បន្ន) នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៣នេះ។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ២៤,១% និងវិស័យសេវាកម្មប្រហែល៣៨,៥%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀត ក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មបានថយចុះពី៣៣,៩%-៣១,៦% ក្នុងចន្លោះឆ្នាំ២០១០-២០១៣ ដោយសារតែវិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្មមានមានការកើនឡើងបន្ទាប់ពីឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក។







| | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|
| Crops | 19.0% | 20.6% | 20.1% | 18.7% |
| Livestock & Poultry | 4.5% | 4.2% | 3.9% | 3.6% |
| Fisheries | 7.5% | 7.2% | 7.2% | 7.1% |
| Forestry & Logging | 2.8% | 2.6% | 2.4% | 2.3% |

<u>ប្រភពទិន្នន័យ:</u> តួលេខប៉ាន់ស្មានរបស់ក្រសួងផែនការខែកុម្ភៈ ឆ្នាំ២០១៤

### ៤.២.២-ការចូលរួមចំណែកជា % ផ្នែកកសិកម្មក្នុង GDP ចាប់ពីឆ្នាំ ២០០៣-២០១៣ គិតតាមថ្លៃថេរឆ្នាំ២០០០

គួរកត់សម្គាល់ដែរថា ការចូលរួមចំណែកជា%នៃផ្នែកកសិកម្មក្នុងGDP (គិតតាមថ្លៃថេរឆ្នាំ២០០០) ជារួមមាននិន្នាការថយចុះពី៣២,១%នាឆ្នាំ២០០៣ មកនៅត្រឹម២៦,៧% នៅឆ្នាំ២០០៧ និងកើនឡើងវិញពី២៦,៨%នៅឆ្នាំ២០០៨ដល់២៩% នៅឆ្នាំ២០១០។ នៅចន្លោះឆ្នាំ២០១១-២០១២ ការចូលរួមចំណែករបស់កសិកម្មក្នុង GDP មានស្ថានភាពប្រែប្រួលថយចុះពី ២៨,៤% មកត្រឹម២៧,៥% និងនៅឆ្នាំ២០១៣នេះ មានប្រហែល២៦% (តាមការប៉ាន់ស្មានជាបឋមរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការខែកុម្ភៈ ឆ្នាំ២០១៤)។ សភាពការណ៍នេះ បានបង្ហាញអំពីភាពប្រកួតប្រជែងរីកចម្រើនរួមនៃវិស័យសេដ្ឋកិច្ចទាំងបីរបស់កម្ពុជា ហើយក្នុងនោះវិស័យកសិកម្មនៅតែបន្តរីកចម្រើនទាំងបរិមាណនិងគុណភាព។




### ៩.២.៣-តម្លៃបន្ថែមសរុប (GVA) ផ្នែកកសិកម្មចាប់ពីឆ្នាំ ២០០៣-២០១៣

ការធ្លាក់ចុះនូវចំណែក (%) របស់វិស័យកសិកម្មក្នុង GDP រយៈពេល១០ឆ្នាំកន្លងមក (២០០៤-២០១៣) មិនមែនមានន័យថាផលិតកម្មកសិកម្មធ្លាក់ចុះនោះទេ។ ផ្ទុយទៅវិញ តម្លៃបន្ថែមសរុបនៃផលិតផលកសិកម្ម (Gross Value Added-GVA) បានកើនឡើងពី៥.៥៩៦ពាន់លានរៀលនៅឆ្នាំ២០០៤ រហូតដល់៧.១៧៤ពាន់លានរៀលនៅឆ្នាំ២០០៧ (កើនប្រហែលជាង ៤០%) និងបានបន្តកើនថែមទៀតដល់៩.០៨៧ពាន់លានរៀលឆ្នាំ២០១៣នេះ (តម្លៃគិតតាមថ្លៃថេរឆ្នាំ២០០០)។




### ៩.២.៤-កំណើន ( %) នៃវិស័យកសិកម្មចាប់ពីឆ្នាំ២០០៣-២០១៣

ជារួមកំណើន (%) នៃវិស័យកសិកម្ម មានការកើនឡើងជាមធ្យមប្រចាំឆ្នាំប្រមាណជាពី៣ទៅ៤% (២០០៤-២០១៣) កំណើនមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំដូចដែលបានបង្ហាញតាមក្រាហ្វិកខាងក្រោម ហើយការប្រែប្រួលនេះ មានពាក់ព័ន្ធទៅនឹងស្ថានភាពអាកាសធាតុនៃឆ្នាំនីមួយៗ។ ដូចនេះ វិស័យកសិកម្មគឺពឹងផ្អែកច្រើននៅឡើយលើកកត្តាធម្មជាតិដែលជះឥទ្ធិពលដល់ផលិតកម្មកសិកម្ម។

នៅឆ្នាំ២០១៣ កំណើននៃវិស័យកសិកម្មមានការប្រែប្រួលកំណើនជាខ្លាំង ដែលតាមការប៉ាន់ស្មានគឺមានចំនួនប្រមាណជា១,៧%។ ជាការកត់សម្គាល់ នៅឆ្នាំ២០០៣ វិស័យកសិកម្មកើនក្នុងរង្វង់ប្រហែល១០,៥% និងនៅឆ្នាំ២០០៥ កើនខ្លាំងរហូតដល់១៥,៧% (អាស្រ័យដោយភាពអនុគ្រោះខ្លាំងពីធម្មជាតិ ពិសេសកត្តាទឹកភ្លៀង និងមិនមានបញ្ហាសត្វល្អិតបំផ្លាញ)។ នៅឆ្នាំ២០០៦ វិស័យកសិកម្មបានកើនប្រមាណ៥,៥% និងឆ្នាំ២០០៩ មានកំណើនប្រហែល៥,៤% និងឆ្នាំ២០១០ កំណើនមានត្រឹមតែ៤%។ ដោយឡែកឆ្នាំ២០១១ កំណើនបានធ្លាក់ចុះប្រហែលជាង៣,១% ដែលនេះគឺជាឥទ្ធិពលនៃគ្រោះទឹកជំនន់នៅរដូវវស្សាឆ្នាំ២០១១កន្លងទៅ និងនៅឆ្នាំ២០១៣កំណើនមានប្រមាណ១,៧%។ គួរកត់សម្គាល់ដែរថា នៅឆ្នាំ២០០៤ កំណើនផ្នែកកសិកម្មជាចំនួនអវិជ្ជមាននេះ គឺអាស្រ័យដោយការជួបប្រទះធ្ងន់ធ្ងរពីកត្តាធម្មជាតិ

ដែលរួមមាន ទឹកជំនន់ រាំងស្ងួត និងការបំផ្លាញដំណាំដោយសត្វចង្រៃ។




## ៤.២.៥-សមាសភាពនៃអនុវិស័យក្នុងវិស័យកសិកម្មឆ្នាំ២០១៣

ពិនិត្យជារួមយើងសង្កេតឃើញថា នៅក្នុងវិស័យកសិកម្មទាំងមូល សមាសភាគចូលរួមចំណែកគិតជា (%) របស់ផលិតកម្មដំណាំគ្រប់ប្រភេទនាឆ្នាំ២០១៣ មានចំនួនជាងពាក់កណ្ដាល ពោលគឺកើនដល់៥៤,២០%នៃផលិតផលសរុបរបស់វិស័យកសិកម្ម។ ផលិតកម្មនេសាទ បានចូលរួមចំណែកច្រើនបង្គួរបន្ទាប់ពីដំណាំ គឺមានប្រមាណ២៦,៤៥% (កើនប្រមាណ១% ធៀបឆ្នាំ២០១២មានចំនួ២៥,៤០%) ផលិតកម្មសត្វបានចូលរួម១៤% និងអាជីវកម្មព្រៃឈើមានត្រឹមតែ៥,៤៩%ប៉ុណ្ណោះ។

ផលិតកម្មដំណាំ ពិសេសស្រូវនៅតែជាមុខដំណាំសំខាន់សម្រាប់ការរកចំណូលរបស់កសិករ។ មុខរបរអាជីវកម្មបន្ទាប់ គឺអាចសន្និដ្ឋានថាអាជីវកម្មនេសាទ (មានសមាសភាគប្រមាណ ២៥-២៧% ពីឆ្នាំ២០០៨-២០១៣) និងផលិតកម្មសត្វមានការចូលរួមតិចជាងអាជីវកម្មនេសាទ (១២,៨-១៥,៥% ក្នុងកំឡុងពេល៦ឆ្នាំកន្លងទៅនេះពីឆ្នាំ២០០៨-២០១៣)។ ដោយឡែក ចំពោះអាជីវកម្មព្រៃឈើមាននិន្នាការថយចុះជាបន្តបន្ទាប់ (សមាសភាគចូលរួមក្នុងវិស័យកសិកម្មមានត្រឹមតែប្រមាណ៥,៤៩% នាឆ្នាំ២០១៣)។




## ៤.២.៦-សមាសភាពនៃអនុវិស័យក្នុងវិស័យកសិកម្មពីឆ្នាំ២០០៨-២០១៣

ការបង្ហាញតាមក្រាហ្វិកឃើញថា ផ្នែកដំណាំមានការកើនឡើងយ៉ាងខ្លាំង ដែលសមាសភាគរបស់ផ្នែកនេះមានចំនួន៥២,៧% នៅឆ្នាំ២០០៨ និងមាននិន្នាការកើនឡើងដល់៥៤,៨% នៅឆ្នាំ២០១២ និងឆ្នាំ២០១៣ កំណើនមានការប្រែប្រួលបន្តិចបន្តួចមកត្រឹមតែ៥៤,២% ដោយជួបបញ្ហាគ្រោះធម្មជាតិនិងទីផ្សារផលិតផលមានការប្រែប្រួលថ្លៃ។ សមាសភាគនៃផ្នែកផលិតកម្មដំណាំនេះបានកើនប្រហែល១,០៣% បើប្រៀបធៀបនឹងឆ្នាំ២០០៨។ ចំពោះ សមាសភាគផ្នែកជលផល

មានការប្រែប្រួលពី២៥%នៅឆ្នាំ២០០៨ កើនរហូតដល់២៦,៤៥%នាឆ្នាំ២០១៣។ ដោយឡែកសមាសភាគចូលរួមផ្នែកអាជីវកម្មព្រៃឈើ មានការថយចុះជាបន្តបន្ទាប់បើធៀបនិងឆ្នាំ២០០៨ ពី៦,៩%មកត្រឹមតែ៥,៧%នៅឆ្នាំ២០១២ និង៥,៤៩%នៅឆ្នាំ២០១៣។ រីឯសមាសភាគផ្នែកផលិតកម្មសត្វមានការប្រែប្រួលនិងថយចុះ បើធៀបរយៈពេលឆ្នាំ៥កន្លងទៅនេះ (១៥,៥%ឆ្នាំ២០០៨ ថយមកត្រឹម១២,៨%ឆ្នាំ២០១០ មានការកើនឡើង១៥%ឆ្នាំ២០១១ ថយចុះមកត្រឹម១៤,១%ឆ្នាំ២០១២ និង១៣,៨៧%ក្នុងឆ្នាំ២០១៣)។




## ៤.២.៧-ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ២០០៩និងឆ្នាំ២០១១

ជារួមពិនិត្យលើសេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកចម្រើនក្នុងល្បឿនមួយគួរឱ្យទុកចិត្តបាន និងមានកម្លាំងពលកម្មបីប្រភេទជាសំខាន់ត្រូវបានបង្កើតឡើងដើម្បីជំរុញសេដ្ឋកិច្ចនេះ។ បើសង្កេតកម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ២០០៩មានចំនួន៦៦%នៃពលកម្មសរុប ហើយមានការថយចុះមកត្រឹមតែ៦២%ឆ្នាំ២០១១ (ចំណាកស្រុកក្នុងប្រទេសនិងក្រៅប្រទេស)។ អត្រា(%)នៃពលកម្មក្នុងវិស័យឧស្សាហកម្មមានតែ៨%ឆ្នាំ២០០៩ និងកើនដល់១០%ក្នុងឆ្នាំ២០១១ ចំពោះអត្រា(%) នៃពលកម្មក្នុងវិស័យសេវាកម្មមានចំនួន២៦%ឆ្នាំ២០០៩ និងកើនដល់២៨%ឆ្នាំ២០១១ (ប្រភពព័ត៌មានពីក្រសួងផែនការ)។







## ៤.៣-ការវិវឌ្ឍនៃផលិតកម្មកសិកម្មរយៈពេល៥ឆ្នាំ

### ៤.៣.១-ការវិវឌ្ឍផលិតកម្មដំណាំស្រូវ

ផលិតកម្មស្រូវ នៅតែជាផលិតកម្មសំខាន់ចម្បងមួយសម្រាប់ទ្រទ្រង់ជីវភាពប្រជាជននៅជនបទស្ទើរតែទាំងអស់ នៅក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេលកន្លងមកនេះ ក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការណែនាំ និងតម្រង់ទិសរបស់រាជរដ្ឋាភិបាល ដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងប្រជាកសិករទូទាំងប្រទេស ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ បានធ្វើឱ្យផលិតកម្មកសិកម្មមានការរីកចម្រើនឡើងគួរឱ្យកត់សម្គាល់។

ជាក់ស្តែងផលិតកម្មស្រូវប្រចាំឆ្នាំ២០១៣នេះ ពិតមែនតែមានភាពមិនប្រក្រតីនៃបាតុភូតធម្មជាតិ ក៏ស្ថានភាពផលិតកម្មកសិកម្មជារួមមានកម្រិតល្អប្រសើរទូទាំងប្រទេស។ ផលិតកម្មដំណាំស្រូវអនុវត្តបានសរុបប្រមាណជាង**៣លានហត** ផ្ទៃដី

អាចប្រមូលផលបានប្រមាណ**២,៩៧លានហត** និងទិន្នផលជាមធ្យមប្រចាំឆ្នាំទទួលបាន**៣,១៦៣ត/ហត**។ ផ្ទៃដីចំនួន ០,៣៨លានហត ត្រូវបានទទួលរងដោយគ្រោះធម្មជាតិនាឆ្នាំ២០១៣កន្លងទៅនេះ ពិសេសគ្រោះទឹកជំនន់ទន្លេមេគង្គ ជំនន់ទឹកភ្លៀង រាំងស្ងួត និងសត្វល្អិតបំផ្លាញ ដែលក្នុងនោះផ្ទៃដីជិត១៣ម៉ឺនហត ត្រូវបានខូចខាតទាំងស្រុង។ តែទោះជាយ៉ាងណាក្ដី គឺផ្ទៃដីជិត៥ម៉ឺនហតបានស្ដារឡើងវិញ ហើយកម្ពុជាអាចទទួលបានបរិមាណផលស្រូវប្រមាណ**៩,៣៩លានតោន** និងអាចសល់ស្បៀងជាអង្ករជាង**៣,០៩លានតោន** (បរិមាណស្បៀងសល់គិតជាស្រូវនៅសល់ប្រមាណ៤,៨៣លានតោន)។

ក្នុងអំឡុងរយៈពេល៥ឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ចេញពូជស្រូវថ្មីៗចំនួន ០៤ពូជបន្ថែមទៀត គឺ ផ្ការមៀត ផ្ការំដេង ផ្កាច័ន្ទសែនសរ និងដំណើបស្បៃមង្គល។ គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោល ដើម្បីជំរុញការផលិតស្រូវលើសឱ្យបានច្រើនជាង៤លានតោន និងគិតជាបរិមាណអង្ករសម្រាប់នាំចេញជាផ្លូវការត្រូវសម្រេចឱ្យបានយ៉ាងតិច**១លានតោន** (ចំណុចទី៧នៃឯកសារគោលនយោបាយ) និងតាមការកំណត់សូចនាករអតិរេកស្រូវសម្រាប់ឆ្នាំ២០១៣ ត្រូវសម្រេចឲ្យបាន៤,០៦លានតោនស្រូវ ប៉ុន្តែអតិរេកស្រូវសម្រេចបានមានរហូតដល់**៤,៨៣លានតោន**នាឆ្នាំ២០១៣ គឺលើសផែនការកំណត់។ នេះជាជោគជ័យមួយគួរជាទីមោទនៈបំផុត សម្រាប់កម្ពុជាក្នុងការជំរុញផលិតកម្មដំណាំស្រូវ។ ភាពជាមោទនៈមួយទៀតនោះ គឺស្រូវផ្ការំដួល ត្រូវចាត់ទុកជាអង្ករមានគុណភាពល្អលើសគេក្នុងពិភពលោកក្នុងឆ្នាំ២០១២និងឆ្នាំ២០១៣ជាប់ៗគ្នា។

**តារាង÷ ប្រៀបធៀបកំណើនដំណាំស្រូវប្រចាំឆ្នាំ២០០៩-២០១៣**

| **បរិយាយ** | **២០០៩** | **២០១០** | **២០១១** | **២០១២** | **២០១៣** | **ប្រៀបធៀបកើន/ថយ ២០១៣/២០១២** |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ(ហត) | 2,719,080 | 2,795,892 | 2,968,529 | 3,007,545 | 3,052,420 | 1.49% |
| ផ្ទៃដីប្រមូលផល(ហត) | 2,674,603 | 2,777,323 | 2,766,617 | 2,980,297 | 2,968,967 | -0.38% |
| ទិន្នផល(តោន/ហត) | 2.836 | 2.97 | 3.173 | 3.117 | 3.163 | 1.48% |
| បរិមាណផល(តោន) | 7,585,870 | 8,249,452 | 8,779,365 | 9,290,940 | 9,389,961 | 1.07% |
| **បរិមាណអង្ករសល់(លានតោន)** | **2,244,598** | **2,516,752** | **2,780,328** | **3,031,017** | **3,090,452** | **1.96%** |
| **គិតជាស្រូវសល់(លានតោន)** | **3,507,185** | **3,932,425** | **4,344,263** | **4,735,964** | **4,828,832** | **1.96%** |

**ក្រាហ្វិក១ ÷ បង្ហាញសមាសភាគចូលរួមនៃផ្ទៃដីដាំដុះស្រូវវស្សាតាមប្រភេទឆ្នាំ២០១៣**




កសិករបានបង្កើនផ្ទៃដីដាំដុះប្រភេទស្រូវកណ្ដាលមានរហូតដល់ប្រមាណ៤៨% (ប្រជាកសិករទទួលយកនូវបច្ចេកទេសសម្រាប់ដាំដុះប្រភេទស្រូវនេះច្រើន) ប្រភេទស្រូវស្រាលមានប្រហែល២៦% និងស្រូវធ្ងន់មាន២២%។ ដោយឡែកស្រូវ

ចម្ការនិងស្រូវឡើងទឹកមានសមាសភាគតិចតួច ពោលគឺ ស្រូវចម្ការមាន២% និងស្រូវឡើងទឹក២% (ក្រាហ្វិក១)។

ជារួមពីមួយឆ្នាំទៅមួយឆ្នាំ ទាំងផ្ទៃដីអនុវត្ត ផ្ទៃដីប្រមូលផល (ក្រាហ្វិក២) និងបរិមាណផល មានការវិវឌ្ឍឈានឡើងជាលំដាប់។ សមិទ្ធផលទទួលបានទាំងនេះ ក៏អាស្រ័យដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ជាពិសេសគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិតកម្មស្រូវនិងនាំចេញអង្ករ បានជួយធ្វើឱ្យវិស័យកសិកម្មមានដំណើរការលូតលាស់ ទាំងការងារគ្រប់គ្រង ទាំងបច្ចេកទេសដាំដុះ ដោយបានបង្កើនការអប់រំណែនាំដល់ប្រជាកសិករឱ្យកែប្រែទន្លាប់ចាស់ បង្កើនចំណេះដឹងក្នុងផលិតកម្ម និងបច្ចេកទេសកែច្នៃផលិតផលកាន់តែប្រសើរឡើង។

**ក្រាហ្វិក២ ÷ បង្ហាញការវិវត្តន៍នៃផ្ទៃដីដាំដុះនិងផ្ទៃដីប្រមូលផលចាប់ពីឆ្នាំ២០០៣-២០១២ (រយៈពេល ១០ ឆ្នាំ)**




ផលិតកម្មស្រូវរដូវវស្សាមានចំណែកប្រមាណជាង៨៤% នៃផ្ទៃដីផលិតកម្មស្រូវទូទាំងប្រទេស។ ប្រទេសកម្ពុជាទទួលរងនូវគ្រោះទឹកជំនន់ទន្លេមេគង្គ ជន់ទឹកភ្លៀង និងរាំងស្ងួតនៅតាមបណ្តារាជធានីខេត្តចំនួន១៩ក្នុងទូទាំងប្រទេស បានធ្វើឱ្យផ្ទៃដីប្រមូលផលថយចុះ ប៉ុន្តែបរិមាណស្រូវនៅតែបន្តកើនឡើង។ ផ្ទៃដីដាំដុះស្រូវរដូវវស្សាឆ្នាំ២០១៣ សម្រេចបានប្រមាណជិត ២,៥៧លានហត ដែលមានទិន្នផលជាមធ្យម២,៩២៥ត/ហត ដោយទទួលបរិមាណផលសរុបប្រមាណជាង៧,២៧លានតោន និងស្រូវរដូវប្រាំង២០១៣-២០១៤ សម្រេចបានលើផ្ទៃដីដាំដុះជាង០,៤៨៤លានហត ទទួលបានទិន្នផលជាមធ្យម៤,៣៨៥ ត/ហត ដោយទទួលបានបរិមាណផលសរុបជាង២,១២លានតោន។

**តារាង÷បង្ហាញពីផលិតកម្មដំណាំស្រូវវស្សានិងប្រាំងឆ្នាំ២០១៣-២០១៤**

| បរិយាយ | ឯកតា | រដូវវស្សា | រដូវប្រាំង | សរុប |
|---|---|---|---|---|
| ផែនការដាំដុះ | ហត | 2,399,837 | 383,630 | **2,783,467** |
| ផ្ទៃដីអនុវត្ត | ហត | 2,567,723 | 484,697 | **3,052,420** |
| ផ្ទៃដីខូចខាត | ហត | 128,360 | 1,581 | **129,941** |
| ផ្ទៃដីស្តារបាន | ហត | 46,157 | 330 | **46,487** |
| ផ្ទៃដីប្រមូលផល | ហត | 2,485,521 | 483,446 | **2,968,967** |
| ទិន្នផលមធ្យម | ត/ហត | 2.925 | 4.383 | **3.163** |
| បរិមាណផល | តោន | 7,371,251 | 2,118,710 | **9,389,961** |

### ក្រាហ្វិក៣ ÷ បង្ហាញការវិវត្តន៍នៃបរិមាណផលស្រូវប្រចាំឆ្នាំ២០០៤-២០១៣




ក្នុងរយៈពេល១០ឆ្នាំចុងក្រោយចាប់ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១៣ ពិនិត្យឃើញថា បរិមាណផលស្រូវសរុបប្រចាំឆ្នាំ ក៏ដូចជាបរិមាណផលស្រូវរដូវវស្សានិងស្រូវរដូវប្រាំងមានការកើនឡើងជាលំដាប់ ទោះបីផ្នែកនេះបានជួបប្រទះនូវគ្រោះធម្មជាតិដូចជាៈ ទឹកជំនន់(ទន្លេមេគង្គនិងទឹកភ្លៀង) រាំងស្ងួត និងសត្វល្អិតបំផ្លាញខ្លះៗក៏ដោយ(ក្រាហ្វិក៣)។ នៅឆ្នាំ២០១៣នេះ បរិមាណផលសរុបកើនឡើងជាងឆ្នាំ២០១២ប្រមាណ៩៩.០២១តោន ស្មើនឹង១,០៧% ដោយសារការខិតខំស្តារឡើងវិញនូវផ្ទៃដីដែលបានខូចខាត និងម្យ៉ាងទៀតគឺអាស្រ័យដោយប្រជាកសិករមានភាពរីកចម្រើនក្នុងការគ្រប់គ្រងស្រែចម្ការ ការផ្លាស់ប្តូរបច្ចេកទេស និងការផ្លាស់ប្តូរពូជដែលមានទិន្នផលខ្ពស់។

### ក្រាហ្វិក៤ ÷ បង្ហាញអំពីកំណើនផលិតកម្មស្រូវពីឆ្នាំ ២០០៩-២០១៣




កំណើននៃផលិតកម្មដំណាំស្រូវមានការប្រែប្រួលតាមឆ្នាំនីមួយៗ អាស្រ័យដោយលក្ខខណ្ឌនិងភាពអនុគ្រោះនៃកត្តាទឹកនិងសមត្ថភាពទប់ទល់ស្តារបានពីការខូចខាត។ ទន្ទឹមនឹងនោះ បើប្រៀបធៀបទៅនឹងឆ្នាំ២០១២ ផ្ទៃដីអនុវត្តដាំដុះបានកើនប្រមាណ១,៤៩% តែផ្ទៃដីប្រមូលផលថយចុះ០,៣៨% (ខូចខាតដោយទឹកជំនន់ទន្លេមេគង្គនិងទឹកភ្លៀងស្មើ៥,១%នៃផ្ទៃដីអនុវត្ត២,៥៧លានហត) និងបរិមាណផលកើន១,០៧% (ក្រាហ្វិក៤)។ ជារួមផលិតផលស្រូវបានកើនឡើងធៀបនឹងឆ្នាំកន្លងមកដែលទាំងអស់នេះ គឺដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ បានជំរុញឱ្យវិស័យកសិកម្មមានដំណើរការល្អគួរលាស់ទាំងបរិមាណនិងគុណភាព ពិសេសការគ្រប់គ្រងទាំងផ្នែកបច្ចេកទេសដាំដុះ និងការកែច្នៃផលិតផលកាន់តែប្រសើរឡើង។

## ៤.៣.២- ការវិវឌ្ឍន៍ដំណាំកសិកម្ម៤ប្រភេទពីឆ្នាំ២០០៤-២០១៣

**ក្រាហ្វិក៥ ÷ បង្ហាញអំពីផ្ទៃដីដំណាំ៤ប្រភេទឆ្នាំ ២០០៤-២០១៣ (ពោត ដំឡូងមី សណ្តែកបាយ និងសណ្តែកសៀង)**




**តារាង: ផ្ទៃដីដាំដុះដំណាំរដូវសំខាន់ៗ៤ប្រភេទ÷**

| មុខដំណាំ (ហត) | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត | 91,203 | 90,732 | 108,836 | 142,391 | 163,106 | 206,058 | 213,622 | 174,257 | 216,330 | 239,748 |
| ដំឡូងមី | 22,749 | 30,032 | 97,918 | 108,122 | 179,945 | 160,326 | 206,226 | 391,714 | 361,854 | 421,375 |
| សណ្តែកបាយ | 39,089 | 60,570 | 85,140 | 65,261 | 45,605 | 49,599 | 69,206 | 68,111 | 66,850 | 54,312 |
| សណ្តែកសៀង | 84,886 | 118,760 | 75,053 | 76,981 | 74,413 | 96,388 | 103,198 | 70,584 | 71,337 | 80,688 |
| សរុបដំណាំ៤មុខ | **237,927** | **300,094** | **366,947** | **392,755** | **463,069** | **512,371** | **592,252** | **704,666** | **716,370** | **796,123** |

ជារួមផ្ទៃដីដាំដុះដំណាំរដូវ មានការប្រែប្រួលចុះឡើងទៅតាមប្រភេទដំណាំនីមួយៗ ហើយក៏អាស្រ័យទៅតាមឥទ្ធិពលនៃកត្តាថ្លៃនិងទីផ្សារ។ ផ្ទៃដីដាំដុះដំណាំសំខាន់ៗ (ពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង) មាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនឡើងបានពី ៧០៤.៦៦៦ហត (ឆ្នាំ២០១១) ដល់ ៧៩៦.១២៣ហត (ឆ្នាំ២០១៣) ពោលគឺកើនប្រហែល ១១,១៣% (ក្រាហ្វិក៥)។

ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មសរុបទូទាំងប្រទេសសម្រាប់ឆ្នាំ២០១៣ សម្រេចដាំដុះបានលើផ្ទៃដីប្រមាណ ៩៤១.០២៨ហត កើនលើសឆ្នាំមុន៣,១% (ឆ្នាំ២០១២សម្រេចបាន៩១២.៨៨៣ហត) និងបរិមាណផលសរុបនៃដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មប្រចាំឆ្នាំក៏មានការកើនឡើងដែរ គឺបានកើនពី៩,៩៣លានតោននាឆ្នាំ២០១១ ដល់១០,៥៤លានតោននាឆ្នាំ២០១៣ (កើនប្រមាណ១៣,៦៧%)។

ទន្ទឹមនឹងនោះ ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ អនុវត្តបានសរុបចំនួន ១៨៣.០៤៨ហត តិចជាងឆ្នាំមុន០,២៤៥% (ឆ្នាំ២០១២មានចំនួន១៩៣.៧៥១ហត)។ ដូចនេះ ផ្ទៃដីដាំដុះដំណាំទូទាំងប្រទេសសម្រេចបានចំនួន ៤,៥០លានហត (ផ្ទៃដីដាំដុះដំណាំស្រូវចំនួន៣.០៥លានហត ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មចំនួន០,៩៤លានហត ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ចំនួន០,១៨លានហត និងកៅស៊ូ០,៣៣លានហត)។

តារាងៈ ផ្ទៃដីដាំដុះដំណាំគ្រប់ប្រភេទឆ្នាំ២០១៣ (ហត)

| ផ្ទៃដីដំណាំគ្រប់ប្រភេទ | ឆ្នាំ២០១៣ | សេចក្តីផ្សេងៗ |
|---|---|---|
| ផ្ទៃដីដំណាំស្រូវ | 3,052,420 | ស្រូវវស្សានិងប្រាំង |
| ផ្ទៃដីដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម | 941,028 | ពោត ដំឡូងឈើ ដំឡូងជ្វា បន្លែ សណ្តែក ល្ង អំពៅ ក្រចៅ ថ្នាំជក់.... |
| ផ្ទៃដីដំណាំអចិន្ត្រៃយ៍ | 183,048 | ស្វាយចន្ទី ចេក ដូងប្រេង ដូង មៀន ស្វាយ ទឹកដោះ ល្មុត ធូរេន ក្រូច កាហ្វេ ទៀប សាវម៉ាវ ត្របែក ម្នាស់ ម្រេច... |
| ផ្ទៃដីដំណាំកៅស៊ូ | 328,771 | |
| សរុបរួម | 4,505,267 | |

### ៤.៣.៣- ការវិវឌ្ឍវិស័យផលិតកម្មនិងបសុពេទ្យ

ជារួមផលិតកម្មសត្វជាលក្ខណៈគ្រួសារនៅកម្ពុជា ជាពិសេស គោ ក្របី និងបក្សីមានការវិវឌ្ឍគួរកត់សម្គាល់ទាំងចំនួនសត្វ ទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះ អាចធានាការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុកនាពេលកន្លងមក គោក្របីមួយចំនួនត្រូវបាននាំចេញទៅបរទេស។ ដោយធ្វើការប្រៀបធៀបផលិតកម្មសត្វរយៈពេល៥ឆ្នាំ (២០០៩-២០១៣) ឃើញថា ផលិតកម្មគោបានថយចុះចំនួន៤,១៦%។ ដោយឡែក បើប្រៀបធៀបនឹងឆ្នាំ២០១២ ការចិញ្ចឹមគោបានកើនពីចំនួន៣,៣៨លានក្បាល ដល់៣,៤៣លានក្បាល កើនប្រមាណ១,៦០% រីឯក្របីសរុបមានចំនួនជិត៦២៣ពាន់ក្បាល ថយចុះ៥,៧៦% និងជ្រូកចិញ្ចឹមបានជាង២,៤៣លានក្បាល កើនប្រមាណ១០,៣៣%។ ការថយចុះចំពោះសត្វក្របីនេះ គឺមូលហេតុបណ្តាលមកពីជំងឺឆ្លងសត្វ (ពិសេសជំងឺសារទឹក ជំងឺអុតក្តាម និងជំងឺជ្រូកត្រចៀកខៀវ) ចលនាពាណិជ្ជកម្មសត្វនាំចូលនាំចេញមិនផ្លូវការ។ល។ ជាពិសេសប្រជាកសិករភាគច្រើនប្រើប្រាស់ត្រាក់ទ័រនិងគោយន្ត និងបានបោះបង់ចោលការចិញ្ចឹមក្របី។

**ក្រាហ្វិកទី ៦ ÷ បង្ហាញអំពីការវិវត្តន៍សត្វនៅកម្ពុជាពីឆ្នាំ២០០៩-២០១៣**




ការចិញ្ចឹមសត្វស្លាប (មាន់ ទា) ជាលក្ខណៈគ្រួសារពីឆ្នាំ២០០៩ដល់២០១៣ មានការកើនឡើងយ៉ាងខ្លាំងរហូតដល់៣៥,២៨% គឺពីជាង២០,១៩លានក្បាលឆ្នាំ២០០៩ ដល់ជិត២៧,៣២លានក្បាលឆ្នាំ២០១៣។ ជាមួយនោះ ឆ្នាំ២០១៣ សត្វ

ស្លាបមានការកើនឡើងចំនួន១៨,២៦% បើប្រៀបធៀបនឹងឆ្នាំ២០១២ នេះបញ្ជាក់ឱ្យឃើញថា ប្រជាកសិករយល់ដឹងជាបណ្តើរៗនូវបច្ចេកទេសចិញ្ចឹមសត្វតាមគោលការណ៍ជីវសុវត្ថិភាព និងការយល់ដឹងពីវិធានការទប់ស្កាត់ជំងឺឆ្លង។ ជាពិសេសការផ្សព្វផ្សាយទូលំទូលាយក្នុងជួរកសិករ ដែលជាលទ្ធផលចំនួនសត្វស្លាបមានការកើនឡើង និងធានាបាននូវការផ្គត់ផ្គង់សាច់ស៊ុត នៅក្នុងប្រទេស និងកសិកដ្ឋានផលិតកម្មមានលក្ខណៈស្របច្បាប់ជាបណ្តើរៗដែរ។ គួរកត់សម្គាល់ថា មានករណីជំងឺសត្វស្លាប់ កើតមាននៅតំបន់មួយចំនួន ប៉ុន្តែត្រូវបានការពារបានយ៉ាងមានប្រសិទ្ធភាព។ ទន្ទឹមនោះ ពាក់ព័ន្ធនឹងការងារផលិតកម្ម និងបសុព្យាបាលនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចុះនូវវិធានការមួយចំនួន ដើម្បីជំរុញការចិញ្ចឹមសត្វស្លាបទាំងកម្រិតគ្រួសារ និងកម្រិតកសិដ្ឋាន ក៏ដូចជាបានលើកទឹកចិត្តវិនិយោគលើការចិញ្ចឹមមាន់សាច់និងស៊ុត។

ជារួមការចិញ្ចឹមសត្វមានសន្ទុះរីកចម្រើនតាមបែបគ្រួសារនិងបែបពាណិជ្ជកម្មគួរឲ្យកត់សម្គាល់ បើធៀបនឹងឆ្នាំមុនលើកលែងការចិញ្ចឹមក្របី។ ប៉ុន្តែចំពោះការកែលម្អពូជសត្វ គឺកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរផងដែរ ព្រោះប្រជាកសិករភាគច្រើន កាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វជាកត្តាសំខាន់ ដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័សធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារបានឆាប់ទៀតផង។ ចំណែកឯចំណីសត្វ និងដំណាំចំណីសត្វ ប្រជាកសិករ មានការចូលរួមយ៉ាងសកម្ម និងយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចក្នុងស្រុកយ៉ាងផុសផុល។

**ក្រាហ្វិកទី ៧ ÷ បង្ហាញអំពីបម្រែបម្រួលស្ថិតិសត្វស្លាប (មាន់ទា) នៅកម្ពុជាពីឆ្នាំ២០០៩-២០១៣**




### ៤.៣.៤- ការវិវឌ្ឍវិស័យកៅស៊ូ

ដំណាំកៅស៊ូត្រូវបានដាំដុះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជានាឆ្នាំ១៩១០ ដោយជនជាតិបារាំងឈ្មោះ លោក **ប៊ូ យ៉ា** នៅក្នុងស្រុកព្រៃនប់ខេត្តកំពតលើផ្ទៃដីជាង១៥០ហត។ រីឯការអភិវឌ្ឍដំណាំកៅស៊ូជាលក្ខណៈឧស្សាហកម្មដោយទ្រង់ទ្រាយធំត្រូវបានបង្កើតឡើងនាឆ្នាំ១៩២១ ដោយក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗចំនួន៥នៅលើដីក្រហមបាសាល់នាខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តរតនគិរីលើផ្ទៃដីទំហំជាង៥០.០០០ហត។ រហូតមកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកការដាំដុះលើផ្ទៃដីជាង៦៤.០០០ហត ក្នុងនោះផ្ទៃដីចៀរជ័រជាង៣៩.០០០ហត ដោយទទួលបានផលិតផលជ័រកៅស៊ូបានជាង៥០.០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុកនិងការនាំចេញទៅបរទេស។

មកដល់ឆ្នាំ២០១៣ ផ្ទៃដីដាំដុះកៅស៊ូសរុបមានចំនួន៣២៨.៧៧១ហត កើនឡើងចំនួន១៧,៣% ប្រៀបធៀបឆ្នាំ២០១២ (២៨០.៣៥៥ហត) ដែលរួមមាន÷ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) មានចំនួន៥៥.៩០៨ហត (ស្មើនឹង១៧%) ផ្ទៃដីចម្ការកៅស៊ូសម្បទានសេដ្ឋកិច្ចមានចំនួន១៣៥.៤៤៦ហត (ស្មើនឹង៤១,២០%) និងផ្ទៃដីចម្ការកៅស៊ូគ្រួសារតូចតាចនិងឯកជនមានចំនួន១៣៧.៤១៧ហត (ស្មើនឹង៤១,៨០%) នៃផ្ទៃដីសរុប។ ផ្ទៃដីចៀរជ័រសរុបមានចំនួន៧៨.៤៩៣ហត ដែលមានផលិតផលចំនួន៨៥.២៤៤តោន។ តាមការព្យាករណ៍បណ្តោះអាសន្នរហូតដល់ឆ្នាំ២០១៨

កម្ពុជានឹងអាចមានផ្ទៃដីដាំដុះកៅស៊ូដល់ជាង៤២ម៉ឺនហត និងទទួលបានផលិតផលជាង៤០ម៉ឺនតោនក្នុងមួយឆ្នាំ ហើយដល់ឆ្នាំ២០២០កម្ពុជានឹងអាចមានផ្ទៃដីដាំដុះកៅស៊ូដល់ជាង៤៥ម៉ឺនហត និងទទួលបានផលិតផលជាង៤០-៤៥ម៉ឺនតោនក្នុងមួយឆ្នាំៗ។

**តារាងស្ថិតិផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១៣**

| ប្រភេទចម្ការកៅស៊ូ | ផ្ទៃដី (ហត) | | | | សមាមាត្រ |
|---|---|---|---|---|---|
| | សម្បទាន | ចៀរជ័រ | ថែទាំ | សរុប | % |
| **១. ចម្ការកៅស៊ូកសិឧស្សាហកម្ម** | | **២៥.៩៧៧** | **២៩.៩៣១** | **៥៥.៩០៨** | **៥៨,២០** |
| ក. អតីតចម្ការកៅស៊ូរដ្ឋ | ៥៥.៩០៨ | ២៥.៩៧៧ | ២៩.៩៣១ | **៥៥.៩០៨** | ១៧,០០ |
| ខ. ចម្ការកៅស៊ូដីសម្បទានសេដ្ឋកិច្ច | ១៣៥.៤៤៦ | 0 | ១៣៥.៤៤៦ | **១៣៥.៤៤៦** | ៤១,២០ |
| **២. ចម្ការកៅស៊ូគ្រួសារ** | **១៣៧៤១៧** | **៥២.៥១៦** | **៨៤.៩០១** | **១៣៧.៤១៧** | **៤១,៨០** |
| **សរុប** | **៦១៨.៦៩៨** | **៧៨.៤៩៣** | **២៥០.២៧៨** | **៣២៨.៧៧១** | **១០០%** |

កៅស៊ូធម្មជាតិគឺជាប្រភេទដំណាំឧស្សាហកម្មរយៈពេលវែងមួយយ៉ាងសំខាន់ ដែលបានផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ ដល់សង្គម ដល់អ្នកដាំ និងដែលបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការការពារបរិស្ថានធម្មជាតិប្រកបដោយចីរភាព។

សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយកត្តាថ្លៃ និងការគួបផ្សំស្ថានភាពនយោបាយសន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយសេរីភាវូបនីយកម្ម លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក ជាពិសេសមានការចូលរួមពីផ្នែកឯកជន ដែលបានធ្វើវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងផ្នែកកៅស៊ូគ្រួសារ ដោយបានធ្វើឲ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើងគួរជាទីមោទនៈ។ ដោយឡែក ចំពោះចម្ការកៅស៊ូកសិឧស្សាហកម្មមានស្រាប់ ការកើនឡើងផ្ទៃដីដាំដុះថ្មីមិនមានការប្រែប្រួលខ្លាំងគួរឲ្យកត់សម្គាល់ទេ គឺធ្វើការដាំដុះតែលើផ្ទៃដីកៅស៊ូចាស់ កាប់និងដាំឡើងវិញតែប៉ុណ្ណោះ។

**ក្រាហ្វិក៨ ÷ ការវិវឌ្ឍនៅក្នុងការដាំដុះកៅស៊ូឆ្នាំ២០០៨-២០១២**




## ៤.៣.៨- ការវិវឌ្ឍវិស័យរុក្ខកម្ម

ឆ្នាំ២០១៣នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាប្រឈមលេចធ្លោសំខាន់ៗមួយចំនួនក្នុងវិស័យព្រៃឈើ ពិសេសការអនុវត្តវិធានការបង្ក្រាបការកាប់ឈើខុសច្បាប់ ការកាប់

រាន ដុត ហ៊ុមព័ទ្ធ រំលោភយកដីព្រៃឈើជាកម្មសិទ្ធិ ដែលជាកត្តាពាក់ព័ន្ធបញ្ហាប្រែប្រួលអាកាសធាតុ។ កម្មវិធី/សកម្មភាពក្នុងការស្តារនិងដាំដុះព្រៃឈើឡើងវិញ កម្មវិធី REDD យន្តការអភិវឌ្ឍស្អាត (CDM) កម្មវិធីព្រៃឈើជាតិ (NFP) ត្រូវបានរៀបចំនិងបានអនុវត្ត។ ចំពោះការងារបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃមានការថយចុះចំនួន ២៦៧ ករណីធៀបនឹងឆ្នាំ២០១២ កិច្ចការនេះគឺដោយសារការខិតខំព្យាយាមទប់ស្កាត់នូវប្រភពបទល្មើស និងការយល់ដឹងរបស់ប្រជាជនក្នុងវិស័យព្រៃឈើតាមរយៈការជំរុញការផ្សព្វផ្សាយដល់មូលដ្ឋាន។

ដើម្បីបង្កើនកិច្ចសហការគ្រប់គ្រងវិស័យព្រៃឈើ សហគមន៍ព្រៃឈើចំនួន៨៦កន្លែង ត្រូវបានចុះកិច្ចព្រមព្រៀងមានផ្ទៃដីចំនួន៦២.០៤៨ហត សហគមន៍ព្រៃឈើចំនួន៥៤កន្លែងផ្សេងទៀតមានផ្ទៃដីចំនួន៥៨.៤៥៧ហត នៅក្នុងខេត្តចំនួន១០ ត្រូវបានទទួលប្រកាសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហគមន៍ព្រៃឈើចំនួន១៩កន្លែងទៀតមានផ្ទៃដីចំនួន២១.០២៤ហត ក្នុងខេត្តចំនួន៨ ត្រូវបានរដ្ឋបាលព្រៃឈើព្រាងប្រកាសរួច និងបានដាក់ស្នើសុំការសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ នេសាទ (ក្រាហ្វិក៩)។

បន្ថែមលើនេះទៀត រដ្ឋបាលព្រៃឈើបានសហការជាមួយមន្ត្រីមូលដ្ឋាន បានបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍សម្រេចតាមផែនការ១០០% ចំនួន៤៦៧ បង្គោល លើដីប្រវែង៧៥គីឡូម៉ែត្រ ។

**ក្រាហ្វិក៩÷ បង្ហាញអំពីសហគមន៍ព្រៃឈើពីឆ្នាំ២០០៨-២០១២៣**




| | 2008 | 2009 | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|---|---|
| ចំនួនសហគមន៍ព្រៃឈើ | 377 | 402 | 441 | 452 | 455 | 457 |
| ផ្ទៃដីព្រៃសហគមន៍(ពាន់ហត) | 347.7 | 380.6 | 391.8 | 391.9 | 399.9 | 400.2 |

ដើម្បីបង្កើនគម្របព្រៃឈើលើផ្ទៃដីព្រៃរេចរឹលនិងស្តារព្រៃឈើឡើងវិញក្នុងឆ្នាំ២០១៣នេះ រដ្ឋបាលព្រៃឈើបានសម្រេចដាំដុះជាចម្ការព្រៃឈើបានដាំកូនឈើទាលចំនួន៨.៣០០ដើម និងបង្កើតចម្ការពូជឈើទាលទឹកនៅស្ថានីយក្បាលឆាយទំហំ៥ហត។ ចំពោះគោលបំណងបង្កើនគម្របព្រៃឈើលើផ្ទៃដីព្រៃរេចរឹលនិងស្តារព្រៃឈើឡើងវិញ មានក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចបានឈូសឆាយសម្អាតដី ដាំដុះលើផ្ទៃដីជាង២៣ពាន់ហត និងបានបណ្តុះធ្វើការចែកចាយកូនឈើចំនួន១.៦០០.៤០០ដើម ។

ក្នុងរយៈពេល៦ឆ្នាំ២០០៨-២០១៣ លទ្ធផលនៃការងារដាំឈើទទួលបានសរុបចំនួន១០៤.៣៧៧,១៥ហត ក្នុងនោះដាំដោយរដ្ឋបាលព្រៃឈើ៤.១៨៨ហត កងយោធពលខេមរភូមិន្ទ៣០០ហត បុគ្គលជាលក្ខណៈគ្រួសារ៦.១២០ហត រុក្ខទិវាចំនួន៤០៨,៧៣ហត និងក្រុមហ៊ុនឯកជនចំនួន៩៣.៣៦០ហត។

តារាង: ការដាំឈើរយៈពេល៦ឆ្នាំ២០០៨-២០១៣

| ឆ្នាំដាំដុះ (ហត) | រដ្ឋបាលព្រៃឈើ (ហត) | កងទ័ព (ហត) | គ្រួសារ (ហត) | វត្តអារាម (ហត) | ក្រុមហ៊ុនឯកជន (ហត) | សរុប (ហត) |
|---|---|---|---|---|---|---|
| 2008 | 900 | 200 | 1,654 | 50.65 | 7,436 | **10,240.65** |
| 2009 | 1,000 | 0 | 385 | 69.00 | 17,924 | **19,378** |
| 2010 | 920 | 100 | 973.50 | 66.00 | 27,748 | **29,807.50** |
| 2011 | 530 | 0 | 314.50 | 67.50 | 3,590 | **4,502** |
| 2012 | 488 | 0 | 2,793 | 83.58 | 13,400 | **16,765** |
| 2013 | 350 | 0 | 0 | 72 | 23,262 | **23,684** |
| **សរុប** | **4,188** | **300** | **6,120** | **408.73** | **93,360** | **104,377.15** |

## ៤.៣.៦- ការអភិវឌ្ឍវិស័យជលផល

នៅក្នុងឆ្នាំ២០១៣នេះ រដ្ឋបាលជលផលបានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងនិងបង្កើតកន្លែងអភិរក្សជលផល ការបង្ក្រាបបទល្មើសនេសាទ ការអភិវឌ្ឍន៍វារីវប្បកម្ម ការបង្កើតស្រះជម្រកត្រី ការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយជាដើម។ល។ ដោយឡែក ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានបច្ចេកទេសមួយចំនួនទៀត ដែលបានរៀបចំត្រូវបានពិនិត្យកែសម្រួលនិងអនុម័ត ដើម្បីដាក់ឱ្យអនុវត្តធានាដល់ការគ្រប់គ្រងវិស័យជលផល ប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ រដ្ឋបាលជលផលក៏បានសហការជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងការរៀបចំផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផល ដែលទាក់ទងដល់ការគ្រប់គ្រងវិស័យជលផល។

ទន្ទឹមនឹងការរីកចម្រើនខាងលើនេះ យើងអាចវាយតម្លៃជាជំហានដំបូងថា ការកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលដែលបានសម្រេចលុបឡូត៍នេសាទទាំងអស់ទុកសម្រាប់ប្រជាពលរដ្ឋ ធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល កំពុងបានផ្តល់ផលជាវិជ្ជមានដល់ប្រជាពលរដ្ឋទូទាំងប្រទេស ហើយតាមរយៈការកើនឡើងផលនេសាទតាមគ្រួសារដែលមានប្រជានេសាទប្រមាណ១,៥លាននាក់កំពង់ចូលរួម។ ជាក់ស្តែងលទ្ធផលសំខាន់ៗ ដែលសម្រេចបានក្នុងឆ្នាំ២០១៣ នេះ មានដូចខាងក្រោម÷

- ការធ្វើនេសាទទឹកសាបឆ្នាំ២០១៣ អនុវត្តបាន០,៥២៨លានតោន ស្មើ១០៣,៥% នៃផែនការកើនលើសឆ្នាំមុន១,៩ម៉ឺនតោន និងមានកំណើនប្រមាណ៣ ៥%រយៈពេល៥ឆ្នាំ (ឆ្នាំ២០០៩-២០១៣)។
- ការធ្វើនេសាទសមុទ្រឆ្នាំ២០១៣ អនុវត្តបាន០,១១លានតោន ស្មើនឹង១២២,២% នៃផែនការកើនលើសឆ្នាំមុន១,១ម៉ឺនតោន និងមានកំណើនប្រមាណ ៤៧% ពេល៥ឆ្នាំ (ឆ្នាំ២០០៩-២០១៣)។
- ការអភិវឌ្ឍវារីវប្បកម្មត្រី-បង្គាឆ្នាំ២០១៣ អនុវត្តបាន៩ម៉ឺនតោន ស្មើ១១២,៥% នៃផែនការ កើនលើសឆ្នាំមុន១,៦ម៉ឺនតោន។ ជាមួយគ្នានេះដែរ ការចិញ្ចឹមក្រពើអនុវត្តបាន៣,២សែនក្បាល ស្មើ១៦០% នៃផែនការ កើនលើសឆ្នាំមុន៧ម៉ឺនក្បាល និងភ្ញាស់កូនត្រីពូជអនុវត្តបាន១៥០លានក្បាល ដែលមានកន្លែងភ្ញាស់ត្រីចំនួន៣០៥កន្លែង ក្នុងនោះ ២៩២កន្លែងជារបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់បច្ចេកទេសពីមន្ត្រីរដ្ឋបាលជលផល និងបានបង្កើតស្រះជម្រកត្រីសហគមន៍បាន៧៧៥កន្លែង ដែលនៅខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៣កន្លែង។ សកម្មភាពនេះ ក៏បានធ្វើឱ្យផលត្រីតាមវាលស្រែកើនឡើងប្រមាណពី៤ទៅ៦ដងផងដែរ។
- បានរៀបចំបង្កើតសហគមន៍នេសាទចំនួន៥១៦ ក្នុងនោះ៣៦០សហគមន៍ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការរួចហើយ។
- ចំណូលវិស័យជលផល: ក្នុងឆ្នាំ២០១៣ អនុវត្តបាន៣.៤៤៩លានរៀល។

ក្រាហ្វិក១០ បង្ហាញពីផលនេសាទទឹកសាប ផលនេសាទសមុទ្រ និងផលវារីវប្បកម្ម រយៈពេល៥ឆ្នាំ




ជាមួយសមិទ្ធផលខាងលើ រដ្ឋបាលជលផលក៏បានសហការជាមួយដៃគូអភិវឌ្ឍនិងប្រទេសផ្តល់ជំនួយនានា ជំរុញការរៀបចំផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយនិងពង្រីកវារីវប្បកម្ម និងការអភិរក្ស ដែលទាក់ទងដល់ការគ្រប់គ្រងនិងអភិវឌ្ឍនវិស័យជលផលប្រកបដោយនិរន្តរភាព។

មិនតែប៉ុណ្ណោះ រដ្ឋបាលជលផលក៏បានបង្កើនការទំនាក់ទំនងល្អជាមួយអាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធនិងអង្គការនានា ដើម្បីគាំទ្រដល់ការរៀបចំគ្រប់គ្រងនិងការអភិវឌ្ឍន៍សហគមន៍នេសាទ និងសហគមន៍ស្រះជំរកត្រី បង្កើនដល់ការលើកស្ទួយក្នុងវិស័យជលផលឱ្យកាន់តែមានការរីកចម្រើន និងបានជួយដល់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅជនបទឱ្យកាន់តែប្រសើរឡើងជាលំដាប់នាពេលកន្លងមក។

ជាទិសដៅដើម្បីជំរុញការងារគ្រប់គ្រងវិស័យជលផលឱ្យមានចីរភាព ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងផ្តោតជាសំខាន់លើការអនុវត្តតាមគោលការណ៍មួយចំនួនរួមមាន÷ បន្តសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ទប់ស្កាត់ឱ្យទាន់ពេលវេលានូវការកាប់បំផ្លាញព្រៃលិចទឹកនិងព្រៃកោងកាង ដោយមានវិធានការជាក់ស្តែងជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ឱ្យបានជាដាច់ខាតនូវការរំលោភយកដីព្រៃលិចទឹកនិងព្រៃកោងកាងធ្វើជាដីកម្មសិទ្ធិផ្ទាល់ខ្លួន។

កិច្ចការសំខាន់និងបន្ទាន់គឺ បង្កើនសកម្មភាពត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល គ្រប់រូបភាពតាមបណ្តាខេត្តឱ្យកាន់តែខ្លាំងក្លា ជាពិសេសបទល្មើសអាគុយឆក់ត្រីនិងស្បៃមុង។ បន្តរៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សនិងកន្លែងនេសាទគ្រួសារឱ្យបានច្បាស់លាស់ ដោយសហការជាមួយក្រសួង ស្ថាប័ននិងអាជ្ញាធរដែនដីពាក់ព័ន្ធ ព្រមទាំងពង្រឹងសកម្មភាពគ្រប់គ្រងកន្លែងអភិរក្សជលផលដោយប្រសិទ្ធភាព។ បន្តយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍន៍វារីវប្បកម្មគ្រប់ប្រភេទដូចជាការចិញ្ចឹមត្រីក្នុងស្រះ ក្នុងស្រែ និងក្នុងបែរទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសតំបន់ដែលខ្វះខាតទឹក ខ្វះខាតត្រី ដោយលើកទឹកចិត្តនិងជំរុញការចិញ្ចឹមត្រីខ្នាតតូចជាលក្ខណៈគ្រួសារ ព្រមទាំងទាក់ទាញអ្នកវិនិយោគិនឱ្យចូលរួមវិនិយោគក្នុងវិស័យវារីវប្បកម្ម ដើម្បីជួយអភិវឌ្ឍន៍វារីវប្បកម្មឱ្យបានខ្លាំងក្លាបន្ថែមទៀត។

# ជំពូក ២
# លទ្ធផលនិងទិសដៅ

**៥-លទ្ធផលឆ្នាំ២០១៣-២០១៤និងទិសដៅឆ្នាំ២០១៤-២០១៥ តាមបណ្តាអនុវិស័យនានា**

**៥.១- ផលិតកម្មដំណាំស្រូវនិងដំណាំផ្សេងៗ** (ឧបសម្ព័ន្ធទី១-១១)

ក្នុងឆ្នាំ២០១៣នេះ ស្ថានភាពទឹកភ្លៀងមានអំណោយផលចាប់ផ្តើមធ្លាក់ពីដើមរដូវវស្សា។ ទោះយ៉ាងណា ក្នុងឆ្នាំនេះ បានជួបប្រទះនូវគ្រោះធម្មជាតិ (គ្រោះរាំងស្ងួតនិងទឹកជំនន់) តាមបណ្តារាជធានី ខេត្តមួយចំនួនដូចជា÷

- ការទទួលរងផលប៉ះពាល់ដោយកង្វះខាតទឹកនៅកណ្តាលរដូវវស្សា បានកើតមានចាប់ពីចុងខែសីហារហូតដល់សប្តាហ៍ទី២នៃខែកញ្ញា បណ្តាលឲ្យប៉ះពាល់ដល់ខេត្តចំនួន០៥រួមមានខេត្តកំពង់ស្ពឺ កំពត កណ្តាល ស្វាយរៀង និងតាកែវ

- ដោយទឹកជំនន់ចំនួន០២លើក ចាប់ពីសប្តាហ៍ទី៣នៃខែសីហា រហូតដល់ដើមសប្តាហ៍ទី១នៃខែកញ្ញា ជំនន់ទឹកភ្លៀងលើកទី១បានកើតមានឡើង ហើយចាប់ពីសប្តាហ៍ទី៤នៃខែកញ្ញា រហូតមកដល់សប្តាហ៍ទី២នៃខែតុលា ក៏កើតមាននូវជំនន់ទឹកភ្លៀងជាលើកទី២ ព្រមជាមួយនឹងជំនន់ទឹកទន្លេមេគង្គប៉ះពាល់និងបណ្តាលឲ្យខូចខាតដល់ដំណាំកសិកម្មនៅបណ្តារាជធានីខេត្តចំនួន២០រួមមានខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កណ្តាល កោះកុង ក្រចេះ ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ មណ្ឌលគិរី សៀមរាប ស្ទឹងត្រែង រតនគិរី ស្វាយរៀង តាកែវ ឧត្តរមានជ័យ ប៉ៃលិន និងរាជធានីភ្នំពេញ។

- ស្ថានភាពនៃអាកាសធាតុបែបនេះបានបណ្តាលឲ្យប៉ះពាល់ដល់ទំហំផ្ទៃដីបង្កបង្កើនផល ការលូតលាស់របស់ដំណាំស្រូវ និងបង្កការខូចខាតដល់ដំណាំរដូវវស្សាមួយចំនួន។

ឆ្នាំ២០១៣នេះ ទោះបីជួបប្រទះគ្រោះធម្មជាតិកង្វះខាតទឹកនិងជំនន់ទឹកភ្លៀងលើផលិតផលដំណាំក៏ដោយ ក៏យើងខិតខំយ៉ាងសកម្មយកអស់កម្លាំងកាយចិត្តជំរុញការងារផលិតកម្មទទួលបានជោគជ័យ ដោយរក្សាបានមិនឲ្យបរិមាណផលធ្លាក់ចុះ ដែលបាននាំឲ្យប៉ះពាល់ដល់សន្តិសុខស្បៀងកម្រិតជាតិ ឬប៉ះពាល់ដល់ការជំរុញការនាំចេញអង្ករឡើយ។

**ក-ដំណាំស្រូវ ៖**

-ផ្ទៃដីអនុវត្តសរុបទូទាំងឆ្នាំសរុបបានចំនួន**៣.០៥២.៤២០ហត**លើសឆ្នាំមុន៤៤.៨៧៥ហត ក្នុងនោះ រដូវវស្សាអនុវត្តបានចំនួន**២.៥៦៧.៧២៣ហត** លើសឆ្នាំមុនចំនួន ៥៥.៦៨៥ហត និងរដូវប្រាំងបានចំនួន**៤៨៤.៦៩៧ហត** តិចជាងឆ្នាំមុន ១០.៨១០ ហត

-ផ្ទៃដីខូចខាតសរុបចំនួន**១២៩.៩៤១ហត** ក្នុងនោះ ផ្ទៃដីដំណាំស្រូវរដូវវស្សា **១២៨.៣៦០ហត** តែស្តារបានវិញ**៨៦.១៥៧ហត** រីឯដំណាំស្រូវរដូវប្រាំងទទួលរងការខូចខាតចំនួន **១,៥៨១ហត** តែស្តារបានវិញ**៣៣០ហត** ។

-ផ្ទៃដីប្រមូលផលសរុប**២.៩៦៤.៩៦៧ហត** តិចជាងឆ្នាំមុន ១១.៣៣១ហត ក្នុងនោះរដូវវស្សា **២.៤៨៥.៥២១ហត** លើសឆ្នាំមុនចំនួន៦៨៩ហត និងរដូវប្រាំងសរុបចំនួន**៤៨៣.៤៤៦ហត** តិចជាងឆ្នាំមុនចំនួន១២.០១៩ហត

-ទិន្នផលមធ្យមប្រចាំឆ្នាំ**៣,១៦៣ត/ហត** លើសឆ្នាំមុន០,០៤៥ត/ហត ក្នុងនោះ រដូវវស្សា**២,៩២៥ត/ហត** (លើសឆ្នាំមុន ០,០៥៤ត/ហត) និងរដូវប្រាំង**៤,៣៨៣ត/ហត** (លើសឆ្នាំមុន០,០៣៣ត/ហត)

-បរិមាណផលទទួលបានសរុប**៩.៣៨៩.៩៦១តោន** លើសឆ្នាំមុន៩៩.០២១តោន ក្នុងនោះ រដូវវស្សា៧.២៧១.២៥១តោន លើសឆ្នាំមុន១៣៥.១១២តោន និងរដូវប្រាំងឆ្នាំ២០១៣-២០១៤ ចំនួន២.១១៨.៧១០តោន តិចជាងឆ្នាំមុនចំនួន៣៦.០៩១តោន

-តុល្យភាពស្បៀងសល់**៣.០៩០.៤៥២តោន**អង្ករ គិតជាស្រូវ**៤.៨២៨.៨៣២តោន** លើសឆ្នាំមុនចំនួន៩២.៨៦៨តោន។

**ខ-ដំណាំកសិកម្មរួមផ្សំ**

***ខ.១- ដំណាំរួមផ្សំ÷***

ដំណាំរួមផ្សំអនុវត្តបានសរុប ៧៧៥.៣១៦ហត កើនលើសឆ្នាំមុន ៤៣.៣៥៩ហត និងបរិមាណផលសរុប ៩.០៩៩.៤៧២តោន លើសឆ្នាំមុន ៣៣២.០៥៦តោន ។

***ខ.២- ដំណាំឧស្សាហកម្ម÷***

ដំណាំឧស្សាហកម្មអនុវត្តបានសរុប ១៦៥.៧១២ហត តិចជាងឆ្នាំមុន ១៥.៣៦៧ហត និងបរិមាណផលសរុប ១.១០៥.២១៤តោន តិចជាងឆ្នាំមុន៦៥៥.១២១តោន ដោយសារការទទួលរងនូវគ្រោះធម្មជាតិនិងកត្តាទីផ្សារផលិតផលក្នុងស្រុក ក្នុងនោះ ដំណាំល្ងថយចុះប្រមាណ៧,៥៨% និងអំពៅប្រមាណ៥១%។

ពិនិត្យជារួមលទ្ធផលដំណាំកសិកម្មបានអភិវឌ្ឍដ៏ល្អប្រសើរ នូវសមិទ្ធផលនៃវិស័យកសិកម្មមានការរីកចម្រើនដូចពេលនេះ ពិសេសដំណាំស្រូវបានកើនឡើងលើសផែនការដែលបានគ្រោងទុក។

***ខ.៣- ដំណាំអចិន្ត្រៃយ៍÷***

ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ អនុវត្តបានសរុបចំនួន ១៨៣.០៤៨ហត តិចជាងឆ្នាំមុន០,២៤៥% (ឆ្នាំ២០១២មានចំនួន ១៩៣.៧៥១ហត)។ ដូចនេះ ផ្ទៃដីដាំដុះដំណាំទូទាំងប្រទេសសម្រេចបានចំនួន ៤,៥០លានហត (ផ្ទៃដីដាំដុះដំណាំស្រូវចំនួន ៣.០៥លានហត ផ្ទៃដីដាំដុះដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មចំនួន០,៩៤លានហត ផ្ទៃដីដាំដុះដំណាំអចិន្ត្រៃយ៍ចំនួន០,១៨លានហត និងកៅស៊ូ០,៣៣លានហត)។

## ៥.២- ការងារសេវាកម្មកសិកម្មរបស់អគ្គនាយកដ្ឋានកសិកម្ម

### ៥.២.១. លទ្ធផល

វិស័យកសិកម្មមានបេសកកម្មដឹកនាំគ្រប់គ្រង និងធ្វើសកម្មភាពជំរុញការអភិវឌ្ឍវិស័យផលិតកម្មដំណាំកសិកម្ម ដើម្បីចូលរួមចំណែក (១) ធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋ (២) គ្រប់គ្រងត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផលិតផល (៣) ជំរុញកំណើនផលិតភាពកសិកម្មតាមរយៈពិពិធកម្មកសិកម្ម (៤) កាត់បន្ថយភាពក្រីក្រតាមរយៈបង្កើនចំណូលដល់កសិករដោយតម្លៃបន្ថែមលើកសិផល និង (៥) ធានាទីផ្សារកសិផល។

តួនាទីនិងភារកិច្ចស្នូលរបស់អគ្គនាយកដ្ឋានកសិកម្មផ្តោតលើការងារស្រាវជ្រាវនិងអភិវឌ្ឍ និងផ្ទេររបច្ចេកវិទ្យាពាក់ព័ន្ធនឹង (១) ការគ្រប់គ្រងធនធានដីកសិកម្ម (២) ការអភិវឌ្ឍដំណាំកសិកម្មគ្រប់ប្រភេទ (៣) ការការពារដំណាំ អនាម័យ និងភូតគាមអនាម័យ (៤) ការប្រើប្រាស់គ្រឿងយន្តកសិកម្ម (៥) ការផ្សព្វផ្សាយកសិកម្ម និង (៦) ការត្រួតពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ ។

ក្នុងឆ្នាំ២០១៣នេះ ដោយមានការគាំទ្រទាំងផ្នែកស្មារតី សម្ភារៈថវិកា និងការតម្រង់ទិសពីថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កិច្ចចូលរួមសហការនិងការគាំពារពីដៃគូរអភិវឌ្ឍនានា ការចូលរួមសហការស្អិតរមួតពីសំណាក់អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និងជាពិសេសការចូលរួមរបស់ប្រជាកសិករ អគ្គនាយកដ្ឋានកសិកម្មសម្រេចបាននូវលទ្ធផលពាក់ព័ន្ធនឹងភារកិច្ចស្នូលខាងលើគួរជាទីមោទនៈដូចខាងក្រោម÷

**ក. ការងារពិសោធន៍ស្រាវជ្រាវ**

ក្នុងគោលបំណងដើម្បីជំរុញការស្រាវជ្រាវនិងអភិវឌ្ឍនូវបច្ចេកទេសថ្មីៗ ការអនុវត្តន៍ល្អធាតុចូលមានគុណភាពសម្រាប់ជំរុញកំណើនផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្មក្នុងឆ្នាំ២០១៣កន្លងមកនេះ អគ្គនាយកដ្ឋានកសិកម្មបានដំណើរការអនុវត្តសកម្មភាពពិសោធន៍ស្រាវជ្រាវសរុប២៣៨ពិសោធន៍ លើគ្រប់មុខជំនាញពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់នៃផលិតកម្មដំណាំទាំងនៅក្នុងស្ថានីយនិងនៅលើស្រែ-ចំការកសិករដែលរួមមានជាអាទិ៍÷ ការពិសោធន៍ស្រាវជ្រាវអភិរក្ស បន្សុទ្ធ និងជ្រើសពូជដំណាំ ការពិសោធន៍ស្តីពីវិធីសាស្ត្រដាំដុះ វិធានការគ្រប់គ្រងកត្តាចង្រៃលើដំណាំ វិធីសាស្ត្រការរៀបចំដី ការគ្រប់គ្រងជីជាតិដី ការប្រើប្រាស់ដី និងកំណត់តំបន់កសិកម្ម ការកែច្នៃនិងអភិវឌ្ឍន៍ឧបករណ៍កសិកម្ម និងការគ្រប់គ្រងផលិតផលក្រោយពេលប្រមូលផល។ល។

**ខ. ការផលិតនិងផ្សព្វផ្សាយពូជដំណាំ**

ដោយសារកម្ពុជាមានសក្តានុពលខ្លាំងក្នុងការផលិតស្រូវ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យវែងឆ្ងាយដូចមានចែងច្បាស់ក្នុងឯកសារគោលនយោបាយស្តីពី "ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ" ដែលត្រូវបានប្រកាសដាក់ឱ្យ

អនុវត្តកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជាគឺសំដៅប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសនាំចេញអង្ករមួយដ៏សំខាន់ក្នុងតំបន់នាពេលខាងមុខ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោលដៅដើម្បីសម្រេចធ្វើយ៉ាងហោចណាស់ឱ្យអតិរេកស្រូវមានជាង៤លានតោន ហើយដែលអាចកែច្នៃជាអង្ករនាំចេញជាផ្លូវការបានយ៉ាងតិចជាង១លានតោន និងធ្វើ យ៉ាងណាឱ្យអង្ករ កម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។ ពូជត្រូវបានគេទទួលស្គាល់ថា ជាកត្តាគន្លឹះមួយដ៏ សំខាន់កំណត់គុណភាពនិងផលិតភាពផលិតកម្មចូលរួមសម្រេចបាន នូវទិសដៅគោលនយោបាយទាំងអស់ខាងលើ។ ក្នុងន័យនេះ វិស័យកសិកម្មបានផ្តល់អាទិភាពខ្ពស់ក្នុងការបង្កើនល្បឿនការងារស្រាវជ្រាវនិងផលិតពូជស្រូវដែលមានគុណភាពសុទ្ធល្អ ពិសេសពូជស្រូវទាំង១០ប្រភេទដែលរាជរដ្ឋាភិបាលបានកំណត់ ដើម្បីផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់។

បរិមាណគ្រាប់ពូជដំណាំមានគុណភាព អគ្គនាយកដ្ឋានកសិកម្មបានផលិត និងផ្សព្វផ្សាយជូនប្រជាកសិករប្រើប្រាស់ក្នុងឆ្នាំ២០១៣ មានចំនួន២.២២៤,២តោន ក្នុងនោះ÷ គ្រាប់ពូជស្រូវចំនួន២.១៦១,៧តោន (អ៊ីអ៊ែ៦៦ចំនួន ១.៥៩៥,៣តោន ពូជស្រូវជលសា៥១៣,២តោន ពូជរាំងជ័យ១៨តោន ពូជស្រូវផ្ការំដួល១៦,៥តោន ពូជស្រូវសែនពិដោរ១០តោន និងផ្កាច័ន្ទសែនសរ០,៧តោន) និង គ្រាប់ពូជដំណាំរួមផ្សំនិង ដំណាំ ឧស្សាហកម្មចំនួន ៩៧,៥តោន (ពោតដំណើប ពោតផ្អែម ត្រសក់ល្ពៅ សណ្តែកកួរ សណ្តែកសៀង សណ្តែកប្រេង និងប៉េងប៉ោះ។

### គ. ការអប់រំនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ចងក្រង និងចុះបញ្ជីសហគមន៏កសិកម្ម

ការងារអប់រំនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្មត្រូវបានជំរុញអនុវត្តយ៉ាងសកម្មតាមរយៈសកម្មភាពផ្សេងៗរួមមាន÷ ការបណ្តុះបណ្តាលនៅក្នុងថ្នាក់ ការបណ្តុះបណ្តាលជាក់ស្តែងនៅទីវាល ឬសាលារៀនស្រែកសិករ ការអនុវត្តស្រែបង្ហាញ ការដំណើរការទិវាស្រែ និង ទស្សនៈកិច្ចសិក្សា។ មន្ត្រីបច្ចេកទេសថ្នាក់ក្រោមជាតិ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ក្រុមប្រឹក្សាឃុំ និង កសិករប្រមាណ២៥.៧១២នាក់ បានចូលរួមទទួលផលប្រយោជន៍ពីសកម្មភាពទាំងនេះ។ ក្រៅពីនេះ ការងារអប់រំនិងផ្សព្វផ្សាយបញ្ញាបបច្ចេកទេសកសិកម្មក៏ត្រូវបានជំរុញតាមរយៈការផលិតនិងចែកចាយជាឯកសារបច្ចេកទេស និងផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសាធារណៈផងដែរ។

ក្នុងឆ្នាំ២០១៣នេះ អគ្គនាយកដ្ឋានកសិកម្មបានផលិតនិងចែកចាយឯកសារបច្ចេកទេសសរុបចំនួន៦៤០.៥៨៥ច្បាប់ ក្នុងនោះ÷ ឯកសារជាសៀវភៅបច្ចេកទេសចំនួន៤៩.០៥៥ក្បាល ខិតប័ណ្ណបច្ចេកទេសចំនួន៥៥០.០០០សន្លឹក ផ្ទាំងរូបភាពបង្រៀនចំនួន៤៨០កំប្លេរ ទស្សនាវដ្តីកសិកម្មចំនួន២.៦០០ក្បាល និងទស្សនាវដ្តីសមិទ្ធផលកសិកម្មចំនួន២.៦០០ក្បាល ព្រឹត្តប័ត្រពត៌មានស្តីពីដំណាំបន្លែ២៣.៩០០ច្បាប់។ ដោយឡែកការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសាធារណៈបានរៀបចំចាក់ផ្សាយអត្ថបទបច្ចេកទេសនិងបទយកការណ៍កសិកម្មចំនួន ៥២លើក តាមរយៈទូរទស្សន៍ជាតិ តាមវិទ្យុចំនួន១២៤លើក កម្មវិធីទិវាចុះស្រែចំនួន១៣អត្ថបទ និងនាទីស្វែងយល់ ពីកសិកម្មចំនួន១២ដង។

ក្នុងឆ្នាំ២០១៣ អគ្គនាយកដ្ឋានកសិកម្មសហការជាមួយដៃគូរអភិវឌ្ឍជាតិនិងអន្តរជាតិ បានចងក្រង និងចុះបញ្ជីសហគមន៍កសិកម្មថ្មីចំនួន១១១សហគមន៍ ដែលមកទល់បច្ចុប្បន្ននេះនៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន៤៨៦សហគមន៍។

### ឃ.ការងារគ្រឿងយន្តកសិកម្ម

បច្ចុប្បន្នការប្រើប្រាស់គ្រឿងយន្តកសិកម្មកំពុងមានការកើនឡើងគួរឱ្យកត់សំគាល់ដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវត្តនៃយន្តូបនីយកម្មក្នុងវិស័យកសិកម្មកម្ពុជា។ ជាក់ស្តែងលទ្ធផលភ្ជួររាស់ឆ្នាំ២០១៣ទូទាំងប្រទេស សម្រេចបាន ៣.៨៥២.៤៩៤ហ.តដែលភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មបានចំនួន២.៨១៥.១៨៧ហ.តឬស្មើនឹង៧៣%នៅពេលដែលភ្ជួរដោយគោក្របីមានតែ១.០៣៧.៣០៧ហ.តឬស្មើនឹង២៧%។ ផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មកើនបានចំនួន៦% គឺក្នុងឆ្នាំ២០១២មានចំនួន៦៧% ហើយឆ្នាំ២០១៣ កើនដល់៧៣%នៃផ្ទៃដីភ្ជួររាស់សរុប។

**ក្រាហ្វិកបង្ហាញការប្រៀបធៀបការងារនិងមធ្យោបាយភ្ជួររាស់ដីឆ្នាំ២០១២-២០១៣**




ចំនួនគ្រឿងយន្តកសិកម្មកើនឡើងជានិច្ចពីមួយឆ្នាំទៅមួយឆ្នាំ ដូចជាត្រាក់ទ័រកើនចំនួន ១.៩៧៦គ្រឿង (ឆ្នាំ២០១២មាន៧.៤៩១គ្រឿង) គោយន្តកើនចំនួន៥៥.៩៧៩គ្រឿង (ឆ្នាំ២០១២មានចំនួន៩៥.៧២២គ្រឿង) ម៉ាស៊ីនបូមទឹកកើនចំនួន៣៩.៩៧៥គ្រឿង (ឆ្នាំ២០១២មាន២១៥.៩៧៩គ្រឿង) ម៉ាស៊ីនច្រូតស្រូវ (រាប់បញ្ចូលទាំងម៉ាស៊ីនច្រូតស្រូវដោយស្វ័យប្រវត្តិ) កើនចំនួន១.៤៦៥គ្រឿង (ឆ្នាំ២០១២មានតែចំនួន៣.១១៥គ្រឿង) ម៉ាស៊ីនបោកស្រូវកើនចំនួន១.០១៨គ្រឿង (ឆ្នាំ២០១២មានចំនួន១៦.០៤៩គ្រឿង) ម៉ាស៊ីនសម្ងួតស្រូវកើនចំនួន២គ្រឿង (ឆ្នាំ២០១២មានចំនួន៩២ គ្រឿង) និងម៉ាស៊ីនកិនស្រូវកើនចំនួន៣.១៥០គ្រឿង (ឆ្នាំ២០១២មាន៥២.១២០គ្រឿង) ។

**ក្រាហ្វិកទី២÷ ប្រៀបធៀបគ្រឿងយន្តកសិកម្មសំខាន់ៗក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣**




### ង.ការងារសម្របសម្រួលជំរុញការនាំចេញផលិតផលកសិកម្ម

ក្នុងឆ្នាំ២០១៣ អគ្គនាយកដ្ឋានកសិកម្មបានពិនិត្យនិងផ្តល់វិញ្ញាបនប័ត្រភូតគាមអនាម័យដល់ក្រុមហ៊ុននាំចេញកសិផលបានចំនួន១២.៤៥៥ច្បាប់សម្រាប់ផលិតផលនាំចេញចំនួន៤៦មុខ មានបរិមាណសរុប**៣.៦៩៩.៩០៨,៤៩តោន។**

ការនាំចេញអង្ករឃើញថា មានកំណើនយ៉ាងខ្លាំងគឺ កើនពីប្រមាណជាង០,២លានតោនក្នុងឆ្នាំ២០១២ រហូតដល់ជាង០,៣៧៨លានតោនក្នុងឆ្នាំ២០១៣ ពោលគឺកើនបានចំនួន១៧៣.១៣៩តោន ឬស្មើនឹង៨៤,១% ធៀបនឹងកំណើនត្រឹមតែ១,៩%ប៉ុណ្ណោះរវាងឆ្នាំ២០១១-២០១២ (ក្រាហ្វិកទី៤)។ ចំនួនប្រទេសនាំចូលអង្ករពីកម្ពុជាក៏បានកើនឡើងជាលំដាប់ផងដែរគឺ÷ ក្នុងឆ្នាំ២០១១មានចំនួន៤៨ប្រទេស ឆ្នាំ២០១២មាន៥៧ប្រទេស និងក្នុងឆ្នាំ២០១៣ មានរហូតដល់៦៦ប្រទេស ដែលភាគច្រើនជាប្រទេសក្នុងសហគមន៍អឺរ៉ុប។ លទ្ធផលនេះបានបញ្ជាក់ថាប្រទេសកម្ពុជាយើងបោះជំហ៊ានទៅមុខបានមួយជំហ៊ានធំក្នុងការធ្វើឱ្យពិភពលោកបានស្គាល់អំពីអង្កររបស់កម្ពុជា ដែលប្រមុខរាជរដ្ឋាភិបាលបានចាត់ទុកជាមាសស។ ជាមួយនឹងយុទ្ធសាស្ត្រពិពិធភាវូបនីយកម្មសេដ្ឋកិច្ចតាមរយៈការបង្កើតបរិយាកាសអំណោយផល សម្រាប់ការ

វិនិយោគនិងការចូលរួមរបស់ផ្នែកឯកជន ព្រមគ្នាជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងៗដូចជា÷ ប្រព័ន្ធឥណទាន ប្រព័ន្ធស្រោចស្រព ប្រព័ន្ធដឹកជញ្ជូន ប្រព័ន្ធស្តុកទុកនិងកែច្នៃ យើងមានក្តីសង្ឃឹមថាទីផ្សារផលិតផលកសិកម្មរបស់កម្ពុជាពិតជានឹងត្រូវបានពង្រីកបន្ថែមទៀតក្នុងឆ្នាំខាងមុខនេះ ពិសេសការនាំចេញអង្ករ ដំឡូងមី ពោត និងសណ្តែក។ល។

ទាក់ទងនឹងការអនុវត្តពិធីសារស្តីពីការនាំចេញដំឡូងមីក្រៀមពីកម្ពុជាទៅប្រទេសចិន អគ្គនាយកដ្ឋានកសិកម្មបានត្រួតពិនិត្យ វាយតម្លៃ និងចុះបញ្ជីឈ្មោះក្រុមហ៊ុនចំនួន៤៥ក្រុមហ៊ុន ដែលមានលក្ខណៈសម្បត្តិនាំចេញដំឡូងមីក្រៀមកម្ពុជាទៅកាន់ប្រទេសចិន។ ការនាំចេញផលិតផលដំឡូងមីក្រៀមទៅកាន់ទីផ្សារប្រទេសចិនសម្រេចបានចំនួន៥៥.២០២តោន (ឆ្នាំ២០១២មានបរិមាណតែ១៨.១៤៥តោន)។ ដោយឡែកការអនុវត្តពិធីសារស្តីពីការនាំអង្ករកម្ពុជាទៅកាន់ប្រទេសចិន ក្នុងឆ្នាំ២០១៣ កម្ពុជាបាននាំអង្ករចេញទៅប្រទេសចិនបានចំនួន២៨ ៣០២តោន។

**ក្រាហ្វិកៈ បរិមាណកសិផលកម្ពុជានាំចេញប្រចាំឆ្នាំ២០១៣ (តោន)**




**ក្រាហ្វិកៈ បរិមាណ និងប្រភេទអង្ករនាំចេញក្នុងឆ្នាំ ២០១៣ (តោន)**




### ច. ការងាររៀបចំកសាងលិខិតបទដ្ឋានគតិយុត្តិ

អគ្គនាយកដ្ឋានកសិកម្ម បានរៀបចំកសាងសេចក្តីព្រាងច្បាប់ចំនួន០៣រួមមាន÷ (១)ច្បាប់ស្តីពីសហគមន៍កសិកម្ម (២) ច្បាប់ស្តីពីការប្រើប្រាស់និងគ្រប់គ្រងធនធានដីកសិកម្ម និង(៣)ច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ។ ជាលទ្ធផល ច្បាប់ស្តីពីសហគមន៍កសិកម្មត្រូវបានរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាអនុម័តហើយ បានប្រកាសដាក់ឱ្យប្រើប្រាស់តាមរយៈព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣កន្លងមកនេះ។ ដោយឡែកសេចក្តីព្រាងច្បាប់២ទៀតនឹងបន្តជំរុញរៀបចំក្នុងឆ្នាំ២០១៤ និងឆ្នាំខាងមុខទៀត។

លិខិតបទដ្ឋានគតិយុត្តិក្រោមច្បាប់ស្តីពី ការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ក៏ត្រូវបានរៀបចំជាសេចក្តីព្រាងផងដែររួមមាន÷

- សេចក្តីព្រាងគោលនយោបាយស្តីពីពូជដំណាំកម្ពុជា
- សេចក្តីព្រាងប្រកាសស្តីពីស្តង់ដារពូជដំណាំជាតិ
- សេចក្តីព្រាងប្រកាសស្តីពីសេចក្តីណែនាំទូទៅដើម្បីវាយតម្លៃភាពខុសប្លែកឯកសណ្ឋានភាពនិងស្ថេរភាពសម្រាប់ពូជថ្មីនៃដំណាំ
- សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ។

ក្រៅពីនេះអគ្គនាយកដ្ឋានកសិកម្មក៏បានរៀបចំសេចក្តីព្រាងប្រកាសមួយចំនួនទៀតរួមមាន÷

- សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងគ្រឿងយន្តកសិកម្មនិងឧបករណ៍កសិកម្ម
- សេចក្តីព្រាងប្រកាសរួមស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យនិងកម្ចាត់សមាសភាពចង្រៃ
- សេចក្តីព្រាងប្រកាសស្តីពីបញ្ជីវាយមុខទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ
- សេចក្តីព្រាងប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌
- វិសោធនកម្មប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យ។

### ឆ. ការងារអន្តរាគមន៍តាមប្រព័ន្ធស្បៀងបម្រុងកម្ពុជា

អគ្គនាយកដ្ឋានកសិកម្ម ត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ចជាអង្គភាពអនុវត្តប្រព័ន្ធស្បៀងបម្រុង (ប.ស.ប.ក) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈអនុក្រឹត្យលេខ១៤៥អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ មានភារកិច្ចចម្បងគឺការផលិត រក្សា និងដឹកជញ្ជូនផ្គត់ផ្គង់គ្រាប់ពូជស្រូវនិងដំណាំរួមផ្សំដល់គោលដៅចែកចាយជូនប្រជាពលរដ្ឋរងគ្រោះដោយគ្រោះធម្មជាតិនានា។

ឆ្លើយតបទៅនឹងបញ្ហាគ្រោះទឹកជំនន់ឆ្នាំ២០១៣ អគ្គនាយកដ្ឋានកសិកម្មបានសម្របសម្រួលផ្គត់ផ្គង់គ្រាប់ពូជស្រូវបានចំនួន៤៦០តោន (៤១០តោន ជាសន្និធិគ្រប់ពូជនៃប្រព័ន្ធស្បៀងបម្រុងកម្ពុជានិង៥០តោន ជាសន្និធិគ្រាប់ពូជរបស់អគ្គនាយកដ្ឋានកសិកម្ម) គ្រាប់ពូជបន្លែចំនួន១,៥តោននិង២៥០យីត និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗចំនួន១០,៦តោន ជូនប្រជាកសិកររងគ្រោះក្នុងខេត្តចំនួន១២÷ខេត្តពោធិសាត់ កំពង់ចាម កំពង់ធំ សៀមរាប បាត់ដំបង ឧត្តរមានជ័យ ព្រះវិហារ ស្វាយរៀង បន្ទាយមានជ័យ ព្រៃវែង តាកែវ និងស្ទឹងត្រែង។ គ្រាប់ពូជដំណាំសរុបដែលបានចែកជូនកសិករទូទាំងប្រទេសយកទៅដាំដុះស្តារការខូចខាតដោយទឹកជំនន់មាន÷ពូជស្រូវចំនួន ១.០៦២,៧១តោន គ្រាប់ពូជបន្លែចំនួន ១.៥៣២គ.ក្រ និង៥.៥៥០យីត និងគ្រាប់ពូជដំណាំរួមផ្សំចំនួន១០,៥តោន។

### ជ. ការងារបញ្ជ្រាបយេនឌ័រក្នុងផលិតកម្មកសិកម្ម

ក្នុងទិសដៅចូលរួមគាំទ្រអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្មបាននិងកំពុងដំណើរការសកម្មភាព ធ្វើសមាហរណកម្មការងារយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រនិងផែនការប្រចាំឆ្នាំតាមរយៈការបើកវគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងយេនឌ័រក្នុងការងារផលិតកម្ម ដោយផ្តោតជាសំខាន់លើកសិករជាស្ត្រីតាមមូលដ្ឋាន ដើម្បីឱ្យពួកគាត់ទទួលបានចំណេះដឹងពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ និងអំពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ក្នុងដំណើរការអភិវឌ្ឍវិស័យកសិកម្ម។ ជាលទ្ធផលរួមអគ្គនាយកដ្ឋានកសិកម្ម បានដំណើរការវគ្គបណ្តុះបណ្តាលស្តីពីយេនឌ័របានចំនួន៦០វគ្គ មានកសិករចូលរួមចំនួន២.៣០០នាក់ ក្នុងនោះស្ត្រីចំនួន១.០៣៥នាក់ នៅក្នុងខេត្តគោលដៅចំនួន៤ ខេត្តតាកែវ កំពង់ស្ពឺ ព្រៃវែង និងស្វាយរៀង។

វគ្គបណ្តុះបណ្តាលនេះបានធ្វើឱ្យកសិករទាំងពីរភេទមានការចាប់អារម្មណ៍និងភ្ញាក់រលឹកអំពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ក្នុងការងារផលិតកម្ម ជាពិសេសកសិករជាបុរសភាគច្រើន មានការភ្ញាក់រលឹកខ្ពស់ក្នុងការផ្តល់តម្លៃទៅលើការចូលរួមចំណែករបស់ដៃគូររបស់គាត់នៅក្នុងដំណើរការអភិវឌ្ឍវិស័យកសិកម្ម។

### ឈ. ការងារសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិដើរតួនាទីដ៏សំខាន់ក្នុងការគៀងគរជំនួយឧបត្ថម្ភ ដើម្បីអនុវត្តការងារស្រាវជ្រាវអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាល្អដល់កសិករ។ ជាក់ស្តែងក្រៅពីបានចូលរួមសហការរៀបចំឯកសារ MoU សម្របសម្រួលការចូលរួមរបស់ថ្នាក់ដឹកនាំនិងមន្ត្រី ដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាច្រើនទាំងក្រោមក្របខ័ណ្ឌអាស៊ាន

ទ្វេភាគី និងសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍអន្តរជាតិនានា។

ការងារសហប្រតិបត្តិការអន្តរជាតិត្រូវបានជំរុញជាមួយនឹងគោលបំណងសំខាន់គៀងគរថវិកាបន្ថែម ដើម្បីអនុវត្តការងារស្រាវជ្រាវអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាល្អដល់កសិករ។ ជាក់ស្តែងមានដៃគូជាតិនិងអន្តរជាតិចូលរួមទ្រទ្រង់សកម្មភាពអភិវឌ្ឍវិស័យកសិកម្មតាមរយៈគម្រោងមួយចំនួនដូចខាងក្រោម÷

១- គម្រោងអភិវឌ្ឍធារាសាស្ត្រនិងបង្កើនផលិតភាពកសិកម្ម (RIAPIP) ដែលប្រើប្រាស់ថវិកាបង្វិលសង IMF

២- គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍកសិករខ្នាតតូចជុំវិញតំបន់ទន្លេសាប (TS-PRSDP) ទ្រទ្រង់ថវិកា ដោយរាជរដ្ឋាភិបាលកម្ពុជានិង ADB

៣- គម្រោងអភិវឌ្ឍ ជនបទទំនាបបឹងទន្លេសាប (TS-RDP) ទ្រទ្រង់ថវិកាដោយរាជរដ្ឋាភិបាលកម្ពុជានិង ADB

៤- គម្រោងជំនួយស្បៀងបន្ទាន់ (EFAP) ទ្រទ្រង់ថវិកាដោយADB

៥- គម្រោងអភិវឌ្ឍន៍កសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ច (PADEE) ទ្រទ្រង់ថវិកាដោយរាជរដ្ឋាភិបាលកម្ពុជានិង IFAD

៦- គម្រោងលើកកំពស់ផលិតភាពកសិកម្ម (APPP) គាំទ្រថវិកាដោយ JICA

៧- គម្រោងស្រាវជ្រាវដំណាំស្រូវគាំទ្រថវិកាដោយ SEARICE និង ACIAR

៨- គម្រោងពិពិធកម្មកសិកម្មកម្ពុជា (PADAC) ដែលជំរុញការស្រាវជ្រាវបច្ចេកទេសដំណាំគម្របដី DMC ហើយទ្រទ្រង់ថវិកាដោយAFD

៩- គម្រោងស្តីពីការកែលំអសន្តិសុខស្បៀងនិងទីផ្សារសម្រាប់កសិករខ្នាតតូច (MALIS) ទ្រទ្រង់ថវិកាដោយ EU និង FAO

១០- គម្រោងស្តីពី Cambodia-China Agriculture Technology Demonstration Center គាំទ្រថវិកា ដោយរដ្ឋាភិបាលប្រទេសចិន ដែលបានឯកភាពគាំទ្រគម្រោងនេះរួចហើយដោយប្រគល់សិទ្ធិជូនក្រុមហ៊ុន FORWARD ក្នុងស៊ីទទួលអនុវត្តនៅក្នុងទីតាំងចំនួន៤រួមមាន÷ ស្ថានីយកប់ស្រូវ កសិដ្ឋានចម្ការលើ ស្ថានីយដីឥដ្ឋ និងស្ថានីយគោកត្រប់

១១- គម្រោង Enhancing Capacities for Disaster Risk Reduction in Agriculture in Cambodia ក្នុងខេត្តកំពង់ស្ពឺ ពីខែកក្កដា-ធ្នូ ឆ្នាំ២០១៣ និងគម្រោង Improving Food Security and Market Linkages for Smallholders អនុវត្តនៅខេត្តឧត្តរមានជ័យនិងព្រះវិហារ ពីខែមករា ឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៥

១២- គម្រោងសិក្សាស្រាវជ្រាវស្តីពី Cambodia Agriculture in Transition: Opportunity and Risks ឧបត្ថម្ភថវិការដោយ World Bank ដើម្បីឈានឆ្ពោះទៅកសាងផែនការមេរយៈពេលវែងសម្រាប់អនុវិស័យដំណាំ។

## ជ. បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលដែលសម្រេចបានដូចបានគោរពជម្រាបជូនខាងលើ ការងារកសិកម្មក៏នៅជួបបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម÷

- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្ភារៈបរិក្ខា មធ្យោបាយផលិតកម្មបម្រើការងារស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យានៅតាមកសិដ្ឋាន ស្ថានីយពិសោធន៍ស្រាវជ្រាវ និងមណ្ឌលអភិវឌ្ឍកសិកម្មក្រោមឱវាទ

- កង្វះខាតធនធានមនុស្សសម្រាប់ការងារស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- ចំណាកស្រុករបស់ប្រជាជនកំពុងក្លាយជាបញ្ហាចោទមួយសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម

- ចំណេះដឹងកសិករនៅមូលដ្ឋាននៅមានកម្រិត ធ្វើឱ្យមានការលំបាកក្នុងការបញ្ជ្រាបបច្ចេកទេសកសិកម្មថ្មី ងាយរងគ្រោះពីការឆបោកឈ្មួញទុច្ចរិត និងកង្វះខាតលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ

- មិនមានប៉ុស្តិ៍ត្រួតពិនិត្យភូតគាមអនាម័យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ សម្រាប់សម្រួលការនាំចេញ-នាំចូលផលិតផលកសិកម្ម និងការត្រួតពិនិត្យទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ

- ចំណេះដឹងកសិករនៅមូលដ្ឋាននៅមានកម្រិត ធ្វើឱ្យមានការលំបាកក្នុងការបញ្ជ្រាបបច្ចេកទេសកសិកម្មថ្មី និងងាយរងគ្រោះពីការឆបោកឈ្មួញទុច្ចរិត ការប្រែប្រួលអាកាសធាតុបង្កឱ្យមានជាគ្រោះធម្មជាតិញឹកញាប់ ធ្វើឱ្យប៉ះពាល់ដល់ដំណើរការផលិតកម្មកសិក។

### ៥.២.២. វាយតម្លៃនិងសន្និដ្ឋាន

ក្នុងឆ្នាំ២០១៣ នៃអាណត្តិទី៤របស់រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** អគ្គនាយកដ្ឋានកសិកម្មសូមធ្វើការវាយតម្លៃនិងសន្និដ្ឋានដោយមោទនភាពថា ទោះបីស្ថិតនៅក្នុងដំណាក់កាលពឹងផ្អែកលើធម្មជាតិ និងជាញឹកញាប់បានទទួលរងការគម្រាមកំហែងពីគ្រោះមហន្តរាយធម្មជាតិជាបន្តបន្ទាប់ក្ដីវិស័យកសិកម្មកម្ពុជាបាននិងកំពុងមានការផ្លាស់ប្ដូរជាវិជ្ជមានប្រកបដោយក្ដីសង្ឃឹមថា វិស័យនេះពិតជានឹងក្លាយជាឆ្អឹងខ្នងយ៉ាងរឹងមាំ សម្រាប់ការពន្លឿននិងការពង្រីកមូលដ្ឋានអភិវឌ្ឍវិស័យសេដ្ឋកិច្ចកម្ពុជា បន្តចូលចូលរួមចំណែកកាត់បន្ថយភាពក្រីក្រប្រកបដោយភាពស្វាហាប់និងចីរភាព។

ការសម្រេចបាននូវកំណើនការនាំចេញផលិតផលកសិកម្មក្នុងឆ្នាំ២០១៣ ពិសេសអង្ករ បន្លែ និងផ្លែឈើពិតជាបានឆ្លុះបញ្ចាំងនូវការអភិវឌ្ឍអនុវិស័យផលិតកម្មកសិកម្មកម្ពុជា កំពុងតែមានការវិវត្តប្រកបដោយអត្ថន័យទាំងបរិមាណនិងគុណភាព ដែលមិនអាចកាត់ផ្ដាច់បានពីកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ នៃអគ្គនាយកដ្ឋានកសិកម្ម ក្រោមកិច្ចសម្របសម្រួលជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់រួមទាំងអជ្ញាធរមូលដ្ឋាន ដៃគូរអភិវឌ្ឍ និងផ្នែកឯកជន។ ការចូលរួមសហការនេះ បាននិងកំពុងលើកកំពស់សមត្ថភាពនិងភាពម្ចាស់ការក្នុងចំណោមប្រជាកសិករ នៅក្នុងដំណើរការផលិតកម្មតម្រង់ឆ្ពោះទៅរកទីផ្សារតាមរយៈការប្រើប្រាស់ពូជដំណាំមានគុណភាពល្អការចាប់យកទៅអនុវត្តនូវបច្ចេកទេសប្រពលវប្បកម្មនិងពិពិធកម្មដំណាំត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេសនិងការរីកចម្រើនខាងផ្នែកយន្តូបនីយកម្មកសិកម្ម។

និយាយជារួម វិស័យកសិកម្មកម្ពុជាកំពុងតែមានការវិវត្តប្រកបដោយអត្ថន័យទាំងបរិមាណនិងគុណភាព។ ប្រជាកសិករកាន់តែមានសមត្ថភាពធានាបាននូវភាពម្ចាស់ការនៅក្នុងដំណើរការផលិតកម្ម ដោយសារការខិតខំរបស់រាជរដ្ឋាភិបាល ដែលបាននិងកំពុងធ្វើឱ្យមានការរីកចម្រើនជាបណ្ដើរៗ នូវមូលដ្ឋានបម្រើឱ្យផលិតកម្មនិងពាណិជ្ជកម្មកសិកម្ម ពិសេសការរីកចម្រើនខាងប្រព័ន្ធធារាសាស្ត្រ យន្តូបនីយកម្មកសិកម្ម ពូជដំណាំមានគុណភាព បច្ចេកទេសដាំដុះនិងថែទាំដំណាំថ្មីៗ និងយន្តការសម្របសម្រួលទីផ្សារផលិតផលកសិកម្ម។ល។ ព្រមជាមួយគ្នានេះ ប្រជាកសិករក៏កំពុងតែមានការកែប្រែទម្លាប់ និងផ្នត់គំនិតជាបណ្ដើរៗ ក្នុងការចាប់យកទៅអនុវត្តនូវបច្ចេកទេសប្រពលវប្បកម្មនិងពិពិធកម្មដំណាំត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស។ កំណើនផលិតកម្មកសិកម្មទាំងផ្ទៃដីដាំដុះ បរិមាណផល ទិន្នផល ពិសេសកំណើននៃការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារបរទេសពិតជាសក្ខីកម្មមិនអាចប្រកែកបានស្ដីពី ការរីកចម្រើននៅក្នុងវិស័យកសិកម្មប្រកបដោយអត្ថន័យ។

ទាំងអស់នេះជាផ្លែផ្កាកើតចេញពីការបំពេញការងារមិនចេះនឿយហត់ និងប្រកបដោយស្មារតីទទួលខុសត្រូវនិងការលះបង់ខ្ពស់របស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃវិស័យកសិកម្មនិងអ្នកពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ក្រោមការជួយឧបត្ថម្ភគាំទ្រទាំងស្មារតី សម្ភារៈ ថវិកានិងការដឹកនាំចង្អុលបង្ហាញប្រកបដោយប្រសិទ្ធភាពរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់ជាន់ថ្នាក់។

### ៥.២.៣. ទិសដៅនិងវិធានការ

ក្នុងគោលបំណងដើម្បីឈានទៅសម្រេចបានសមិទ្ធផលធំៗបន្ថែមទៀតសម្រាប់អនុវិស័យផលិតកម្មដំណាំវិធានការគន្លឹះដែលត្រូវបន្តជំរុញអនុវត្តនាឆ្នាំ២០១៤ក៏ដូចជាបណ្ដាឆ្នាំបន្តបន្ទាប់ទៀតខាងមុខនេះរួមមាន÷

- បន្តជំរុញការលើកកំពស់ផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម តាមរយៈការគៀងគរថវិកា ដើម្បីស្ដារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឱ្យការងារពិសោធន៍ស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាសមស្របទៅដល់ស្រទាប់ប្រជាកសិករនិងផលិតករទាំងការបង្កើនទិន្នផលនិងគុណភាពផលិតផល ឆ្លើយតបទៅនឹងសេចក្ដីត្រូវទីផ្សារក្នុងស្រុកនិងក្រៅ
- បន្តជំរុញការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍ អនុវិស័យដំណាំរយៈពេលមធ្យមនិងរយៈពេលវែង និងពង្រឹងការងារគ្រប់គ្រងតាមដានការអនុវត្តចំណាយថវិកា ក្រោមក្របខ័ណ្ឌថវិកាតាមកម្មវិធី ដោយធ្វើយ៉ាងណាឱ្យមានប្រសិទ្ធភាពនិងមានសង្គតភាពជាមួយនឹងគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បន្តពង្រឹងនិងពង្រីកសេវាអប់រំផ្សព្វផ្សាយបច្ចេកទេសកសិកម្មជូនដល់ប្រជាកសិករឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅថែមទៀត ដើម្បីពង្រីកការទទួលយកទៅអនុវត្តនូវបច្ចេកទេសសមស្របសម្រាប់ ការដាំដុះ ការគ្រប់គ្រងជីជាតិដី ការការពារដំណាំ ការប្រើប្រាស់និងថែទាំគ្រឿងយន្តនិងឧបករណ៍កសិកម្ម ការប្រមូលផលទុកដាក់និងកែច្នៃក្រោយពេលប្រមូលផលប្រកបដោយប្រសិទ្ធភាព

- បន្តជំរុញធ្វើឯកទេសកម្មពូជដំណាំ ពិសេសស្រូវសំខាន់ៗទាំង១០ពូជ តាមរយៈការស្រាវជ្រាវនិងអប់រំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ និងបន្តពង្រឹងពង្រីកប្រព័ន្ធផលិតកម្មនិងផ្គត់ផ្គង់ពូជដំណាំ ដែលមានគុណភាពល្អតាមតម្រូវការទីផ្សារធន់នឹងការបំផ្លាញដោយសមាសភាពចង្រៃ និងការប្រែប្រួលអាកាសធាតុ

- បន្តកិច្ចខិតខំជំរុញការចងក្រងនិងពង្រឹងសហគមន៍កសិកម្ម តាមរយៈការកសាងសមត្ថភាពដឹកនាំគ្រប់គ្រងជំនាញក្នុងការធ្វើផែនការ ដំណើរការមុខរបរ ការធ្វើជំនួញទីផ្សារ និងសេវាកម្មពាក់ព័ន្ធនឹងខ្សែចង្វាក់ផលិតកម្មកសិកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្តុំ ក្នុងភាពជាដៃគូរជាមួយផ្នែកឯកជនក្រោមក្របខ័ណ្ឌនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីទទួលបានទាំងបច្ចេកវិទ្យាថ្មី និងឥណទានគ្រប់គ្រាន់ ធានាបានស្ថេរភាពនៃការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារ ទាំងបរិមាណនិងគុណភាព

- បន្តខិតខំជំរុញការងារអង្កេតសិក្សាវាយតម្លៃនិងការធ្វើសារពើភណ្ឌការប្រើប្រាស់ដីកសិកម្ម ដើម្បីទទួលបាននូវទិន្នន័យជាក់លាក់ជាធាតុចូលសម្រាប់បម្រើឱ្យការរៀបចំផែនការអភិវឌ្ឍន៍វិស័យកសិកម្ម ដោយអាចកំណត់បានដំបន់ដាំដុះជាក់លាក់ដើម្បីតម្រង់ទិសដល់ការធ្វើប្រពលវប្បកម្ម និងពិពិធភាវូបនីយកម្មកសិកម្ម និងធានានិរន្តរភាពនៃការប្រើប្រាស់ដីកសិកម្ម

- បន្តខិតខំស្រាវជ្រាវនិងកំណត់ប្រតិទិនដាំដុះស្របតាមប្រព័ន្ធបរិស្ថានដំណាំនិងលក្ខខណ្ឌអាកាសធាតុ ដើម្បីធានាបាននូវផលិតភាពកសិកម្មខ្ពស់ ធានាការផ្គត់ផ្គង់កសិផលនៅគ្រប់រដូវកាលតាមតម្រូវការទីផ្សារ និងអាចកាត់បន្ថយបាននូវផលប៉ះពាល់ដោយគ្រោះធម្មជាតិដូចជា គ្រោះរាំងស្ងួត និងទឹកជំនន់ ដែលកើតឡើងដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ

- បន្តជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកទេសក្រោយប្រមូលផល ដោយត្រូវពង្រឹងទាំងផ្នែកបច្ចេកទេសនិងធ្វើឱ្យមានទំនើបកម្មផ្នែកសម្ភារៈនិងឧបករណ៍ និងការអនុវត្តប្រកបដោយភាព ប្រាកដប្រជាក្នុងទិសដៅកាត់បន្ថយការបាត់បង់កសិផលនិងធានាបាននូវគុណភាពកសិផល

- ពង្រីកសមត្ថភាព ឈានចូលទីផ្សារតំបន់និងពិភពលោកនៃកសិផលកម្ពុជា តាមរយៈការជំរុញការអនុវត្តផលិតកម្មតាមគោលការណ៍នៃការអនុវត្តកសិកម្មល្អ និងការបង្កើតស្តង់ដារគុណភាពនិងសុវត្ថិភាព ផលិតផលផ្សារភ្ជាប់នឹងយន្តការត្រួតពិនិត្យនិងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពដែលទុកចិត្តបាន

- ជំរុញការស្រាវជ្រាវនិងប្រើប្រាស់ភ្នាក់ងារជីវសាស្ត្រ ថ្នាំកសិកម្មជីវសាស្ត្រ និងថ្នាំផ្សំពីរុក្ខជាតិដើម្បីកម្ចាត់សមាសភាពចង្រៃការពារដំណាំក្នុងទិសដៅកាត់បន្ថយជាបណ្តើរៗការប្រើប្រាស់ថ្នាំកសិកម្ម និងសារធាតុគីមីសំយោគដែលពុលខ្លាំងប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពមនុស្សនិងបរិស្ថាន

- បន្តខិតខំសហការរួមគ្នាជាមួយវិស័យឯកជននិងដៃគូរអភិវឌ្ឍនានាក្នុងការលើកកំពស់សមត្ថភាពយល់ដឹងដល់ប្រជាកសិករលើការចេះប្រើប្រាស់ ថែទាំ និងជួសជុលគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម

- បន្តខិតខំរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលជាឧបករណ៍អនុវត្តការងារឱ្យឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្មនាពេលបច្ចុប្បន្ននិងអនាគត រួមមានជាអាទិ៍÷ សេចក្តីព្រាងច្បាប់ស្តីពីការប្រើប្រាស់និងគ្រប់គ្រងដីកសិកម្ម សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីសហគមន៍កសិកម្ម និងឯកសារយុទ្ធសាស្ត្របន្សាំនិងកាត់បន្ថយផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុក្នុងផលិតកម្មដំណាំកសិកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ពន្ធ័នឹងប្រតិបត្តិការរបស់មន្ទីរពិសោធន៍ជាតិកសិកម្ម

- បន្តរក្សានូវប្រពៃណីសាមគ្គីភាពសហការផ្ទៃក្នុងល្អ និងកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន គ្រប់លំដាប់ថ្នាក់ និងដៃគូអភិវឌ្ឍកសិកម្មដទៃទៀតឱ្យបានល្អប្រសើរ ដើម្បីធ្វើយ៉ាងណាឱ្យប្រជាកសិករទទួលបាននូវព័ត៌មាន

ថ្មីៗបន្ថែមទៀតទាន់សភាពការណ៍ ស្តីពីបច្ចេកទេសផលិតកម្មកសិកម្មឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងស្មារតីសាមគ្គីភាពទូលាយដើម្បីរួមចំណែកដោះស្រាយនូវបញ្ហាទាំងឡាយដែលកសិករជួបប្រទះ។

## ៥.៣- ការងារស្រាវជ្រាវបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

ក្នុងឆ្នាំ២០១៣នេះ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាមានមន្ត្រីនិយោជិតសរុបចំនួន១៤៤នាក់ (មន្ត្រីរាជការចំនួន៤៧នាក់) ក្នុងនោះមាននារីចំនួន៣៩នាក់។ អនុវត្តតាមតួនាទី និងក្រោមការដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាល ព្រមទាំងការគាំទ្របន្ថែមផ្នែកបច្ចេកទេស និងថវិកាពីដៃគូរអភិវឌ្ឍន៍នានា និងកិច្ចសហប្រតិបត្តការជាមួយមជ្ឈដ្ឋានស្រាវជ្រាវជាតិ អន្តរជាតិ និងជាពិសេសជាមួយអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្មទាំងអស់ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានបន្តខិតខំប្រឹងប្រែងអនុវត្តយ៉ាងសស្រាក់សស្រាំលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាសម្រាប់ (១)ការអភិវឌ្ឍន៍ពូជដំណាំកសិកម្ម (២)ការគ្រប់គ្រងជីជាតិដីនិងសារធាតុចិញ្ចឹម (៣)ការអភិវឌ្ឍន៍បច្ចេកទេសដាំដុះនិងប្រព័ន្ធកសិកម្ម (៤)ការការពារដំណាំពីការបំផ្លាញដោយកត្តាចង្រៃផ្សេងៗមានដូចជាសត្វតចង្រៃនិងជំងឺ (៥)ការអភិវឌ្ឍន៍បច្ចេកទេសមុននិងក្រោយពេលប្រមូលផល (៦)ការវិភាគសេដ្ឋកិច្ចសង្គមពាក់ព័ន្ធវិស័យកសិកម្ម និង(៧)ការបណ្តុះបណ្តាល ការផ្សព្វផ្សាយចំណេះដឹងបច្ចេកទេស និងព័ត៌មានកសិកម្ម។

### ៥.៣-១. លទ្ធផល

សមិទ្ធផលការងារស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយរបស់វិទ្យាស្ថានចែកចេញជា៦ផ្នែកធំៗ ដែលសរុបទាំងអស់មានចំនួន២៥ចំណុច ដូចខាងក្រោម÷

#### ក. ការងារអភិរក្ស

-ពូជដំណាំៈ បានធ្វើយុវកម្មលើដំណាំចំនួន២ប្រភេទរួមមាន ដំណាំស្រូវចំនួន៦៩០បញ្ជីក/សំណាក (ដុះបាន ៥៣៣ បញ្ជីក/សំណាក) និងដំណាំអំពៅចំនួន២៧សំណាក។ បានដាំសំណាកស្រូវប្រមូលបានថ្មីៗ វាយតម្លៃនិងកំណត់លក្ខណៈសរុបចំនួន២៨៥សំណាក។ បន្តការអភិរក្សពូជដំណាំ ដែលមាននៅក្នុងធនាគារពូជនៅក្នុងផ្ទះសំណាញ់ និងនៅក្នុងចម្ការ។ ទន្ទឹមនឹងនេះ ដែរ បានទុកដាក់សំណាកស្រូវដែលប្រមូលមកពីខេត្តក្នុងឆ្នាំ២០១២ និងក្រោយពីការធ្វើយុវកម្មសរុបចំនួន១០០៥បញ្ជីក/សំណាក។ បាន ចុះប្រមូលពូជស្រូវប្រពៃណីពីខេត្តកោះកុងបានចំនួន៤១សំណាក និងស្វាយបានចំនួន២៤សំណាកពីបណ្តាខេត្តនានា។ គិតត្រឹម ដំណាច់ឆ្នាំ២០១៣នេះ វិទ្យាស្ថានបានប្រមូល និងបន្តអភិរក្សលើដំណាំចំនួន៣០ប្រភេទ ដែលក្នុងនោះមានស្រូវចំនួន៥.៩៦០បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ២៩ប្រភេទរួមមាន ៩៦៥សំណាកសរុបទាំងអស់មាន៦.៩២៥បញ្ជីក/សំណាក។

#### ខ. ការអភិវឌ្ឍន៍ និងជ្រើសរើសពូជដំណាំ

**-ពូជស្រូវដំណើបស្បៃមង្គលៈ** វិទ្យាស្ថានបានបញ្ចេញពូជស្រូវដំណើបស្បៃមង្គល ដែលជាពូជស្រូវទី៣៩ របស់វិទ្យាស្ថានជូនកសិករប្រើប្រាស់។ ដំណើបស្បៃមង្គល ជាពូជស្រូវធ្ងន់ប្រកាន់រដូវ ចេញផ្កាក្នុងអាទិត្យទី២ ខែវិច្ឆិកា មានទិន្នផលជាមធ្យម៣,២តោន/ហត កម្ពស់ជាមធ្យម១,៥ម ប្រវែងកួរជាមធ្យម២៩ស.ម និងគ្រាប់ស្រូវ ១០០គ្រាប់មានទម្ងន់៣,៤ក្រាម។ អង្ករល្វូនវែងមានប្រវែងគ្រាប់៧,០ម.ម បន្ទារកម្រាស់២,១ម.ម និងមានអាមីឡូស១,៦%។

-បានដាំស្រឡាយសម្រាប់ធ្វើបង្កាត់ និងបង្កាត់ត្រឡប់ចំនួន៧ប្រជាករ និងដាំតាមដានលើការលូតលាស់របស់ស្រឡាយបង្កាត់ដើម្បីអភិវឌ្ឍពូជស្រូវឲ្យមានភាពធន់ទ្រាំនឹងភាពរាំងស្ងួត ធន់ទ្រាំនឹងការលិចទឹក ធន់ទ្រាំនឹងអាកាសធាតុក្តៅ ធន់ទ្រាំនឹងការដួលដើម ធន់ទ្រាំនឹងដីប្រៃ ធន់ទ្រាំនឹងមមាចត្នោត ធន់ទ្រាំនឹងជំងឺ និងអភិវឌ្ឍពូជលើគុណភាពគ្រាប់សរុបចំនួន១.៩៥១ស្រឡាយ។ ជាមួយគ្នានេះដែរ បានជ្រើសរើសឯកត្តៈពីពូជស្រូវប្រពៃណីដាំដុះនៅតំបន់ទឹកប្រៃចំនួន៧ ពូជ។

-បានពិសោធន៍ជ្រើសរើសរកពូជដំណាំថ្មីប្រកបដោយសក្តានុពលទិន្នផល អាយុកាលសមស្រប និងគុណភាពល្អសរុបមានពិសោធន៍ចំនួន៣៩ប្រភេទ ក្នុងនោះពិសោធន៍មានសារសរុបចំនួន១៣៧កន្លែង ពិសោធន៍បន្សាំបឋមលើស្រែកសិករ និង ស្រែបង្ហាញមានចំនួនសរុប២១១កន្លែង ដែលមានពូជ/ស្រឡាយចូលរួមសរុបចំនួន១.៩៩១ពូជ/ស្រឡាយ។ ជារួមបានជ្រើសរើស (១) ពូជស្រូវស្រាលអាយុកាលខ្លីបានចំនួន៦ស្រឡាយ (២) ជម្រើសឯកត្តៈផ្ការំដួលប្រាំងចំនួន៣ស្រឡាយ ដែលស្រឡាយទាំង អស់នេះ នឹងបន្តធ្វើពិសោធន៍បន្សាំបឋមលើស្រែកសិករក្នុងរដូវប្រាំងឆ្នាំ២០១៤។

-បានផលិតគ្រាប់ពូជរុក្ខជម្រើសវិទ្ធរបស់ដំណាំចំនួន៦ប្រភេទ ដែលក្នុងនោះមានពូជស្រូវចំនួន១៦ពូជ សណ្តែកបាយចំនួន៤ពូជ ពោតចំនួន២ពូជ ប៉េងប៉ោះចំនួន២ពូជ ឪឡឹកចំនួន២ពូជ និងស្វាយចំនួន២ពូជ។

**គ. ការបង្កើនផលិតភាពដំណាំ**

-ការប្រើប្រាស់ជីលាមកគោ (៥ត/ហត CM) រួមផ្សំជាមួយជី NPK តាមកម្រិតណែនាំ (CM+NPK) លើក្រុមដីប្រទះឡាងជារៀងរាល់ឆ្នាំ បានជួយឱ្យផលិតកម្មដំណាំស្រូវវស្សាមានស្ថេរភាពល្អប្រសើរជាងការប្រើប្រាស់ជី NPK ឬជីលាមកគោតែមួយមុខដូចមានបង្ហាញដោយក្រាហ្វិក១។ ផ្ទុយទៅវិញ ការដាំដុះដំណាំស្រូវដោយពុំប្រើប្រាស់ជី បានបង្ហាញពីនិន្នាការធ្លាក់ចុះនៃផលិតកម្មតាមពេលវេលាជាក់លាក់។

ក្រាហ្វិក១: ទិន្នផលស្រូវវស្សា(ត/ហត) ឆ្លើយតបទៅនឹងការប្រើប្រាស់ជីផ្សេងៗចាប់ពីឆ្នាំ២០០៥(1) ដល់ឆ្នាំ២០១១(7)




-លទ្ធផលនៃការសិក្សារយៈពេល០៦ឆ្នាំ ដែលក្នុង០១ឆ្នាំដាំដុះដំណាំស្រូវ០២ដង បានបញ្ជាក់ថា និន្នាការនៃផលិតភាពដីកាន់តែមានស្ថេរភាពតាមរយៈការប្រើប្រាស់ជីតាមកម្រិតណែនាំឱ្យបានជាប់លាប់តាមរដូវកាលដាំដុះ ហើយក្នុងករណីនេះ កំណើនផលិតកម្មដំណាំមានការប្រែប្រួលពី១៥ទៅ៣៥%។ ផ្ទុយទៅវិញ ការមិនបានដាក់ជីតាមរដូវកាលដាំដុះដំណាំនាំឱ្យទិន្នផលផលិតកម្មស្រូវថយចុះប្រមាណ៦១%ក្នុងរយៈពេល៦ឆ្នាំ។

-លទ្ធផលស្រែបង្ហាញចំនួន៣៦កន្លែងនៅខេត្តព្រះវិហារ ស្ទឹងត្រែង និងមណ្ឌលគីរីក្នុងឆ្នាំ២០១៣ នៅតែបញ្ជាក់យ៉ាងច្បាស់ថា ការប្រើប្រាស់នូវបង្កិបច្ចេកវិទ្យានៅតែល្អជាងតាមទម្លាប់កសិករ។ សរុបលទ្ធផលរយៈពេល៦ឆ្នាំកន្លងមកដែលមានស្រែបង្ហាញចំនួន១២៦កន្លែង បានបង្ហាញថា (១)ការជំនួសពូជស្រូវកសិករដោយពូជស្រូវជំរុញដោយរាជរដ្ឋាភិបាល (ផ្ការំដួល ផ្ការមៀត ផ្កាចន្ទសែនសរ និងសែនពិដោរ) ទិន្នផលស្រូវកើនពី២,៤៥ត/ហ.តទៅ៣,០៣ត/ហ.ត និងផ្តល់ប្រាក់ចំណេញដុលបន្ថែមចំនួន០,៦៥លានរៀលលើទម្លាប់កសិករ (១,២៧លានរៀល) និង(២)ការប្រើប្រាស់បង្កិបច្ចេកទេសបង្កើនផលិតភាព ទិន្នផលដំណាំស្រូវបានកើនរហូតដល់៣,៩៨ត/ហ.ត និងផ្តល់ប្រាក់ចំណេញដុលបន្ថែមរហូតដល់១,៣៩លានរៀល។

**ក្រាហ្វិក២: ទិន្នផលមធ្យម និងប្រាក់ចំណេញដុលរបស់ការអនុវត្តតាមបង្កិបច្ចេកទេស និងការបញ្ចូលពូជស្រូវធៀបជាមួយការដាំដុះតាមទម្លាប់របស់កសិករ។**



-លទ្ធផលបឋមបានមកពីការសាកល្បងបញ្ចូលពូជស្រូវក្រអូប (ផ្ការំដួល និងផ្ការមៀត) ចំនួន២៥កន្លែង នៅខេត្តព្រះសីហនុ និងកោះកុង បានបង្ហាញថា ពូជស្រូវទាំងពីរនេះអាចដុះលូតលាស់សមស្របនៅស្រែកណ្តាល ដោយផ្តល់ផលជាមធ្យមចំនួន២,៩៦ត/ហាត ខ្ពស់ជាងពូជស្រូវកសិករប្រមាណ០,៥ត/ហាត និងស្រូវលក់បានថ្លៃជាងយ៉ាងហោចណាស់ក៏១,៣ដង ដែលជួយឱ្យកសិករបង្កើននូវប្រាក់ចំណូលរបស់ខ្លួនផង ព្រមទាំងខេត្តអាចមានលទ្ធភាពផ្គត់ផ្គង់អង្ករក្រអូប និងបាយឆ្ងាញ់បម្រើដល់វិស័យទេសចរណ៍ផង។ ពូជស្រូវក្រអូបផ្ការំដេង ផ្ការំដួល និងផ្ការមៀត មានលក្ខណៈធន់ទ្រាំមធ្យមទៅនឹងដីប្រៃ បើធៀបជាមួយពូជស្រូវធន់ដីប្រៃអន្តរជាតិ (Pokkali) និងពូជស្រូវប្រពៃណីដាំដុះនៅតំបន់ឆ្នេរសមុទ្រ (Sar Kramom) នៅស្រុកស្រែអំបិល ខេត្តកោះកុង។

| Variety | DTM (day) | GY (t/ha) | Variety | DTM (day) | GY (t/ha) |
|---|---|---|---|---|---|
| Pokkali | 141 | 1.4 | Phka Romeat | 141 | 1.1 |
| IR66 | 137 | 0.4 | Phka Chan Sen Sar | 164 | 0.7 |
| Chul'sa | 105 | 0.7 | Sar Kramom | 141 | 1.6 |
| Sen Pidao | 137 | 0.7 | Srov Prai | 137 | 0.8 |
| Phka Rumduol | 141 | 1.1 | Hay Vin | 137 | 0.9 |
| Phka Rumdeng | 141 | 1.5 | Neang Kok | 137 | 1.3 |

Variety= ពូជ DTM (day)= អាយុកាល (ថ្ងៃ)  GY (t/ha)= ទិន្នផល (ត/ហាត)

-ការពន្លិចទឹកដំណាំស្រូវនៅដំណាក់កាលសំណាប ទៅបែកគុម្ពឱ្យលិចពាក់កណ្តាលស្លឹកក្នុងរយៈពេលពី៦ ទៅ ១០ថ្ងៃ ជាវិធានការដ៏ល្អមួយក្នុងការកាត់បន្ថយកូនញាស់របស់មមាចត្នោត និងអត្រារស់របស់វា។ ក្នុងករណីនេះ អត្រាកូនញាស់បានថយមក៥៨% (៦ថ្ងៃ) ទៅ៣៤% (១០ថ្ងៃ) ហើយ%កូនញាស់ដែលនៅរស់ បន្ទាប់ពីបង្ខុះទឹកបាន៦ថ្ងៃ មានពី ៥០% (៦ថ្ងៃ) ទៅ៣២% (១០ថ្ងៃ)។

ក្រាហ្វិក៣. បរិមាណកូនមមាចត្នោតញាស់ (អ័ក្ស Y, Hatching) បន្ទាប់ពន្លិចទឹកពី២ ទៅ១០ថ្ងៃ (អ័ក្ស X, day) និង%កូនមមាចត្នោតដែលញាស់ ហើយនៅរស់បន្ទាប់ពីបង្ខុះទឹករយៈពេល៦ថ្ងៃ (Surviving after 6 day, %)




## ឃ. ការបង្កើនរដូវកាលដាំដុះដំណាំស្រូវ និងវិធីសាស្ត្ររៀបចំដី

-លទ្ធផលពិសោធន៍ចំនួន៦កន្លែងនៅស្រែទំនាបរំពឹងទឹកភ្លៀង ដែលមានប្រភពទឹកស្រោចស្រពបន្ថែម ឬពេញលេញ ក្នុងរយៈពេល២ឆ្នាំបានបង្ហាញថា (១)កសិករអាចដាំដុះដំណាំស្រូវបាន៣ដង/ឆ្នាំ ដោយប្រើពូជស្រូវជលសារ (ឬពូជស្រូវមានអាយុកាលខ្លីជាង១០០ថ្ងៃ) សម្រាប់ស្រូវប្រាំង (DS) និងស្រូវដើមរដូវវស្សា (EWS) និងពូជស្រូវផ្ការំដួល (ឬ

ពូជស្រូវចេញផ្កាដំណាល) សម្រាប់រដូវវស្សា (WS) (២)ការដាំដុះដំណាំស្រូវ២ ឬពាដងក្នុង១ឆ្នាំដោយការប្រើប្រាស់ជី និងរៀបចំដីសមស្រប មិនបណ្តាលឲ្យផលិតភាពដីធ្លាក់ចុះទេ (៣)ការដាំដុះដំណាំស្រូវពាដង/ឆ្នាំ (DS+EWS+WS) បង្កើនបរិមាណផលស្រូវក្នុងផ្ទៃដី១ហតដល់១០,៣តោន និងប្រាក់ចំណេញដុល១.០២៤ដុល្លារ និង(៤)ការដាំដុះដំណាំស្រូវដើមរដូវវស្សា និងរដូវវស្សា (EWS+WS) ផ្តល់បរិមាណផល៧,៣តោន និងប្រាក់ចំណេញដុល៩២៥ដុល្លារ ហើយក៏ជាប្រព័ន្ធដាំដុះដែលមានអត្រាវិនិយោគល្អជាងប្រព័ន្ធដាំដុះដទៃទៀត ព្រមទាំងអនុញ្ញាតិឲ្យកសិករអាចដាំដុះដំណាំបន្លែ ឬសណ្តែកបាយក្នុងរដូវប្រាំង។




ក្រាហ្វិក៤. បរិមាណផលស្រូវឆ្នាំទី១ (PY1) និងទី២ (PY2) ទុនចំណាយ (Input) ប្រាក់ចំណូល (Income) និងប្រាក់ចំណេញដុល (GM) របស់ប្រព័ន្ធដាំដុះ ១)ស្រូវប្រាំង+ដើមរដូវវស្សា (DS+EWS) ២)ស្រូវប្រាំង+ស្រូវវស្សា (DS+WS) ៣)ស្រូវដើមរដូវវស្សា+ស្រូវវស្សា (EWS+WS) និង៤)ស្រូវប្រាំង+ស្រូវដើមរដូវវស្សា+ស្រូវវស្សា (DS+EWS+WS)




ក្រាហ្វិក៥. ទិន្នផលស្រូវប្រាំង (DS) ស្រូវដើមរដូវវស្សា (EWS) ឆ្នាំ២០១២និង២០១៣ និងទិន្នផលមធ្យមប្រចាំឆ្នាំ (MDS, MEWS) នៃការភ្ជួររាស់ដី (Tillage) និងមិនភ្ជួររាស់ដី ដាំដោយឧបករណ៍ Rogor (No tillage)

-ការដាំដុះស្រូវប្រាំង និងស្រូវដើមរដូវវស្សា ដោយប្រើប្រាស់ឧបករណ៍ដាំគ្រាប់ស្ទូតជាជួរ Rogor និងមិនបានភ្ជួររាស់ដី (No tillage) គឺមិនសមប្រកបសម្រាប់ដីស្រែទំនាបរំពឹងទឹកភ្លៀងឡើយ (ក្រាហ៊ិក៥)។ ទិន្នផលស្រូវជាមធ្យមទទួលបានពីការមិនភ្ជួររាស់ដីបានធ្លាក់ចុះប្រមាណ១ត/ហត ធៀបទៅនឹងការភ្ជួររាស់ដី។

### ង. មន្ទីរពិសោធន៍

**-មន្ទីរពិសោធន៍គុណភាពអង្ករ:** បានអនុវត្តលើការវិភាគរកធាតុអាមីឡូស រកសីតុណ្ហភាពចម្អិននិងរកលក្ខណៈរូបរបស់គ្រាប់អង្ករដោយប្រើម៉ាស៊ីន S21 សរុបបានចំនួន៩១សំណាក

**-មន្ទីរពិសោធន៍ជីវបច្ចេកវិទ្យា:** បានបំពាក់នូវឧបករណ៍ PCR និង Gel documentation ជំនួសឲ្យឧបករណ៍ចាស់ សម្រាប់ធ្វើការកំណត់ពន្ធុដោយប្រើសារធាតុសម្គាល់ជាជំនួយ (MAS) និងបានរៀបចំដាក់ឲ្យដំណើរការប្រើប្រាស់។

**-មន្ទីរពិសោធន៍ជាលិកាវប្បកម្មដំណាំ:** បានដាំពូជចេកអំបូងបានចំនួន៧០កូននិងបានដាំពង្រីកបន្តលើកទី១។ ជាមួយគ្នានេះដែរបានបន្តដាំពង្រីកនិងអភិរក្សដំណាំចេក ដំឡូងឈើ ដំឡូងជ្វា ដំឡូងបារាំងនិងពពួកផ្កា

**-មន្ទីរពិសោធន៍វិភាគដីនិងទឹក:** បានវិភាគលើសំណាកដីនូវ pH, OC, OM, NH4+, NO3-, PSA, Field Capacity, Soil Water, អាសូត (N) និង ផូស្វ័រ (P) សរុបចំនួន២.០០០សំណាក ព្រមទាំងបានវិភាគលើសំណាកទឹកនូវ pH, EC, TDS, Turbidity, Fe, Al, $NO_3^-$ និង $NH_4^+$ សរុបចំនួន៥៩សំណាក។

### ច. ការផ្សព្វផ្សាយ បណ្តុះបណ្តាល និងសហប្រតិបត្តិការ

**-តាមរយៈកិច្ចប្រជុំក្រៅប្រទេស:** បានធ្វើបទបង្ហាញនូវលទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថានទៅដល់អ្នកវិទ្យាសាស្ត្រពាក់ព័ន្ធបានចំនួន១៩លើក។

**-តាមរយៈអត្ថបទវិទ្យាសាស្ត្រ:** តាមរយៈលទ្ធផលនៃការងារស្រាវជ្រាវបានចូលរួមសរសេរអត្ថបទវិទ្យាសាស្ត្រ និងបោះពុម្ពក្នុងទស្សនាវដ្តីវិទ្យាសាស្ត្របានចំនួន១អត្ថបទ (Jaquie Mitchella, Kimngoy Cheth, Vang Seng, Bunna Lor, Makara Ouk, Shu Fukai (2013). Wet cultivation in lowland rice causing excess water problems for the subsequent non-rice crops in the Mekong region. Field Crops Research 152 (2013) 57-64

**-តាមរយៈការបោះពុម្ព និងចែកចាយ:** បានបកប្រែជាភាសាខ្មែរ និងបោះពុម្ពសៀវភៅស្នោចង្រៃនៃដំណាំស្រូវនៅអាស៊ីរបស់ IRRI សរុបចំនួន១.៥០០ក្បាល ព្រឹត្តិបត្រព័ត៌មានកសិករចំនួន១២ប្រភេទសរុបចំនួន២០.០០០ច្បាប់ របាយការណ៍ប្រចាំឆ្នាំ២០១២ចំនួន៥០០ក្បាល ប្រតិទិនឆ្នាំ២០១៤ចំនួន៧០០ច្បាប់ និងបដាសកម្មភាពប្រចាំឆ្នាំ២០១៣ចំនួន១០ផ្ទាំង។ បានធ្វើការបែងចែកសៀវភៅស្តីពីស្មៅចង្រៃនៃដំណាំស្រូវនៅអាស៊ី ពូជស្រូវនិងបច្ចេកទេសដាំដុះ ការគ្រប់គ្រងដីជាតិដី កម្រងឯកសារអំពីក្សេត្របរិស្ថានដំណាំស្រូវក្នុងប្រទេសកម្ពុជា ការកំណត់ក្រុមដីស្រែលក្ខណៈសំខាន់ៗរបស់ពូជស្រូវចំនួន១០ពូជ បង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ សមិទ្ធផល១០ឆ្នាំរបស់វិទ្យាស្ថាន និងទស្សនាវដ្តីកសិកម្មកម្ពុជាចំនួន៣.៦០០ច្បាប់ បដាស្តីពីប្រភេទដីគីមី បរិមាណ និងពេលវេលាបាចចំនួន៤០ផ្ទាំង ព្រមទាំងបានបែងចែកព្រឹត្តិបត្រព័ត៌មានកសិករចំនួន១៤.៧០០ច្បាប់ ជូនថ្នាក់ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាល អង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្ម ការិយាល័យកសិកម្មស្រុក និងអ្នកពាក់ព័ន្ធជាពិសេសដល់កសិករ

**-តាមរយៈគេហទំព័រ www.cardi.org.kh និង www.crkb.org.kh:** ក្នុងរយៈពេលមួយឆ្នាំនេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន៣២២.៩០០នាក់ មកពីប្រទេសចំនួន៩៩ប្រទេស (តិចជាងឆ្នាំ២០១២ចំនួន៥ប្រទេស) ដោយគិតជាមធ្យមមានប្រមាណ៨៩៦នាក់/ថ្ងៃ (កើនលើសឆ្នាំ២០១២ចំនួន៥៩២នាក់/ថ្ងៃ)

**-ទិវាស្រែបង្ហាញ និងការបណ្តុះបណ្តាលកសិករ:** បានធ្វើទិវាស្រែបង្ហាញចំនួន១០កន្លែង ដែលមានកសិករចូលរួមសរុបចំនួន២៥០នាក់ បានបើកវគ្គបណ្តុះបណ្តាលកសិករចំនួន១៤វគ្គដែលមានអ្នកចូលរួមចំនួន៥៥០នាក់។ បានចែកពូជស្រូវផ្ការំដួល ផ្ការំដេង ផ្ការមៀត និងសែនពិដោរ (ដោយក្នុងមួយគ្រួសារចំនួន៥គីឡូក្រាម) ព្រមទាំងបានបង្រៀនអំពីវិធីសាស្ត្រផលិត និងសម្រិតសម្រាំងគ្រាប់ពូជស្រូវជូនកសិករចំនួន១៦៦គ្រួសារ (ស្ទឹងត្រែង=៧០ មណ្ឌលគីរី=៥៩ និងព្រះវិហារ=៣៧) ដោយផលិតគ្រាប់ពូជស្រូវបានបរិមាណជាង៥០តោន ទុកសម្រាប់ដាំដុះនារដូវក្រោយ

**-តាមរយៈការចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុនិងទូរទស្សន៍:** បានចូលរួមជាវាគ្មិននៃកិច្ចប្រជុំផ្សេងៗ វិទ្យុជាតិកម្ពុជា និងវិទ្យុអាស៊ីសេរីចំនួន១៣លើក ព្រមទាំងផ្តល់បទយកការណ៍ និងថតវីដេអូដល់ CHANNEL NewsAsia នៅវិទ្យាស្ថានចំនួន១លើក

**-តាមរយៈសារណា:** បានដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្របានចំនួន២០នាក់ ដែលក្នុងនោះ៧នាក់មកពីសាលាជាតិកសិកម្មព្រែកលៀបនិង១៣នាក់មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម

**-ការងារបណ្តុះបណ្តាល:** បានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន១០វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន២២៥នាក់។ បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន១៤លើក ដែលមានមន្ត្រីវិទ្យាស្ថានទៅចូលរួមសរុបចំនួន២៣នាក់ និងក្រៅប្រទេសចំនួន៣៥លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន៤៩នាក់

**-ការងារសហប្រតិបត្តិការ:** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយ AusAID, ACIAR, UQ, NSWDI, CSIRO, KOPIA Center, RDA, IRRI, JIRCAS, YAAS, Tokyo University, CASS, YASS, CIAT, AVRDC និង IAS បានល្អខ្ជាប់ខ្ជួន

-បានចូលរួមបង្រៀនថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

### ៥.៣-២. វាយតម្លៃនិងសំណើ

ក្នុងឆ្នាំ២០១៣នេះ ថ្នាក់ដឹកនាំនិងមន្ត្រីនិយោជិតទាំងអស់ បានខិតខំប្រឹងប្រែងដឹកនាំនិងបំពេញភារកិច្ច ដើម្បីកសាង និងអភិវឌ្ឍន៍វិទ្យាស្ថានដោយស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ស្របតាមវិធានការ ដែលបានលើកឡើងក្នុងឆ្នាំ២០១២។ សមិទ្ធផលសំខាន់ៗមានជាអាទិ៍ (១)វិទ្យាស្ថានបានធ្វើពិសោធន៍ចំនួន៧៤ប្រភេទ នៅ៥៧៥កន្លែង ដែលនៅក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន៣៧៧កន្លែង និងបានធ្វើអង្កេតបានចំនួន១០ប្រភេទដោយបានធ្វើសម្ភាសន៍កសិករចំនួន៥.០០០គ្រួសារ (២)បានធ្វើទិវាស្រែបង្ហាញចំនួន១០កន្លែង មានកសិករចូលរួមសរុបចំនួន២៥០នាក់ និងបានបើកវគ្គបណ្តុះបណ្តាលកសិករចំនួន១៤វគ្គ មានអ្នកចូលរួមចំនួន៥៥០នាក់ (៣)បាន

បកប្រែជាភាសាខ្មែរ និងបោះពុម្ពសៀវភៅស្ទោចង្រៃនៃដំណាំស្រូវនៅអាស៊ីរបស់ IRRI ព្រឹត្តិបត្រព័ត៌មានកសិករ និងរបាយការណ៍ប្រចាំឆ្នាំចំនួន២២.៥០០ច្បាប់ ក្នុងនោះបានធ្វើការបែងចែកសៀវភៅឯកសារនានា របស់វិទ្យាស្ថានចំនួន៣.៦០០ក្បាល និងព្រឹត្តិបត្រព័ត៌មានកសិករចំនួន១៤.៧០០ច្បាប់ ជូនថ្នាក់ដឹកនាំក្រសួង ក្រុមប្រឹក្សាភិបាល អង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក និងអ្នកពាក់ព័ន្ធ ជាពិសេសដល់កសិករ ដើម្បីចូលរួមអនុវត្តក្នុងមុំបង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបណីយកម្មដំណាំកសិកម្ម នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយជំរុញផលិតកម្មដំណាំស្រូវនិងការនាំចេញអង្ករ (៤)បានបញ្ចេញពូជស្រូវដំណើបស្បៃមង្គល (៥)បានបង្កើត និងជ្រើសរើសបាននូវស្រឡាយស្រូវមួយចំនួន ដែលចាំបាច់សម្រាប់ធ្វើពិសោធន៍បន្ត និង (៦)បញ្ជាក់នូវបច្ចេកទេសបង្កើនផលិតភាពដំណាំមួយចំនួនដូចមានរៀបរាប់ខាងលើ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនិយោជិតទាំងអស់ ព្រមទាំងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណនិងគោលនយោបាយជំរុញផលិតកម្មដំណាំស្រូវនិងការនាំអង្ករចេញរបស់រាជរដ្ឋាភិបាល ក៏ដូចជាផែនការយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានមានសំណូមពរសំខាន់ៗចំនួន០៣គឺ (១)សុំជួយបង្កើនថវិការាជរដ្ឋាភិបាលដល់វិទ្យាស្ថានឱ្យស្របតាមតម្រូវការ (២)សុំជួយផ្គត់ផ្គង់ត្រាក់ទ័រ ផាលរនាស់ ម៉ាស៊ីនស្ទូង និងម៉ាស៊ីនច្រូតកាត់បោកបែន (Combine harvester) និង(៣)សុំជួយផ្តល់មន្ត្រីក្របខណ្ឌដែលមានជំនាញស្រាវជ្រាវ ជាពិសេសនិស្សិតដែលទើបនឹងចប់ការសិក្សានិងប្រលងជាប់ក្របខណ្ឌរដ្ឋ។

ទន្ទឹមនឹងនោះដែរ វិទ្យាស្ថាននៅជួបប្រទះការលំបាកចំនួន០៣ធំៗ ដែលទោះបីជាបញ្ហាចំនួន០២ថ្នាក់ដឹកនាំ និងជាពិសេស ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានជួយធ្វើអន្តរាគមន៍ជាបន្តបន្ទាប់ទៅស្ថាប័នទទួលខុសត្រូវក៏ដោយ ក៏បញ្ហាទាំងនេះនៅតែជាបញ្ហាប្រឈមដដែល ពីព្រោះជាបញ្ហាផែនការយូរអង្វែងរបស់រាជធានីភ្នំពេញ និងការប្រកួតប្រជែងទីផ្សារធនធានមនុស្ស។ បញ្ហាទាំង០៣នោះគឺ (១)ប្រព័ន្ធទឹកស្អាតមិនទាន់មកដល់ (២)ភ្លើងអគ្គិសនីនៅតែបន្តដាច់ជាប្រចាំជារៀងរាល់ថ្ងៃ ដែលបញ្ហាទាំង០២នេះបង្កឱ្យមានការលំបាកក្នុងដំណើរការមន្ទីរពិសោធន៍ និងជាពិសេសបណ្តាលឱ្យឆាប់ខូចខាតឧបករណ៍ សារធាតុគីមីវិភាគ ព្រមទាំងបរិមាណប្រេងប្រើប្រាស់ច្រើន និង(៣)ទាំងមន្ត្រីរាជការ និងបុគ្គលិកកិច្ចសន្យារបស់វិទ្យាស្ថាន ដែលបានទទួលការបណ្តុះបណ្តាលកម្រិតខ្ពស់ភាគច្រើនបានសុំព្យួរការងារ និងឈប់ ដែលបង្កឱ្យការងារស្រាវជ្រាវនៅតែមានកម្រិត។

### ៥.៣-៣. វិធានការ

ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គភាពស្រាវជ្រាវជាតិនិងអន្តរជាតិ មន្ទីរកសិកម្មរាជធានីខេត្ត អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងក្រៅស្រុកនានាដើម្បី (១)បន្តអភិវឌ្ឍពូជដំណាំកសិកម្ម ដែលមានសក្តានុពលទិន្នផលខ្ពស់ហើយប្រកបដោយគុណភាពល្អប្រពៃធន់ទ្រាំនឹងទឹកជំនន់ គ្រោះរាំងស្ងួត ជាតិប្រៃនិងកំដៅ ពូជស្រូវអាយុកាលខ្លីជាង ១០០ថ្ងៃ និងបន្តធ្វើការស្រាវជ្រាវដោយប្រើវិធីសាស្ត្ររួមគ្នា ប្រកបដោយសុវត្ថិភាព និងមាននិរន្តរភាព ដើម្បីជួយកសិករក្នុងការការពារការបាត់បង់ទិន្នផលដំណាំ និងប្រាក់ចំណេញ (២)បន្តស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសនៃប្រព័ន្ធគ្រប់គ្រងជីជាតិដី សារធាតុចិញ្ចឹមប្រកបដោយលក្ខណៈសេដ្ឋកិច្ច និងនិរន្តរភាពខ្ពស់ ដើម្បីជួយប្រជាកសិករក្នុងការបង្កើន និងធ្វើឱ្យមានស្ថេរភាពទិន្នផលដំណាំនៅក្នុងប្រព័ន្ធកសិកម្មនៃតំបន់ទំនាប តំបន់ស្រោចស្រពនិងតំបន់ខ្ពង់រាប តាមរយៈការធ្វើឱ្យកាន់តែប្រសើរឡើង នូវចំណេះដឹងលើផ្នែកគ្រប់គ្រងដី និងសារធាតុចិញ្ចឹមរបស់ដំណាំ (៣)បន្តសិក្សារកលទ្ធភាពបង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្មក្នុងប្រព័ន្ធកសិកម្មនៃតំបន់ទំនាប និងតំបន់ខ្ពង់រាប (៤)បន្តស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ សមត្ថភាពវិភាគក្នុងមន្ទីរពិសោធន៍ផ្នែកវិភាគដី ទឹក រុក្ខជាតិ ជំងឺ រុក្ខវិទ្យា និងជាលិកាវប្បកម្ម(៥)បន្តពង្រឹងនិងជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាទៅដល់កសិករ និងអ្នកពាក់ព័ន្ធនានាតាមរយៈការបោះពុម្ពផ្សាយគេហទំព័រ កាសែត វិទ្យុ និងទូរទស្សន៍ (៦)លើកកម្ពស់សមត្ថភាពរបស់មន្ត្រី និយោជិតតាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំផ្សេងៗទាំងក្នុង និងក្រៅប្រទេស និង(៧)ប្រើប្រាស់អគ្គិសនីដោយសន្សំសំចៃ។

## ៥.៤- ការងារសេវាកម្មរបស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល (ឧបសម្ព័ន្ធទី១២-១៤)

ការងារផលិតកម្មសត្វ និងសុខភាពសត្វ ជាវិស័យមួយយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២និងកំពុងឈានចូលបន្តការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់បញ្ចូលវិស័យនេះក្នុងមុំមួយ គឺការលើកកំពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ជាពិសេសបាននឹងកំពុងបន្តបំពេញការអនុវត្តការងារ និងភារកិច្ចរបស់ខ្លួនយ៉ាងមមាញឹកបំផុត និងធ្វើឲ្យសម្រេចសមិទ្ធផលយ៉ាងធំធេងជាបន្តបន្ទាប់ប្រកបដោយជោគជ័យយ៉ាងត្រចះត្រចង់។

វិស័យនេះ បានបង្កើតការងារ និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករនៅតាមជនបទ ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងកំណើនជីវភាពគ្រួសារឲ្យមានភាពធូរធា និងសេដ្ឋកិច្ចរុងរឿង ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ ដើម្បីសម្រេចគោលដៅ និងគោលបំណងខាងលើ វិស័យនេះបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបន្តការគាំទ្រ និងពង្រឹងសន្តិសុខស្បៀង ផ្តល់អាហាររូបត្ថម្ភគ្រប់គ្រាន់ និងសុវត្ថិភាពម្ហូបអាហារសម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ។ ក្នុងឆ្នាំ២០១៣កន្លងទៅនេះ ក៏ដូចជារយៈពេលឆ្នាំបន្តបន្ទាប់ទៀត សកម្មភាពជាច្រើនត្រូវបានអនុវត្តនៅក្នុងរាជធានី ខេត្តទាំង២៤ ដោយមានការសម្របសម្រួល និងសហការជាមួយអង្គភាពជំនាញ មន្ទីរកសិកម្មរាជធានី ខេត្ត គម្រោងកម្មវិធីនានា ព្រមទាំងជាមួយភ្នាក់ងារប្រតិបត្តិមួយចំនួននៅតាមមូលដ្ឋាន អង្គការក្រៅ រដ្ឋាភិបាល បណ្តាប្រទេសជាមិត្ត អាជ្ញាធរមូលដ្ឋាន និងផ្នែកឯកជន សំដៅជួយក្នុងការអភិវឌ្ឍន៍លើការងារផលិតកម្ម និងសុខភាពសត្វនេះយ៉ាងសកម្មបំផុត។

ទោះបីយ៉ាងនេះក្តីវិស័យផលិតកម្មនិងបសុព្យាបាល នៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជាជំងឺឆ្លងរាលដាលសត្វជាពិសេសជំងឺផ្តាសាយបក្សី គោក្របីខ្វះខាតចំណីអាហារ ការយល់ដឹងរបស់កសិករលើបច្ចេកទេស និងការផ្សព្វផ្សាយបច្ចេកទេស នៅមានកម្រិត ថ្លៃដើមផលិតកម្មខ្ពស់ និងវិនិយោគទុនលើវិស័យចិញ្ចឹមសត្វនៅមានសន្ទុះយឺត។ល។

ឆ្នាំ២០១៣កន្លងទៅនេះ ជំងឺឆ្លងសត្វ នៅជាបញ្ហាប្រឈមសំខាន់បំផុត ដែលវិស័យផលិតកម្មនិងបសុព្យាបាលបាននឹងកំពុងយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការប្រយុទ្ធប្រឆាំង ជាពិសេសជំងឺផ្តាសាយបក្សីលើបក្សី ដែលបានផ្ទុះឡើងចំនួន០៧ករណីនៅខេត្តតាកែវ កំពង់ស្ពឺ កំពង់ចាម កំពត សៀមរាប និងបាត់ដំបង។ បន្ថែមលើសពីនេះ ស្ថានភាពជំងឺដទៃផ្សេងទៀតរួមមាន ជំងឺជ្រូកត្រចៀកខៀវ ជំងឺសារទឹក និងជំងឺអុតក្តាម គឺមានការផ្ទុះរាលដាលនៅតំបន់មួយចំនួន ដែលបង្កឲ្យមានការប៉ះពាល់ដល់ផលិតកម្មសត្វ។

លទ្ធផលដែលសម្រេចបានទាំងនេះ ក៏ដោយសារមានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល ជាពិសេសក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដោយមានការខិតខំប្រឹងប្រែងយក ចិត្តទុកដាក់ពីមន្ត្រីនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល មន្ទីរកសិកម្មខេត្ត ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ភ្នាក់ងារសុខភាពសត្វភូមិប្រជាកសិករម្ចាស់សត្វ ជាពិសេសម្ចាស់ជំនួយពីអង្គការជាតិ និងអន្តរជាតិនានា។

### ៥.៤.១-លទ្ធផល

#### ក- គោលដៅនិងយុទ្ធសាស្រ្តសំខាន់ៗ

ឆ្នាំ២០១៣នេះ អនុវិស័យផលិតកម្ម និងបសុព្យាបាល បានកំណត់គោលដៅគោលនយោបាយ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ ដើម្បីបង្កើននូវផលិតភាពសត្វ ដោយធានាបាននូវកំលាំងអូសទាញ ការពារ និងទប់ស្កាត់ជំងឺឆ្លងសត្វ សុខភាពសាធារណៈ ម្ហូបអាហារ និងការនាំចេញសត្វ និងផលិតផលមានដើមកំណើតពីសត្វ ដើម្បីប្តូរជារូបិយប័ណ្ណសម្រាប់ជាចំណូលគ្រួសារ និងសេដ្ឋកិច្ចជាតិ ក្នុងការអនុវត្តការងារលើអនុវិស័យនេះ ប្រកបដោយប្រសិទ្ធភាព ស្របតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យរយៈពេលខ្លី មធ្យម និងវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ នៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ គម្រោងសកម្មភាពកម្មវិធីជាអទិភាពសម្រាប់ការអនុវត្តឱ្យស្របតាមគោលនយោបាយជាតិរួមមាន÷

- កសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ

- អភិវឌ្ឍធនធានមនុស្ស និងអង្គភាព
- លើកកម្ពស់ការចិញ្ចឹមសត្វតាមគ្រប់រូបភាព
- ការកាត់បន្ថយអត្រាសត្វឈឺ និងងាប់
- ការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពគុណភាពម្ហូបអាហារមានប្រភពពីសត្វដើម្បីធានាសុខភាពសាធារណៈ ពិសេសការទប់ស្កាត់ជំងឺសួណូស
- ការធ្វើឱ្យប្រសើរឡើងនូវផលិតកម្មចំណីសត្វ និងធ្វើឱ្យប្រសើរឡើងនូវពូជសត្វ
- ជំរុញការគ្រប់គ្រងកាកសំណល់សត្វ ជាពិសេសតាមរយៈការសាងសង់ឡជីវឧស្ម័ន
- ជំរុញជាបណ្តើរៗ ការកែទម្លាប់ការចិញ្ចឹមសត្វរបស់កសិករបែបយថាផល និងកែប្រែពីការចិញ្ចឹមសត្វសម្រាប់ផ្គត់ផ្គង់គ្រួសារទៅជាការចិញ្ចឹមសត្វតាមបច្ចេកទេសក្នុងទ្រង់ទ្រាយបែបពាណិជ្ជកម្ម ដោយមានជីវសុវត្ថិភាព
- បង្កើន និងពង្រឹងការផ្សព្វផ្សាយលើការងារចិញ្ចឹមសត្វ និងសុខភាពសត្វ
- បង្កើន និងពង្រឹងការស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- ជំរុញឱ្យប្រសើរឡើងនូវឥណទានក្នុងការសាងសង់ឡជីវឧស្ម័ន និងការចិញ្ចឹមសត្វ
- លើកទឹកចិត្តការវិនិយោគលើការចិញ្ចឹមសត្វ សេវាកម្មសុខភាពសត្វ និងធ្វើឱ្យប្រសើរឡើងនូវទីផ្សារសត្វ និងផលិតផលមានដើមកំណើតពីសត្វ

## ខ. សកម្មភាពនិងលទ្ធផលសម្រេចបានឆ្នាំ២០១៣

### ខ.១. លទ្ធផលសំខាន់ៗឆ្នាំ២០១៣

ការអនុវត្តការងារអនុវិស័យនេះ ក្នុងរយៈមួយឆ្នាំកន្លងទៅនេះ ទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម÷

-ស្ថិតិសត្វ បានកត់សម្គាល់ថា គោ ក្របីសរុប **៤.០៥០.០០៩** ក្បាល កើនឡើងចំនួន ០,៤០% ក្នុងនោះ គោសរុបចំនួន **៣.៤៣០.៨៩៥** ក្បាល កើនឡើង ១,៦០ % និងក្របីសរុបចំនួន **៦១៩.១១៤** ក្បាល ថយចុះ **៥,៧៦** % ធៀបឆ្នាំ២០១**២** ។ សត្វស្លាបសរុបចំនួន២៧.៣១៦.៤១៥ កើន **១៧,៦៧**% និងជ្រូកចំនួន២.៤៣៦.៦៩៩ កើនឡើង **១០,៣៣** % ធៀបទៅនឹងឆ្នាំ២០១**២**។

-តាមការវិភាគពីសូចនាករនៃសត្វគ្រប់ប្រភេទ បានសន្និដ្ឋានថា សត្វសុរបមានការកើនឡើងដល់ ៣៣,៩៩លានក្បាល ដែលស្មើនឹង១៤.៧៥% ធៀបនឹងចំណុចដៅ **២៩,៣**លានក្បាល។

-ចុងឆ្នាំ២០១៣ ស្ថានីយមានជ្រូកពូជសរុបចំនួន **១៤២**ក្បាល ក្នុងនោះមេពូជមានចំនួន **១៣០**ក្បាល និងបាពូជមានចំនួន**១២**ក្បាល និងកូនជ្រូក ៧៥ក្បាល។ ឆ្នាំ២០១៣ ស្ថានីយផលិតបានកូនជ្រូកពូជចំនួន **៥៦៨**ក្បាល ដែលបានលក់ចែកចាយជូនកសិករសម្រាប់ធ្វើពូជក្នុងតម្លៃគោលនយោបាយរដ្ឋ។ កសិករពីខេត្តចំនួន**១២** រួមមាន ខេត្តកណ្តាល ព្រះវិហារ តាកែវ ព្រះសីហនុសៀមរាប ព្រៃវែង កំពង់ចាម រាជធានីភ្នំពេញ ពោធិសាត់ បន្ទាយមានជ័យ កំពតនិងរតនៈគីរីបានទទួលទិញជ្រូកពូជពីស្ថានីយ ដើម្បីចិញ្ចឹមផ្សព្វផ្សាយពូជបន្ត

-ចុងឆ្នាំ២០១៣ ស្ថានីយមានចំនួនគោសរុប **២០៦** ក្បាល ក្នុងនោះមានគោពូជកំផែងសែនចំនួន **៣៨**ក្បាល និងក្នុងឆ្នាំនេះផលិតគោបានចំនួន៣៣ក្បាល។ ស្ថានីយបានផ្សព្វផ្សាយពូជគោទៅតាមបណ្តាខេត្តដូចជា ខេត្តសៀមរាប កំពត និងបាត់ដំបង។ ស្ថានីយមិនគ្រាន់តែជាកន្លែងចិញ្ចឹមគោពូជប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកន្លែងដាំ និងផ្សព្វផ្សាយដំណាំចំណីសត្វផងដែរ។ ឆ្នាំ២០១៣ ស្ថានីយបានចែកពូជស្មៅឃីងក្រាសហ្គីណេ ម៉ារ៉ាន់ខូមុលឡាតូប៉ាស្ពាឡូមនិងស៊ីម្ពងដល់បណ្តាខេត្តមួយចំនួន។

-ការកែលំអរពូជសត្វនិងការដាំដំណាំចំណីសត្វ កំពុងតែមានការរីកចម្រើនល្អប្រសើរ និងពង្រីកការផ្សព្វផ្សាយពូជសត្វ និងពូជស្មៅជាបន្តទៅតំបន់ផ្សេងៗ ទូទាំងប្រទេសយ៉ាងផុសផុល

-ការសាងសង់ឡជីវឧស្ម័ន÷ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៣ ការកសាងឡជីវឧស្ម័ន បានអនុវត្តក្នុងខេត្តចំនួន ១៤ សុរបមានចំនួន ២០.៣៣៨ ឡ ដែលក្នុងនោះ នៅឆ្នាំ ២០១៣ ឡជីឧស្ម័ន បានសាងសង់ចំនួន **១.១១៥** ឡ

-ជំងឺអុតក្តាម សារទឹក បូសខ្យល់ ជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀត គឺត្រូវបានចាត់ទុកថា ជាជំងឺឆ្លងដ៏សំខាន់ ដែលនៅតែបន្តការបង្កនូវភាពស្មុគស្មាញ បំផ្លិចបំផ្លាញ និងគ្រោះមហន្តរាយដល់អាយុជីវិតមនុស្ស សត្វ

-ជំងឺផ្តាសាយបក្សី គឺនៅជាបញ្ហាចំបង ហើយនាឆ្នាំ២០១៣ ជំងឺផ្តាសាយបក្សីលើបក្សី បានផ្ទុះឡើងចំនួន០៧ករណី នៅខេត្តតាកែវ កំពង់ស្ពឺ កំពង់ចាម កំពត សៀមរាប និងបាត់ដំបង។ បន្ថែមលើសពីនេះ ស្ថានភាពជំងឺដទៃផ្សេងទៀតរួមមាន ជំងឺជ្រូកត្រចៀកខៀវ ជំងឺសារទឹក និងជំងឺអុតក្តាម គឺមានការផ្ទុះរាលដាលនៅតំបន់មួយចំនួន ដែលបង្កឲ្យមានការប៉ះពាល់ដល់ផលិតកម្មសត្វ

-ជាលទ្ធផលនៅទូទាំងប្រទេសសត្វបានទទួលការចាក់ថ្នាំការពាររួមមាន÷ សារទឹកគោក្របីបានចំនួន ១.៣៩៣.៨០៤ ក្បាល អុតក្តាមគោក្របីបានចំនួន៨៦.៥៥២ក្បាល បូសខ្យល់ចំនួន១៨.១០២ក្បាល សារទឹកជ្រូកចំនួន១៩១.២៣៧ ក្បាល ប៉េស្តជ្រូកចំនួន២៤២.៨៨២ក្បាល សាល់ម៉ូជ្រូកចំនួន១៣១.០៦៥ក្បាល អុតក្តាមជ្រូកចំនួន៧.៦០៦ក្បាល អូហ្សេស្គីជ្រូកចំនួន៣៩.២២០ក្បាល កញ្ជ្រឹលជ្រូកចំនួន៥.៨៧៧ក្បាល ញូវកាសបក្សីចំនួន ៦៣១.៥៣១ក្បាល អាសន្នរោគមាន់ចំនួន៤៤២.៩៥៤ក្បាល អុតបក្សីចំនួន ៣៦៤.០៨៧ ក្បាល អាសន្នរោគទាចំនួន ៤៤.៣៧៦ក្បាល ហ្គុមបូរូចំនួន ៣.៥០០ ក្បាល និងប៉េស្តទាចំនួន១០៨.៤០៥ក្បាល

-ការទប់ស្កាត់ជំងឺឆ្លងសត្វៈ បានពង្រឹងការត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ពង្រឹងការស្រាវជ្រាវ យកវត្ថុវិភាគ ធ្វើការផ្សព្វផ្សាយជាប្រចាំនូវផលប៉ះពាល់នៃជំងឺឆ្លង វិធានការការពារ និងជីវសុវត្ថិភាពក្នុងការចិញ្ចឹមសត្វនៅតាមផ្ទះ ក៏ដូចជានៅតាមកសិដ្ឋាន ចុះស្រាវជ្រាវ និងទប់ស្កាត់តាមគ្រប់ច្រកនាំចូល ពិសេសបណ្តាខេត្តតាមព្រំដែន រាយការណ៍ជាប្រចាំពីស្ថានភាពវិវត្តន៍នៃជំងឺឆ្លង និងលទ្ធផលនៃការអនុវត្តវិធានការទាំងឡាយ

-ការទប់ស្កាត់បទល្មើសៈ ការឃាត់ចាប់ និងដុតកំទេចចោលតាមវិធានបសុពេទ្យផលិតផលសត្វខុសច្បាប់នាំមកពីប្រទេសជិតខាង មានចំនួន ៣៧៧ករណី និងផាកពិន័យជាប្រាក់ចំនួន១២៣.០០០.០០០រៀល

-ត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វៈ ការនាំចេញសត្វគោ ក្របីក្នុងស្រុក គោឆ្លងកាត់ ការនាំចូលជ្រូក ព្រមទាំងបាននាំចេញ-ចូលសត្វ និងផលិតផលមានដើមកំណើតសត្វប្រភេទផ្សេងទៀត

-ភ្នាក់ងារសុខភាពសត្វភូមិសរុបមាន**១២.៦៧៤**នាក់ក្នុងនោះមានបុរសចំនួន១១.៥៤៤នាក់ និងនារីចំនួន**១.១២៩**នាក់។

-ស្ថិតិសត្តឃាតដ្ឋានទាំងប្រភេទ “ក” និង “ខ” ដែលមានគោលការណ៍អនុញ្ញាតដោយអនុលោមតាមអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់និងផលិតផលសត្វ និងប្រកាសពាក់ព័ន្ធ ពីរាជធានី ខេត្តមានចំនួនសរុប**១២២** កន្លែង ក្នុងនោះរួមមាន÷ រាជធានីភ្នំពេញ១០កន្លែង កណ្តាល២១កន្លែង កំពង់ឆ្នាំង១០កន្លែង សៀមរាប០៦កន្លែង បន្ទាយមានជ័យ ០៩កន្លែង ព្រះសីហនុ០៣កន្លែង ព្រៃវែង០៥កន្លែង កំពង់ស្ពឺ១០កន្លែង មណ្ឌលគីរី០២កន្លែង ស្ទឹងត្រែង ០១កន្លែង រតនៈគីរី០២កន្លែង បាត់ដំបង១៣កន្លែង កំពត០៥កន្លែង ក្រចេះ០៥កន្លែង កោះកុង០១កន្លែង កែប០១កន្លែង ពោធិសាត់០៦កន្លែង កំពង់ធំ០៥កន្លែង ស្វាយរៀង០៦កន្លែង និង ប៉ៃលិន០១កន្លែង ។

នៅក្នុងឆ្នាំ២០១៣ សត្តឃាតដ្ឋានប្រភេទ " ខ " ដែលបានបង្កើតថ្មីមានចំនួនសរុប ០៩កន្លែង ក្នុងនោះមានៈ កណ្តាល ០១កន្លែង កំពត០១កន្លែង ព្រៃវែង០២កន្លែង ព្រះសីហនុ០១កន្លែង ស្វាយរៀង០៣កន្លែង និង ប៉ៃលិន០១កន្លែង និងសត្តឃាតដ្ឋានដែលត្រូវបានការអនុញ្ញាតឲ្យបន្តសុពលភាពទៀតមានចំនួន០៩កន្លែង ក្នុងនោះរួមមានៈ រាជធានីភ្នំពេញ ០២កន្លែង ខេត្តបន្ទាយមានជ័យ ០៧កន្លែង។

-វត្ថុវិភាគ ដែលបានធ្វើវិភាគរកវត្តមានមេរោគបង្កជំងឺ មានចំនួនសរុប **១០.៩៥០** វត្ថុវិភាគ ក្នុងនោះប៉ារ៉ាស៊ីតសាស្ត្រចំនួន **២.២៨៦** បាក់តេរីសាស្ត្រចំនួន**២.៥០៨**លោហិតសាស្ត្រចំនួន **២.២៨៦**ស៊េរ៉ូមសាស្ត្រចំនួន **៣.៦៩៨** និងសរីរៈរោគសាស្ត្រ**១៧២** វត្ថុវិភាគ។ តាមការវិភាគនេះ វិទ្យាស្ថានជាតិ បានរកឃើញពពួកប៉ារ៉ាស៊ីត វីរុស (ផ្តាសាយ បក្សី ញូវកាស អុតក្តាម ប៉េស្តជ្រូក ត្រចៀកខៀវ) និងបាក់តេរី (សារទឹក និងអ៊ីកូលី)។

-អង្កេតតាមដាន និងស្រាវជ្រាវជំងឺសត្វ រួមមានសិក្សាស្រាវជ្រាវកន្លែងផ្ទុះជំងឺសារទឹក ជំងឺអុតក្តាម និងជំងឺប៉េស្តជ្រូក នៅតាមបណ្តារាជធានី ខេត្ត និងតាមដានឃ្លាំមើលពីស្ថានភាពជំងឺផ្តាសាយបក្សី នៅតាមបណ្តាភូមិនៅទូទាំងប្រទេស ដោយប្រើប្រាស់ភ្នាក់ងារសុខភាពសត្វភូមិ ព្រមទាំងនៅតាមទីផ្សារលក់បក្សីរបស់រាជធានី ខេត្តផងដែរ

-ព័ត៌មានស្ដីពីស្ថានភាពជំងឺសត្វនៅក្នុងប្រទេសកម្ពុជា ត្រូវបានរាយការណ៍ជាប្រចាំទៅប្រទេសអាស៊ាន និងអង្គការសុខភាពសត្វពិភពលោកតាមរយៈប្រព័ន្ធព័ត៌មានពីរ÷ (១)ប្រព័ន្ធព័តិមានសុខភាពសត្វនៅក្នុងតំបន់អាស៊ាន (ARAHIS) និង(២) ប្រព័ន្ធព័តិមានសុខភាពសត្វពិភពលោក (WAHIS)។តាមរយៈប្រព័ន្ធព័ត៌មានសុខភាពសត្វទាំងពីរនេះ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល អាចទទួលបានមកវិញនូវព័ត៌មានស្ដីពីស្ថានភាពជំងឺសត្វរបស់ប្រទេសក្នុងតំបន់ និងពីបណ្ដាប្រទេសជាសមាជិកអង្គការសុខភាពសត្វពិភពលោក។ វិស័យផលិតកម្មនិងបសុព្យាបាល មានបណ្ដាញទំនាក់ទំនងការងារនៅតាមបណ្ដាភូមិ ស្រុក និងរាជធានី ខេត្ត ដែលរួមមានភ្នាក់ងារសុខភាពសត្វភូមិ មន្ត្រីការិយាល័យផលិតកម្មនិងបសុព្យាបាលស្រុក និងរាជធានី ខេត្ត ដើរតួនាទីសំខាន់ក្នុងការរាយការណ៍ពីស្ថានភាពជំងឺសត្វ និងមានអង្គការ និងក្រុមហ៊ុនឯកជនមួយចំនួនក៏បានចូលរួមក្នុងការរាយការណ៍ពីជំងឺសត្វផងដែរ មានបណ្ដាញព័តិមានទាន់ហេតុការណ៍ចំនួនពីរខ្សែដែលមានលេខ ០១២ ២១៤ ៩៧០ និង ០១២ ៨៣៣ ៧៩៥ ឬ ១២៨៧ និង១២៨៩។

-កសាងច្បាប់ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗនៃផ្នែកផលិតកម្ម និងបសុព្យាបាល បានទទួលលទ្ធផលល្អគួរឱ្យកត់សម្គាល់ ដូចជា សេចក្ដីព្រាងច្បាប់ស្ដីពីសុខភាពសត្វនិងផលិតកម្មសត្វ ដែលមាន២២ជំពូកនិង១២៥មាត្រាត្រូវបានបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេច បញ្ជូនទៅរដ្ឋសភាជាតិ

-ការផ្សព្វផ្សាយបច្ចេកទេស គឺកំពុងតែមានការចាប់អារម្មណ៍ និងមានការគាំទ្រពីគ្រប់ជំនាញ អង្គការជាតិ និងអន្តរជាតិ និងម្ចាស់ជំនួយជាច្រើន ហើយបាននឹងកំពុងតែអនុវត្តយ៉ាងសកម្ម នៅតាមមូលដ្ឋានរាជធានី ខេត្តទូទាំងប្រទេស។ ផ្នែកផលិតកម្មនិងបសុព្យាបាលបានយកចិត្តទុកដាក់ប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ តាមវិទ្យុ ទូរទស្ស ទស្សនាវដ្ដី បទសម្ភាសន៍ ឯកសារបច្ចេកទេស ការតាំងពិព័ណ៌ ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ការឃោសនាផ្សព្វផ្សាយនៅតាមមូលដ្ឋាន និងទស្សនកិច្ចសិក្សា។ល។ ដោយផ្ដោតការយកចិត្តទុកដាក់ទៅលើបញ្ហាជាអទិភាពដូចជាបញ្ហាជំងឺឆ្លង អត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺឆ្លងសត្វ បច្ចេកទេសចិញ្ចឹម ពូជនិងបច្ចេកទេសជ្រើសរើសពូជ បច្ចេកទេសបង្កាត់ពូជតាមបែបសិប្បនិមិត្ត បច្ចេកទេសដាំដំណាំចំណីសត្វ បច្ចេកទេសកែច្នៃចំណីសត្វ និងលិខិតបទដ្ឋានគតិយុតពាក់ព័ន្ធនឹងវិស័យផលិតកម្ម និងបសុព្យាបាល ។ល។

-សហការជាមួយដៃគូរអភិវឌ្ឍន៍មួយចំនួនដូចជាៈ OIE, SEAFMD, FAO, WHO, SLPP, WB, USDA, USAID, JICA, ACIAR, IPC និង SNV ។ល។

## ខ.២. ការងារផលិតកម្មសត្វ

សមិទ្ធផលផ្នែកផលិតកម្មសត្វឆ្នាំ២០១៣ មានការវិវត្តន៍ជាបន្តបន្ទាប់និងគួរឱ្យកត់សម្គាល់ដែលក្នុងនោះ÷

### *ខ.២.១. ស្ថានភាពរួមនៃការចិញ្ចឹមសត្វ*

**តារាងប្រៀបធៀបស្ថិតិសត្វ**

| ប្រភេទសត្វ | | ឆ្នាំ២០១២ (ក្បាល) | ឆ្នាំ២០១៣ (ក្បាល) | ការប្រៀបធៀប ២០១២- ២០១៣ | |
|---|---|---|---|---|---|
| | | | | កើន/ថយ | %(%) |
| គោ | គ្រួសារ | 3,372,212 | 3,425,952 | 53,740 | 1.59 |
| | កសិដ្ឋាន | 4,593 | 4,943 | 350 | 7.62 |
| | សរុប | **3,376,805** | **3,430,895** | **54,090** | **1.60** |
| ក្របី | គ្រួសារ | 656,938 | 619,114 | -37,824 | -5.76 |
| | កសិដ្ឋាន | 37 | 0 | -37 | -100.00 |
| | សរុប | **656,975** | **619,114** | **-37,861** | **-5.76** |
| គោ ក្របី | គ្រួសារ | 4,029,187 | 4,045,066 | 15,879 | 0.39 |
| | កសិដ្ឋាន | 4,593 | 4,943 | 350 | 7.62 |
| | សរុប | **4,033,780** | **4,050,009** | **16,229** | **0.40** |
| កម្លាំងអូសទាញ | | **1,516,110** | **1,344,541** | **-171,569** | **-11.32** |
| ជ្រូក | គ្រួសារ | 1,952,321 | 2,067,975 | 115,654 | 5.92 |
| | កសិដ្ឋាន | 256,290 | 368,724 | 112,434 | 43.87 |
| | សរុប | **2,208,611** | **2,436,699** | **228,088** | **10.33** |

| | | | | | |
|---|---|---|---|---|---|
| បក្សី | គ្រួសារ | 19,374,139 | 21,429,519 | 2,055,380 | 10.61 |
| | កសិដ្ឋាន | 3,974,291 | 6,043,924 | 2,069,633 | 52.08 |
| | សរុប | **23,348,430** | **27,473,443** | **4,125,013** | **17.67** |
| សេះ | គ្រួសារ | 12,394 | 10,850 | -1,544 | -12.46 |
| | កសិដ្ឋាន | 137 | 47 | -90 | -65.69 |
| | សរុប | **12,531** | **10,897** | -1,634 | -13.04 |
| ចៀម | គ្រួសារ | 174 | 100 | -74 | -42.53 |
| | កសិដ្ឋាន | 41 | 0 | -41 | -100.00 |
| | សរុប | **215** | **100** | -115 | -53.49 |
| ពពែ | គ្រួសារ | 11,995 | **15,831** | 3,836 | 31.98 |
| | កសិដ្ឋាន | 1,728 | 0 | -1,728 | -100.00 |
| | សរុប | **13,723** | **15,831** | 2,108 | 15.36 |
| សរុបរួម | | **29,617,290** | **33,986,979** | **4,369,689** | **14.75** |

តាមការវិភាគស្ថានភាពចិញ្ចឹមសត្វប្រចាំឆ្នាំ បានបង្ហាញថា លទ្ធផលសូចនាករក្នុងឆ្នាំនៃផលិតភាពសត្វគ្រប់ប្រភេទមានការកើនឡើងសរុបចំនួន ៤.៣៦៩.៦៨៩ ក្បាល ដែលស្មើនឹង១៤.៧៥%។ ឆ្នាំ២០១៣ចំនួនគោកើន១.៦០% ក្របីថយចុះ -៥,៧៦% ជ្រូកកើន ១០,៣៣% និងបក្សីកើន១៧,៦៧% ធៀបនឹងឆ្នាំ ២០១២។

- ការកើនឡើងចំនួនគោបណ្តាលមកពីប្រជាជនមានយល់ដឹងពីការចិញ្ចឹមសត្វ ការចាក់ថ្នាំការពារ ទប់ស្កាត់បានជំងឺឆ្លងសត្វ ជាពិសេសនៅរដូវវស្សានិងទឹកជំនន់ដោយទន្លេមេគង្គមិនមានជំងឺឆ្លងគោក្របីផ្ទុះឡើងឡើយ។ បន្ថែមលើសពីនេះ តម្លៃគោរស់កើនឡើង មានទីផ្សារ និងជាប្រភពចំណូល។

-ការថយចុះក្របី គឺបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួន រួមមានកំណើននៃការ ប្រើប្រាស់គ្រឿងយន្តកសិកម្ម ការបម្រែបម្រួលអាកាសធាតុ ការកើនឡើងនៃផ្ទៃដីកសិកម្ម និងកំណើននៃតម្រូវការសាច់ជាម្ហូបអាហារក្នុងស្រុកនិងទីផ្សារនាំចេញសត្វរស់ទៅប្រទេសជិតខាង

-ការចិញ្ចឹមជ្រូក មានការកើនឡើង ដោយសារមានតម្រូវការទីផ្សារខ្ពស់ ផ្តល់នូវប្រាក់ចំណូល មានវដ្តផលិតកម្មខ្លី និងការរីកចម្រើននៃបច្ចេកវិជ្ជាថ្មីៗ និងមានការចូលរួមពីផ្នែកឯកជន

-ការចិញ្ចឹមបក្សី ក៏នៅតែមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារការចិញ្ចឹមជាលក្ខណៈគ្រួសារមានការរីកចម្រើន ជាពិសេសសន្ទុះកើនឡើងនៃការវិនិយោគផ្នែកឯកជន និងមានកំណើនតម្រូវការទីផ្សារខ្ពស់។

### ១.២.២ ស្ថានីយចិញ្ចឹមសត្វរដ្ឋ

**ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិន**

ស្ថានីយចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា-ចិននៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល បានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការឧបត្ថម្ភគាំទ្ររបស់សាធារណៈរដ្ឋប្រជាមានិតចិននិងរាជរដ្ឋាភិបាលកម្ពុជា។ ចុងឆ្នាំ២០១៣ ស្ថានីយមានជ្រូកពូជមេបាសរុបចំនួន **១៤២** ក្បាល ក្នុងនោះ មេពូជមានចំនួន **១៣០** ក្បាលបាពូជមានចំនួន**១២** ក្បាល និងកូនជ្រូក ៧៥ ក្បាល។ ឆ្នាំ២០១៣ស្ថានីយផលិតបានកូនជ្រូកពូជចំនួន **៥៦៤**ក្បាល ដែលបានលក់ចែកចាយជូនកសិករសម្រាប់ធ្វើពូជក្នុងតម្លៃគោលនយោបាយរដ្ឋ។ កសិករពីខេត្តចំនួន **១២** រួមមាន ខេត្តកណ្តាល ព្រះវិហារ តាកែវ ព្រះសីហនុ សៀមរាប ព្រៃវែង តាកែវ កំពង់ចាម រាជធានីភ្នំពេញ ពោធិសាត់ កំពត និងរតនៈគីរី បានទទួលទិញជ្រូកពូជពីស្ថានីយ ដើម្បីចិញ្ចឹមផ្សព្វផ្សាយពូជបន្ត។

**ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ**

នាឆ្នាំ២០១៣ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅបានរៀបចំនិងកំពុងជម្រុញការចិញ្ចឹម ថែទាំពូជគោ ការបង្កាត់ពូជដោយសិប្បនិម្មិត កែលំអពូជគោ និងការដាំដំណាំចំណីសត្វក្នុងស្ថានីយ ជាពិសេសការរៀបចំកែច្នៃចំណីគោត្រៀមសម្រាប់ការចិញ្ចឹមគោពូជក្នុងស្ថានីយប្រកបដោយនិរន្តរភាព។ ក្នុងឆ្នាំ ២០១៣ស្ថានីយមានគោសរុបចំនួន **២០៦** ក្បាល ក្នុងនោះមានគោពូជកំផែងសែន ចំនួន**៣៨**ក្បាល និងក្នុងឆ្នាំនេះផលិតគោបានចំនួន៣៣ក្បាល។

ស្ថានីយបានផ្សព្វផ្សាយពូជគោទៅតាមបណ្តាខេត្តដូចជា ខេត្តសៀមរាប ខេត្តកំពត និងខេត្តបាត់ដំបង។ ស្ថានីយមិនគ្រាន់តែជាកន្លែងចិញ្ចឹមគោពូជប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកន្លែងដាំ និងផ្សព្វផ្សាយដំណាំចំណីសត្វផងដែរ។ ឆ្នាំ ២០១៣ ស្ថានីយបានចែកពូជស្មៅឃីងក្រាសហ្គីណេ ម៉ារ៉ាន់ខ្វមុលឡាតូប៉ាស្ពាឡូមនិងស៊ីម្ពងដល់បណ្តាខេត្តមួយចំនួន។

### ៦.២.៣ ការកែលម្អពូជសត្វ

ការកែលំអពូជសត្វ បានអភិវឌ្ឍន៍ជាជំហានៗតាមគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យសុខភាពសត្វនិងផលិតកម្មសត្វ ដូចជាការនាំចូលរូបធាតុសេនេទិកសត្វពូជសត្វ ការជ្រើសរើសពូជសត្វក្នុងស្រុកដែលមានផលិតភាពខ្ពស់ដើម្បីយកមកបង្កាត់ និងផ្សព្វផ្សាយពូជទាំងក្នុងជួរកសិករក៏ដូចជាតាមបណ្តាកសិដ្ឋានចិញ្ចឹមសត្វឯកជននៅក្នុងប្រទេសកម្ពុជា។ ពូជសត្វសំខាន់ៗ ដែលត្រូវបានយកមកបង្កាត់ និងផ្សព្វផ្សាយពូជ មានដូចជា÷

-ពូជកំផែងសែន និងពូជប្រាមាន់ នៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ

-កន្លងមកការនាំចូលទឹកមេជីវិតបង្កកពូជគោស៊ីមប្រា និងពូជគោសាន់តា ដែលត្រូវបានបង្កាត់ដោយសិប្បនិម្មិតជាមួយគោក្នុងស្រុកតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តពោធិសាត់ (បង្កាត់សិប្បនិម្មិតមេគោបានចំនួន១៣១ក្បាល បានកូនញីចំនួន៥៥ក្បាល និងឈ្មោលចំនួន៣២ក្បាល) ខេត្តតាកែវ បង្កាត់សិប្បនិម្មិតមេគោបានចំនួន១៣៥ក្បាល បានកូនញីចំនួន១៧ក្បាល និងឈ្មោលចំនួន១៤ក្បាលក្នុងឆ្នាំ ២០១៣។ ទន្ទឹមនឹងនេះការបង្កាត់សិប្បនិម្មិតបានផ្សព្វផ្សាយតាមបណ្តាខេត្តផ្សេងៗទៀតដូចជា ខេត្ត កំពង់ស្ពឺ កំពត កំពង់ធំ កំពង់ឆ្នាំង កែប បាត់ដំបង។ ជារួមការបង្កាត់សិប្បនិម្មិតគោទូទាំងប្រទេសបានសរុបចំនួន៣២៧ក្បាល បានចំនួនកូនគោសរុបចំនួន១៤៧ក្បាល ក្នុងឆ្នាំ២០១៣

-ស្ថានីយចិញ្ចឹមជ្រូកបង្ហាញកម្ពុជា ចិន ធ្វើការបង្កាត់និងផ្សព្វផ្សាយពូជជ្រូកខ្មែរជ្រេស យ៉កសៀ និងឌុយរ៉ុក។ ការបង្កាត់សិប្បនិម្មិតជ្រូកធ្វើការផ្សព្វផ្សាយតាមបណ្តាលខេត្តមួយចំនួនដូចជា ខេត្តពោធិសាត់ បង្កាត់សិប្បនិម្មិតមេជ្រូកបានចំនួន ១.២៦១ក្បាល បានកូនសរុបចំនួន៧.៩២២ក្បាល (ញីចំនួន៤.១២៦ក្បាល) ខេត្តតាកែវបង្កាត់សិប្បនិម្មិតមេជ្រូកបានចំនួន ៣.៨៣៦ក្បាល បានកូនសរុបចំនួន១៧.៩៩៥ក្បាល ខេត្តបន្ទាយមានជ័យបង្កាត់សិប្បនិម្មិតមេជ្រូកបានចំនួន១.០២៧ក្បាល បានកូនសរុបចំនួន ៧.១២៩ក្បាលក្នុងឆ្នាំ ២០១៣

-ការបង្កាត់មាន់យកសាច់ ស៊ុត ពូជKI (ពូជមាន់ខ្មែរបង្កាត់ជាមួយអ៊ីសាប្រោន)នៅខេត្តសៀមរាប

-ការចិញ្ចឹមគោយកទឹកដោះ ក្រោមគម្រោងកិច្ចសហប្រតិបត្តិជប៉ុន(JLTA) អនុវត្តនៅរាជធានីភ្នំពេញនិងខេត្តកណ្តាល

-វិស័យឯកជនបានទឹងកំពុងបង្កាត់និងផ្សព្វផ្សាយលក់ពូជសត្វគ្រប់ប្រភេទ ដែលធ្វើឲ្យមានការផ្លាស់ប្តូរពូជសត្វគួរឲ្យកត់សម្គាល់

-ការផ្សព្វផ្សាយពូជតាមរយៈអង្គការ សម្បុរសជន ដូចជាការផ្តល់ជ្រូក មេគោ មេក្របី មានទា ដល់កសិករតាមបណ្តាខេត្តមួយចំនួន។

**ក្រាហ្វិកបង្ហាញពំពីការបង្កាត់សប្បនិម្មិតគោនៅតាមបណ្តាខេត្តឆ្នាំ២០០៣**



## ក្រាហ្វិកចំនួនកូនគោតាមរយៈការបង្កាត់សប្បនិម្មិតគោនៅតាមបណ្តាខេត្តឆ្នាំ២០១៣




### ១.២.៤.ការកែលំអចំណីសត្វ

ការកែលម្អចំណីសត្វ បាននឹងកំពុងជម្រុញការដាំដំណាំចំណីសត្វ ផ្តល់ពូជ និងផ្សព្វផ្សាយពូជស្មៅ បច្ចេកទេសដាំដំណាំចំណីសត្វ ព្រមទាំងជម្រុញការអនុវត្ត សាកល្បងពិសោធន៍ ផ្សព្វផ្សាយពីវិធីសាស្ត្រ និងបច្ចេកទេសកែច្នៃ និងផ្ស៊ំចំណីសត្វ ដល់ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត និងកសិករតាមបណ្តាខេត្តនានានៅទូទាំងប្រទេស។

ពូជដំណាំចំណីសត្វ ដែលបានផ្សព្វផ្សាយដល់កសិករនាពេលបច្ចុប្បន្ន រួមមាន÷ Simung Mulato, Paspalum, Marandu, Ruzi, Elephant grass, King grass កន្ទិថេត ទ្រីចាន់ផារ៉ា ។ល។

ខេត្តព្រៃវែងស្វាយរៀង សៀមរាប រតនៈគិរី ពោធិសាត់ តាកែវ មណ្ឌលគិរី កណ្តាល កំពត កំពង់ឆ្នាំង កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ បាននឹងកំពុងដំណើរការដាំដំណាំចំណីសត្វទទួលបានជោគជ័យ និងបានអនុវត្តការកែច្នៃផ្ស៊ំចំណីសត្វ ព្រមទាំងផ្សព្វផ្សាយពូជ បច្ចេកទេសដាំដុះ បច្ចេកទេសកែច្នៃផ្ស៊ំ ដល់កសិករក្នុងខេត្តរបស់ខ្លួន និងខេត្តដទៃផ្សេងទៀត។

ក្នុងគម្រោង CIAT (Center International for Tropical Agriculture) អនុវត្តនៅខេត្ត ÷

**១. ពោធិ៍សាត់**បានចែកពូជស្មៅចំនួន៥មុខ(ម៉ារ៉ាន់ឌូ មុលឡាតូ ប៉ាស្ពាឡូម អាត់ត្រាទូម រូស៊ី និងស៊ីម៉ូង) ជូនកសិករចំនួន ៣២គ្រួសារ យកទៅដាំលើផ្ទៃដី ទួន ១៣,៧២៤ម² នៅស្រុកសំពៅមាស និងស្រុកបាកាន

**២.រតនគិរី** បានចែកពូជស្មៅចំនួន ៥មុខ (ម៉ារ៉ាន់ឌូ, មុលឡាតូ ប៉ាស្ពាឡូម អាត់ត្រាទូម, រូស៊ី និងស៊ីម៉ូង) ជូនកសិករចំនួន ២៦គ្រួសារ យកទៅដាំលើផ្ទៃដី ចំនួន ១៥៩.៥០អារនៅស្រុកត្រាំកក់

**៣.បាត់ដំបង** បានចែកពូជស្មៅចំនួន ៥មុខ (ម៉ារ៉ាន់ឌូ, មុលឡាតូ ប៉ាស្ពាឡូម អាត់ត្រាទូម, រូស៊ី និងស៊ីម៉ូង)ជូនកសិករយកទៅដាំ ។

**៤.ប៉ៃលិន** បានចែកពូជស្មៅចំនួន ៥មុខ (ម៉ារ៉ាន់ឌូ, មុលឡាតូ ប៉ាស្ពាឡូម អាត់ត្រាទូម, រូស៊ី និងស៊ីម៉ូង) ជូនកសិករយកទៅដាំ ។

### ១.២.៥ ការអភិវឌ្ឍនកម្មវិធីឡជីវឧស្ម័ន

ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១៣ ការកសាងឡជីវឧស្ម័នបានអនុវត្តក្នុងខេត្តចំនួន១៤ សរុបមានចំនួន២០,២៨៨ឡ ដែលក្នុងនោះ នៅឆ្នាំ ២០១៣ ឡជីឧស្ម័នបានសាងសង់ចំនួន**១.១១៥**ឡ ។

ក្រាហ្វិកបង្ហាញចំនួនឡជីវឧស្ម័នដែលបានសាងសង់ចាប់ពីឆ្នាំ២០០៦ដល់២០១៣




## គ. **ការងារសុខភាពសត្វ**

### ***គ.១ ស្ថានភាពជំងឺឆ្លងសត្វ***

ជារៀងរាល់ឆ្នាំ ជំងឺឆ្លងសត្វច្រើនប្រភេទ បានបង្កឱ្យសត្វឈឺ និងងាប់ នឹងបណ្តាលឱ្យមានការខាតបង់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិផងដែរ។ នៅឆ្នាំ២០១៣ កន្លងទៅនេះ សភាពការណ៍នៃជំងឺឆ្លងសត្វ មានសភាពរាលដាលមិនសូវខ្លាំងក្លាគួរឱ្យកត់សម្គាល់ទេ ប៉ុន្តែតាមការសង្កេតជារួម ទិន្នន័យនៃស្ថានភាពជំងឺឆ្លងសំខាន់ៗ ដែលបង្កឱ្យមានមហន្តរាយដល់ជីវិតមនុស្សសត្វ និងសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសេដ្ឋកិច្ចជាតិរួមមាន ÷

**ជំងឺអុតក្តាម÷** មានការផ្ទុះឡើងចំនួន៧២ កន្លែងគឺ: ខេត្តសៀមរាប០១កន្លែង ពោធិសាត់០៥កន្លែងបាត់ដំបង០៤កន្លែងបន្ទាយមានជ័យ០២កន្លែងកំពង់ចាម០១កន្លែងកំពត០១កន្លែងកំពង់ស្ពឺ២០កន្លែងស្វាយរៀង០៩កន្លែងកណ្តាល០៧កន្លែងក្រចេះ០៦កន្លែងតាកែវ០៩កន្លែងព្រៃវែង០៧ កន្លែង។

**ជំងឺសារទឹក÷** មានផ្ទុះឡើងចំនួ ២៥ កន្លែងគឺៈខេត្តកោះកុង ០៤ កន្លែង (ស្រែអំបិល ថ្មបាំង ខេមរភូមិន្ទ បទុម សាគរ) ឧត្តរមានជ័យ ០៤ កន្លែង (សំរោង ចុងកាល់ បន្ទាយអំពិល អន្លង់វែង) ក្រចេះ ០១ កន្លែង (ចិត្របូរី) ពោធិសាត់ ០១ កន្លែង (បាកាន) ព្រៃវែង ១៥ កន្លែង (ពាមជ័រ កំចាយមារ កញ្ជៀច ស៊ីធរកណ្តាល ស្វាយអន្ទរ មេសាង ពោធិរៀង ពារាំង និងព្រៃវែង)

**ជំងឺប្ញសខ្យល់÷ ៖** មានផ្ទុះឡើងចំនួន៣កន្លែងគឺ: ១ កន្លែងនៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ១ កន្លែងនៅស្រុកចិត្របូរី ខេត្តក្រចេះនិង ១ កន្លែងនៅស្រុកភ្នំព្រឹកខេត្តបាត់ដំបង ។

**ជំងឺផ្តាសាយបក្សី÷** ក្នុងឆ្នាំ២០១៣នេះ មានករណីផ្ទុះជំងឺផ្តាសាយបក្សីចំនួន ០៧ កន្លែង គឺនៅខេត្តតាកែវ កំពង់ស្ពឺ កំពង់ចាម កំពត សៀមរាប និងបាត់ដំបង។ ករណីផ្ទុះជំងឺផ្តាសាយបក្សីចុងក្រោយគឺនៅភូមិដំណាក់ដង្កោ ឃុំរាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង (ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៣)។

### ***គ.២ ការបង្ក្រាបបទល្មើស និងការទប់ស្កាត់ជំងឺឆ្លងសត្វ***

ផ្នែកលើវិធានបច្ចេកទេសនិងវិធានច្បាប់ បានទប់ស្កាត់និងបង្ក្រាបបទល្មើស ដែលទទួលបានលទ្ធផលដូចខាងក្រោម÷

**<u>នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល</u>÷** បានត្រួតពិនិត្យចរាចរសត្វនិងផលិតផលមានដើមកំណើតពីសត្វ ជាលទ្ធផលបានទទួលបានៈ ការត្រួតពិនិត្យចរាចរសត្វនិងផលិតផលមានដើមកំណើតពីសត្វមានច្បាប់អនុញ្ញាតត្រឹមត្រូវចំនួន៣៥៣ករណី ក្នុងនោះមានគោក្របី១២៩ ករណី ជ្រូក១៤៩ករណី ស៊ុត១០ករណី មាន់៦៥ករណី និងបង្ក្រាបទល្មើសដឹកជញ្ជូនសត្វនិងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន៣៣ករណី ក្នុងនោះមានគោក្របី ០៤ករណី ១០៧ក្បាល បក្សី១០ករណី ១៧.៣៥២ក្បាល ស៊ុត០៨ករណី ២១៨.៦៨៤គ្រាប់ ជ្រូកចំនួន១០ករណី ៣១៤ក្បាល សាច់មាន់០១ករណី ០៥តោន គ្រួច០១ករណីចំនួន៦០០គ.ក្រ បានធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន១០១.០០០.០០០រៀល (មួយរយមួយលានរៀលគត់)

**<u>ការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី ខេត្ត</u>÷** បានត្រួតពិនិត្យចលនាសត្វ និងផលិតផលមានដើមកំណើតពីសត្វ ជាលទ្ធផលបានរកឃើញនិងបង្ក្រាបបទល្មើសដឹកជញ្ជូនសត្វនិងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន២៤

ករណី ក្នុងនោះមានគោ ក្របីចំនួន១១០ក្បាលបក្សីចំនួន៣.២៣៥ក្បាលស៊ុតមាន់-ទាចំនួន១១.៦៥០គ្រាប់ ផលិតផលខូចគុណភាពចំនួន៦.៧៧៥គ.ក្រ បានដុតបំផ្លាញចំនួន០៧ករណី និងធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន២២.០០០.០០០រៀល (ម្ភៃពីរលានរៀលគត់)។

### *គ.៣ ការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វ*

ជាលទ្ធផល នៅទូទាំងប្រទេស សត្វបានទទួលការចាក់ថ្នាំការពាររួមមាន÷ សារទឹកគោក្របីបានចំនួន១. ៣៩៣. ៨០៤ក្បាល អុតក្តាមគោក្របីបានចំនួន ៨៦.៥៥២ក្បាល បួសខ្យល់ចំនួន ១៨.១០២ក្បាល សារទឹកជ្រូកចំនួន ១៩១.២៣៧ក្បាល ប៉េស្តជ្រូកចំនួន ២៤២.៨៨២ក្បាល សាល់ម៉ូជ្រូកចំនួន ១៣១.០៦៥ក្បាល អុតក្តាមជ្រូកចំនួន ៧.៦០៦ក្បាល អូហ្សេស្គីជ្រូកចំនួន ៣៩.២២០ក្បាល កញ្ជ្រឹលជ្រូកចំនួន៥.៨៧៧ក្បាល ញូវកាសបក្សីចំនួន ៦៣១.៥៣១ក្បាល អាសន្នរោគមាន់ចំនួន ៤៤២.៩៥៤ក្បាល អុតបក្សីចំនួន ៣៦៤.០៨៧ ក្បាល អាសន្នរោគទាចំនួន ៤៤.៣៧៦ក្បាល ហ្គុមបូរ៉ូចំនួន ៣.៥០០ ក្បាល និងប៉េស្តទាចំនួន១០៨.៤០៥ក្បាល។

### *គ.៤ ការងារត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ*

នៅក្នុងឆ្នាំ២០១៣ ការត្រួតពិនិត្យសត្វ និងផលិតមានដើមកំណើតពីសត្វ ដែលបាននាំចេញ នាំចូល និងនាំឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាមានដូចតទៅៈ **ការនាំចេញ÷** គោ-ក្របីក្នុងស្រុកចំនួន **១៩.៧៥៣**ក្បាល ជ្រូកពូជសរុបចំនួន **២២.៩៨៩** ក្បាល ( កូនជ្រូកពូជចំនួន**២១.៦៤០**ក្បាល និងជ្រូកពូជមេបា **១.៣៤៩** ក្បាល) កូនមាន់ចំនួន**១២៤.០០០ក្បាល** ស្វាក្តាមចំនួន **៥.៣៤៥**ក្បាល សាច់គោចំនួន **១២.២០០**គ.ក្រ ចំណីឆ្កែចំនួន **១.០១៥.២៤៥**គ.ក្រ ស្បែកគោ ក្របីចំនួន **១.៦៥៩**.០០០ គ.ក្រ និងរោមសត្វចំនួន **៥០.៩៩០,៥**គ.ក្រ **ការនាំឆ្លងកាត់÷** សត្វគោពីប្រទេសថៃចំនួន **២៨.៣៨០** ក្បាល និង**ការនាំចូល÷** ជ្រូកសរុបចំនួន**៣០៤.១១២** ក្បាល (ជ្រូកសាច់ចំនួន៣០២.៦២០ ក្បាល កូនជ្រូកពូជចំនួន**១.៤៩២**ក្បាល និងជ្រូកពូជមេបា ០ ក្បាល) កូនមាន់ពូជចំនួន **១៦៥.៨១៥**ក្បាល **ស៊ុត**មាន់**៣៦០.០០០**គ្រាប់ សាច់គោ**២៧២.៦៦២** គ.ក្រ **គ្រឿងក្នុង**គោចំនួន**៧៧.៥០១,៥ គ. ក្រ**សាច់ចៀមចំនួន**៣៨៥**គ.ក្រ សាច់ភ្លៅឆ្អិនចំនួន ០គក្រ សាច់មាន់**១៤.៤៨១** គ.ក្រ មាន់**រស់**ចំនួន**៣០.៦១០គ.ក្រ** សាច់ក្រក **១៤០**គ.ក្រ វត្ថុធាតុដើមសត្វ**១.៩០០.៥**គ.ក្រ និងស្បែកគោផ្សំចំណីឆ្កែ**១.០៨៨.៥៤០**គ.ក្រ សាច់មាន់/ទ្រូងមាន់ផ្សំចំណីឆ្កែ **៤៥៦.០០៣**គ.ក្រ។

### *គ.៥ ភ្នាក់ងារសុខភាពសត្វភូមិ*

ភ្នាក់ងារសុខភាពសត្វភូមិសរុបមានចំនួន**១២.៦៤៤**នាក់ក្នុងនោះមានបុរសចំនួន១១.៥៤៤នាក់ និងនារីចំនួន**១.១២៩**នាក់។

## ឃ. ការងារសុខភាពសាធារណៈ

ការងារសុខភាពសាធារណៈក៏ជាផ្នែកមួយដ៏សំខាន់នៃវិស័យផលិតកម្មនិងបសុព្យាបាល។ កិច្ចការសំខាន់ៗ របស់សុខភាពសាធារណៈរួមមាន ការអង្កេតតាមដាន ស្រាវជ្រាវ ដើម្បីបង្ការទប់ស្កាត់ និងចាត់វិធានការប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ និងជំងឺឆ្លងសូណូសព្យាករណ៍ហានិភ័យ ការផ្ទុះជំងឺឆ្លងរាលដាលជំងឺឆ្លងស៊ូណូស ការគ្រប់គ្រង និងការត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន និងកន្លែងតាំងលក់ ដើម្បីការពារការផ្ទុះជំងឺឆ្លងសត្វ និងជំងឺឆ្លងស៊ូណូស ដែលអាចប៉ះពាល់ដល់អ្នកបរិភោគ និងសុខភាពសាធារណៈ។

សមិទ្ធិផលសំខាន់ៗដែលសម្រេចបាន រួមមាន÷

### ង. ស្ថិតិសត្តឃាតដ្ឋាន

ស្ថិតិសត្តឃាតដ្ឋានទាំងប្រភេទ “ក” និង “ខ” ដែលមានគោលការណ៍អនុញ្ញាតដោយអនុលោមតាមអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងប្រកាសពាក់ព័ន្ធ ពីរាជធានី ខេត្តមានចំនួនសរុប**១២២** កន្លែង ក្នុងនោះរួមមាន÷ រាជធានីភ្នំពេញ១០កន្លែង កណ្តាល២១កន្លែង កំពង់ឆ្នាំង១០កន្លែង សៀមរាប០៦កន្លែង បន្ទាយមានជ័យ ០៩កន្លែង ព្រះស៊ីហនុ០៣កន្លែង ព្រៃវែង០៥កន្លែង កំពង់ស្ពឺ១០កន្លែង មណ្ឌលគីរី០២កន្លែង ស្ទឹងត្រែង ០១កន្លែង រតនៈគីរី០២កន្លែង បាត់ដំបង១៣កន្លែង កំពត០៥កន្លែង ក្រចេះ០៥កន្លែង កោះកុង០១កន្លែង កែប ០១កន្លែង ពោធិសាត់០៦កន្លែង កំពង់ធំ០៥កន្លែង ស្វាយរៀង ០៦កន្លែង និង ប៉ៃលិន០១កន្លែង ។

នៅក្នុងឆ្នាំ២០១៣ សត្តឃាតដ្ឋានប្រភេទ" ខ" ដែលបានបង្កើតថ្មីមានចំនួនសរុប ០៩កន្លែង ក្នុងនោះមាន: កណ្តាល ០១កន្លែង កំពត០១កន្លែង ព្រៃវែង០២កន្លែង ព្រះសីហនុ០១កន្លែង ស្វាយរៀង០៣កន្លែង និង ប៉ៃលិន០១កន្លែង និងសត្តឃាតដ្ឋានដែលត្រូវបានការអនុញ្ញាតឱ្យបន្តសុពលភាពទៀតមានចំនួន០៩កន្លែង ក្នុងនោះ រាជធានីភ្នំពេញចំនួន០២កន្លែង ខេត្តបន្ទាយមានជ័យ ០៧កន្លែង។

ចំនួនសត្វពិឃាតនៅទាំងប្រទេសឆ្នាំ២០១៣ សរុបមាន÷ គោ **១០៨.២៧១**ក្បាល ក្របី**២.៨០៨** ក្បាល និងជ្រូក **៧៩៩.៧០០**ក្បាល។

## ច. ការងារវិទ្យាស្ថានជាតិស្រាវស្រាវបសុព្យាបាល

នាពេលបច្ចុប្បន្ននេះ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើអង្កេតតាមដានឃ្លាំមើល សិក្សាស្រាវជ្រាវ វិភាគរកមេរោគ និងធ្វើរោគវិនិច្ឆ័យជំងឺសត្វ និងសម្រេចបាននូវលទ្ធផលប្រកបដោយប្រសិទ្ធិភាព និងទាន់ពេលវេលាក្នុងការឆ្លើតបជាបន្ទាន់ នៅគ្រប់រូបភាព និងស្ថានភាពទាន់ហេតុការណ៍នានានៃជំងឺសត្វ ដែលបង្កឡើងដោយមេរោគគ្រប់ប្រភេទនិងបានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័ននិងអង្គការនានាដូចជា ក្រសួងសុខាភិបាល វិទ្យាស្ថានសុខភាពសាធារណៈ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា គម្រោងកម្មវិធីចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប គម្រោងសិក្សាពីជំងឺបង្កដោយប៉ារ៉ាស៊ីតជាមួយប្រទេសបែលស៊ិក ACIAR, ILRI, SEAFMD, OIE, TADs, JICA, USDA, WHO, World Bank។ លទ្ធផលដែលទទួលបានមានដូចខាងក្រោម÷

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល បានបំពាក់នូវម៉ាស៊ីន និងឧបករណ៍សម្រាប់ធ្វើរោគវិនិច្ឆ័យជំងឺនិងមានធនធានមនុស្សគ្រប់គ្រាន់សម្រាប់បំពេញការងារនេះ។ម៉ាស៊ីននិងឧបករណ៍ទាំងនេះបានទទួលពីគម្រោងបង្កើនផលិតភាពកសិកម្ម (APIP) អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ (FAO) អង្គការសុខភាពសត្វពិភពលោក (OIE)JICA USDA USAID SEAFMDប្រទេសជប៉ុន អាល្លឺម៉ង់ និងសហរដ្ឋអាមេរិក ។ល។

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើអង្កេតតាមឃ្លាំមើល សិក្សាស្រាវជ្រាវ វិភាគរកមេរោគនិងធ្វើរោគវិនិច្ឆ័យជំងឺសត្វនិងសម្រេចបាននូវលទ្ធផលដូចខាងក្រោម÷

-ផ្នែកស៊េរ៉ូមសាស្ត្រ/វីរុសសាស្ត្រ÷បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួន រួមមាន: ជំងឺផ្តាសាយបក្សី ញ្ញវកាស មីក្សូប្លាស្មា ប៉េស្តជ្រូក ប្រ៊ុយសែលឡូស សាទឹក អុតក្តាម សាល់ម៉ូណែលឡូស ឆ្កែឆ្កួត ជ្រូកត្រចៀកខៀវ និងជំងឺស្វា(SRV STLV CHV)

-ផ្នែកបាក់តេរីសាស្ត្រ÷ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួនរួមមាន:ជំងឺសាទឹក បូសខ្យល់ ឈាមខ្មៅ ស្តាហ្វីឡូកុកកូស ស្ត្រិបតូកុកកូស សាល់ម៉ូណែលឡូស អ៊ិកូលី ស៊ីយ៉េលឡា និងវិភាគរកមេរោគក្នុងចំណីសត្វ ។ល។និងជំងឺស្វា(Shigella Salmonella)

-ផ្នែកប៉ារ៉ាស៊ីត÷ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកជំងឺបង្កដោយប៉ារ៉ាស៊ីតសត្វ។

-ផ្នែកលោហិតសាស្ត្រ÷ បានពិនិត្យ សិក្សាស្រាវជ្រាវ និងវិភាគរកជំងឺលើសត្វជាច្រើនប្រភេទដូចជា អេម៉ូក្រាម ប៉ារ៉ាស៊ិតក្នុងឈាម និងប្រូតេអ៊ីន។

-ផ្នែកសរីរៈរោគសាស្ត្រ: បានធ្វើការវះពិនិត្យប្រភេទសត្វតូច (ជ្រូក ចៀម ពពែ និងបក្សី) និងអ៊ីស្តូក្រាម (ការដាក់ពណ៌និង ពិនិត្យនៅលើកញ្ចក់ឡាម) ដើម្បីសិក្សាស្រាវជ្រាវ និងវិភាគរកមេរោគលើជំងឺសត្វមួយចំនួន។

-ផ្នែកអេពីដេមីសាស្ត្រ: តាមដានឃ្លាំមើលជំងឺសត្វ ស្រាវជ្រាវរកប្រភពជំងឺសត្វ អង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺ គ្រប់គ្រងទិន្នន័យជំងឺសត្វ វិភាគទិន្នន័យនិងបកស្រាយលទ្ធផលនៃការអង្កេតស្រាវជ្រាវឬការសិក្សាជាដើម។

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលនៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលបានប្រមូលនិងធ្វើវិភាគរកវត្ថុមានមេរោគបង្កជំងឺ មានចំនួនសរុប **១០.៩៥០** វត្ថុវិភាគ ក្នុងនោះប៉ារ៉ាស៊ីតសាស្ត្រចំនួន **២.២៨៦** បាក់តេរីសាស្ត្រចំនួន **២.៥០៨**លោហិតសាស្ត្រចំនួន **២.២៨៦**ស៊េរ៉ូមសាស្ត្រចំនួន **៣.៦៩៨** និងសរីរៈរោគសាស្ត្រ**១៧២** វត្ថុវិភាគ។ តាមការវិភាគនេះ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល បានរកឃើញពពួកប៉ារ៉ាស៊ីត វីរុស(ផ្តាសាយបក្សី ញ្ញកាស អុតក្តាម) និងបាក់តេរី (សារទឹក បូសខ្យល់ និងអ៊ិកូលី)។

ព័ត៌មានស្តីពីស្ថានភាពជំងឺសត្វនៅក្នុប្រទេសកម្ពុជា ត្រូវបានរាយការណ៍ជាប្រចាំទៅប្រទេសអាស៊ាននិងអង្គការសុខភាពសត្វពិភពលោកតាមរយៈប្រព័ន្ធព័ត៌មានពីរ÷ (១) ប្រព័ន្ធពត៌មានសុខភាពសត្វ នៅក្នុងតំបន់អាស៊ាន (ARAHIS) និង(២) ប្រព័ន្ធព័ត៌មានសុខភាពសត្វពិភពលោក (WAHIS)។ តាមរយៈប្រព័ន្ធព័ត៌មានសុខភាពសត្វទាំងពីរនេះ អនុវិស័យទទួលបានមកវិញនូវព័ត៌មានស្តីពីស្ថានភាពជំងឺសត្វរបស់ប្រទេសក្នុងតំបន់ និងពីបណ្តាប្រទេសជាសមាជិកអង្គការសុខភាពសត្វពិភពលោក។ ចំពោះផលិតកម្ម និងបសុព្យាបាល មានបណ្តាញទំនាក់ទំនងការងារនៅតាមបណ្តាភូមិ ស្រុក និងរាជធានី ខេត្ត ដែលរួមមានភ្នាក់ងារសុខភាពសត្វភូមិ មន្ត្រីការិយាល័យផលិតកម្មនិងបសុព្យាបាលស្រុក និងរាជធានី ខេត្ត ដើរតួនាទីសំខាន់ក្នុងការរាយការណ៍ ពីស្ថានភាពជំងឺសត្វ និងមានអង្គការនិងក្រុមហ៊ុនឯកជនមួយចំនួនក៏បានចូលរួមក្នុងការរាយការណ៍ពីជំងឺសត្វផងដែរមានបណ្តាញពត៌មានទាន់ហេតុការណ៍ចំនួនពីរខ្សែដែលមានលេខ ០១២ ២១៤ ៩៧០ និង ០១២ ៨៣៣ ៧៩៥ ឬ ១២៨៧ និង១២៨៩។

ឆ្នាំក្នុងឆ្នាំ២០១៣ មានករណីជំងឺផ្តាសាយបក្សីលើបក្សីចំនួន ០៧កន្លែងគឺ នៅភូមិស្នោ ស្រុកព្រៃកប្បាស ខេត្តតាកែវ ភូមិព្រៃញាតិ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ភូមិក្បាលអូរ ឃុំមេសរជ្រៃស្រុកស្ទឹងត្រង់និងភូមិតាឡៃ ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិស្រង៉ែ ឃុំបឹងនិមល ស្រុកឈូក ខេត្តកំពត ភូមិខ្នារថ្មី ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ភូមិដំណាក់ដង្កោ ឃុំរាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង។

កសាងច្បាប់ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗនៃផ្នែកផលិតកម្ម និងបសុព្យាបាល បានទទួលលទ្ធផល ល្អគួរឱ្យកត់សម្គាល់ដូចជា ឆ្នាំ២០១៣កន្លងទៅនេះបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធវិស័យផលិតកម្មនិងបសុព្យបាលដែលបានទទួលលទ្ធផលដូចតទៅ÷ប្រកាសស្តីពីនីតិវិធីនៃការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ និងសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ កំពុងកែសម្រួល។ ទន្ទឹមនឹងនោះ សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វត្រូវបានបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រីតាមរយៈលិខិតលេខ៧០៤៨ កសក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ ហើយត្រូវបានដាក់ឲ្យប្រជុំពិនិត្យពិភាក្សាជាមួយក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រីចំនួន ១៩លើក ពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២ ដល់ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១២។

សេចក្តីព្រាងច្បាប់នេះក៏ត្រូវបានដាក់ឲ្យប្រជុំពិនិត្យ ពិភាក្សាក្នុងប្រជុំអន្តរក្រសួងនាថ្ងៃទី០៥ និងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ និងកិច្ចប្រជុំអន្តរក្រសួងចង្អៀតនាថ្ងៃទី២០និងថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣។

តាមការណែនាំក្នុងកំឡុងពេលប្រជុំអន្តរក្រសួងនៅទីស្តីការណៈរដ្ឋមន្ត្រីនាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌ បានជួបប្រជុំពិភាក្សា និងបានសម្រេចកែសម្រួលលើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វជំពូកទី១៩ស្តីពីអធិការកិច្ច ជំពូកទី២០ស្តីពីទោសប្បញ្ញត្តិ ជំពូកទី២១ស្តីពីអន្តរប្បញ្ញត្តិ និងជំពូកទី២២ស្តីពីអវសានប្បញ្ញត្តិ។

សេចក្តីព្រាងច្បាប់នេះ នឹងត្រូវដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេចលើមតិ ដែលមិនស្របគ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ការងារផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍវិស័យផលិតកម្ម និងបសុព្យាបាល ជាមធ្យោបាយសម្រាប់ផ្ទេរចំណេះដឹងថ្មីៗតាមបែបវិទ្យាសាស្ត្រក្នុងការចិញ្ចឹមសត្វ វាគឺជាចលករដ៏សំខាន់ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបទរបស់កសិករក្នុងការចិញ្ចឹមសត្វតាមបែបយថាផលទៅជាការចិញ្ចឹមតាមបែបបច្ចេកទេស ការចិញ្ចឹម សត្វសម្រាប់តែតម្រូវការហូបចុកក្នុងគ្រួសារ ទៅជាការចិញ្ចឹមសម្រាប់ធ្វើពាណិជ្ជកម្ម។ ដោយយល់ឃើញពីសារៈសំខាន់នៃការងារផ្សព្វផ្សាយ និងបានយកចិត្តទុកដាក់ប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ តាមវិទ្យុ ទូរទស្ស ទស្សនាវដ្ដី បទសម្ភាសន៍ ឯកសារ បច្ចេកទេស ការតាំងពិព័ណ៌ ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ការឃោសនាផ្សព្វផ្សាយនៅតាមមូលដ្ឋាន និងទស្សនកិច្ចសិក្សា។ល។ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាជាអទិភាពដូចជាបញ្ហាជំងឺឆ្លង អត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺឆ្លងសត្វ បច្ចេកទេសចិញ្ចឹម ពូជនិងបច្ចេកទេសជ្រើសរើសពូជ បច្ចេកទេសបង្កាត់ពូជតាមបែបសិប្បនិមិត្ត បច្ចេកទេសដាំដំណាំចំណីសត្វ បច្ចេកទេសកែច្នៃចំណីសត្វ និងលិខិតបទដ្ឋានគតិយុតពាក់ព័ន្ធនឹងវិស័យ ផលិតកម្ម និងបសុព្យាបាល ។ល។

ចងក្រងអត្ថបទបច្ចេកទេសនិងខិត្តប័ណ្ណជំងឺឆ្លងគោ ក្របីស្តីពីជំងឺផ្តាសាយបក្សី ជំងឺអុតក្តាមជំងឺសាទឹក និងជំងឺបួស ខ្យល់ ជំងឺប៉េស្តជ្រូក ជំងឺជ្រូកត្រចៀកខៀវ បច្ចេកទេសចិញ្ចឹមសត្វ អត្ថប្រយោជន៍នៃការបង្កាត់ពូជតាមបែបសិប្បនិម្មិត។ ចងក្រងឯកសារបច្ចេកទេស និងលទ្ធផលការងារសុខភាពសត្វនិងផលិតកម្មសត្វប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តីកសិកម្ម។

គម្រោងគាំទ្រដោយដៃគូអភិវឌ្ឍន៍ ÷ ដើម្បីធានាសុវត្ថិភាព និងការអភិវឌ្ឍន៍អនុវិស័យផលិតកម្មសត្វ និងសុខភាពសត្វប្រកបដោយចីរភាព និងភាពរីកចម្រើន អនុវិស័យមានកិច្ចសហការយ៉ាងជិតស្និតជាមួយអង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ជាច្រើនផ្សេងទៀត និងផ្នែកឯកជននានា ដូចជា OIE, FAO, EU, JICA, WB, ACIAR, USAID, CP ដែលជាប្រភពធនធានយ៉ាងសំខាន់ ក្នុងការផ្តល់នូវការគាំទ្រទាំងផ្នែកបច្ចេកទេសនិងថវិកា សម្រាប់ជួយដំណើរការនៃការអនុវត្តសកម្មភាពការងារក្នុងអនុវិស័យនេះ។

កិច្ចសហប្រតិបត្តិការទ្វេភាគី÷ មកទល់ពេលនេះ អនុវិស័យមានកិច្ចសហប្រតិបត្តិការទ្វេភាគីលើអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វជាមួយសាធារណៈរដ្ឋសង្គមនិយមវៀតណាម សាធារណៈរដ្ឋប្រជាមានិតចិន ថៃឡង់ដ៍ ជប៉ុន និងកូរ៉េ ក្រោមកិច្ចព្រមព្រៀងMOU។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយភាគីវៀតណាម ជារៀងរាល់ឆ្នាំ ភាគីទាំងពីរមានការជួបប្រជុំគ្នា ដើម្បីជជែកពិភាក្សាគ្នាស្តីពីកិច្ចសហការលើសុខភាពសត្វនៃប្រទេសទាំងពីរ ដោះស្រាយរាល់ប្រឡូម ការផ្លាស់ប្តូរបច្ចេកទេស ការផ្តល់ជំនួយជាសម្ភារបរិក្ខារ វគ្គបណ្តុះ បណ្តាល និងទស្សនកិច្ចសិក្សា។ ចំពោះកិច្ចសហប្រតិបត្តិការជាមួយភាគីចិន ក្រោមកិច្ចព្រមព្រៀង MOU ភាគីទាំងពីរបានបង្កើតស្ថានីយ ចិញ្ចឹមជ្រូកពូជបង្ហាញកម្ពុជា ចិន ដោយមានការគាំទ្រទាំងបច្ចេកទេស ថវិកា និងពូជជ្រូក ដល់ភាគីកម្ពុជា។ ក្រៅពីនេះភាគីចិនមានការបន្តផ្តល់ជំនួយឡជីវឧស្ម័នចំនួនប្រមាណ៣០០ឡ សម្រាប់ប្រជាកសិករកម្ពុជា នៅតាមជនបទ។ ចំពោះកិច្ចហាសប្រតិបត្តិការទ្វេភាគីកម្ពុជា ជប៉ុន ភាគីទាំងពីរ បានផ្តោតលើការចិញ្ចឹមគោយកទឹកដោះនៅតាមសហគមន៍អ្នកចិញ្ចឹមសត្វ ដោយភាគីជប៉ុន បានផ្តល់ជំនួយផ្នែកបច្ចេកទេស ឧបករណ៍សម្ភារបរិក្ខារ និងថវិកាមួយចំនួន សម្រាប់គាំទ្រគម្រោងនេះ។ ចំពោះកិច្ចសហការជាមួយកូរ៉េ ភាគីទាំងពីរ បានសង្កត់លើការងារមន្ទីរពិសោធន៍ និងផ្នែកសុខភាពសត្វ ដោយផ្តល់នូវសម្ភារបរិក្ខារ និងផ្លាស់ប្តូរបទពិសោធន៍បច្ចេកទេសជំនាញតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចសិក្សានៃមន្ត្រីជំនាញរវាងប្រទេសទាំងពីរ។

ការផ្គត់ផ្គង់និងបើកផ្តល់ថ្នាំការពារ សម្ភារបរិក្ខារបសុពេទ្យ និងសម្ភារផ្សេងទៀតដូចជា÷ ផ្នែកផលិតកម្មនិងបសុព្យាបាលបានធ្វើការផ្គត់ផ្គង់សម្ភារបិក្ខារ និងប្រេងដល់ផ្នែកជំនាញ សម្រាប់កិច្ចដំណើការរបស់ខ្លួន និងចុះបំពេញការងារនៅតាមមូលដ្ឋាន។ ក្រៅពីនេះ បានធ្វើការបែងចែកថ្នាំការពារព្យាបាល និងសម្ភារបរិក្ខារបសុពេទ្យតាមបណ្តារាជធានី ខេត្ត និងស្ថានីយចិញ្ចឹមសត្វទាំងពីររួមមាន÷ វ៉ាក់សាំងទឹកចំនួន១.៩៤៥.៥០០កម្រិត វ៉ាក់សាំងអុតក្តាមចំនួន៤៤.២៧០កម្រិត បួសខ្យល់ចំនួន១៩.៥០០កម្រិត វ៉ាក់សាំងផ្សេងៗ ៦.៤០០កម្រិត ស៊ីរ៉ាំង១០និង២០មម ចំនួន៩៧៥គ្រឿង ម្ជុលចំនួន១.២០៩ប្រអប់ ដង្កៀបចំនួន១១០គ្រឿង ទែម៉ូម៉ែតចំនួន១៣០ គ្រឿង ថ្នាំព្យាបាល៣៩មុខចំនួន៣.៥១៧ដប ប្លីមេទីឡែនចំនួន១៤៥គ.ក្រ អាកុលចំនួន៥៦០លីត្រ សំឡីចំនួន៣២២.៥គក្រ អាវអៀមចំនួន៨៧៣អាវ កាបូបពេទ្យសត្វចំនួន២៣៧កាបូប និងធុងទឹកកកចំនួន២២គ្រឿង ស្បែកជើងកវែង៩០គូរ ស្រោមដៃ១.៥៩០គូរម៉ាស់១៥៥ប្រអប់ អាវការពារ១៣៨អាវ ម្ជុក២.១០០ម្ជុក ស្រោមដៃស្តើង២២០ប្រអប់ម៉ាស៊ីនបាញ់រម្ងាប់មេរោគ០១គ្រឿង ថ្នាំរម្ងាប់មេរោគ១៦២០លីត្រ និងខិតប័ណ្ណ និងផ្ទាំងរូបភាព២៣.៥០០សន្លឹក។

ការអង្កេតតាមដាននិងការវាយតម្លៃលើការងារពាក់ព័ន្ធ÷ អនុវិស័យនេះ បានចុះអនុវត្តត្រួតពិនិត្យ តាមដានលើការអនុវត្តគម្រោងតាមកម្មវិធីនិងការប្រមូលចំណូល តាមរយៈរាជធានី ខេត្ត។ ក្រៅពីនេះ ជារៀងរាល់ឆ្នាំ តែងតែធ្វើការក្រើនរំលឹកនិងចេញសេចក្តីណែនាំស្តីពីការប្រមូលចំណូលនេះ ជាហូរហែផងដែរ។

### ៥.៤.២. វាយតម្លៃនិងសន្និដ្ឋាន

ជារួមវិស័យនេះ កាន់តែមានសារៈសំខាន់ក្នុងវិស័យសេដ្ឋកិច្ចជាតិនិងមានតួនាទីសំខាន់ក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក និងក្នុងតំបន់ដូចជាការផ្តល់នូវកំលាំងអូសទាញផ្តល់សាច់ ស៊ុត វត្ថុធាតុដើម ចំណូលគ្រួសារ និងចំណូលសេដ្ឋកិច្ចជាតិ។

តាមការវិភាគពីសូចនាករនៃកើនសត្វគ្រប់ប្រភេទសរុប**៥.៣៦៩.៦៨៩**ក្បាលស្មើនឹង**១៤,៧៥%**។ ឆ្នាំ២០១៣ ផលិតកម្មគោបានកើនឡើងចំនួន**១,៦០%** ជ្រូក**១០,៣៣ %** និងចំនួនសត្វស្លាបមានការកើនឡើងចំនួន**១៧,៦៧%** បើធៀបនឹងស្ថិតិឆ្នាំ២០១២។ មូលហេតុនៃការកើនឡើងនេះគឺបណ្តាលមកពីមានកំណើនតម្រូវការទីផ្សារខ្ពស់ ផ្តល់នូវប្រាក់ចំណូលមានវដ្ត

ផលិតកម្មខ្លី និងការរីកចម្រើននៃបច្ចេកវិជ្ជាថ្មីៗ និងការចិញ្ចឹមជាលក្ខណៈគ្រួសារមានការរីកចម្រើន ជាពិសេសសន្ទុះកើនឡើងនៃការវិនិយោគផ្នែកឯកជន។ ការវិនិយោគក្នុងការផលិតចំណីសត្វ មានការរីកចម្រើនគួរឲ្យកត់សំគាល់ ដោយសារមានការបង្កើតឡើងនូវរោងចក្រចំណីសត្វគ្រប់ប្រភេទពីសំណាក់វិនិយោគិនក្នុងស្រុក និងវិនិយោគិនពីបរទេស ដូចជាក្រុមហ៊ុនស៊ី ភី ខេមបូឌា ក្រុមហ៊ុនអេស ស៊ី អេហ្វ ក្រុមហ៊ុនអេហ្វ្រីម៉ាស្ទ័រ ក្រុមហ៊ុនម៉ុង ឬទ្ធី គ្រុប ក្រុមហ៊ុនហ្វ្រ៊ីនហ្វិត។ល។ សម្រាប់ផលិតចែកចាយក្នុងស្រុក និងក្រុមហ៊ុនជីហ្វៃ ផលិតចំណីសត្វសម្រាប់នាំចេញទៅក្រៅប្រទេស។ ប៉ុន្តែផ្ទុយទៅវិញកំលាំងអូសទាញ និងចំនួនក្របី មានការថយចុះចំនួន ១១,៣២ % និង៥,៦៧ ធៀបនឹងស្ថិតិសត្វឆ្នាំ ២០១២។ ការថយចុះកម្លាំងអូសទាញ និងក្របី គឺបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួន រួមមានកំណើននៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម ការប្រែប្រួលអាកាសធាតុ ការកើនឡើងនៃផ្ទៃដីកសិកម្ម និងកំណើននៃតម្រូវការសាច់ជាម្ហូបអាហារក្នុងស្រុកនិងទីផ្សារនាំចេញគោរស់ទៅប្រទេសជិតខាង។

ការកែលំអរពូជសត្វមានការបន្តសកម្មភាពរបស់ខ្លួនខ្លាំងក្លា ដោយបានបង្កាត់ និងផ្សព្វផ្សាយពូជសត្វ ដូចជានៅស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅស្ថានីយចិញ្ចឹមជ្រូកពូជកម្ពុជា-ចិន និងមជ្ឈមណ្ឌលបង្កាត់ពូជគោសាន់តានិងស៊ីមប្រាដោយសិប្បនិម្មិតនៅខេត្តពោធិសាត់ មជ្ឈមណ្ឌលបង្កាត់ជ្រូកពូជដោយសិប្បនិម្មិតនៅខេត្តតាកែវ និងការបង្កាត់ពូជមាន់ KI នៅខេត្តសៀមរាប ហើយផ្សព្វផ្សាយពូជនេះបន្តដល់ខេត្តផ្សេងៗទៀត។

ដំណាំចំណីសត្វ កាន់តែមានការពង្រីកសកម្មភាពរបស់ខ្លួនខ្លាំងក្លាផងដែរ នៅគ្រប់រាជធានី ខេត្តទូទាំងប្រទេសដោយស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅជាកន្លែងផ្សព្វផ្សាយពូជស្មៅ និងចែកចាយពូជទៅតាមបណ្តាខេត្ត និងគម្រោង ACIAR គាំទ្រហិរញ្ញប្បទានដោយរដ្ឋាភិបាលអូស្ត្រាលី ជាពិសេសនៅមានស្រុកព្រៃឈរខេត្តកំពង់ចាម និងស្រុកត្រាំកក់ ខេត្តតាកែវ ប្រជាជនដាំស្មៅទទួលបានជោគជ័យនិងផ្សព្វផ្សាយដល់ខេត្តផ្សេងៗទៀត។ក្រៅពីនេះ ក៏នៅមានការដាំស្មៅបង្ហាញនៅតាមខេត្តស្រុកមួយចំនួនទៀតផងដែរ។

ការគ្រប់គ្រងកាកសំណល់សត្វតាមរយៈការសាងសង់ឡជីវឧស្ម័នសរុប ដែលបានសាងសង់ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០១៣ គឺមានចំនួន **២០.៣៣៨ឡ** ដែលក្នុងនោះសម្រាប់ឆ្នាំ ២០១៣ ឡជីឧស្ម័នមានចំនួន **១.១១៥ឡ** ។

នៅឆ្នាំ២០១៣ នេះសភាពការណ៍ និងស្ថានភាពជំងឺសត្វ បានបង្កការឆ្លងរាលដាល និងប៉ះពាល់ខ្លាំងក្លាដល់ជីវិតមនុស្សសត្វ ជាពិសេសជំងឺផ្តាសាយបក្សី។ ប៉ុន្តែ នាយកដ្ឋានផ.ប និងការិយាល័យផ.ប បានរៀបចំផែនការគ្រប់គ្រងការត្រួតពិនិត្យបានគ្រប់ជ្រុងជ្រោយ និងចាត់វិធានបសុពេទ្យ ដើម្បីទប់ស្កាត់ជំងឺសត្វបានល្អប្រសើរ និងទាន់ពេលវេលា។

ការរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាទាក់ទងវិស័យសុខភាពសត្វនិងផលិតកម្មសត្វ បាននឹងកំពុងដំណើរការប្រកបដោយផ្លែផ្កា ជាពិសេសសេចក្តីព្រៀងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បានដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី និងដាក់ឆ្លងបន្តទៅរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីធ្វើការអនុម័ត។

សមិទ្ធិផលទាំងអស់នេះ សម្រេចបានដោយសារមានការគាំទ្រពីរាជរដ្ឋាភិបាល ពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការខិតខំប្រឹងប្រែងចូលរួមយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ព្រមទាំងមានការចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរកសិកម្មរាជធានី ខេត្ត មន្ត្រីរាជការការិយាល័យផលិតកម្មនិងបសុព្យាបាល រាជធានី ខេត្ត ភ្នាក់ងារសុខភាពសត្វភូមិ និងដោយមានកិច្ចសហប្រតិបត្តិការ និងជំនួយឧបត្ថម្ភពីបណ្តាប្រទេសនានាក្នុងតំបន់ ភ្នាក់ងារផ្តល់ជំនួយអង្គការជាតិអង្គការអន្តរជាតិនានា និងផ្នែកឯកជនជាដើម ។

### ៥.៤.៣-វិធានការ

វិធានការច្បាស់លាស់ សម្រាប់ទិសដៅអនុវត្តសកម្មភាពរបស់ខ្លួនក្នុងឆ្នាំ២០១៤ ដូចខាងក្រោម ÷

-បន្តពង្រឹងនិងគ្រប់គ្រងអង្គភាព សម្រាប់អនុវត្តការងារវិស័យប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់

-រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ផែនការសកម្មភាព កម្មវិធីនិងគម្រោងសកម្មភាពអាទិភាពលើវិស័យផលិតកម្មសត្វ និងសុខភាពសត្វ និងលើកកម្ពស់ការចិញ្ចឹមសត្វតាមគ្រប់រូបភាព

- រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តិ លើវិស័យផលិតកម្មសត្វ និងសុខភាពសត្វ

-បន្តនិងធ្វើឲ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើវិស័យផលិតកម្ម និងបសុព្យាបាល ជាមួយបណ្តាប្រទេសជាមិត្ត ដៃគូរអភិវឌ្ឍន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នពាក់ពន្ធ័ និងកិច្ចសហការជាមួយផ្នែកឯកជន។

### ៥.៥- ផលិតកម្មនិងសេវាកម្មដំណាំកៅស៊ូ (ឧបសម្ព័ន្ធទី១៥-១៨)

កៅស៊ូធម្មជាតិគឺជាប្រភេទដំណាំកសិឧស្សាហកម្មរយៈពេលវែងមួយយ៉ាងសំខាន់ ដែលបានផ្តល់ផលប្រយោជន៍ជាច្រើនដល់សេដ្ឋកិច្ចជាតិ ដល់សង្គម ដល់អ្នកដាំ និងបរិស្ថានធម្មជាតិប្រកបដោយចីរភាពមានដូចជា÷ បង្កើនប្រាក់ចំណូលដល់សេដ្ឋកិច្ចជាតិនិងដល់អ្នកដាំ បង្កើតការងារនៅជនបទ កាត់បន្ថយភាពក្រីក្រ និងទប់ស្កាត់ការធ្វើចំណាកស្រុក រួមចំណែកដល់ការពារបរិស្ថាន ដោយបង្កើតជាគម្របបៃតង រក្សាលំនឹងធម្មជាតិ និងការហូរច្រោះដី និងជាវត្ថុធាតុដើមដ៏ចាំបាច់សម្រាប់កម្មន្តសាលផលិតទំនិញឧស្សាហកម្មរាប់ពាន់មុខ ជាពិសេស សំបកកង់យានយន្តគ្រប់ប្រភេទ សម្ភារកីឡា បរិក្ខារពេទ្យ ស្រោមដៃស្រោមអនាម័យ រហូតដល់សំណង់អគារ និងស្ពានធំៗ...។ល។

### ៥.៥.១- លទ្ធផល

នៅឆ្នាំ២០១៣ ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម និងចម្ការកៅស៊ូគ្រួសារ ព្រមទាំង វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានដំណើរការអនុវត្តទៅតាមផែនការរៀងៗខ្លួន ក្នុងនោះ មុខព្រួញសំខាន់ៗរួមមានការធ្វើអាជីវកម្ម ផលិតកម្ម នីហ័រណកម្មការដាំដុះថ្មី និងការកាប់ដើមកៅស៊ូចាស់ៗនិងដាំកៅស៊ូឡើងវិញ ដោយទទួលបានលទ្ធផលដូចខាងក្រោមនេះ ÷

#### ក. ការងារអាជីវកម្ម-ផលិតកម្មកៅស៊ូ

- ផ្ទៃដីដាំដុះកៅស៊ូសរុបមានចំនួន៣២៨.៧៧១ហិកតាកើនឡើងចំនួន ១៧,៣% ធៀបនឹងឆ្នាំ២០១២
- ផ្ទៃដីចៀរជ័រ ៧៨.៤៩៣ ហត ក្នុងនោះ ផ្ទៃដីចៀរជ័រកៅស៊ូគ្រួសារ ចំនួន ៥២.៥១៦ ហត
- ផលិតផលកៅស៊ូស្ងួត ៨៥.២៤៤តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ៥៤.៩៨៤តោន
- ការនាំចេញកៅស៊ូស្ងួត ៨៦.០៥២តោន ក្នុងនោះ ផលិតផលកៅស៊ូគ្រួសារចំនួន ៥៤.៩៨៤តោន
- កូនកៅស៊ូកំពុងថែទាំសរុបចំនួន២៥០.២៧៨ហត ក្នុងនោះកៅស៊ូកសិឧស្សាហកម្មសរុបចំនួន ១៦៥.៣៧៧ហត និង កៅស៊ូគ្រួសារចំនួន ៨៤.៩០១ហត។

**ផលិតផលនិងការនាំចេញកៅស៊ូឆ្នាំ ២០០៨-២០១៣**




#### ខ. ក្របខណ្ឌច្បាប់

ដោយទទួលបាននូវគម្រោងថវិកាតាមកម្មវិធី វិស័យកៅស៊ូបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ។ រហូតមកដល់ចុងឆ្នាំ២០១៣នេះ សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូនឹងត្រូវបញ្ចប់ ក្នុងកម្រិតក្រុមការងារតាក់តែងច្បាប់នៃអគ្គនាយកដ្ឋានកៅស៊ូដែលរួមមាន១២ជំពូក ៩៤មាត្រា ដោយក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់នេះ បានប្រជុំពិភាក្សាចំនួន១៤៦ដង ប្រជុំអន្តរនាយកដ្ឋានអគ្គនាយកដ្ឋានកៅស៊ូចំនួន៧លើក និងកិច្ចប្រជុំជាមួយអ្នកពិគ្រោះយោបល់អន្តរជាតិក្រោមជំនួយ AFD ចំនួន៥ដងសិក្ខាសាលា១ដង បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់កម្រិតអន្តរនាយកដ្ឋានក្រសួងកសិកម្មនិងប្រតិបត្តិករ

កៅស៊ូចំនួន៣ដង និងបានឆ្លងការផ្តល់យោបល់ពីនាយកដ្ឋាននីតិកម្មកសិកម្ម ស្តីពីទម្រង់នៃសេចក្តីព្រាងច្បាប់នេះបានចំនួន ១ដង។ សង្ឃឹមថា សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ នឹងបានធ្វើការកែសម្រួលរួចរាល់នៅក្នុងខែមីនា ឆ្នាំ២០១៤ នឹងបញ្ជូនទៅក្រសួងកសិកម្មដើម្បីអនុវត្តបន្តតាមនីតិវិធីក្នុងការកសាងច្បាប់។

ជាមួយគ្នានោះដែរអគ្គនាយកដ្ឋានកៅស៊ូ ក៏បានកសាងយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជារយៈពេល ១០ឆ្នាំ (២០១១-២០២០) បានអនុម័តរួចក្នុងឆ្នាំ២០១១ ធ្វើជាត្រីវិស័យសម្រាប់ការអនុវត្តមួយផងដែរ។

## គ. គម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូ

ផ្អែកតាមអនុសញ្ញាហិរញ្ញប្បទានគម្រោង "ធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា" NoCKH 1123 01H រវាងរាជរដ្ឋាភិបាលកម្ពុជានិងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១២ខែកក្កដា ឆ្នាំ២០១២ និងលិខិតលេខ៤៤២២សហវ ចុះថ្ងៃទី០៤ខែកក្កដា ឆ្នាំ២០១២ ស្តីពីករណីសំណើសុំហិរញ្ញប្បទាន សម្រាប់ជួយទ្រទ្រង់ការអនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូ បាននិងកំពុងអនុវត្តការងារគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូ ក្នុងគោលបំណងកែលម្អផលិតភាពដំណាំកៅស៊ូនៅកម្ពុជា ដោយរុក្ខសម្ភារដែលមានការបញ្ជាក់ត្រឹមត្រូវ។ ការងារដែលត្រូវអនុវត្តក្នុងគម្រោងនេះរួមមាន÷ (១)ការធ្វើបញ្ជីសារពើភ័ណ្ឌច្បារពូជកៅស៊ូនៅទូទាំងប្រទេស (២)ការបង្កើតច្បារពូជនិងថ្នាលកូនកៅស៊ូ សម្រាប់ជួសកូនកៅស៊ូក្នុងច្បារពូជណាដែលមិនត្រឹមត្រូវ (៣)ការធ្វើវិភាគ DNA ទៅលើច្បារពូជ ដែលមានស្រាប់ (៤)ការដាំជួសកូនកៅស៊ូពូជត្រឹមត្រូវក្នុងច្បារពូជ និង(៥)ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃច្បារពូជត្រឹមត្រូវ។ គម្រោងនេះមានរយៈពេល៣ឆ្នាំ (២០១៣-២០១៥) ក្នុងទឹកប្រាក់ចំនួន២.៦៨៨.០០០អឺរ៉ូ (ជាង៣លានដុល្លារសហរដ្ឋ) ក្នុងនោះរួមមានថវិកា÷

- AFD មានចំនួន ១.០០០.០០០អឺរ៉ូ
- បដិភាគរាជរដ្ឋាភិបាល(MEF,DGH,IRCC) មានចំនួន ២៧៦.០០០អឺរ៉ូ
- ធនាគារអភិវឌ្ឍន៍ជនបទសម្រាប់ឲ្យខ្ចីចំនួន ១.០០១.០០០អឺរ៉ូ
- ចម្ការកៅស៊ូកសិឧស្សាហកម្មនិងដីសម្បទានសេដ្ឋកិច្ចចំនួន៤១១.០០០អឺរ៉ូ

មកដល់ចុងឆ្នាំ២០១៣នេះ ក្រុមការងារអនុវត្តគម្រោង បានចុះយកសំណាកស្លឹកកៅស៊ូនៅច្បារពូជសរុបចំនួន១.១២០ សំណាកក្នុងនោះ÷ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានចំនួន៦៦០សំណាកលើ៤១ក្លូន ច្បារពូជឯកជនចំនួន៣លើ៥ក្លូន សរុប៣០០សំណាក (២០សំណាក/ក្លូន/ម្ចាស់) និងនៅច្បារពូជចម្ការកៅស៊ូកសិឧស្សាហកម្មលើ៨ក្លូនមានចំនួន១៦០សំណាក (២០សំណាក/ក្លូន) ព្រមទាំងបានផ្ញើសំណាកទាំងនោះទៅ CIRAD ប្រទេសបារាំងដើម្បីវិភាគDNA។ រីឯលទ្ធផលនៃការវិភាគ DNA នៃសំណាកក្លូនកៅស៊ូចំនួន១.១២០ កំពុងដំណើរការ។

## ឃ. ការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារ

ចាប់តាំងពីឆ្នាំ២០០៣មក ការដាំដុះកៅស៊ូលក្ខណៈគ្រួសារនិងឯកជន ដែលប្រើប្រាស់ទុនខ្លួនឯងផ្ទាល់មានការរីកលូតលាស់យ៉ាងខ្លាំងទាំងក្នុងតំបន់ប្រពៃណី និងតំបន់មិនប្រពៃណីដែលពីមុនជាតំបន់មិនធ្លាប់ដាំកៅស៊ូក៏ដោយ។

ដោយទទួលបាននូវគម្រោងថវិកាតាមកម្មវិធី នៅក្នុងឆ្នាំ២០១៣នេះ អគ្គនាយកដ្ឋានកៅស៊ូ បានបំពេញសកម្មភាពការងារតាមគម្រោងជាអាទិភាព ដោយធ្វើការសហការជាមួយមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន បានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារឯកជននៅក្នុងខេត្តចំនួន១៨ រួមមានៈ រតនគីរី ស្ទឹងត្រែង ក្រចេះ មណ្ឌលគីរី កំពង់ចាម កំពង់ធំ ព្រះវិហារ បាត់ដំបង ប៉ៃលិន ពោធិសាត់ បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ កោះកុង ព្រះសីហនុ កំពត ព្រៃវែង និងស្វាយរៀង។ ជារួមក្នុងរយៈពេល៤ឆ្នាំនេះ ក្រុមការងារអនុវត្តគម្រោងអាទិភាពបានចុះស្រង់ស្ថិតិកៅស៊ូគ្រួសារ ដែលមានផ្ទៃដីដាំដុះចំនួន១៣៧.៤១៧ហ.ត ស្មើនឹងចំនួន២៨.១៧៨គ្រួសារ ។

## ការវិវត្តន៍ចម្ការកៅស៊ូគ្រួសារឆ្នាំ២០០០-២០១៣




## ទំហំផ្ទៃដី និងចំនួនគ្រួសារ




### ង. ការងារផ្សព្វផ្សាយបណ្តុះបណ្តាលនិងពិសោធន៍ស្រាវជ្រាវ

បានបើកវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដូចជា ការជ្រើសរើសពូជ ការងារដាំដុះ ថែទាំព្យាបាលជំងឺ និងការបើកមុខចៀរដំបូងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងបច្ចេកទេសកែច្នៃជ័រកៅស៊ូ ក៏ដូចជាបើកវគ្គផ្សព្វផ្សាយពីទីផ្សារកៅស៊ូ ដល់កសិករឱ្យទទួលបានចំណេះដឹងពីកៅស៊ូ ដើម្បីទទួលបានលទ្ធផលល្អនៅថ្ងៃខាងមុខ។

បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីបង្គោល ដើម្បីបង្កើនសមត្ថភាពយល់ដឹងដល់មន្ត្រីបង្គោលលើជំនាញដំណាំកៅស៊ូ និងប្រែក្លាយជាអ្នកផ្សព្វផ្សាយបន្តដល់អ្នកដាំកៅស៊ូ ជាពិសេសជួយដល់កសិករដាំកៅស៊ូ និងអ្នកមានបំណងដាំកៅស៊ូក្នុងខេត្តរបស់ខ្លួន។

បាននិងកំពុងអនុវត្តលើការស្រាវជ្រាវរួមមាន÷ (១)ការស្រាវជ្រាវអំពីការបង្កាត់ពូជនិងជម្រើសពូជកៅស៊ូ បង្កើតប្រព័ន្ធនិងតាមដានទិន្នន័យចម្ការពិសោធន៍ពូជចំនួន២១កន្លែង និងចេញអនុសាសន៍ក្លូនឆ្នាំ២០១៤-២០១៦ (២)ការស្រាវជ្រាវសរីរៈវិទ្យានិងអាជីវកម្ម ដោយបានបង្កើតនិងតាមដានទិន្នន័យពិសោធន៍ចំនួន១៨ពិសោធន៍ (៣)ការស្រាវជ្រាវការដាំដុះនិងការពារ ដោយបានបង្កើត និងតាមដានទិន្នន័យចម្ការពិសោធន៍ចំនួន១៩ នៅក្នុងស្ថានីយ៍អនុវត្តន៍វិទ្យាស្ថានដែលបានបង្កើតឡើងតាំងពីឆ្នាំ២០០៥ រហូតមកដល់បច្ចុប្បន្ន។

## អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០១៤-២០១៦

| Class I | Class II | Class III |
|---|---|---|
| IRCA 130 | GT 1 | BPM 24 |
| IRCA 230 | IRCA 109 | IRCA 111 |
| RRIM 600 | RRIC 121 | IRCA 41 |
| PB 280 | RRIM 712 | PR 303 |
| | PB 260 | PB 254 |
| | PB 217 | PB 310 |
| | RRIC 101 | PB 314 |
| | | PB 324 |
| | | PB 330 |
| | | PR 261 |
| | | KV 4 |
| | | PB 235 |
| | | RRIC 100 |

បាននិងកំពុងអនុវត្តផ្នែកមន្ទីពិសោធន៍រួមមាន÷ (១)ការធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន៣១២សំណាក ដើម្បីបញ្ជាក់គុណភាពកៅស៊ូ និងការកែច្នៃរបស់រោងចក្រនីមួយៗ (២)ការចុះបញ្ជិការមន្ទីរពិសោធន៍យថាប្រភេទនៅបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ ដើម្បីបានលិខិតទទួលស្គាល់ជាផ្លូវការនិងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (៣)ការទទួលយកបុគ្គលិកមន្ទីរពិសោធន៍យថាប្រភេទតាមបណ្តាក្រុមហ៊ុន ដើម្បីធ្វើការបណ្តុះបណ្តាលអំពីរបៀបធ្វើតេស្ត និងចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (៤)ការចូលរួមវគ្គបណ្តុះបណ្តាល "e-precision" និងកិច្ចប្រជុំស្តីពីផលិតផលជ័រកៅស៊ូឬផលិតផលចេញពីជ័រកៅស៊ូ នៅប្រទេសមីយ៉ាន់ម៉ា (៥)ក្រុមការងារអាស៊ាន ផ្នែកផលិតផលចេញពីជ័រកៅស៊ូបានលើកគម្រោងស្នើសុំជំនួយបច្ចេកទេសទៅប្រទេសអូស្ត្រាលី នូវែលហ្សេឡង់ ដើម្បីជួយទទួលស្គាល់ដល់អ្នកផ្តល់កម្មវិធីសមត្ថភាពតេស្តវិភាគ (PT) ស្របតាមបមាណីយ៍ ISO/IEC17043 សម្រាប់វិស័យកៅស៊ូរបស់បណ្តាប្រទេសអាស៊ាន (៦)ការរៀបចំសេចក្តីព្រាង ស្តីពីការបង្កើតមន្ទីរពិសោធន៍អាស៊ានសម្រាប់ផលិតផលកៅស៊ូធម្មជាតិ នៅក្នុងបណ្តាប្រទេសអាស៊ាន ដែលត្រូវមានការទទួលស្គាល់តាមបមាណីយ៍ ISO/IEC17025 និងការចូលរួមកម្មវិធីសមត្ថភាពតេស្តវិភាគ (PT) ស្របតាម ISO/IEC17043:2010 (៧)ការចូលរួមនិងសរុបលទ្ធផលធ្វើតេស្តវិភាគអន្តរមន្ទីរពិសោធន៍លើកទី១០៧ ១០៨ និង១០៩ ជាមួយសមាគមកៅស៊ូអន្តរជាតិ ដើម្បីពង្រឹងសមត្ថភាពតេស្តវិភាគ និងសម្រាប់កិច្ចសន្យាកៅស៊ូបញ្ជាក់គុណភាពតាមបច្ចេកទេស (TSR: Technically Specified Rubber) (៨)ត្រួតពិនិត្យតាមដានរោងចក្រកែច្នៃកៅស៊ូ (CSR: Cambodian Specified Rubber) នៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ និងបានប្រកាសទទួលស្គាល់មន្ទីរពិសោធន៍មូលដ្ឋានក្រុមហ៊ុនជាផ្លូវការ (៩)ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដារនិងគុណភាពកៅស៊ូនៅក្រុមប្រឹក្សាកៅស៊ូម៉ាឡេស៊ី(MRB: Malaysian Rubber Board) និងបានបង្ហាញអំពីការគ្រប់គ្រងនិងត្រួតពិនិត្យឧស្សាហកម្មកៅស៊ូប្រទេសម៉ាឡេស៊ី និងទំនាក់ទំនងស្តង់ដារអន្តរជាតិលើការធ្វើតេស្តវិភាគនិងវិញ្ញាបនបត្រផលិតផលកៅស៊ូ។

### ច. កិច្ចសហប្រតិបត្តិការអន្តរជាតិ

១. **សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ** (ANRPC: Association of Natural Rubber Producing Countries) គឺជាអង្គការអន្តររដ្ឋាភិបាលដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៧០។ កម្ពុជាបានចូលជាសមាជិកពេញសិទ្ធិរបស់ ANRPC កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩។ ការចូលជាសមាជិករបស់កម្ពុជានៅក្នុងសមាគមនេះ គឺជាការធ្វើសមាហរណកម្មវិស័យកៅស៊ូធម្មជាតិកម្ពុជាទៅក្នុងពិភពលោក ដែលមានប្រទេសចំនួន១១ចូលរួមជាសមាជិកនិងមានប្រទេសមួយចំនួនកំពុងសិក្សាលទ្ធភាពដើម្បីចូលរួមក្នុងសមាគមនេះផងដែរ។ រហូតមកដល់ឆ្នាំ២០១៣សមាគមនេះមានរដ្ឋាភិបាលជាសមាជិកចំនួន១១ប្រទេសរួមមាន÷ កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ប៉ាពួញូហ្គីណេ ហ្វីលីពីន សឹង្ហបុរី ស្រីលង្កា ថៃ និងវៀតណាម។ បរិមាណផលិតផលកៅស៊ូធម្មជាតិរបស់ប្រទេសទាំង១១ គឺមាន៩២%នៃផលិតផលកៅស៊ូធម្មជាតិក្នុងពិភពលោក។ ជាមួយគ្នានេះ នៅក្នុងឆ្នាំ២០១៣ កម្ពុជាបាន (១) បានចូលរួមក្នុងកិច្ចប្រជុំនិងសន្និសីទកៅស៊ូឆ្នាំ របស់សមាគមនៃបណ្តាប្រទេសផលិត

កៅស៊ូធម្មជាតិនៅទីក្រុងColombo នៃប្រទេសស្រីលង្កា ដែលបានប្រព្រឹត្តទៅអស់រយៈពេល៦ថ្ងៃ គឺចាប់ពីថ្ងៃទី៧-១៤ ខែតុលា ឆ្នាំ២០១៣។ អង្គប្រជុំបានជ្រើសរើសប្រទេសជាសមាជិកសម្រាប់ធ្វើជាម្ចាស់ផ្ទះឆ្នាំ២០១៤ ២០១៥ និង២០១៦ រួមមាន÷ នៅឆ្នាំ២០១៤នេះ ប្រទេសម៉ាឡេស៊ីត្រូវទទួលវេនធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំ សន្និសីទ និងសន្និបាតប្រចាំឆ្នាំ២០១៤។ **សម្រាប់ឆ្នាំ២០១៥ប្រទេសកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំទាំងនេះ។** ប្រទេសប៉ាពួញូហ្គីណេ ក៏បានសន្យាទទួលធ្វើជាម្ចាស់ផ្ទះសម្រាប់ កិច្ចប្រជុំក្នុងឆ្នាំ២០១៦ ផងដែរ (២) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការបណ្តុះបណ្តាលពី Demand-Supply Modeling ក្នុងការរៀបចំស្ថិតិនិន្នាការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ ក្នុងរយៈពេលជាក់លាក់ណាមួយនាពេលអនាគតនៅប្រទេសថៃរយៈពេលបីថ្ងៃ និង(៣)បានចូលរួមក្នុងកិច្ចប្រជុំក្រុមជំនាញរបស់ Expert Group on Promotion of NR as Environment Friendly Raw Material ស្តីពី “Eligibility of Rubber Cultivation for Carbon Credit under CDM” នៅគូឡាលំពួរ ប្រទេសម៉ាឡេស៊ី រយៈពេលពីរថ្ងៃផងដែរ។

២. **ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ** (IRRDB: International Rubber Research and Development Board) គឺជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេស ផលិតកៅស៊ូធម្មជាតិទាំងអស់ដែលមាន៩៥% នៃបរិមាណផលិតផលកៅស៊ូធម្មជាតិនៅក្នុងពិភពលោក ដែលបានកើតឡើងតាំងពីឆ្នាំ១៩៣៤។ កម្ពុជាបានចូលជាសមាជិកទី១៦នៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់ខ្លួនកាលពីថ្ងៃទី២៧-២៨ ខែកញ្ញាឆ្នាំ២០០១នៅទីក្រុង Montpellier នៃសាធារណរដ្ឋបារាំង។ នៅឆ្នាំ២០១៣ កិច្ចប្រជុំប្រចាំឆ្នាំនិងសន្និសីទកៅស៊ូអន្តរជាតិ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៤-២៩ ខែមិថុនា ឆ្នាំ២០១៣ នៅសណ្ឋាគារ Millenium Hotel Mayfair នៃទីក្រុងឡុងនៃប្រទេសអង់គ្លេស។

៣. **ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ** (Agence Fran Caise de Developpement-AFD) គឺជាគ្រឹះស្ថានសាធារណៈនៃកិច្ចសហប្រតិបត្តិការ បានអនុវត្តការងារអស់រយៈពេលជាង៧០ឆ្នាំមកហើយ ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនិងជំរុញការអភិវឌ្ឍនៅក្នុងបណ្តាប្រទេសភាគខាងត្បូងនិងឯនាយសមុទ្រ។

នៅក្នុងឆ្នាំ២០១៣កន្លងមក ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) បានផ្តល់ហិរញ្ញប្បទានលើគម្រោងបីគឺ÷

- គម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូ ដែលមានទឹកប្រាក់ជាង១លានដុល្លារ
- គម្រោងផ្តល់អ្នកពិគ្រោះយោបល់អន្តរជាតិលើសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូដែលមានទឹកប្រាក់ជាង១០០.០០០ដុល្លារអាមេរិក
- គម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ដែលមានការយល់ព្រមពីរាជរដ្ឋាភិបាលរួចហើយ។ ក្នុងជំហានដំបូងគម្រោងនេះត្រូវធ្វើការសិក្សាជាពីរដំណាក់កាលគឺ ការសិក្សាអំពីបញ្ហាដីធ្លី និងការសិក្សាអំពីកិច្ចដំណើរការនៃគម្រោងទាំងមូលក្នុងឆ្នាំ២០១៤នេះ។

៤. **កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យអន្តរជាតិ** រួមមាន (១)បានចូលរួមសហការជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya នៃប្រទេសជប៉ុន ក្នុងការថែទាំនិងជួសជុលឧបករណ៍ Sap flow, $CO_2$ profile នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (២)សហការការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Kuyshu ប្រទេសជប៉ុន ដើម្បីស្រាវជ្រាវអំពី leaf photosynthesis និង (៣)បានចូលរួមសហការ ការងារជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Hawaii សហរដ្ឋអាមេរិកដើម្បីថែទាំនិងជួសជុល Flux Tower នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

៥. **កិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន** រួមមាន÷ (១) វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន បានព្រមព្រៀងចុះអនុស្សរណៈនៃការយោគយល់គ្នាកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុងកូឡំបូ ប្រទេសស្រីលង្កា (២) តាមរយៈកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-ចិន និងតាមកិច្ចប្រជុំលើកទី២ កាលពីថ្ងៃទី៩-១០ ខែឧសភាឆ្នាំ២០១៣ របស់ក្រុមការងារទ្វេភាគីកម្ពុជា-ចិន សម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ភាគីចិនបានយល់ព្រមពិភាក្សាលម្អិត និងឈានទៅចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MoU) ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ តែមិនទាន់ទទួលបានធ្វើការចុះហត្ថលេខាជាផ្លូវការនៅឡើយទេ។ ជាមួយគ្នានោះ អគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក៏បានលើកជាសំណើជូនភាគីចិន ក្នុងការជួយគាំទ្រនូវគម្រោងមួយចំនួនរួមមាន (១)ការបង្កើតការិយាល័យកៅស៊ូនៅតាម

ខេត្ត (Construction and installation rubber office in Provinces) (២)ការគ្រប់គ្រងចម្ការកៅស៊ូគ្រួសារ តាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Management Rubber Smallholder by Geographical Information System-GIS) និង (៣)ការបង្កើន គុណភាពកៅស៊ូធម្មជាតិកម្ពុជាតាមរយៈការពង្រឹងបរិក្ខាសម្រាប់ធ្វើតេស្តនិងការស្រាវជ្រាវ (Improving the Quality of Cambodian Natural Rubber through Enhancing Rubber Testing Facilities and Researches)។

### ៥.៥.២- វាយតម្លៃ

ផ្អែកកតាមឯកសារគោលសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ នៃរដ្ឋសភា បានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងកម្មវិធីនយោបាយ និងឯកសារមួយចំនួនទៀតដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិ នៅកម្ពុជា២០១១-២០២០ ជាដើម ។ល។

តាមឯកសារខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតអាទិភាពទៅលើការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម និងជាពិសេស ការដាក់ចេញ និងជំរុញអនុវត្ត “***គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ***” និង “***យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០***” ឱ្យបានជោគជ័យ។ បន្តផ្តោតការយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍដំណាំកៅស៊ូ ឲ្យរីកចម្រើនទាំងបរិមាណ និងគុណភាព ដើម្បីឲ្យក្លាយទៅជាវិស័យដ៏មានសក្តានុពល និងភាពប្រកួតប្រជែង តាមរយៈការពង្រីកការដាំដុះកៅស៊ូប្រកបដោយទិន្នផលខ្ពស់នោះ អគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តការងារយ៉ាងសកម្ម តាមស្នូលយុទ្ធសាស្ត្រសំខាន់ៗទាំងប្រាំនៃការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា មានជាអាទិ៍ ការធានាគុណភាព និងផលិតភាពនៃការដាំដុះ ការសិក្សាលទ្ធភាពប្រើប្រាស់សក្តានុភាពនៃដីទំនេរដែលអាចដាំកៅស៊ូបាន ការជំរុញដំណាំកៅស៊ូគ្រួសារ ការជំរុញដំណាំកៅស៊ូកសិឧស្សាហកម្ម ដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍកៅស៊ូគ្រួសារ និងការជំរុញខ្សែចង្វាក់តម្លៃឲ្យបានខ្ពស់ ក្នុងនោះតាមរយៈគម្រោងថវិកាតាមកម្មវិធីប្រចាំឆ្នាំនិងថវិកា ដៃគូអភិវឌ្ឍ (AFD ) អគ្គនាយកដ្ឋានកៅស៊ូបាននឹងកំពុង÷

- ចុះស្រង់ស្ថិតិកៅស៊ូគ្រួសារ និងតាមរបាយការណ៍ពីបណ្តាក្រុមហ៊ុន មកដល់ចុងឆ្នាំ២០១៣ទៅនេះ ស្ថានភាពនៃការអភិវឌ្ឍកៅស៊ូធម្មជាតិនៅទូទាំងប្រទេស មានការវិវត្តឈានឡើងប្រកបដោយថាមភាពខ្ពស់ នៅតាមតំបន់ (ប្រពៃណី និងមិនមែនប្រពៃណី)។ ផ្ទៃដីដាំដុះកៅស៊ូសរុបមានចំនួន៣២៨.៧៦១ហិកតា ឃើញថាផ្ទៃដីដាំដុះកៅស៊ូ លើសការនិទស្សន៍ទុកក្នុងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ២០១១-២០២០ រួចទៅហើយ ដែលទាមទារតម្រូវឱ្យមានការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនេះជាបន្ទាន់។ ព្រោះតាមការប៉ាន់ស្មានជាបណ្តោះអាសន្ន រហូតដល់ឆ្នាំ២០១៨ ផ្ទៃដីដាំដុះកៅស៊ូអាចកើនឡើងដល់ជាង៤០០.០០០ហិកតា ឯណោះ និងមានផលិតផលប្រហែលជា៤០-៤៥ម៉ឺនតោន ក្នុងមួយឆ្នាំៗ
- ការអនុវត្តន៍ គម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅគ្រប់តំបន់ទូទាំងប្រទេស ដើម្បីឲ្យក្លូនកៅស៊ូក្នុងច្បារពូជទាំងអស់មានគុណភាព និងមានទិន្នផលខ្ពស់ ដោយរុក្ខសម្ភារដែលមានការបញ្ជាក់ត្រឹមត្រូវ។ ការងារដែលត្រូវអនុវត្តក្នុងគម្រោងនេះរួមមាន (១)ការធ្វើបញ្ជីសារពើភ័ណ្ឌច្បារពូជកៅស៊ូនៅទូទាំងប្រទេស (២)ការបង្កើតច្បារពូជ និងថ្នាលកូនកៅស៊ូ សម្រាប់ជួសកូនកៅស៊ូក្នុងច្បារពូជណាដែលមិនត្រឹមត្រូវ (៣)ការធ្វើវិភាគDNAទៅលើច្បារពូជដែលមានស្រាប់ (៤)ការដាំជួសកូនកៅស៊ូពូជត្រឹមត្រូវក្នុងច្បារពូជនិង (៥)ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃច្បារពូជត្រឹមត្រូវ។ គម្រោងនេះមានរយៈពេល៣ឆ្នាំ (២០១៣-២០១៥)ក្នុងទឹកប្រាក់ចំនួន២.៦៨៨.០០០អឺរ៉ូ (ជាង៣លានដុល្លារសហរដ្ឋ) ដែលរាល់ចំណាយទាំងអស់គឺជាបន្ទុកថវិការួមរបស់រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់បារាំងសម្រាប់ការអភិវឌ្ឍ (AFD)
- ការចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលដល់កសិករនិងប្រតិបត្តិករកៅស៊ូ លើការជ្រើសរើសពូជ ដើម្បីដាំបច្ចេកទេសការដាំដុះ ការថែទាំ ការបើកមុខចៀរជ័រ ការប្រមូលផល ការកែច្នៃផលិតផលកៅស៊ូ និងការធ្វើពាណិជ្ជកម្មកៅស៊ូ ដែលធ្វើឱ្យកសិករកៅស៊ូមានការយល់ដឹងពីសារប្រយោជន៍កៅស៊ូធម្មជាតិ នឹងយកចិត្តទុកដាក់ខ្ពស់ក្នុងការដាំដុះ ថែទាំ ប្រមូលផល

ការកែច្នៃ ក៏ដូចការធ្វើពាណិជ្ជកម្ម ធ្វើឱ្យកសិករដាំកៅស៊ូទទួលបាននូវចម្ការកៅស៊ូប្រកបដោយគុណភាពសេដ្ឋកិច្ចខ្ពស់ ទទួលបានចំណូលច្រើន ចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទដ៏មានប្រសិទ្ធភាពខ្ពស់

កត្តាជាវិជ្ជមានជាច្រើនដែលមិនអាចកាត់ផ្តាច់បាននោះគឺ (១)យុទ្ធសាស្ត្រឈ្នះឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើឱ្យប្រទេសជាតិបានទទួលឯកភាពជាតិមានសន្តិភាព និងមានសន្តិសុខ សណ្តាប់ធ្នាប់សង្គម ល្អប្រសើរទូទាំងប្រទេស (២)រដ្ឋាភិបាលបានរៀបចំនិងដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅទូទាំងប្រទេស និងព្រមទាំងបានផ្តល់ដីសម្បទានសេដ្ឋកិច្ចសម្រាប់ដំណាំកៅស៊ូដល់វិនិយោគិនក្នុងស្រុក និងបរទេសក្នុងគោលបំណងប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតករកៅស៊ូដ៏មានសក្តានុពល នៅក្នុងតំបន់ និងជាប្រទេសផ្គត់ផ្គង់ផលិតផលកៅស៊ូមួយទៅក្នុងទីផ្សារពិភពលោក (៣)ការផ្តល់សិទ្ធិក្នុងការធ្វើពាណិជ្ជកម្មដោយសេរីក្នុងប្រទេស និងមិនធ្វើជាតិតូបណីកម្មលើដីឯកជន (៤)ការអនុវត្តគោលនយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លីគឺរាជរដ្ឋាភិបាលកម្ពុជា បានបែងចែកដីជូនដល់ប្រជាពលរដ្ឋជាកម្មសិទ្ធិ (៥)តម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារអន្តរជាតិមានតម្លៃខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាកត្តាលើកទឹកចិត្តនិងជំរុញឲ្យកសិករ និងវិនិយោគិនអនុវត្តការដាំដុះកៅស៊ូដោយព្រមៗគ្នានៅលើដីចម្ការរបស់ខ្លួនជាបន្តបន្ទាប់ ដែលជំរុញឲ្យការអភិវឌ្ឍកៅស៊ូនៅកម្ពុជាមានការវិវត្តន៍ឈានឡើងគួរជាទីមោទនៈ។

### ៥.៥.៣- វិធានការ និងទិសដៅ

ដើម្បីសម្រេចបាននូវគោលដៅក្នុងឆ្នាំ២០១៤ខាងមុខ សមស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព និងកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា គោលនយោបាយអភិវឌ្ឍជាតិ២០១៤-២០១៨ ក្នុងការរួមចំណែក សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គម សំដៅកាត់បន្ថយភាពក្រីក្រ លើកកំពស់គុណភាពផលិតផលកៅស៊ូធានាក្នុងការប្រកួតប្រជែងនៅលើទីផ្សារនោះ អគ្គនាយកដ្ឋានកៅស៊ូ បានដាក់វិធានការជាទិសដៅសម្រាប់អនុវត្តការងារក្នុងឆ្នាំ២០១៤ ដូចខាងក្រោម ÷

- បន្តអនុវត្តតួនាទីនិងភារកិច្ច ដើម្បីឱ្យដំណើរការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងការិយាល័យក្រោមឱវាទ ឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងបន្តអនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ឱ្យ
- ពិនិត្យឡើងវិញអំពីការកំណត់អនុកម្មវិធី និងសូចនាករ ដើម្បីឱ្យសមស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្រ អនុសាសន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨
- ពិនិត្យតាមដានការអនុវត្តផែនការ កម្មវិធីវិនិយោគលើដីសម្បទានសេដ្ឋកិច្ច សង្គមកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន
- កែសម្រួល និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាឆ្នាំ២០១១-២០២០
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រ
- ខិតខំកៀរគរកដៃគូសហប្រតិបត្តិការ ក្នុងការគាំទ្រថវិកានិងបច្ចេកទេស ដើម្បីជួយទ្រទ្រង់ដល់ការអភិវឌ្ឍកៅស៊ូគ្រួសារ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងលិខិតគតិយុត្តពាក់ព័ន្ធមួយចំនួន និងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូបញ្ចប់
- បន្តការបើកវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលស្តីពីការដាំដុះ ថែទាំកូនកៅស៊ូ ការប្រើប្រាស់ថ្នាំសម្លាប់ស្មៅ ការគ្រប់គ្រងសមាសភាពជ្រៃ និងជំងឺកៅស៊ូ ការប្រមូលផល ការកែច្នៃដល់កសិករបន្ថែមទៀត
- អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់នាំចេញជ័រកៅស៊ូ

- បន្តការប្រមូលយកគំរូស្លឹកកៅស៊ូនៅតាមបណ្តាច្បារពូជតាមបណ្តាខេត្តដើម្បីធ្វើការវិភាគ DNA តាមផែនការនិងដាំជួសកូន ដែលបានកំណត់ក្នុងគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា

- ទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ជាពិសេសពិនិត្យគោលនយោបាយ បេសកកម្ម និងសកម្មភាពរបស់ក្រុមប្រឹក្សាកៅស៊ូត្រីភាគីអន្តរជាតិដែលស្នើសុំអញ្ជើញកម្ពុជា ឡាវ និងវៀតណាម ឲ្យចូលជាសមាជិកក្នុងក្រុមប្រឹក្សានេះ។

## ៥.៦- លទ្ធផលការងាររុក្ខកម្ម

### ៥.៦.១-លទ្ធផល

### ក. ការប្រមូលចំណូលពីវិស័យព្រៃឈើ

បានប្រមូលចំណូលពីវិស័យព្រៃឈើបាន ទឹកប្រាក់សរុបចំនួន ៦៣.៣២២.៦៧៤.២៤០៛ ស្មើនឹង ២៩៥.២៧% នៃផែនការក្នុងនោះចំណូលបានមកពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ៥៣.៣៧៩.៧៩៥.១០០៛០០ និងពីការផាកពិន័យ ព្រមទាំងលក់ឡាយឡុងនូវផលអនុផលព្រៃឈើបានចំនួន ៩.៩៤២.៨៧៩.១៤០៛០០។

### ខ- ការកំណត់ព្រំប្រទល់ព្រៃឈើការចាត់ថ្នាក់និងចុះបញ្ជិកា

-បានកែសម្រួលបញ្ចប់ឯកសារបច្ចេកទេសបកស្រាយផ្កាយរណបនិងការប្រើប្រាស់ឧបករណ៍សម្រាប់ធ្វើ សារពើភ័ណ្ឌរៀបចំដោយជំនាញការជប៉ុន ហើយបានធ្វើការវាយតម្លៃគម្របព្រៃឈើលើរូបភាពផ្កាយរណប Landsat 2005 និង Landsat 2010 សម្រាប់ការងារវាយតម្លៃកាបោនស្តុក

-ការងារប្រមូលផលអនុផលព្រៃឈើពីដីសម្បទានសេដ្ឋកិច្ចនិងពីប្រភពផ្សេងៗ សម្រេចបានរួមមាន÷ ឈើហ៊ុបមូលចំនួន១៥៦.១១១ម៣ ឈើអារ៥.០១០ម៣ ឈើជ្រុងចំនួន៨.៧៨៣ម៣ ឈើកែច្នៃ (S2S,S4S) ចំនួន២១៧ម៣ និងអនុផលព្រៃឈើមួយចំនួនទៀត។

### គ- ការរៀបចំលិខិតបទដ្ឋាន និងឯកសារបច្ចេកទេស

-បានប្រជុំឆ្លងផ្ទៃក្នុងរដ្ឋបាលព្រៃឈើនូវ÷ ១)សេចក្តីព្រាងអនុក្រឹត្យស្តីពីសំលៀកបំពាក់ ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ២)សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ ៣)សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ព្រៃឈើជាតិ និង៤)ការធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ

-បានបញ្ជូនទៅសេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិនិងសត្វព្រៃ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ដោយបានធ្វើការប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី

### ឃ- ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

-បានទទួលសំណុំរឿងបទល្មើសព្រៃឈើដើម្បីពិន័យអន្តរការណ៍និងច្បាប់ចម្លងសំណុំរឿងបទល្មើសព្រៃឈើ ដែលបានបញ្ជូនទៅតុលាការសរុបចំនួន ១.៥២៣ករណី ក្នុងនោះវត្ថុតាងបទល្មើសព្រៃឈើនិងសត្វព្រៃដែលត្រូវបានចាប់ឃាត់និងរឹបអូសរួមមាន÷ ឈើមូលចំនួន៥៧០ម៣ ឈើអារ៤.០៨០ម៣ ឈើជ្រុង១៥១ ម៣ ឈើគ្រាក់គ្រញូង ២២២ម៣និង ៩.២០៤គ.ក្រ កូនឈើ ២.៦៥២ដើម ជន្លង់ម្រេច ៣២៧៨ដើម សសរមូល ៣៣ដើម ឫស្សី ១៥២៤ដើម អុស១៣៨ស្ទែរ ផ្តៅ៧១៧០គ.ក្រ ជ័រទឹក៥០០០គ.ក្រ គល់ធ្នង់៧១គល់ ពកឈើ៣១៦០គ.ក្រ សត្វព្រៃចម្រុះប្រភេទ១១៨៣គ.ក្រនិង ២៦៤៦ក្បាល រថយន្ត៦១៧គ្រឿង អេស្កាវ៉ាទ័រ០៤គ្រឿង ត្រាក់ទ័រ១៣គ្រឿង ម៉ូតូ១៤៩គ្រ ទូក-កាណូត៣៦គ្រ គោយន្ត ១៩គ្រ ម៉ូតូកង់បី៣គ្រ រទេះកង់ឡាន៤២គ្រ ម៉ាស៊ីនផ្សេងៗ៥៩គ្រ តុឈូសច្រៀកឈើ១៥គ្រ ទ្វារ១១វង់ រណារយន្ត៤៨គ្រ

-បានចុះស្រង់ស្ថិតិនៃការកាប់រានដីព្រៃចំនួន ១.៧២១ហត និងដកហូតដីព្រៃឈើដែលបានកាប់រានចំនួន១.៨៦៤ ហត ព្រមទាំងបានបង្ក្រាបនិងដកហូតរណារយន្តបាន ១៤៤ គ្រឿង។

## ង-ការងារដាំដើមឈើនិងស្តារព្រៃឈើ

-ស្ថានីយ៍ផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋបាលព្រៃឈើដាំឈើបានចំនួន ៣៥០ហត

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើទាំងអស់ បណ្តុះកូនឈើបានចំនួន៤.២០៩.៩៤៥ដើម និងបានចែកចាយជូនប្រជាជនចំនួន ២.១៨៦.៩០៤ ដើម

-បានរៀបចំពិធីបុណ្យរុក្ខទិវាថ្នាក់ជាតិ ៩កក្កដា ២០១៣ នៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ លើផ្ទៃដីចំនួន២០ហត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត របស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និងមានវត្តមានដ៏ខ្ពង់ខ្ពស់ផងដែរពីសំណាក់ **សម្តេចអគ្គពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភាជាតិ និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងមានវត្តមានអ្នកមុខអ្នកការនិងប្រជាពលរដ្ឋចូលរួមជាង ៧.៥០០នាក់។ ដោយឡែកនៅតាមរាជធានី ខេត្តទាំង២៥ ខណ្ឌរដ្ឋបាលព្រៃឈើ។

-បានរៀបចំសួនអាពាហ៍ពិពាហ៍ចំនួន៣៩ កន្លែង មានផ្ទៃដីសរុបចំនួន៤២១,៨៦ហត ស្ថិតនៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើចំនួន១៨ និង មានភរិយាស្វាមីចំនួន៨៤គូរ បានដាំឈើក្នុងសួន គិតមកដល់ឆ្នាំ២០១៣នេះ

-បានធ្វើការស្រាវជ្រាវពូជឈើដូនចែមដែលដុះក្នុងព្រៃធម្មជាតិមានផ្ទៃដីសរុបចំនួន៣៥០ហត ស្ថិតនៅក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ។

## ច-ការងារសហប្រតិបត្តិការអន្តរជាតិ

បានសហការជាមួយអង្គការអន្តរជាតិ និង ដៃគូរអភិវឌ្ឍន៍ អនុវត្តគម្រោងដូចខាងក្រោម ÷

១-គម្រោងគ្រប់គ្រងព្រៃការពារតំបន់ត្រីកោណមរកត ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិរក្សជីវចម្រុះតាមព្រំដែនរវាងប្រទេសថៃ-កម្ពុជានិងឡាវ(ជំហានទី៣) ឧបត្ថម្ភដោយរាជរដ្ឋាភិបាលជប៉ុន តាមរយៈអង្គការ ITTO PD 577/10 រយៈពេល ៣ឆ្នាំ (២០១២-២០១៥) មានទឹកប្រាក់សរុប១.១៤១.៦១០ដុល្លារអាមេរិក

២-គម្រោងស្តីពី ការពង្រឹងសមត្ថភាពការអនុវត្តច្បាប់ព្រៃឈើនិងអភិបាលកិច្ចនៃសម្បត្តិព្រៃឈើអចិន្រ្តៃយ៍ នៅខេត្តក្រចេះនិងមណ្ឌលគីរី ដែលឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលជប៉ុននិងសាធារណៈកូរ៉េ តាមរយៈអង្គការ ITTO PD 673/12 រយៈពេល ៣ឆ្នាំ (២០១៣-២០១៦) មានទឹកប្រាក់សរុប៤៦៤.០៣៣ដុល្លារអាមេរិក

៣-គម្រោងសាងសង់វិទ្យាស្ថានស្រាវជ្រាវព្រៃឈើ-សត្វព្រៃ និងការស្តារព្រៃឈើរេចរឹល (Forest Restoration and Establishment of Forest Research Facilities) ផ្តល់ថវិកាដោយប្រទេស Korea ចំនួន៣.៤៧៨.០០០ដុល្លារអាមេរិក រយៈពេល ០៤ឆ្នាំ (២០១២-២០១៥)

៤-គម្រោងស្រាវជ្រាវនិងស្តារព្រៃសហគមន៍ នៅខេត្តសៀមរាបនិងបង្កើតបន្ទប់ពិសោធន៍ជាលិការុក្ខជាតិផ្តល់ថវិកាដោយ Korea Forest Service ចំនួន ១០០.០០០ដុល្លារអាមេរិក រយៈពេល០១ឆ្នាំ (២០១៣)

៥-គម្រោងស្រាវជ្រាវប្រមូលសំណាកឈើកម្ពុជាផ្តល់ថវិកាដោយ JICA ចំនួន៧.០០០ដុល្លារអាមេរិក រយៈពេល ០១ឆ្នាំ (២០១៣)

៦-គម្រោងស្រាវជ្រាវពូជឈើក្រញូងផ្តល់ថវិកាដោយ AKECOP/Korea Forest Service ចំនួន១០.០០០ដុល្លារអាមេរិករយៈពេល០១ឆ្នាំ (២០១២-២០១៣)

៧-គម្រោងស្រាវជ្រាវ ស្តារព្រៃឈើតាមវិធីសាស្រ្តចម្រុះ ផ្តល់ថវិកាដោយ APFNet ចំនួន៣៨៦.៥៧០ដុល្លារអាមេរិក រយៈពេល០៣ឆ្នាំ (២០១២-២០១៤)

៨-គម្រោងរបៀងអភិរក្សជីវចម្រុះនៃមហាអនុតំបន់មេគង្គក្រោមជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន៩.៥០០.០០០ ដុល្លារអាមេរិក សម្រាប់រយៈពេល០៧ឆ្នាំ (២០១២-២០១៨)

៩-គម្រោងពង្រឹងការគ្រប់គ្រងធនធានព្រៃឈើនិងទីជម្រកជីវចម្រុះ ដើម្បីលើកកំពស់និរន្តរភាព បរិស្ថាន និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជា ចំនួន៣.៨៦៣៦៣៨ដុល្លារអាមេរិក សម្រាប់រយៈពេល ០៤ ឆ្នាំ។

## ឆ. ការអភិវឌ្ឍឧស្សាហកម្មនិងពាណិជ្ជកម្មឈើ

### ឆ.១ ការងារឧស្សាហកម្ម

- បានទទួលប្រកាសអនុញ្ញាតបង្កើតរោង ម៉ាស៊ីនអារ-កែច្នៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រុមហ៊ុនចំនួន១៥លិខិត

-បានទទួលប្រកាសអនុញ្ញាតពន្យាសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទជូនក្រុមហ៊ុនចំនួន១៧ លិខិត

-បានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញចំនួន ៣៦៨ ច្បាប់

-បានផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចូលចំនួន ២ ច្បាប់។

### ឆ.២ ការងារពាណិជ្ជកម្ម នាំចេញ-នាំចូល

-បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញចំនួន១០ក្រុមហ៊ុន មានឈើកែច្នៃសរុបចំនួន៣៩.៧៤២ម³៤៨៥ ចំណាំង ចំណិតឈើចំនួន ១.០០០តោន និងចំណិតឈើចម្ការចំនួន ១៨.២២២តោន៨១៣

-បានពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃចំនួន ៦១ម³៣៤៤ ជូនក្រុមហ៊ុនចំនួន០១

-បានផ្តល់គោលការណ៍អាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃគ្រប់ប្រភេទចំនួន១៤.៨៥៨ម³៥៥៨ និងពីចម្ការ ឈើដាំចំនួន២៦០.០៣៣ តោន ជូនក្រុមហ៊ុនចំនួន០៤

-បានពន្យារគោលការណ៍អាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃគ្រប់ប្រភេទចំនួន៧.០៥៦ម³៨៤០ជូនក្រុមហ៊ុន ចំនួន០១

-បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផលិតផលឈើអារនិងឈើឡាំង ចំនួន៥០០ម³ជូនក្រុមហ៊ុនចំនួន០១។

## ជ- ការអភិរក្សសត្វព្រៃ

-មានសត្វព្រៃគ្រប់ប្រភេទមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំគួរឲ្យកត់សម្គាល់ ពិសេសវត្តមានសត្វខ្លាតសរុប ទូទាំងប្រទេសមានចំនួន២៩៧ក្បាល ត្រូវបានកត់ត្រានិង បានផ្តល់ចំណីចំនួន៤៧លើកនៅព្រៃការពារមណ្ឌលគីរី ព្រៃ ការពារសៀមប៉ាង និងនៅតំបន់ព្រៃខេត្តក្រចេះ និងព្រះវិហារ

-បរិមាណសត្វដំរីព្រៃមានការកើនឡើងដែរ រហូតដល់មានការរំខានពីពពួកសត្វនេះនៅតាមតំបន់មួយចំនួន។ ក្នុង ឆ្នាំកន្លងទៅនេះ រដ្ឋបាលព្រៃឈើសហការជាមួយអង្គការដៃគូបានសម្របសម្រួលជាមួយប្រជាពលរដ្ឋ ដែលទទួលរង គ្រោះដោយសារសត្វដំរីព្រៃបំផ្លាញដំណាំ និងបានកត់ត្រាការខូចខាតសរុបចំនួន៦១លើក ស្មើនឹង៨៩ករណី នៅក្នុងខេត្ត ព្រះសីហនុ កោះកុងនិងកំពង់ស្ពឺ

-ចាប់បានរូបភាពសត្វដំរី ខ្លាឃ្មុំ ខ្ទីង ឆ្កែព្រៃ កែះ ប្រើស ឈ្លូស កាំប្រម៉ា សំពោច ស្វា ជ្រូកពោន ឬ(ជ្រូកព្រុល) និងពង្រូល ដោយមាស៊ីនថតស្វ័យប្រវត្តិ ដែលអ្នកបច្ចេកទេសជំនាញស្រាវជ្រាវសត្វព្រៃបានដាក់នៅតំបន់ជួរភ្នំក្រវាញ ផ្នែកខាងលិចជាច្រើន នេះជាភស្តុតាងបញ្ជាក់ពីវត្តមានសត្វព្រៃមានការកើនឡើង

-កសិដ្ឋានចិញ្ចឹមនិងបង្កាត់ពូជសត្វស្វាក្តាមមានចំនួន៦កន្លែង មានសត្វស្វាសរុប៥៧.៩៩៧ក្បាល

-ឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ បាននិងកំពុងថែរក្សាសត្វចំនួន១.១៨០ក្បាល (បក្សី ៤៧ប្រភេទ ថនិកសត្វ៤១ប្រភេទ និងលូន១០ប្រភេទ) ហើយបានសង្គ្រោះសត្វថ្មីចំនួន៧៨២ក្បាល និងបានធ្វើដោះលែងទៅ ព្រៃធម្មជាតិវិញចំនួន២៤ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន២៧៦ក្បាល និងបានធ្វើការអប់រំផ្សព្វផ្សាយសិស្សនិស្សិត បានចំនួន ១១.៨៦៣នាក់។

**ឈ-ការស្រាវជ្រាវនិងបណ្តុះបណ្តាល**

- បាននឹងកំពុងអនុវត្តគម្រោងសហប្រតិបត្តិការចំនួន១៨គម្រោង

-បាននឹងកំពុងសហការនិងចូលរួមអនុវត្តជាមួយអង្គការ Wildlife Alliance ក្នុងការរៀបចំស្តារលទ្ធភាពសត្វព្រៃនៅស្រុកថ្មបាំង ខេត្តកោះកុង

-បានអនុវត្តគម្រោងស្តារព្រៃឈើឡើងវិញក្រោយអាជីវកម្មនៅតំបន់បាក់ស្នា ខេត្តកំពង់ធំ (ថវិកាជាតិ) ដោយបានបញ្ចប់ការងារដាំបញ្ចូលកូនឈើក្នុងឡូត៍គម្រូ បន្តយាមការពារកាប់បើកប្រឡោះព្រៃ ថែរក្សាកូនឈើដែលបានដាំរួចក្នុងចម្ការ និងថែទាំស្រោចទឹក កាប់ល្បាស់សំអាតកូនឈើដែលនៅសល់ក្នុងថ្នាលជាប្រចាំ។

-បានសហការជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា ADB, JICA, FFPRI/Japan, Kyushu university/Japan, AusAID, APFNet/China, UN-REDD Program Cambodia, AKECOP/Korea, AFoCO/Korea និង FAO អនុវត្តការងារស្រាវជ្រាវរុក្ខជាតិ សត្វព្រៃ និងអាកាសធាតុ លើគម្រោងចំនួន១៤ ដែលមានថវិកាអនុវត្តសរុបចំនួន ៩០០.៦១៨ ដុល្លារអាមេរិក។

**ញ-ការងាយស្រួល**

-មានច្បាប់ស្តីពីព្រៃឈើ គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីព្រៃឈើច្បាស់លាស់និងបទបញ្ញាជាច្រើន របស់រាជរដ្ឋាភិបាលសម្រាប់ជាមូលដ្ឋានពង្រឹងការគ្រប់គ្រងនិងអនុវត្តច្បាប់ក្នុងវិស័យព្រៃឈើទូទាំងប្រទេស

-កិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិកាន់តែទូលំទូលាយ ទទួលបាននូវជំនួយឥតសំណងជាច្រើនសម្រាប់កិច្ចការងារអភិរក្សនិងអភិវឌ្ឍព្រៃឈើ

-មានការផ្តួចផ្តើមចង្អុលបង្ហាញ និងគាំទ្រយ៉ាងពេញទំហឹងពីថ្នាក់ដឹកនាំជាតិគ្រប់ស្ថាប័ន ជាពិសេសពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**ផ្ទាល់ និងឯកឧត្តមរដ្ឋមន្ត្រីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងពីអន្តរជាតិ ពិសេសលើការអនុវត្តកម្មវិធីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយសារការបាត់បង់និងរេចរឹលព្រៃឈើ REDD+

-មានកិច្ចសហការកាន់ជិតស្និតពីស្ថាប័នអយ្យការ តុលាការ កម្លាំងរាជអាវុធហត្ថលើផ្ទៃប្រទេស កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដែលជាដៃគូអភិវឌ្ឍន៍ ពិសេសមានកិច្ចសហការល្អជាមួយអង្គភាពប្រឆាំងអំពើពុករលួយក្នុងការងារពង្រឹងការអនុវត្តច្បាប់។

**ដ-ការលំបាកនិងភាពប្រឈម**

ទន្ទឹមនឹងវឌ្ឍនភាពដែលរដ្ឋបាលព្រៃឈើសម្រេចបាន ក៏នៅមានការលំបាកនិងបញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះក្នុងពេលបំពេញការងារនៅតាមបណ្តាមូលដ្ឋានដូចជា÷

-ខ្វះខាតធនធានមនុស្សនិងមធ្យោបាយសម្រាប់ដំណើរការវិស័យព្រៃឈើឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា

-នៅតែមានការគម្រាមកំហែងពីក្រុមជនល្មើសមកលើមន្ត្រីមានសមត្ថកិច្ចរដ្ឋបាលព្រៃឈើ ក្នុងពេលចុះបំពេញបេសកកម្ម

-ការគ្រប់គ្រងជនចំណាកស្រុកនៅមានការធូររលុងពីសំណាក់អាជ្ញាធរមូលដ្ឋាន បង្កលក្ខណៈងាយស្រួលដល់ការកាប់រានទន្ទ្រានព្រៃឈើពីសំណាក់ជនចំណាកស្រុក ដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ។ ប្រភពបទល្មើសព្រៃឈើនៅតំបន់មួយចំនួនតាមបណ្តោយព្រំប្រទល់កម្ពុជានិងប្រទេសជិតខាង ពិបាកក្នុងការបង្ក្រាបដោយសារបទល្មើសកើតមានឡើងក្នុងព្រៃជ្រៅៗមិនមានផ្លូវគមនាគមន៍ចូលទៅដល់ពីខាងប្រទេសយើងហើយការបង្ក្រាបមានការចំណាយច្រើន

-បទល្មើសព្រៃឈើផ្លាស់ប្តូររូបភាពពីការដឹកជញ្ជូនតាមរថយន្តធំ មករថយន្តតូច ហើយបច្ចុប្បន្ននេះ បានប្រែប្រួលមកប្រើប្រាស់រទេះគោរ៉ឺម៉កម៉ូតូកង់ជាហេតុធ្វើឱ្យចំនួនបទល្មើសក្រោមរូបភាពតូចតាចមានការកើនឡើង។

### ៥.៦.២. វាយតម្លៃនិងសន្និដ្ឋាន

សម្រាប់ឆ្នាំ២០១៣នេះ រដ្ឋបាលព្រៃឈើបានខិតខំប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព មានការកើនឡើងខ្ពស់ជាងឆ្នាំមុន។ ចំពោះការងារបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃមានការថយចុះចំនួន២៦៧ករណីធៀបនឹងឆ្នាំ២០១២កិច្ចការនេះគឺ ដោយ សារការខិតខំព្យាយាមទប់ស្កាត់នូវប្រភពបទល្មើស និងការយល់ដឹងរបស់ប្រជាជនក្នុងវិស័យព្រៃឈើតាមរយៈការជំរុញការផ្សព្វផ្សាយដល់មូលដ្ឋាន។ ចំពោះកិច្ចការស្តារព្រៃឈើឡើងវិញ រដ្ឋបាលព្រៃឈើបានធ្វើការដាំដុះបន្ថែម និងបណ្តុះកូនឈើ ដើម្បីចែកចាយជូនប្រជាពលរដ្ឋទៀតផង។ ទន្ទឹមនឹងសកម្មភាពការងារក្នុងប្រទេសសម្រាប់កិច្ចសហប្រតិបត្តិការ អន្តរជាតិក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ ក្នុងនោះមានការអនុវត្តគម្រោងមួយចំនួន និងការសាងសង់អគារធំៗចំនួនពីរក្រោមការឧបត្ថម្ភរបស់ប្រទេសកូរ៉េ និងជប៉ុន។

### ៥.៦.៣. ទិសដៅនិងវិធានការ

ដើម្បីសម្រេចគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍព្រៃឈើដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឆ្នាំ២០១៤នេះ រដ្ឋបាលព្រៃឈើបានលើកវិធានការ ផែនការសកម្មភាពសម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ដូចខាងក្រោម÷

- បន្តពង្រឹងនិងពង្រីកសាមគ្គីភាពផ្ទៃក្នុងក្រមសីលធម៌វិន័យ ការចាត់តាំង ភាពស្មោះត្រង់ និងឆន្ទៈក្នុងការបំពេញការងារ
- បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ដោយមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ
- បន្តពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ច ដោយធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទបញ្ជាលេខ០១-០២ សជណនិងអនុសាសន៍សម្តេចតេជោនាយករដ្ឋមន្ត្រី
- បន្តជំរុញដាក់ដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមអំណាចសាលក្រមតុលាការ និងពិន័យអន្តរការណ៍ដើម្បីកុំឲ្យឈើបាត់បង់គុណភាពនិងតម្លៃ
- បន្តជំរុញពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយផ្តល់ការលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋាន រួមទាំងវិស័យឯកជនចូលរួមដាំដុះដើមឈើបង្កើតជាចម្ការព្រៃដាំ ដែលផ្តល់ផលប្រយោជន៍ច្រើនយ៉ាងតាមរយៈការបង្កើនដាំដុះព្រៃឈើ
- បន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា អនុវត្តគម្រោងការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធតាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃនិងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍ ដែលមានស្រាប់និងស្វែងរកដៃគូថ្មីៗទៀត
- បន្តកំណត់តំបន់ព្រៃឈើរេចរឹល ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មនិងថែរក្សាការពារចម្ការព្រៃពូជនិងប្រមូលគ្រាប់ពូជឈើ
- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ច និងភាគីពាក់ព័ន្ធនានា ជាពិសេសប្រព័ន្ធព័ត៌មានព្រះរាជអាជ្ញាស្ថាប័នតុលាការក្នុងការគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់
- បន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងតំបន់ និងជាមួយប្រទេសជិតខាងក៏នឹងត្រូវបានយកចិត្តទុកដាក់ពង្រឹងពង្រីកជាប្រចាំតាមរយៈកិច្ចសហការទ្វេរភាគីនិងការចូលរួមអនុវត្តកម្មវិធីតំបន់ឬអន្តរជាតិ។

## ៥.៧- **ការងារជលផល** ( ឧបសម្ព័ន្ធទី១៩)

### ៥.៧.១- លទ្ធផល

លទ្ធផលនៃការអនុវត្តការងារវិស័យជលផលក្នុងឆ្នាំ២០១៣ កន្លងមកមានដូចខាងក្រោម ÷

### ៥.៧.១.១. កំណែទម្រង់វិស័យជលផល

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលបានលុបឡូតិ៍នេសាទចំនួន១៥៨ឡូតិ៍ ដែលមានផ្ទៃឡូត៍សរុប៩៥៣.៨៦១ហតក្នុងនោះបានផ្តល់ជូនប្រជាពលរដ្ឋប្រើប្រាស់តាមរយៈសហគមន៍នេសាទចំនួន៨៥៦.៣៥៨ហត ស្មើនឹង៨៩,៧៧% និងរក្សាទុកកន្លែងអភិរក្សជលផលចំនួន៩៧.៥០៣ហត ស្មើនឹង១០,២៣%។

### ៥.៧.១.២. ការអភិវឌ្ឍន៍សហគមន៍នេសាទ

រហូតមកដល់ឆ្នាំ២០១៣នេះ បង្កើតសហគមន៍នេសាទបានចំនួន៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាប ចំនួន ៤៧៧ និងសហគមន៍នេសាទសមុទ្រ៣៩។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍ នេសាទចំនួន ៣៦០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចហើយ។

ដោយឡែក ការបង្កើតធនាគារក្ដាមមានចំនួន៣២កន្លែង ស្មើនឹង៩៥បែ ដែលក្នុងឆ្នាំ២០១៣នេះបានលែងមេក្ដាមពងចំនួន៦.៣៥៦គក្រ ស្មើនឹង៥៣.៤០៦ក្បាល។ បើគិតពីឆ្នាំ២០០៨មកដល់បច្ចុប្បន្ន គឺបានលែងមេក្ដាមចំនួន៣៥.៧៦២គក្រ ស្មើនឹង២៥៩.៤៩៨ក្បាល ដែលបានផ្ដល់កូនក្ដាមចំនួនប្រមាណ២០៧.១៦៣លានក្បាល ចូលទៅក្នុងសមុទ្រវិញ។ សកម្មភាពនេះតាមការស្រាវជ្រាវរបស់វិទ្យាស្ថានឃើញថា បានធ្វើឲ្យផលក្ដាមសេះមានកំណើនប្រមាណ៤ដង បើប្រៀបធៀបមុនពេលបង្កើតធនាគារក្ដាម។

### ៥.៧.១.៣. ការអភិរក្សធនធានជលផល

ក្រោយការកែទម្រង់ស៊ីជម្រៅវិស័យជលផល ដោយរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេស មានកន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែង សរុបទូទាំងប្រទេសមានចំនួន៤៩១កន្លែង (សហគមន៍៣៦៤កន្លែង)។ ក្នុងឆ្នាំ២០១៣នេះ បានបោះបង្គោលបេតុងបានចំនួន៣២ដើម និងសាងសង់ស្នាក់ការបណ្ដែតទឹកបានចំនួន៤ ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានដូចខាងក្រោម÷

- អភិរក្សថ្កាថ្ម ស្មៅសមុទ្រចំនួន៣.៨៣១ហត នៅតាមតំបន់ឆ្នេរ
- ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន១០០ហត
- រៀបចំអន្លង់ត្រីមេពូជបានចំនួន១៨កន្លែង នៅតំបន់មេគង្គលើ
- បានរៀបចំទិវាមច្ឆជាតិ ០១ កក្កដា នៅអាងទឹក០១ មករា ភូមិតាភោគ ឃុំបាល្ល័ង ស្រុកបារាយ ខេត្តកំពង់ធំ ដោយមានការចូលរួមពីឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តំណាងដ៏ខ្ពង់ខ្ពស់សម្ដេចតេជោសែននិងលោកជំទាវ
- បានលែងកូនត្រីនិងកូនបង្កងចំនួន៥.០០០.០០០ក្បាល ទៅក្នុងបឹងធម្មជាតិ។

### ៥.៧.១.៤. ការបង្ក្រាបបទល្មើសជលផល

ដោយមានបទបញ្ជា០១បប និងច្បាប់ជលផលជាបង្អែក មន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់បានសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធខិតខំបំពេញការងារយ៉ាងសកម្ម ទោះបីខ្វះកម្លាំង មធ្យោបាយធ្វើដំណើរ និងថវិកាក៏ដោយ ជាពិសេសបានយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផលមិនឲ្យមានការលួចចូលធ្វើនេសាទអាណាធិបតេយ្យឡើយ។ ប៉ុន្តែទោះជាខិតខំយ៉ាងណាក៏ដោយ ជាមួយដែននេសាទដ៏ធំធេងនោះ ក៏មិនទាន់អាចទប់ស្កាត់នូវបទល្មើសនេសាទបាន ១០០% នៅឡើយ។

ឯលទ្ធផលជាក់ស្ដែង គឺបង្ក្រាបបទល្មើសបានចំនួន៣.៨២៦ករណី ប្រៀបធៀបឆ្នាំមុនថយចុះចំនួន១.៤៨១ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន៣.៥០៥ករណី ពិន័យអន្តរការណ៍ចំនួន២២៥ករណី បញ្ជូនទៅតុលាការចំនួន៩៦ករណី ដាក់ពន្ធនាគារចំនួន៥១នាក់ ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន១១១.៩០៣.០០០រៀល។ វត្ថុតាងដែលបានធ្វើការរុះរើបំផ្លាញចោលនិងដកហូតឃាត់ទុកបណ្ដោះអាសន្ន រួមមាន÷ របាំងស្បៃមុងនិងសាច់អួនប្រវែង១.០១០.៧៦៥ម៉ែត្រ របាំងព្រួលប្រវែង៩.៣៦០ម៉ែត្រ មងប្រវែង៣៤៧.២៧០ម៉ែត្រ ឈ្នក់/ឆ្នុកចំនួន២៧០គ្រឿង បរ/លូស្បៃមុងនិងសាច់អួនចំនួន១៥.៦៦៦មាត់ ឧបករណ៍ឆក់ត្រីចំនួន១.២៤១គ្រឿង អួនហ៊ុមចំនួន១១៩វង់ លប/តុម/ឡើ/បួម/សៃយីនចំនួន២.១២៧គ្រឿង សន្ទូចចំនួន២៤.២៥០ផ្លែ ដាយត្រីចំនួន១៣៧មាត់ សំណាញ់/ចៃវ៉ា/ជនចំនួន៨៥វង់ ម៉ាញ់/នាមចំនួន៣៦វង់ បង្គោល/ចម្រឹងចំនួន៤២២.២៥៩ដើម សម្រាស់ទំហំ៥៥.០៣៧ម៉ែត្រក្រឡា កាណូត/ទូកបំពាក់ម៉ាស៊ីនចំនួន១២០គ្រឿង ទូកចំនួន៥៥គ្រឿង លែងកូនត្រីប្រាមៀ្បចំនួន២.៧០០.០០០ក្បាល លែងកូនត្រីឆ្តោនិងត្រីរស់ចំនួន៣៩៥.៦១៧ក្បាល

លែងត្រីចម្រុះចូលដែនទឹកធម្មជាតិវិញចំនួន៩២.៦២៤គ.ក្រ អួនអូសចំនួន២៨ចូរ ផ្លុងផាងចំនួន៤មាត់ ឈ្នាងអូសចំនួន ២១គ្រឿង លែងកូនក្ដាមចំនួន១.១២០កូន និងលែងកូនគ្រុំ/គ្រែងឈាមចំនួន៧៣៥គ.ក្រ ។

បានប្រជុំផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសាសន៍ថ្នាក់ដឹកនាំនៅតាមមូលដ្ឋានចំនួន២៩៨វគ្គ អ្នកពាក់ព័ន្ធចូលរួមចំនួន២៥.២៥៩នាក់ ក្នុងនោះស្ត្រីចំនួន១០.៩៦០នាក់។

**៥.៧.១.៥. ការអភិវឌ្ឍន៍វារីវប្បកម្ម**

- ការចិញ្ចឹមត្រី បង្កាឆ្នាំ២០១៣ អនុវត្តបាន៩០.០០០តោន ស្មើ១១២,៥០% នៃផែនការ៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១៦.០០០តោន
- ការចិញ្ចឹមក្រពើឆ្នាំ២០១៣ អនុវត្តបាន៣២០.០០០ក្បាល ស្មើ១៦០% នៃផែនការ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៧០.០០០ក្បាល
- ការភ្ញាស់កូនត្រីពូជឆ្នាំ២០១៣ អនុវត្តបាន១៥០.០០០.០០០ក្បាល ស្មើ១០០% នៃផែនការ ១៥០.០០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១០.០០០.០០០ក្បាល
- កន្លែងភ្ញាស់ត្រីសរុបចំនួន៣០៥កន្លែង ដែលក្នុងនោះមាន២៩២កន្លែងជារបស់ប្រជាពលរដ្ឋតាមរយៈការផ្ដល់បច្ចេកទេសពីមន្ត្រីរដ្ឋបាលជលផល
- មានប្រជាពលរដ្ឋប្រមាណ៦២.០០០គ្រួសារ បានចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រី ដោយបានទទួលការបណ្ដុះបណ្ដាលពីបច្ចេកទេសចិញ្ចឹមត្រីជាបន្តបន្ទាប់ ក្នុងនោះមានកសិករ១៥៤នាក់ ជាគ្រូបង្គោល និងជាគ្រូផ្សព្វផ្សាយនៅមូលដ្ឋាន។

**៥.៧.១.៦. ការបង្កើតស្រះជម្រកត្រីសហគមន៍**

អនុវត្តតាមអនុសាសន៍ពេជ្ររបស់ **សម្ដេចតេជោ** កាលពីឆ្នាំ២០០៩ នៅខេត្តកែប មន្ត្រីរដ្ឋបាលជលផលគ្រប់ខេត្តបានបង្កើតស្រះជម្រកត្រីសហគមន៍បាន៧៧៥កន្លែង គិតរហូតដល់ចុងឆ្នាំ២០១៣នេះ ដែលនៅខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៣កន្លែង។ សកម្មភាពនេះ ក៏បានធ្វើឲ្យផលត្រីតាមវាលស្រែកើនឡើងប្រមាណពី៤ទៅ៦ដងផងដែរ។

**៥.៧.១.៧. ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃនិងគុណភាព**

ជាការងារថ្មីដែលរដ្ឋបាលជលផលកំពុងពន្យល់និងផ្សព្វផ្សាយ ដើម្បីឲ្យគ្រប់កន្លែងផលិតនិងកែច្នៃត្រី គោរពទៅតាមស្តង់ដារអនាម័យឲ្យបានត្រឹមត្រូវ ក្នុងន័យធានាសុខភាពសាធារណៈ និងទីផ្សារនាំចេញ ដោយរួមទាំងសកម្មភាពភូមិ១ផលិតផលជលផល១ផងដែរ។ បង្កើតសមាគមអ្នកកែច្នៃបានចំនួន១៦ និងបានរៀបចំស្តង់ដារផលិតផលចំនួន៣ រួមមានស្តង់ដារប្រហុក ស្តង់ដារងៀតត្រីរ៉ស់-ឆ្តោ និងស្តង់ដារបង្គា បង្កករហ៊ស។

**៥.៧.១.៨. ការសិក្សាស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាបនិងសមុទ្របានដំណើរការល្អ ដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាដូចជា JICA, MRC, FAO, AIDA, World Fish Center ជាដើម។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍនេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ចំពោះលទ្ធផលស្រាវជ្រាវ ត្រូវបានបោះពុម្ព សៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល និងប៉ុស្ទ័រ ជាច្រើនម៉ឺនសន្លឹក។

**៥.៧.១.៩. ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល**

ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល១០ឆ្នាំ (២០១០-២០១៩) បានរៀបចំឡើងដោយសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះស្ដីពីកំណែទម្រង់ជលផល ហើយត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុម័តយល់ព្រមឲ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ នោះ អនុវត្តបាន៣ឆ្នាំរួចមកហើយ។ បច្ចុប្បន្នរដ្ឋបាលជលផលកំពុងរៀបចំកែសម្រួលដើម្បីអនុវត្តតាមសភាពការណ៍វិវឌ្ឍន៍ជាក់ស្ដែងរបស់ប្រទេសកម្ពុជា។

**៥.៧.១.១០. ស្ថិតិផលនេសាទ**

- ស្ថិតិផលនេសាទទឹកសាបសរុបចំនួន៥២៨.០០០តោន ក្នុងនោះមានដូចខាងក្រោម÷

- នេសាទដាយត្រីរដូវនេសាទឆ្នាំ២០១២-២០១៣ អនុវត្តបាន១៣.០០០តោន ស្មើ ១៣០% នៃផែនការ ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៣៣.០០០តោន
- នេសាទគ្រួសារក្នុងដែននេសាទឆ្នាំ២០១៣ អនុវត្តបាន៣៥៥.០០០តោន ស្មើ១០១,៤៣%នៃផែនការ ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៨៦.០០០តោន
- នេសាទគ្រួសារក្នុងវាលស្រែឆ្នាំ២០១៣ អនុវត្តបាន១៦០.០០០តោន ស្មើ១០៦,៦៧% នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង២០.០០០តោន។

- ស្ថិតិផលនេសាទសមុទ្រឆ្នាំ២០១៣ អនុវត្តបាន១១០.០០០តោន ស្មើនឹង១២២,២២% នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង១១.០០០តោន។

**៥.៧.១.១១. ការងារហិរញ្ញវត្ថុ**

ប្រាក់ចំណូលពីគ្រប់ខេត្ត រាជធានីប្រមូលបាន**៣.៨៤៩.០៣៣.៨៦៧ រៀល** ក្នុងនោះមានប្រាក់ចំណូលពី÷

| | |
|---|---|
| - ថ្លៃឈ្នួលឡូត៍ដាយត្រី ដាយបង្កង | ១.៥១៦.៤៣០.០០០រៀល |
| - ប្រាក់ធានាស្ថាពរ | ៨៤៩.១២៥.០០០រៀល |
| - ថ្លៃឈ្នួលដែននេសាទសមុទ្រ | ៤៣៥.១៦១.៤០០រៀល |
| - ប្រាក់ពិន័យនិងលក់វត្ថុតាង | ១១១.៩០៣.០០០រៀល |
| - បំណុលឆ្នាំចាស់ | ៤៣.៩៥០.០០០រៀល |
| - សេវាសាធារណៈ | ១០៦.០៦០.០០០រៀល |
| - ចំណូលផ្សេងៗ (ឈ្នួលអាគារ រោងចក្រ) | ៣៨៦.៤០៤.៤៦៧រៀល |

**៥.៧.១.១២. បញ្ហាប្រឈម**

- បទល្មើសនេសាទនៅតែកើតមាន
- ការយល់ដឹងរបស់ប្រជានេសាទពីសារៈប្រយោជន៍នៃធនធានជលផលនៅមានកម្រិត
- ការអនុវត្តច្បាប់នៅមានកម្រិត
- ការទន្ទ្រានយកដីក្នុងដែននេសាទធ្វើជាកម្មសិទ្ធឯកជននៅតែមានសកម្មភាព
- កិច្ចសហការពីអាជ្ញាធរពាក់ព័ន្ធមួយចំនួននៅមានកម្រិត
- ចំណាកស្រុក (មកពីក្រៅប្រទេសនិងបណ្តាខេត្តផ្សេងៗ)
- ខ្វះមន្ត្រីរាជការបំពេញការងារ
- សហគមន៍នេសាទពុំមានថវិកាសម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន និងសមាជិកសហគមន៍នេសាទភាគច្រើនជាអ្នកក្រីក្រ
- ថវិកា មធ្យោបាយ និងសម្ភារៈមិនគ្រប់គ្រាន់សម្រាប់ការអនុវត្តសកម្មភាពការងារ។

**៥.៧.២- វាយតម្លៃនិងសន្និដ្ឋាន**

ការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យជលផលរយៈពេល១០ឆ្នាំកន្លងមកនេះ មានការប្រែប្រួលរីកចម្រើនគួរឲ្យកត់សម្គាល់ដែលជាលទ្ធផលសំខាន់រួមមាន÷

- ការសាងសង់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍជលផលទឹកសាប
- ការសាងសង់វិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្ម **សម្តេចតេជោ ហ៊ុន សែន**
- ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មសមុទ្រ
- ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវនេសាទបឹងទន្លេសាប
- ការសាងសង់និងអភិវឌ្ឍមជ្ឈមណ្ឌលផលិតត្រីពូជបាទី
- ការរៀបចំបង្កើតវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍជលផលសមុទ្រ

- ការជំរុញការស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មដែលឈានដល់ការភ្ញាស់កូនត្រីប្រា កូនត្រីឆ្តង់ និងកូនបង្កង បានទទួលជោគជ័យជាប្រវត្តិសាស្ត្រ
- ការជំរុញសកម្មភាពបង្ក្រាបបទល្មើសជលផល ដោយអនុវត្តតាមស្មារតីបទបញ្ជាលេខ០១បបរបស់រាជរដ្ឋាភិបាល តាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ ហ៊ុន សែន**
- ការចាត់វិធានការអភិរក្សធនធានជលផលរួមមានទាំងផ្កាថ្ម ស្មៅសមុទ្រ ព្រៃលិចទឹកនិងព្រៃកោងកាងជាដើម ដើម្បី ឈានទៅបង្កើតឧទ្យានអភិរក្សជលផលសមុទ្រ
- ការរៀបចំក្របខណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល១០ឆ្នាំ (២០១០-២០១៩)
- ការបោះពុម្ពផ្សាយសៀវភៅបច្ចេកទេស ប៉ាណូ ប៉ូស្ទ័របានជាច្រើនម៉ឺនច្បាប់។ល។

ប៉ុន្តែទោះជាអនុវត្តការងារបានយ៉ាងច្រើនក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវបំពេញជាបន្ទាន់ ជាពិសេសការបង្ក្រាបបទល្មើសនេសាទ ដែលតែងតែកើតមានឡើងជាបន្តបន្ទាប់។ ការបង្ក្រាបបទល្មើសនេសាទនេះគឺជាការយកចិត្តទុកដាក់យ៉ាងខ្លាំងពីមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់ ដោយបានបង្ក្រាបជាច្រើនពាន់ករណី ដែលជាលទ្ធផលនៃការបង្ក្រាបបានមួយភាគធំហើយ ក៏ប៉ុន្តែនៅមានមួយផ្នែកតូចទៀត ដែលទាមទារការខិតខំប្រឹងប្រែងដោយប្រើកម្លាំងសរុប មធ្យោបាយសរុបបន្ថែមទៀត។

### ៥.៧.៣- ទិសដៅវិធានការ

ដើម្បីគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព រដ្ឋបាលជលផលបានលើកផែនការអនុវត្តបន្តដូចខាងក្រោម÷

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល និងរៀបចំពង្រឹងសង្កាត់រដ្ឋបាលជលផលគ្មានបទល្មើស
- បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទ
- រៀបចំបោះបង្គោលបេតុងចំនួន៤១បង្គោល និងសាងសង់ស្នាក់ការល្បាតចំនួន១០កន្លែងនៅកន្លែងអភិរក្សជលផលក្នុងនោះស្នាក់ការបណ្តែតទឹក០៥កន្លែង
- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទឱ្យក្លាយជាសហគមន៍គ្មានបទល្មើស
- រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល
- បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹក ដែលកាន់កាប់អនាធិបតេយ្យ ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ
- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ
- បន្តបង្កើតនិងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ និងបន្តរៀបចំទិវាមច្ឆជាតិ១កក្កដា រៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងអំពីសារៈសំខាន់ដល់ធនធានជលផល
- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ មានដូចខាងក្រោម÷

+ នេសាទទឹកសាបៈ
  . នេសាទដាយត្រី ដាយបង្កង និងសិប្បកម្ម ១៥.០០០តោន
  . នេសាទគ្រួសារក្នុងដែននេសាទ ៣៩០.០០០តោន
  . នេសាទគ្រួសារក្នុងវាលស្រែ ១៨០.០០០តោន
+ អាជីវកម្មនេសាទសមុទ្រ ១១០.០០០តោន
+ វារីវប្បកម្មៈ
  . ការចិញ្ចឹមត្រី បង្គា ១០០.០០០តោន
  . ការចិញ្ចឹមក្រពើ ៣០០.០០០ក្បាល
  . ការផលិតកូនត្រីពូជ ១៨០.០០០.០០០កូន

+ ការកែច្នៃផលនេសាទៈ

. ការកែច្នៃផលនេសាទទឹកសាប ១៥០.០០០តោន

. ការកែច្នៃផលនេសាទសមុទ្រ ៨.០០០តោន

. ការផលិតទឹកត្រី ៦០.០០០.០០០លីត្រ

+ ការនាំចេញផលនេសាទ ៣០.០០០តោន

+ ចំណូលថវិកា ៣.០០០.០០០.០០០រៀល

## ៥.៨- ការងារសេវាកម្មនិងការគាំទ្រ ផ្សេងៗទៀត

### ៥.៨.១-ការងារគោលនយោបាយផែនការនិងវិនិយោគ

លទ្ធផលសម្រេចបានឆ្នាំ២០១៣-២០១៤ ក្នុងក្របខ័ណ្ឌខាងលើជាគន្លឹះសំខាន់នៃការងារដំណោះស្រាយការលំបាកដែលរាំងស្ទះនានា ហើយទាមទារឱ្យមានការត្រួតពិនិត្យតាមដាននិងវាយតម្លៃច្បាស់លាស់ ទើបមានមូលដ្ឋានគ្រឹះ ដើម្បីធ្វើការសម្រេចចិត្តកែលម្អ ក្នុងការគ្រប់គ្រងនិងដឹកនាំបានល្អ។ សភាពការណ៍និងលទ្ធផលតាមផ្នែកនីមួយៗ នៃការងារបម្រើសេវាកម្មនេះ មានដូចខាងក្រោម ៖

### ក- ការងារផែនការគោលនយោបាយ

### ក.១- ការងារគោលនយោបាយយុទ្ធសាស្ត្រ

- បានតាមដានការអនុវត្តនិងរបាយការណ៍ជឿនលឿន នៃលទ្ធផលសម្រេចបាន ចំពោះការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣
- រៀបចំនិងផ្តល់ធាតុចូលរបស់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨
- រៀបចំនិងកែសម្រួលសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៣
- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨
- រៀបចំផែនការសកម្មភាព ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨
- រៀបចំកសាងផែនការមេរយៈពេលវែងសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០៣៤
- រៀបចំផែនកសាងផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ
- ណែនាំតម្រង់ទិស និងជំរុញតាមដានការអនុវត្ត ផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទតាមកម្មវិធី និងអនុកម្មវិធីស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៤-២០១៨
- ជំរុញការអនុវត្តប្រព័ន្ធផែនការផ្ទៃក្នុង (Internal Planning) និងការកសាងផែនការថវិកា ដោយផ្អែកតាមថវិកាកម្មវិធីប្រចាំឆ្នាំ (Program Budgeting) នៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកា (BSP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយជំរុញការអនុវត្តតាមទម្រង់ P3 និង P4 និងកំណត់ឱ្យបានច្បាស់លាស់ នូវគោលដៅលទ្ធផលចុងក្រោយ សូចនាករ និងធនធានដែលមានដោយផ្អែកតាមកម្មវិធី អនុកម្មវិធីរបស់អនុវិស័យនីមួយៗ
- សម្របសម្រួលតាមដានត្រួតពិនិត្យ និងវាយតំលៃល្បឿននៃការអនុវត្តផែនការ និងកម្មវិធីនានា ដើម្បីលើកជាសំណើតម្រង់ទិសនៅឆ្នាំខាងមុខ។

### ក.២-ការងារវិនិយោគសាធារណៈនិងជំនួយអភិវឌ្ឍន៍ផ្លូវការ

**-ការងារវិនិយោគសាធារណៈ**

នៅក្នុងឆ្នាំ២០១៣ ក្រសួងកសិកម្មបានរៀបចំស្នើសុំគម្រោងកម្មវិធីវិនិយោគសាធារណៈ០៣ឆ្នាំរំកិល ២០១៤-២០១៦ សម្រាប់វិស័យកសិកម្ម នឹងបានអនុមតិដោយក្រសួងផែនការលើគម្រោងចំនួន៣១គម្រោង មានថវិកាសរុបចំនួន ២០៧.៧៧៦.៧០០,០០ ដុល្លារអាមេរិក ក្នុងនោះ÷

- <u>គម្រោងកំពុងដំណើរការ</u> (On-going project) មានចំនួន១១គម្រោង មានថវិកាសរុបចំនួន ១០០.៧៥៣.០០០,០០ ដុល្លាអាមេរិក ក្នុងនោះ÷
  - គម្រោងវិនិយោគជាទុន(Investmet project) មាន០៥គម្រោង មានថវិកាសរុបចំនួន ៤៤.៦៩៧.៤០០,០០ ដុល្លារអាមេរិក
  - គម្រោងជំនួយបច្ចេកទេស (Technical assistance project) មាន០៦គម្រោងថវិកាសរុបចំនួន៥៦.០៥៥.៦០០,០០ ដុល្លារអាមេរិក។
- <u>គម្រោងអនុវត្ត ផយអជ</u> (Planned-project) មានចំនួន២០គម្រោង មានថវិកាសរុបចំនួន១០៧.០២៣.៧០០,០០ ដុល្លារអាមេរិក ក្នុងនោះ÷
  - គម្រោងវិនិយោគជាទុន(Investmet project) មាន០៨គម្រោង មានថវិកាសរុបចំនួន ៦៨.០០៩.០០០,០០ ដុល្លារអាមេរិក
  - គម្រោងជំនួយបច្ចេកទេស (Technical assistance project) មាន១២គម្រោងថវិកាសរុបចំនួន ៣៩.០១៤.៧០០,០០ ដុល្លារអាមេរិក។

**-ការងារផែនការថវិកាតាមកម្មវិធី**

នៅចុងឆ្នាំ២០១៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុម័តថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានទឹកប្រាក់សរុប ២៧.៥៦៧.១០០.០០០ រៀល ក្នុងនោះ ÷

**<u>គម្រោងថវិកាតាមកម្មវិធីនៅឆ្នាំ២០១៤</u> (២៧.៥៦៧.១០០.០០០ រៀល)**

| | |
|---|---|
| **ក-<u>កម្មវិធីទី១ :</u>** | មានទឹកប្រាក់ចំនួន ១៣.៦៤៣.០០០.០០០ រៀល |
| **ខ-<u>កម្មវិធីទី២ :</u>** | មានទឹកប្រាក់ចំនួន ៥២៨.០០០.០០០ រៀល |
| **គ-<u>កម្មវិធីទី៣ :</u>** | មានទឹកប្រាក់ចំនួន ៧៣២.១០០.០០០ រៀល |
| **ឃ-<u>កម្មវិធីទី៤ :</u>** | មានទឹកប្រាក់ចំនួន ៧.៣៦៧.០០០.០០០ រៀល |
| **ង-<u>កម្មវិធីទី៥ :</u>** | មានទឹកប្រាក់ចំនួន ៥.២៩៧.០០០.០០០ រៀល |

**ក.៣-ការងារវិនិយោគឯកជន**

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់គោលការណ៍វិនិយោគជូនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន១២២ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុបចំនួន១.៣១៦.៣៩៦ហត និងផ្ទៃដីអាជីវកម្ម-ផលិតកម្មសរុបចំនួន៧៧១.៦៩៤ហតស្ថិតនៅខេត្តចំនួន១៧។ ប្រភេទដំណាំដែលបានដាំដុះរួមមាន កៅស៊ូ ឈើ ដូងប្រេង ស្វាយចន្ទី ដំឡូងមី និងចិញ្ចឹមសត្វ។

ក្រុមហ៊ុនទាំង១២២ មានក្រុមហ៊ុនក្នុងស្រុកចំនួន៤២ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុបចំនួន៦៦១.៧២៥ហត ដាំដុះបានចំនួន៨២.១៥៥ហត និងក្រុមហ៊ុនមកពីបរទេសសរុបចំនួន៨០ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុបចំនួន ៦៥៤.៦៧១ ហត ដាំដុះបានចំនួន ១៤៨.៧២៧ ហត។

ក្រុមហ៊ុនមកពីបរទេសចំនួន៨០ក្រុមហ៊ុនមកពី÷ ប្រទេសវៀតណាមចំនួន៣៤ ក្រុមហ៊ុនលើផ្ទៃដីចំនួន២៤៩.៥០០ហត ប្រទេសចិនចំនួន២៥ក្រុមហ៊ុន លើផ្ទៃដីចំនួន២៥២.៥៣៣ហត ប្រទេសថៃឡង់ចំនួន០៥ ក្រុមហ៊ុន លើផ្ទៃដីចំនួន៣៨.៨៣៦ហត ក្រុមហ៊ុនមកពីប្រទេសកូរ៉េចំនួន០៥ក្រុមហ៊ុន លើផ្ទៃដីចំនួន៣៧.៣៥២ហត ប្រទេសម៉ាឡេស៊ីចំនួន០៣ក្រុមហ៊ុនលើផ្ទៃដីចំនួន ២៣.៩៩២ហត ប្រទេសឥណ្ឌាចំនួន០៣ក្រុមហ៊ុន លើផ្ទៃដីចំនួន១៧.៧២៧ហត ប្រទេសអ៊ីស្រាអែលចំនួន០២ក្រុមហ៊ុនលើផ្ទៃដីចំនួន៧.៩៣៤ហត ប្រទេសសិង្ហបូរីចំនួន០១ ក្រុមហ៊ុន លើផ្ទៃដីចំនួន៨.០០០ហត ប្រទេសអាមេរិកចំនួន ០១ក្រុមហ៊ុន លើផ្ទៃដីចំនួន ៩.៨២០ហត ប្រទេសអូស្ត្រាលី ចំនួន០១ ក្រុមហ៊ុន លើផ្ទៃដីចំនួន ៨.៩៧៧ហត ។

ក្រុមហ៊ុនវិនិយោគដីសម្បទានសរុបទាំង១២២ក្រុមហ៊ុនមានទីតាំង ទំហំផ្ទៃដី និងចំនួនក្រុមហ៊ុនស្ថិតនៅតាមបណ្តាខេត្តដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១-ខេត្តស្ទឹងត្រែង | ចំនួន | ១១ | ក្រុមហ៊ុន | លើផ្ទៃដីកិច្ចសន្យាសរុប១៨៤.៣៩៥ហត |
| ២-ខេត្តកោះកុង | ចំនួន | ០៤ | ក្រុមហ៊ុន | លើផ្ទៃដីកិច្ចសន្យាសរុប៨៤.៨២៥ ហត |
| ៣-ខេត្តកំពត | ចំនួន | ០៣ | ក្រុមហ៊ុន | លើផ្ទៃដីកិច្ចសន្យាសរុប២២.២០៩ ហត |

៤-ខេត្តពោធិសាត់និងកំពង់ឆ្នាំងចំនួន ០២ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប៣១៨.៣៦៧ហត
៥-ខេត្តមណ្ឌលគីរី ចំនួន ១៦ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប១១៩.៤៦៤ ហត
៦-ខេត្តព្រះសីហនុ ចំនួន ០២ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប១២.៨០០ ហត
៧-ខេត្តរតនគីរី ចំនួន ១៦ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប៨៨.៩៦៣ ហត
៨-ខេត្តសៀមរាប ចំនួន ០២ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប៩.៥៧៧ ហត
៩-ខេត្តព្រះវិហារ ចំនួន ១១ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប៨៨.៤០៨ ហត
១០-ខេត្តឧត្តរមានជ័យ ចំនួន ០៤ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប២៩.៣៩៤ ហត
១១-ខេត្តស្វាយរៀង ចំនួន ០១ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប១.២០០ ហត
១២-ខេត្តកំពង់ស្ពឺ ចំនួន ០៧ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប៦១.៨៦៦ហត
១៣-ខេត្តក្រចេះ ចំនួន ២៨ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប២១៦.០៤៤ហត
១៤-ខេត្តកំពង់ចាម ចំនួន ០៥ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប១២.០៧០ ហត
១៥-ខេត្តកំពង់ធំ ចំនួន ០៩ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប៦១.៦១៤ ហត
១៦-ខេត្តបាត់ដំបង ចំនួន ០១ ក្រុមហ៊ុន លើផ្ទៃដីកិច្ចសន្យាសរុប ៥.២០០ហត។

គិតមកដល់ឆ្នាំ២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានស្នើសុំចុះបញ្ជីដីឯកជនរបស់រដ្ឋបានចំនួន ១៣៨ ក្រុមហ៊ុនក្នុងនោះមាន ក្រុមហ៊ុនមានទំហំផ្ទៃដីធំជាង១០០០ហត សរុបមានចំនួន១២៤ក្រុមហ៊ុន លើផ្ទៃដីសរុបចំនួន ១.២៥៨.៦២៣,៥ហត និងក្រុមហ៊ុនមានទំហំផ្ទៃដីតូចជាង១០០០ហត សរុបមានចំនួន១៤ក្រុមហ៊ុន លើផ្ទៃដីសរុបចំនួន ១០.៥៣៨ហត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចាត់តំណាងនីតិបុគ្គលចូលរួមបំពេញបែបបទលើឯកសារចុះបញ្ជីដីសរុបបានចំនួន២៨ក្រុមហ៊ុន ស្ថិតនៅខេត្តចំនួន៧ ដោយទទួលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុសរុបចំនួន ១១ ក្រុមហ៊ុន។

គិតមកដល់ឆ្នាំ២០១៣ នេះ ក្នុងចំណោមក្រុមហ៊ុនដែលបានចុះកិច្ចសន្យារួចជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន១២២ក្រុមហ៊ុន មានក្រុមហ៊ុនចំនួន៤៤ក្រុមហ៊ុន ដែលត្រូវជាប់កាតព្វកិច្ចបង់ថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច។ បច្ចុប្បន្ននេះគណៈកម្មការអន្តរក្រសួង បាននឹងកំពុងដំណើរការអនុវត្ត និងប្រមូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ។

## ខ. ការងារសម្របសម្រួល តាមដាន និងវាយតម្លៃគម្រោង

### ខ.១ ការតាមដាននិងវាយតម្លៃថវិកាតាមកម្មវិធី

-បានចុះតាមដាននិងវាយតម្លៃការអនុវត្តថវិកាតាមកម្មវិធីនៅតាមអង្គភាពថ្នាក់កណ្តាល ចំនួន ១០ អង្គភាព

-បានចុះតាមដានការអនុវត្តថវិកាតាមកម្មវិធីនៅទីវាល បានចំនួន១៥លើក

-បានបណ្តុះបណ្តាលដោយអនុវត្តផ្ទាល់ (On the job training) ដល់មន្ត្រីតាមបណ្តាអង្គភាពក្នុងកម្មវិធីទាំង០៥

-បានបូកសរុបលទ្ធផលនៃការតាមដាននិងវាយតម្លៃថវិកាកម្មវិធី ប្រចាំឆមាស និងប្រចាំឆ្នាំ

-បានសម្របសម្រួលនិងរៀបចំបើកសិក្ខាសាលាចំនួន០២លើក នៅខេត្តព្រះសីហនុនិងខេត្តសៀមរាប លើប្រធានបទស្តីពីប្រព័ន្ធតាមដាននិងវាយតម្លៃថវិកាកម្មវិធី ក្រោមគម្រោងជំនួយបច្ចេកទេស ADB-Grant. 0222-PFM: RDMs

### ខ.២ ការតាមដាននិងវាយតម្លៃគម្រោងអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម

-បានចុះតាមដាននិងវាយតម្លៃលើការអនុវត្តគម្រោងចំនួន០២របស់អង្គការ JICA, FIDR

-បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី អភិក្រមគោលនយោបាយគាំទ្រដល់ជនក្រីក្រ ដើម្បីឆ្លើយតបហានិភ័យ និងភាពងាយរងគ្រោះនៅកម្រិតប្រទេស ក្រោមគម្រោងជំនួយបច្ចេកទេសរបស់អង្គការ FAO។

-បានរៀបចំវេទិការគោនយោបាយស្តីពី ការលើកកម្ពស់ផលិតភាពវិស័យកសិកម្មនៅកម្ពុជា ក្រោមគម្រោងជំនួយបច្ចេកទេសរបស់វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី។

-បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតម្លៃដែលរៀបចំដោយក្រសួងផែនការចំនួន០២លើក

## គ-ការងារស្ថិតិ

ជារួមការងារស្ថិតិកសិកម្មត្រូវបានពង្រឹងនិងបន្តបង្កើនសមត្ថភាពធនធានមនុស្ស ជំនាញបច្ចេកទេសនិងវិធីសាស្ត្រនៃការធ្វើអង្កេតជំរឿន និងវិភាគ។ ផ្នែកស្ថិតិកសិកម្មជាសេនាធិការមានយន្តការនៃការដឹកនាំគ្រប់គ្រង ប្រមូល វិភាគ ចងក្រង និងចែកចាយនៃទិន្នន័យស្ថិតិកសិកម្ម។ លទ្ធផលសម្រេចបានតាមផ្នែកមានដូចខាងក្រោម÷

### គ.១. ផ្នែកតាមដានបូកសរុបនិងវិភាគទិន្នន័យ

-ការប្រមូលព័ត៌មាននិងរបាយការណ៍តាមបណ្តានាយកដ្ឋានក្រោមឱវាទក្រសួង និងតាមបណ្តារាជធានី ខេត្ត ដែលពាក់ពន្ធ័ការងារប្រព័ន្ធទិន្នន័យស្ថិតិកសិកម្ម

-តាមដានការងារបង្កបង្កើនផលដំណាំកសិកម្ម (ដំណាំស្រូវរដូវវស្សានិងរដូវប្រាំង ដំណាំរដូវផ្សេងៗ និងដំណាំអចិន្ត្រៃយ៍ ដើម្បីធ្វើការវាយតម្លៃលើផ្ទៃដីដាំដុះ ទិន្នផល បរិមាណផលប្រចាំឆ្នាំ

-តាមដានពិនិត្យ វាយតម្លៃ វិភាគ និងធ្វើរបាយការណ៍ជាប្រចាំស្តីពី ល្បឿនបង្កបង្កើនផលស្រូវរដូវវស្សា និងរដូវប្រាំង និងដំណាំរួមផ្សំឆ្នាំ២០១៣-២០១៤ នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-វិភាគនិងបកស្រាយលើទិន្នន័យ ដែលបានបញ្ចូលក្នុងប្រព័ន្ធអេឡិចត្រូនិចនិងផ្ទៀងផ្ទាត់លើផ្ទៃដី ទិន្នផល បរិមាណផល ដែលបានប្រមូលតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-ពិនិត្យវាយតម្លៃនិងសិក្សាវិភាគទិន្នន័យ ដែលបានបញ្ចប់ការដាំដុះដំណាំរដូវវស្សានិងប្រាំង ដើម្បីធ្វើការវាយតម្លៃ ប៉ាន់ស្មានតុល្យភាពស្បៀងប្រចាំឆ្នាំតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស

-តាមដានទឹកភ្លៀងនិងគ្រោះធម្មជាតិ (រាំងស្ងួត ទឹកជំនន់ សត្វល្អិត) នៅតាមបណ្តារាជធានីខេត្តនិងធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបាន ដើម្បីធ្វើការកែច្នៃនិងវិភាគសកម្មភាពការងារបង្កបង្កើនផលដំណាំកសិកម្មរដូវវស្សានិង រដូវប្រាំង។

-បានសហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កសិកម្មនិងជនបទ (CARD) អង្គការស្បៀងនិងកសិកម្ម (FAO) ប្រចាំកម្ពុជា និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) ប្រចាំនៅកម្ពុជា បានផលិតព្រឹត្តិបត្រតាមដានព័ត៌មានផលិតផលប្រចាំខែ និងព្រឹត្តិបត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភប្រចាំត្រីមាស។

សកម្មភាពនិងលទ្ធផលការងារនេះ បានផលិតចេញជារបាយការណ៍កសិកម្មរៀងរាល់សប្តាហ៍ផ្ញើជូនខុទ្ទកាល័យ**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** របាយការណ៍ប្រចាំឆ្នាំនិងរបាយការណ៍ពិសេសដោយឡែកមួយចំនួនទៀត និងសៀវភៅស្ថិតិកសិកម្មប្រចាំឆ្នាំ។ល។

### គ.២- ផ្នែករៀបចំវិធីសាស្ត្រអង្កេតដំណាំ

- ធ្វើការជ្រើសរើសចំនួនភូមិ ចំនួនគ្រួសារ និងចំនួនសំណាកគំរូតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស ដើម្បីដំណើរការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សានិងរដូវប្រាំងឆ្នាំ២០១៣-២០១៤

-ធ្វើទម្រង់បញ្ជីសំណួរថ្នាក់ភូមិ សម្រាប់ការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សានិងរដូវប្រាំង

-ធ្វើបញ្ជីឈ្មោះគ្រួសារដាំដំណាំស្រូវក្នុងភូមិ ដែលត្រូវធ្វើការជ្រើសរើសចៃដន្យសំណាកគំរូ បញ្ជីសំណួរអង្កេតស្ទង់ទិន្នផលដំណាំស្រូវ និងស្លាកកំណត់ត្រាដំណើរការធ្វើអង្កេតស្ទង់

-ធ្វើការជ្រើសរើសគ្រួសារចៃដន្យតាមប្រព័ន្ធអេឡិត្រូនិច ដើម្បីអនុវត្តការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សា និងរដូវប្រាំងប្រចាំឆ្នាំ២០១៣-២០១៤ តាមបណ្តារាជធានី ខេត្ត

-ធ្វើការសាកល្បងលើសំណាកគំរូតាមប្រភេទស្រូវ (ស្រាល កណ្តាល និងធ្ងន់) នៅមូលដ្ឋានស្រុក ភូមិ និងគ្រួសារ និងដំណើរការធ្វើអង្កេតស្ទង់ទិន្នផលស្រូវរដូវវស្សានិងរដូវប្រាំងឆ្នាំ២០១៣-២០១៤

-ដំណើរការធ្វើអង្កេតទិន្នផលដំណាំអចិន្ត្រៃយ៍ឆ្នាំ២០១៣

-បង្កើតនិងកែច្នៃទម្រង់សម្រាប់ធ្វើការអង្កេតក្នុងប្រព័ន្ធអេឡិត្រូនិច ដើម្បីងាយស្រួលក្នុងការបញ្ចូលនិងវិភាគទិន្នន័យ

-បែងចែកទិន្នន័យមួយចំនួនទៅតាមលំដាប់បណ្តារាជធានី ខេត្ត ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធព័ត៌មានស្ថិតិថ្នាក់ជាតិ

-ទទួលអនុវត្តនូវគម្រោងប្រព័ន្ធព័ត៌មានដីកសិកម្មជាលើកទី២ ក្រោមគម្រោងប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ាន ឧបត្ថម្ភថវិកាដោយរាជរដ្ឋាភិបាលជប៉ុន

-សហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) ដើម្បីសិក្សាស្រាវជ្រាវនូវវិធីសាស្ត្រ សម្រាប់ការគិតគូរគណនា កំណើនរបស់វិស័យកសិកម្ម GDP ប្រចាំឆ្នាំ និងចំនួនប្រជាជនទូទាំងប្រទេស២៤រាជធានី ខេត្ត

-សហការជាមួយក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ) ក្រោមការជួយឧបត្ថម្ភគាំទ្រថវិកាបដិភាគពីរាជរដ្ឋាភិបាល អង្គការ FAO និងដៃគូអភិវឌ្ឍ ក្នុងដំណើរការធ្វើជំរឿនកសិកម្មជាលើកទី១ នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣។ ថវិកាសរុបសម្រាប់អនុវត្តជំរឿនកសិកម្មមានចំនួន៥,៣លានដុល្លារអាមេរិក ក្នុងនោះ ថវិកាបដិភាគរាជរដ្ឋាភិបាលកម្ពុជាចំនួន ១,៤២លានដុល្លារអាមេរិក។ ជំរឿនកសិកម្មបានចាប់ផ្តើមប្រតិបត្តិការវគ្គទី១ នៅខែមេសា ដល់ ខែមិថុនា ឆ្នាំ២០១៣ និងបានបន្តនូវវគ្គទី២ នៃការអង្កេតជ្រើសរើសគំរូចំនួន៨០.០០០គ្រួសារទូទាំងប្រទេស សម្រាប់តារាងសំណួរបំពេញបន្ថែម នៅខែមករា ឆ្នាំ២០១៤នេះ។ តាមការគ្រោងទុក លទ្ធផលចុងក្រោយនៃការធ្វើជំរឿនកសិកម្មឆ្នាំ២០១៣ នឹងប្រកាសផ្សព្វផ្សាយនៅចុងឆ្នាំ២០១៤។

ជារួមសមត្ថភាពនៃការធ្វើអង្កេតស្ទង់ទិន្នផលស្ថិតិកសិកម្ម ដោយមានការជួយឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល បានជំរុញឱ្យដំណើរការងារនេះ មានការរីកចម្រើនបន្ថែមនូវការអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ បានមួយកម្រិត។ តែទោះជាយ៉ាងណាក្តី ក៏ការធ្វើអង្កេតស្ទង់ដំណាំកសិកម្ម នៅមានការសេសសល់ការងារជាច្រើនទៀត ដែលមិនបានធ្វើដោយកត្តាផ្សេងៗ ដូចជាខ្វះខាតថវិកា និងធនធានមនុស្សនៅមានកម្រិត។

## ឃ-ការងារទីផ្សារកសិកម្ម

សេវាព័ត៌មានទីផ្សារកសិកម្ម គឺជាគុជរំយ៉ាងសំខាន់ក្នុងដំណើរការទីផ្សារ សំដៅជួយបង្កើននូវតម្លៃបន្ថែម និងប្រាក់ចំណូលដល់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសកសិករ និងពាណិជ្ជករ និងការផ្តល់ព័ត៌មានទីផ្សារកសិកម្មអំពីបរិមាណ និងគុណភាពដល់អ្នកពាក់ព័ន្ធទាំងអស់។

កង្វះព័ត៌មានទីផ្សារ ក្នុងស្រុក និងអន្តរជាតិ មានន័យថាការសម្រេចចិត្តធ្វើផលិតកម្មមិនត្រូវបានធ្វើការពិចារណាទៅលើការប្រែប្រួលលក្ខខណ្ឌនៃការផ្គត់ផ្គង់និងតម្រូវការក្នុងទីផ្សារ។ ក្នុងន័យនេះ ព័ត៌មានទីផ្សារដែលប្រើប្រាស់មានប្រយោជន៍ ដើម្បីជំរុញការធ្វើផលិតកម្មនិងការតម្រង់ទិសទៅរកទីផ្សារ គឺជាតម្រូវការបន្ទាន់មួយ។

ផ្នែកទីផ្សារកសិកម្មនៃនាយកដ្ឋានផែនការនិងស្ថិតិ បានខិតខំបំពេញសេវាពត៌មានទីផ្សារកសិកម្មដោយផ្តល់នូវសេវាសំខាន់ៗ ចំនួនពីរ គឺសេវាព័ត៌មានទីផ្សារកសិផល និងការអភិវឌ្ឍទីផ្សារកសិកម្ម ដើម្បីឲ្យអ្នកពាក់ព័ន្ធមានលទ្ធភាពទទួលបានព័ត៌មានទីផ្សារ ប្រមូលនិងវិភាគព័ត៌មានត្រឹមត្រូវ ទាន់ពេល និងជាប់ជាប្រចាំ។ សេវាព័ត៌មានទីផ្សារកសិកម្មនឹងជួយធ្វើឲ្យជីវភាពប្រជាកសិករ បានប្រសើរឡើង និងដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងចូលរួមកាត់បន្ថយភាពក្រីក្រ។

**ផ្នែកសេវាព័ត៌មានទីផ្សារកសិកម្ម:** ផ្នែកនេះបានពង្រីកការប្រមូលទិន្នន័យតម្លៃលក់ដុំ/លក់រាយពី ២៤ រាជធានី ខេត្តចាប់តាំងពីឆ្នាំ២០១២ លើផលិតផលកសិកម្មចំនួន១៦០។ ព័ត៌មានតម្លៃកសិកម្មផ្សព្វផ្សាយតាមរយៈ ១. ទូរទស្សន៍ ២. ព្រឹត្តិបត្រតម្លៃប្រចាំខែ ដែលចែកចាយទៅឱ្យស្ថាប័នក្រោមឱវាទក្រសួង និងក្រសួងពាក់ព័ន្ធដទៃទៀត NOGs អង្គការអន្តរជាតិ ៣. វេបសាយ (www.agriculturalmarketinformation.org.kh) និង ៤. ផ្ញើសារជាអក្សរតាមរយៈទូរស័ព្ទ។ ដោយសហការជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ អង្គការស្បៀង និងកសិកម្មនិងអង្គការស្បៀងអាហារពិភពលោក ផ្នែកទីផ្សារកសិកម្មបានផលិតការត្រួតពិនិត្យតម្លៃម្ហូបអាហារប្រចាំខែនិងព្រឹត្តិបត្រសន្តិសុខស្បៀងប្រចាំត្រីមាស។

ការងារទីផ្សារបានប្រើទិន្នន័យតម្លៃផលិតផលកសិកម្មសំខាន់ៗមួយចំនួន (ទីផ្សារក្នុងស្រុកនិងអន្តរជាតិ) ដើម្បីត្រួតពិនិត្យតាមដានថ្លៃអង្ករក្នុងទីផ្សារ។ ជាទូទៅតម្លៃអង្ករក្នុងស្រុក ត្រូវបានរងឥទ្ធិពលថ្លៃលើទីផ្សារអន្តរជាតិ ជាពិសេសដោយប្រទេសជិតខាងដូចជាប្រទេសថៃនិងប្រទេសវៀតណាម។ ក្រាហ្វិកខាងក្រោមបង្ហាញពីនិន្នាការតម្លៃអង្ករចំរុះ នៅក្នុងប្រទេសកម្ពុជានិងអង្ករបាក់ (២៥%) នៅក្នុងប្រទេសថៃនិងអង្ករបាក់ (៥%) ក្នុងប្រទេសវៀតណាម។ និន្នាការតម្លៃក្នុងទីផ្សារចំនួនបីគឺ

មានលក្ខណៈប្រហាក់ប្រហែលគ្នា។ តម្លៃបានកើនឡើងខ្ពស់នៅចុងឆ្នាំ២០១១ ហើយបន្ទាប់មកបានបន្តធ្លាក់ចុះរហូតដល់ឆ្នាំ ២០១៣ ។ នៅខែធ្នូឆ្នាំ២០១៣ តម្លៃអង្ករចម្រុះនេះគឺ៤៧០ដុល្លា/តោន បានធ្លាក់ ២,៧៦% ធៀបទៅនឹងខែមុន និង ៩,៤០% ធៀបទៅនឹងឆ្នាំមុនក្នុងខែដូចគ្នា។ ថ្លៃអង្ករបាក់ (៥% វៀតណាម) ក៏មាននិន្នាការដូចគ្នា។ ក៏ប៉ុន្តែ ថ្លៃអង្ករបាក់ (២៥%, ប្រទេសថៃ) គឺ ៣៨៧ដុល្លា/តោន បានកើនឡើងប្រហែល ៥% ធៀបនឹងខែមុនតែបានធ្លាក់ចុះប្រហែល ២៥% ធៀបទៅនឹងឆ្នាំមុនក្នុងខែដូចគ្នា។




អង្ករផ្ការំដួល ជាអង្ករល្អបំផុតសម្រាប់ការនាំចេញអង្ករដែលបានឈ្នះពានរង្វាន់ដ៏ល្អបំផុត។ ទិន្នន័យបង្ហាញថាតម្លៃលក់ដុំជាមធ្យមក្នុងត្រីមាសទីបួនឆ្នាំ២០១៣ បានធ្លាក់ចុះរយៈពេលបីខែជាប់គ្នា។ នៅក្នុងខែធ្នូនេះ តម្លៃអង្ករផ្ការំដួលគឺ ២.៦០០ រៀល/គីឡូក្រាម កើនឡើង ២% ធៀបទៅនឹងខែមុននិង២% ធៀបទៅនឹងឆ្នាំមុនក្នុងខែដូចគ្នា ។




ជារួមផ្នែកទីផ្សារកសិកម្ម បានសម្រេចសមិទ្ធិផលយ៉ាងច្រើនក្នុងឆ្នាំ ២០១៣ ស្របតាមផែនការរំពឹងទុក។ ព័ត៌មានទីផ្សារដែលផ្តល់ជូនកសិកម្មបានល្អប្រសើរនិងផ្តល់ព័ត៌មានតម្លៃគុណភាពទៅឱ្យអ្នកប្រើជាពិសេសកសិករនិងអាជីវករ។ ព័ត៌មានតម្លៃនេះ ត្រូវបានរួមចំណែកការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ក្នុងគោលបំណង ដើម្បីរួមចំណែកលើកកំពស់វិស័យកសិកម្មនិងការកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើពិពិធកម្មកសិកម្ម ។

## ង-ការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- បានចុះពិនិត្យនិងសិក្សាស្ថានភាពដី លើការស្នើសុំប្តូរមុខដំណាំរបស់ក្រុមហ៊ុន មៀង លីហេង វិនិយោគ ដែលមានទីតាំងស្ថិត ក្នុងខេត្តឧត្តរមានជ័យ

- បានចុះពិនិត្យនិងសិក្សាស្ថានភាពដី លើការស្នើសុំប្ដូរមុខដំណាំរបស់ក្រុមហ៊ុន អភិវឌ្ឍរតនាវិសាល ដែលមានទីតាំងស្ថិតក្នុងខេត្តពោធិសាត់

- បានចុះពិនិត្យនិងវាយតម្លៃសកម្មភាពវិនិយោគ របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនៅខេត្ត កំពង់ធំ និងព្រះវិហារ

- ពិគ្រោះយោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើដំណាំកៅស៊ូចំនួនពីរក្រុមហ៊ុនដូចជា÷ ក្រុមហ៊ុន Cambodian Blu Haven Ltd. មានទីតាំងនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព ខេត្តព្រះវិហារ និងរបស់ក្រុមហ៊ុន Cambodian Dawn Plantation មានទីតាំងនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃគូលេនព្រហ្មទេព ស្រុកគូលេន ខេត្តព្រះវិហារ

- ចូលរួមប្រជុំផ្ដល់យោបល់លើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងវិនិយោគៈ អភិវឌ្ឍន៍តំបន់លំហែកាយកោះក្របីរបស់ក្រុមហ៊ុន R P B Investment Co,.LTD ដែលមានទីតាំងក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃស្នួល ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ

- ចូលរួមពិគ្រោះយោបល់លើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើដំណាំកៅស៊ូមានក្រុមហ៊ុនបីរួមមាន÷ ក្រុមហ៊ុន Hoang Anh Mang Yang K Aphivath Caouthoul Co,Ltd មានទីតាំង នៅឃុំសំកុក ស្រុកវីនសៃ ខេត្តរតនគីរី ក្រុមហ៊ុន Krong BokranakKIrI Aphivath Coutchoul Co,Ltd មានទីតាំងក្នុងស្រុកអណ្ដូងមាស និងស្រុកតាវែង ខេត្តរតនគីរី និងក្រុមហ៊ុន Veasna Investment Co,Ltd មានទីតាំងក្នុងស្រុកបរកែវ និងស្រុកអណ្ដូងមាស នៃខេត្តរតនគីរី ។ ជាមួយនោះ រួមមានការរុករកនិងធ្វើអាជីវកម្មរ៉ែលោហៈរបស់ក្រុមហ៊ុន Phu Yang (Cambodia) Co,Ltd ដែលមានទីតាំងនៅ ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី

- ពិគ្រោះយោបល់ផលប៉ះពាល់បរិស្ថាននិងសង្គមដំបូង លើគម្រោងសាងសង់កំពង់ផែអន្តរជាតិ នៃគម្រោងតំបន់វិស្សមកាលទេសចរណ៍មាត់សមុទ្ររបស់ក្រុមហ៊ុន Union Development Group Co,ltd ក្នុងស្រុកគីរីសាគរ ខេត្តកោះកុង និងលើគម្រោងវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម (ដូងប្រេង កៅស៊ូ ល្ហុងប្រេង)ក្នុងតំបន់ឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) ក្នុងស្រុកឈូក និងស្រុកជុំគីរី ខេត្តកំពត របស់ក្រុមហ៊ុន VIRUS GREEN PLANTATIONS (CAMBODIA) PTE,LTD.

- ចូលរួមកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្ដីពីការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើសុវត្ថិភាពស្បៀងក្នុងអាងទន្លេមេគង្គក្រោម និងវេទិកាគោលនយោបាយស្ដីពី ការលើកកំពស់ផលិតភាពវិស័យកសិកម្មនៅកម្ពុជា។ ទន្ទឹមនឹងនោះ កិច្ចប្រជុំថ្នាក់តំបន់ស្ដីពី Asia and the Pacific Regional High-level Consultation On Gender, Food Security and Nutrition

-ចូលរួមសិក្ខាសាលាស្ដីពី យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ឆ្នេរប្រកបដោយនិរន្តរភាពនៅកម្ពុជា សម្រាប់ផែនការ៥ឆ្នាំ និងលិខិតបទដ្ឋានគតិយុត្ត

- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការស្វែងយល់ទីផ្សារកាបូនិងប្រព័ន្ធតាមដាន និងការវាយតម្លៃថវិកាតាមកម្មវិធី

## ច- វាយតម្លៃនិងសន្និដ្ឋាន

ជារួមការងារផែនការនិងស្ថិតិ គឺជាសេនាធិការឱ្យក្រសួងក្នុងផ្នែកការងារគោលនយោបាយយុទ្ធសាស្ត្រ ផែនការសេដ្ឋកិច្ច និងវិនិយោគ។ ការងារវិភាគគោលនយោបាយយុទ្ធសាស្ត្រ និងការកសាងកម្មវិធី និងគម្រោងការងារនានា ជាបញ្ហាគន្លឹះ ដើម្បីសម្រេចបានជោគជ័យក្នុងវិស័យ។ ក្នុងឆ្នាំ២០១៣ ការងារក្នុងផ្នែកនេះ សម្រេចបានលទ្ធផលល្អប្រសើរជាងឆ្នាំកន្លងមក និងតាមផែនការដែលបានគ្រោងទុក។ ក៏ប៉ុន្តែជាមួយនឹងការខិតខំនេះ យើងក៏ជួបការប្រឈមនិងបញ្ហាខ្លះៗ ដូចជាៈ កង្វះធនធានមនុស្ស ដែលមានសមត្ថភាពបរិបូរណ៍ និងមធ្យោបាយសម្ភារធ្វើការ ដែលទាំងអស់នេះ ទាមទារឱ្យមានការជួយឧបត្ថម្ភគាំទ្រពីអ្នកពាក់ព័ន្ធ ដើម្បីជំរុញឱ្យការងារនេះ កាន់តែមានប្រសិទ្ធិភាពខ្ពស់ថែមទៀត។

## ឆ- វិធានការ

- ជំរុញការរៀបចំកសាងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ឱ្យស្របនឹង NSDP ២០១៤-២០១៨។

- បន្តខិតខំរៀបចំផែនការយុទ្ធសាស្ត្រថវិកា២០១៥-២០១៧ និហការរៀបចំអនុវត្តថវិកាកម្មវិធីពេញលេញសម្រាប់ឆ្នាំ ២០១៥ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

-បន្តកិច្ចសហការជាមួយស្ថាប័ន និងអង្គភាពពាក់ពន្ធ័ពិនិត្យដោះស្រាយទំនាស់ផ្សេងៗ ក្នុងតំបន់វិនិយោគសម្បទានដីសេដ្ឋកិច្ច ដែលមានគោលការណ៍ និងចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បន្តជំរុញឱ្យក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច គោរពតាមកិច្ចសន្យាផែនការមេនិងការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បន្តការសហការជាមួយអង្គភាពជំនាញ ដើម្បីពិនិត្យលើការយកថ្លៃសម្បទានពីក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ដែលដល់កំណត់ពេលត្រូវយកថ្លៃសម្បទាន

-បន្តជំរុញឱ្យក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ធ្វើ EIA និងចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋ ចំពោះក្រុមហ៊ុនណាដែលពុំបានធ្វើ

-បន្តធ្វើបច្ចុប្បន្នភាពលើការរៀបចំ ចងក្រង ប្រមូលព័ត៌មាន និងទិន្នន័យគម្រោង ដែលផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងត្រៀមលក្ខណៈចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

-បន្តជំរុញដំណើរការធ្វើអង្កេតកសិកម្មនិងអនុវត្តផែនការសកម្មភាពប្រមូលទិន្នន័យស្ថិតិកសិកម្មទូទាំងប្រទេស ដើម្បីវិភាគ ចងក្រងនិងផ្សព្វផ្សាយឲ្យបានកាន់តែទូលាយ

-បន្តជំរុញការអនុវត្តសេវាព័ត៌មានទីផ្សារកសិកម្មរាជធានី ខេត្ត ធ្វើការវិភាគកែច្នៃព័ត៌មានទីផ្សារកសិកម្មឱ្យកាន់តែល្អប្រសើរឡើង ដើម្បីចងក្រងព្រឹត្តិប័ត្រប្រចាំខែ ប្រចាំឆ្នាំ ជាមូលដ្ឋានសម្រាប់ផ្សព្វផ្សាយបន្តដល់ប្រជាកសិករនៅតាមជនបទ

-បន្តជំរុញការផ្សព្វផ្សាយព័ត៌មានទីផ្សារតាមរយៈគេហទំព័រ ទូរទស្សន៍ វិទ្យុ និងបោះពុម្ពខិត្តប័ណ្ណ និងពិនិត្យតាមដានការប្រមូលព័ត៌មានថ្លៃទីផ្សារនៅតាមរាជធានី ខេត្តនិងសិក្សាបញ្ហាទីផ្សារ ដែលធ្វើឱ្យមានឥទ្ធិពលដល់ការប្រែប្រួលតម្លៃរបស់ផលិតផល។

### ៥.៩.២-ការងារសហប្រតិបត្តិការអន្តរជាតិ

### ក- លទ្ធផល

### ក.១. ការគ្រប់គ្រងឯកសារនិងកិច្ចការទំនាក់ទំនង

- មុខការលិខិតចូល ២២១៧ ច្បាប់ ព្រមទាំងរៀបចំ និងបញ្ជូនលិខិតចេញបាន១២១៨ ច្បាប់

- បានទំនាក់ទំនង និងបំពេញបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រី ដើម្បីចូលរួមប្រជុំ សន្និសីទ វគ្គបណ្តុះបណ្តាល វេទិកាសិក្ខាសាលា និងទស្សនកិច្ចនៅបរទេស ចំនួន ៨៤៥ នាក់ ក្នុងនោះ ១៧០ នាក់ ទាក់ទងនឹងកិច្ចសហការជាមួយអង្គការអន្តរជាតិ ១១៥ នាក់ ទាក់ទង កិច្ចការអាស៊ាន និង ១៦០ នាក់ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការសហប្រតិបត្តិការទ្វេភាគី និងពហុភាគី

- បានសម្របសម្រួលការជួបពិភាក្សាការងាររវាងថ្នាក់ដឹកនាំ ជាមួយតំណាងស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា អំពីកិច្ចការសហ ប្រតិបត្តិការអភិវឌ្ឍន៍ និងវិនិយោគលើវិស័យកសិកម្ម

### ក.២. ការងារអាស៊ានកសិកម្ម

- បានសម្របសម្រួលជាមួយស្ថាប័នជំនាញក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យនិងផ្តល់យោបល់លើការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញក្រោមតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន+១ ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសេចក្តីព្រាងផែនការសកម្មភាព ដើម្បីអនុវត្តភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងអូស្ត្រាលីសម្រាប់រយៈពេល៥ ឆ្នាំ ២០១៤-២០១៨ ដោយបានបញ្ជូនទៅលេខាធិការអាស៊ាន

- បានសម្របសម្រួលជាមួយអង្គភាពជំនាញពាក់ពន្ធ័ ដើម្បីពិនិត្យ និងផ្តល់យោបល់លើ Reservation List ទាក់ទងនឹងពិធីសារ ស្តីពីវិសោធនកម្មលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ដោយបានបញ្ជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានសម្របសម្រួលជាមួយអង្គភាពជំនាញពាក់ពន្ធ័ ដើម្បីពិនិត្យនិងជំរុញការអនុវត្តកាតព្វកិច្ចនានារបស់កម្ពុជា ដែលមានចែង នៅក្នុងផែនការលម្អិតស្តីពីសហគមន៍សេដ្ឋកិច្ចអាស៊ាន

- បានសម្របសម្រួលរៀបចំសំណើសុំថវិកាចំនួន ៨៥.០០០ ដុល្លាអាមេរិក ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បង់វិភាគទាន ជូនលេខាធិការអាស៊ាន APTERR ប្រចាំឆ្នាំ២០១៣ ។

- បានសម្របសម្រួលទៅលេខាធិការអាស៊ាន APTERR ដើម្បីស្នើសុំអង្ករសម្រាប់ជួយប្រជាជន ដែលទទួលរងគ្រោះ ដោយធម្មជាតិចំនួន ៧០០ តោន ជាលទ្ធផលមិនបានទទួលចំនួនអង្ករតាមការស្នើសុំដោយសារពុំមានសល់នៅក្នុងស្តុករបស់ APTERR

- បានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំពាក់ពន្ធ័ នឹងកិច្ចការអាស៊ានកសិកម្ម នៅខេត្តសៀមរាប ៖

១- ថ្ងៃទី២៨ ខែឧសភា ដល់ថ្ងៃទី១ ខែមិថុនា ២០១៣ ៖ កិច្ចប្រជុំលើកទី ១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ានលើចំណីអាហារ ដែល មានប្រភពផលិតផលបម្រែបម្រួលហ្សែន ។

២-បានសម្របសម្រួលរៀបចំ Workshop II of the ASEAN-Australia Development Cooperation Programme (AADCP) ASEAN GAP Project នៅចាប់ពីថ្ងៃទី ២៩-៣០ ខែមេសា ឆ្នាំ ២០១៣ នៅកម្ពុជា ។

- បានរៀបចំលិខិតគោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ក្នុងគោលបំណងស្នើសុំគោលការណ៍ សិទ្ធិប្រទានសម្រាប់ចូលរួមកិច្ចប្រជុំលើកទី៣៥ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន ព្រមទាំងកិច្ចប្រជុំអមមួយចំនួន ផ្សេងៗ ទៀត និងធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំស្តីពីវិស័យកសិកម្ម និងព្រៃឈើអាស៊ានឆ្នាំ ២០១៤

ក- ឯកសារដែលត្រូវសុំសិទ្ធិប្រទានពីសម្តេច ដើម្បីចុះហត្ថលេខានៅក្នុងកិច្ចប្រជុំលើកទី៣៥ នៅប្រទេសម៉ាឡេស៊ីមានៈ

- អនុស្សារណៈនៃការយោគយល់គ្នារវាងរដ្ឋអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិនស្តីពី កិច្ចសហប្រតិបត្តិការស្បៀង និងកសិកម្ម ក្នុងនោះ **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រី**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះហត្ថលេខាលើឯកសារនេះ ។

ខ- ការធ្វើម្ចាស់ផ្ទះសម្រាប់រៀបចំកិច្ចប្រជុំអាស៊ានក្នុងឆ្នាំ២០១៣-២០១៤

- កិច្ចប្រជុំលើកទី១០ នៃក្រុមការងារបមាណីអាស៊ានស្តីពីផលិតផលសាកវប្បកម្ម និងកិច្ចប្រជុំពាក់ពន្ធ័
- កិច្ចប្រជុំលើកទី ១៦ នៃក្រុមការងារជំនាញការ និងលើកទី២១ នៃក្រុមការងារដំណាំអាស៊ាន
- កិច្ចប្រជុំលើកទី១៧ នៃឧត្តមមន្ត្រីព្រៃឈើអាស៊ាន និងកិច្ចប្រជុំពាក់ពន្ធ័
- ទស្សនកិច្ចផ្លាស់ប្តូរសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីសហគន៍កសិកម្មអាស៊ាន

## ក.៣. ការងារកសិ-ពាណិជ្ជកម្មពិភពលោក

- បានសម្របសម្រួលជាមួយអង្គភាពពាក់ពន្ធ័ក្រោមឳវាទក្រសួងរុក្ខាម្រាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្មក្នុងការកែសម្រួល និងបញ្ជូនឯកសារស្តីពី អជ្ញាប័ណ្ណនាំចេញ

- បានសម្របសម្រួលករណីសំណើពិនិត្យ និងផ្តល់យោបល់លើខ្លឹមសារកិច្ចព្រមព្រៀងស្តីពីការទិញ-លក់ ផ្លាស់ប្តូរទំនិញ និងសេវាពាណិជ្ជកម្មនៅតំបន់ព្រំដែន និងកិច្ចព្រមព្រៀងស្តីពី ទំនិញឆ្លងកាត់រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

- បានលើកគម្រោងស្នើសុំប្រើប្រាស់ថវិកាតាមកម្មវិធី P3 P4 ឆ្នាំ២០១៣

-បានលើកសំណើសុំគោលការណ៍រៀបចំវគ្គបណ្តុះបណ្តាលស្តីពី កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្មអនាម័យ និងភូតគាមអនាម័យ និងទីផ្សារកសិកម្មអន្តរជាតិ នៅខេត្តបាត់ដំបង និងខេត្តតាកែវ

-បានចូលរួមប្រជុំពិភាក្សាផ្តល់មតិលើសេចក្តីព្រាង Work Program of the RGC on WTO requirements and related issues នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ក.៤. ការងារសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល

- បានសម្របសម្រួលបំពេញបែបបទស្នើសុំកិច្ចអន្តរាគមន៍ផ្តល់ទិដ្ឋាការស្នាក់នៅដល់ទីប្រឹក្សា និងជំនាញការបរទេសព្រមទាំងស្លាកលេខរថយន្ត និងម៉ូតូមួយចំនួន

- បានពិនិត្យនិងសម្របសម្រួលបែបបទទាក់ទង នឹងការចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយអង្គការ HEKS POH KAO German Agro Action (GAA) និងអង្គការ FAO

- បានរៀបចំទិវាស្បៀងអាហារពិភពលោករបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ នៅវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានសម្របសម្រួលចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងរបស់អង្គការ ADRA, Wilfelife Alliance, FIDR នៅខេត្តកោះកុង ពោធិសាត់ និងកំពង់ឆ្នាំង។ ល។

- កិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយអង្គការក្រៅរដ្ឋាភិបាលឆ្នាំ២០១៣

| ល.រ | ឈ្មោះអង្គការ | ឈ្មោះគម្រោង | អនុវត្ត | ថវិកា |
|---|---|---|---|---|
| ១ | អង្គការអាល្លឺម៉ង់ប្រឆាំងគ្រោះអត់ឃ្លាន (GAA) | ពង្រឹងសម្លេងរបស់អង្គការកសិករលើកិច្ច ពិភាក្សាគោលនយោបាយស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅខេត្តរតនគីរី | 1-1-2013 31-12-2014 | Euro 457,870 |
| ២ | អង្គការ អាយ វីវ៉ាយ (IVY) | ការកាត់បន្ថយភាពក្រីក្រតាមជនបទ តាមរយៈការបង្កើតប្រពន្ធ័គ្រប់គ្រង ដែលមាននិរន្តភាពដល់សហគមន៍ផ្គត់ផ្គង់កសិផល ខេត្តស្វាយរៀង | 19-2-2013 18-2-2014 | USD 169,286 |
| ៣ | អង្គការជំនួយអភិវឌ្ឍន៍អាត់វែនទីស្ទកម្ពុជា (ADRA) | សន្តិសុខស្បៀងសម្រាប់ទាំងអស់គ្នា | 1-5-2013 31-10-2016 | USD 572,422 |
| ៤ | អង្គការដាណាអេស៊ា (DAna Asia) | មជ្ឈមណ្ឌលខ្មែរ-ជប៉ុនបណ្តុះបណ្តាលការ ចិញ្ចឹមមាន់ខ្មែរ | 1-2-2013 31-12-2015 | USD 210,000 |
| ៥ | អង្គការ School Aid Japan | កសិដ្ឋានបណ្តុះបណ្តាល School Aid Japan | 1-4-2013 31-3-2014 | USD 972,290 |

## ក.៨. ការសហប្រតិបត្តការទ្វេភាគី ពហុភាគី

- បានសម្របសម្រួល រៀបចំឯកសារ ស្នើសុំលិខិតឆ្លងដែនផ្លូវការចំនួន ៦០ ច្បាប់ ជូនថ្នាក់ដឹកនាំ និងមន្ត្រីក្រសួង

- បានរៀបចំឯកសារជំនួយស្មារតី ធ្វើកំណត់ហេតុ និងសម្រង់ពត៌មានអំពីជំនួបរវាងថ្នាក់ដឹកនាំជាមួយ អូស្រ្តាលី ជប៉ុន បារាំង បេឡារុស្ស សហរដ្ឋអាមេរិក កូវ៉ៃបី អាល្លឺម៉ង់ ចិន ថៃ អារ៉ាប៊ីសាអូឌីត ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធ មនុស្សប្រចាំកម្ពុជា ញូវហ្ស៊ីឡែន កូរ៉េ ឥណ្ឌា អង់គ្លេស កិច្ចប្រជុំកំពូលអាស៊ីប៉ូពាំ សឹង្ហបូរី ទីភ្នាក់ងារសហប្រតិបត្តិការ អន្តរជាតិនៃប្រទេសជប៉ុនJICA។ ល។

- បានចុះត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពគម្រោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយបណ្តាប្រទេសដៃគូ ដូចជា សាធារណរដ្ឋកូរ៉េ ចិន ជប៉ុន វៀតណាម នៅខេត្តប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម កំពង់ធំ

- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមប្រពន្ធ័ទិន្នន័យ(Database)

- រៀបចំលិខិតគោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី សំណើសុំសិទ្ធិប្រទាន ដើម្បីចុះហត្ថលេខាលើលិខិតប្តូរសារ ស្តីពីការផ្តល់ជំនួយជាកញ្ចប់នូវសម្ភារសម្រាប់វិស័យព្រៃឈើជូនដល់រាជរដ្ឋាភិបាលកម្ពុជា ពីរដ្ឋា ភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

- បានសម្របសម្រួលការចុះហត្ថលេខាលើសហប្រតិបត្តិការជាមួយប្រទេសជាមិត្តនិងដៃគូអភិវឌ្ឍ។

| ល.រ | អនុស្សារណនៃការយោគយល់គ្នា | ជាមួយប្រទេស | ថវិកា | ចុះហត្ថលេខា |
|---|---|---|---|---|
| ១ | Exchange of Notes on Aid of the Batch of Forestry Equipment given by the Government of the People"s Republic of China to the Royal Government of Cambodia | China | RMB 4,100,OOO | Sep.4.2013 |
| ២ | The Multi-Year Training Program on the Fisheries Process and Hazard Analysis Control Point Program Capacity Building | KOICA-Korea | | 1-Nov-2013 |
| ៣ | MOU of Cooperation on Agricultural between | China | | 28-Feb-2014 |

| | | | | |
|---|---|---|---|---|
| | Kg.Cham Province of Kingdom of Cambodia and Hinan Provinceof China | | | |
| ១ | Ageement of Project on Joint Research /Survey for the Kingdom of Cambodia Development of Agricultural Technolocy and Extension System | KREI-Korea | 9,000 $ | June 2013 |
| ២ | Record og Discussions on Project for Establishing é Oriented Agricultural Cooperative Model | Jica-Japan | | 23 Dece 2013 |
| ៣ | Project Docement on China-Cambodia-UNDP Trilateval Cooperation Cassava Project | China-UNDP-Cambodia | 400,000$ | 21 May 2013 |

## ខ- ការវាយតម្លៃនិងសន្និដ្ឋាន

ក្នុងនាមឬឋានៈជាអង្គភាពសម្របសម្រួលនិងទំនាក់ទំនងអន្តរជាតិ ថ្នាក់ដឹកនាំនិងមន្ត្រីនៃនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់អនុវត្ត ព្រមទាំងដោះស្រាយយ៉ាងអស់លទ្ធភាព ដែលជាហេតុធ្វើឱ្យសម្រេចបានស្នាដៃ និងលទ្ធផលល្អជាច្រើន គួរឱ្យកត់សម្គាល់ខាងលើ។ ជាក់ស្តែងនៅឆ្នាំ២០១៣កន្លងមកនេះ ក្រសួងបានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងកម្មវិធី ជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងក្របខណ្ឌទ្វេភាគី-ពហុភាគី និងអាស៊ាន និងអនុស្សារណៈនៃការយោគយល់គ្នាព្រម ទាំងពិធីសារនានា ។

ទន្ទឹមនឹងនោះ ការងារនេះបានជួបប្រទះបញ្ហាជាច្រើនក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ពិសេសគឺការគ្រប់គ្រងនិងសម្របសម្រួលសកម្មភាពដែលដំណើរការក្រោមឥណទានជំនួយនៅមានកម្រិត។ ដូចនេះដើម្បីអនុវត្តភារកិច្ចនេះឱ្យបានរលូន និងមានប្រសិទ្ធ ភាពខ្ពស់ សូមឱ្យមានកិច្ចសហការគាំទ្រពីអង្គភាពពាក់ពន្ធ័ និងមានការលើកទឹកចិត្តលើការងារនេះ។

## គ- ទិសដៅនិងវិធានការ

នៅក្នុងឆ្នាំ២០១៤ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នឹងសហការជាមួយអង្គភាពជំនាញក្នុងការ រៀបចំកិច្ចប្រជុំក្រុមការងារ អាស៊ានចំនួន ៤ នៅខេត្តសៀមរាប គឺ ÷

- កិច្ចប្រជុំលើកទី១០ នៃក្រុមការងារបមាណីអាស៊ានស្តីពីផលិតផលសាកវប្បកម្ម និងកិច្ចប្រជុំពាក់ពន្ធ័ នៅថ្ងៃទី៣១ ខែមីនាដល់ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤

- កិច្ចប្រជុំលើកទី១៦ នៃក្រុមការងារជំនាញការនិងលើកទី២១ នៃក្រុមការងារដំណាំអាស៊ាន នៅថ្ងៃទី៩-១៣ ខែមិថុនា ឆ្នាំ២០១៤

- កិច្ចប្រជុំលើកទី១៧ នៃឧត្តមមន្ត្រីព្រៃឈើអាស៊ាននិងកិច្ចប្រជុំពាក់ពន្ធ័ នៅថ្ងៃទី ២៣-២៧ ខែ មិថុនា ឆ្នាំ២០១៤

- ទស្សនកិច្ចផ្លាស់ប្តូរសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីសហគន៍កសិកម្មអាស៊ាន នៅខែវិច្ឆិកា ឆ្នាំ២០១៤

- បន្តការយកចិត្តទុកដាក់ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ព្រមទាំងប្រទេសជាមិត្តនានា ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម សំដៅរួមចំណែកអនុវត្តគោលនយោបាយកាបន្ថយភាពក្រីក្រ និងជំរុញបង្កើនផលិតកម្ម ស្រូវនិងនាំចេញអង្ករបស់រាជរដ្ឋាភិបាល

- បន្តកិច្ចសហការជាមួយស្ថាប័នអង្គភាពពាក់ពន្ធ័ ពិនិត្យ តាមដាន និងវាយតម្លៃ លើការអនុវត្តខ្លឹមសារអនុស្សារណៈពិធីសារ អនុសញ្ញា និងកិច្ចព្រមព្រៀងផ្សេងៗ ដែលបានចុះហត្ថលេខារួចហើយ ។

**- ត្រៀមសម្របសម្រួលចុះហត្ថលេខាលើឯកសារស្តីពីកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាមិត្តនិងដៃគូអភិវឌ្ឍដូចជា ÷**

| ល.រ | សេចក្តីព្រាង MOU | ជាមួយប្រទេស |
|---|---|---|
| ១ | សេចក្តីព្រាង MOU ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងពាណិជ្ជកម្ម រវាងកម្ពុជា- ហ្វីលីពីន | ហ្វីលីពីន |
| ២ | សេចក្តីព្រាង MOU ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម រវាង កម្ពុជា- បេឡារូស | បេឡារូស |
| ៣ | សេចក្តីព្រាង MOU ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម រវាងកម្ពុជា- ម៉ិចស៊ិកូ | ម៉ិចស៊ិកូ |
| ៤ | សេចក្តីព្រាង MOU ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម រវាងកម្ពុជា- អារ៉ាប៊ីសាអូឌីត | អារ៉ាប៊ីសាអូឌីត |
| ៥ | សេចក្តីព្រាង MOU ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងចិញ្ចឹមសត្វ រវាងកម្ពុជា- អេមីរ៉ាតអារ៉ាប់រួម | អេមីរ៉ាតអារ៉ាប់រួម |
| ៦ | សេចក្តីព្រាង MOU ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម រវាងកម្ពុជា- ឥណ្ឌូនេស៊ី | ឥណ្ឌូនេស៊ី |
| ៧ | សេចក្តីព្រាង MOU ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម រវាងកម្ពុជា- បង់ក្លាដេស | បង់ក្លាដេស |

- បន្តការយកចិត្តទុកដាក់ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ព្រមទាំងប្រទេសជាមិត្តនានា ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម សំដៅរួមចំណែកអនុវត្តគោលនយោបាយកការបន្ថយភាពក្រីក្រ និងជំរុញបង្កើនផលិតកម្មស្រូវ និងនាំចេញអង្ករបស់រាជរដ្ឋាភិបាល

-បន្តកិច្ចសហការជាមួយស្ថាប័ន អង្គភាពពាក់ពន្ធ័ ពិនិត្យ តាមដាន និងវាយតម្លៃ លើការអនុវត្តខ្លឹមសារអនុស្សារណៈ ពិធីសារ អនុសញ្ញា និងកិច្ចព្រមព្រៀងផ្សេងៗដែលបានចុះហត្ថលេខារួចហើយ

**- បានសម្របសម្រួលត្រៀមចុះហត្ថលេខាលើសហប្រតិបត្តិការជាមួយប្រទេសជាមិត្តនិងដៃគូអភិវឌ្ឍ ។**

## ៥.៤.៣-ការងារកិច្ចការរដ្ឋបាល

### ក. លទ្ធផល

ក្នុងឆ្នាំ២០១៣ ដោយអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងទិសដៅការងាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញតួនាទីយ៉ាងសកម្មលើការងារៀបចំនិងចរាចរឯកសារផ្សព្វផ្សាយច្បាប់គោលការណ៍ផ្សេងៗ÷

### ក.១. ផ្នែករៀបចំទទួលលិខិតចូលនិងចរាចរឯកសារ

- ទទួលពីស្ថាប័ននានា សរុបចំនួន៥. ៣១៧ច្បាប់
-ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន៤.១៦៩ច្បាប់
-ទទួលពីរាជធានី ខេត្ត សរុបចំនួន ១.១៧៨ច្បាប់

### ក.២ ផ្នែកចុះលិខិតចេញ

-បញ្ជូនទៅក្រសួងស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទរាជធានី ខេត្តសរុបចំនួន៩. ៣៣៩ច្បាប់
-សេចក្តីសម្រេចនិងប្រកាស សរុបចំនួន ៥៦១ ច្បាប់
-ថតចម្លងនិងបែងចែងតាមអង្គភាពក្រោមឱវាទ សរុបចំនួន ៧៣៥ ច្បាប់
-បញ្ជូនលិខិតបទដ្ឋានចុះក្នុងរាជកិច្ច សរុបចំនួន ១០ ច្បាប់

### ក.៣-ការងារសន្តិសុខ អនុវត្តបានល្អប្រសើរ

-ភ្ញៀវមកពីអង្គភាពក្រោមឱវាទ សរុបចំនួន ២.៥២០នាក់
-ភ្ញៀវមកពីអន្តរក្រសួង សរុបចំនួន ២៥០នាក់
-ភ្ញៀវមកពី រាជធានី ខេត្ត សរុបចំនួន ២១៤នាក់
-ភ្ញៀវជាអតិថិជន សរុបចំនួន ២.៩៣៤នាក់
-ភ្ញៀវអន្តរជាតិ សរុបចំនួន ៤០០នាក់

### ខ. វាយតម្លៃនិងសំណើ

ជារួមការងារកិច្ចការរដ្ឋបាល បានដំណើរការប្រព្រឹត្តទៅយ៉ាងរលូន ដោយសារការខិតខំប្រឹងប្រែងយកចិត្តទុកដាក់របស់មន្ត្រីគ្រប់លំដាប់ថ្នាក់ ដែលជំរុញឲ្យការងារប្រកបដោយប្រសិទ្ធភាពល្អប្រសើរ ។ ទន្ទឹមនឹងនោះ នៅមានកង្វះខាតក្នុងស្ថានភាពការងារនិងធនធានមនុស្សមានកម្រិត ខ្វះខាតឧបករណ៍និងសម្ភារៈបម្រើការងារ។

### គ. វិធានការ

- បណ្តុះបណ្តាលធនធានមនុស្សនៃការកែទម្រង់ ទាំងផ្នែករដ្ឋបាល ផ្នែកជំនាញ និងភាសាបរទេស
- បន្តពង្រឹងប្រសិទ្ធភាពការងាររដ្ឋបាល និងការងារគ្រប់គ្រង និងបែងចែកបញ្ជូនលិខិតស្នាមតាមបែបបទរដ្ឋបាលឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងការរៀបចំប្លូកសរុបលិខិតបទដ្ឋានក្រោមឱវាទផ្ញើមក ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច។

## ៥.៤.៤-ការងារនីតិកម្មកសិកម្ម

ក្នុងឆ្នាំ ២០១៣ នេះ ការងារនីតិកម្មកសិកម្ម បានផ្តោតលើសកម្មភាពដូចខាងក្រោម ÷

-ពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មសម្ភារកសិកម្ម តាមរយៈការត្រួតពិនិត្យនៅពេលនាំចូលចែកចាយនិងតាមដានត្រួតពិនិត្យជាប្រចាំ ដល់សកម្មភាពធ្វើអាជីវកម្មលក់ដុំ លក់រាយសម្ភារកសិកម្មនៅគ្រប់មូលដ្ឋានរាជធានី ខេត្ត

-ពង្រឹងយន្តការគ្រប់គ្រងសម្ភារកសិកម្មនីតិកម្មកសិកម្មរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្តច្បាប់ ការលើកកំពស់ប្រសិទ្ធភាពការគ្រប់គ្រង និងអនុវត្តកម្មវិធីផ្សព្វផ្សាយដល់គ្រប់មូលដ្ឋានរាជធានី ខេត្ត នូវការយល់ដឹងផ្នែក បច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

### ក-លទ្ធផល

### ក.១-ការងារអាជីវកម្មសម្ភារកសិកម្ម

**-ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្ម** ជូន**១១៦**ក្រុមហ៊ុនសរុបចំនួន**១.៣៨៩**មុខ រួមមាន÷ (១).ជីកសិកម្ម **៤២២**មុខ (២).ថ្នាំកសិកម្ម**៥៥២**មុខ (៣).ចំណីសត្វ **២១៦**មុខ (៤).បសុឱសថ **១៨៦**មុខ និង(៥).គ្រាប់ពូជ **១៣**មុខ

**-ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្ម**ជូន**១២០**ក្រុមហ៊ុន ត្រូវជា**១៤៧**ករណីនាំចូល ក្នុងនោះ (១).ជីកសិកម្ម **៨៦៥.៤៧៩**តោន (២).ថ្នាំកសិកម្ម**១៤.៩៣៧**តោន (៣).ចំណីសត្វ-ចំណីបន្ថែម**១៥៣.៤៥៨**តោននិងវត្ថុធាតុដើមផលិតចំណីសត្វ **២០៦.២៦០**តោន និងចេញ**លិខិតអនុញ្ញាតនាំចេញ**ចំណីសត្វ**១០,០០០តោន** (៤).បសុឱសថ**២.១០៩**តោននិងបរិក្ខាបសុពេទ្យ **១៧៦**មុខ(៥).ពូជដំណាំ**២.១០០**តោន និង(៦).វត្ថុធាតុដើមផលិតស្រាបៀរ **៣៤៨**តោន

**-ផ្តល់លិខិតអនុញ្ញាតផ្សេងទៀត**រួមមាន÷ (១).លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្ម១៥ក្រុមហ៊ុន (២).វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មនិងថ្នាំកសិកម្ម១៧ក្រុមហ៊ុន ក្នុងនោះ ឃ្លាំងថ្នាំកសិកម្មចំនួន៣ ឃ្លាំងជីកសិកម្មចំនួន១១ និងឃ្លាំងថ្នាំនិងជីកសិកម្មចំនួន៣ក្រុមហ៊ុន(៣).លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មនិងជីកសិកម្ម១៦ក្រុមហ៊ុន ក្នុងនោះ ជីកសិកម្ម១៣ក្រុមហ៊ុន និងថ្នាំកសិកម្ម៤ក្រុមហ៊ុន(៤)-លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីជីកសិកម្ម១ក្រុមហ៊ុន។

**-ការងារបន្ទប់ពិសោធន៍គុណភាពជីកសិកម្ម** បានធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្ម ដែលស្នើសុំចុះបញ្ជិកាបានចំនួន៣៨៧សំណាកក្នុងនោះ បានរកឃើញសារធាតុលោហៈធ្ងន់លើសបមាណីយកំណត់ចំនួន**១៥**សំណាកជីកសិកម្ម

-**មូលដ្ឋានអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្ម**នៅតាមបណ្តាខេត្ត រាជធានី មានចំនួន**៥.២៨៤**កន្លែង ក្នុងនោះ មូលដ្ឋានមានលិខិតអនុញ្ញាតមានចំនួន**៤១១២**កន្លែង ស្មើនឹង**៨០%** និងមូលដ្ឋានគ្មានលិខិតអនុញ្ញាតមានចំនួន**១.០៥៩**កន្លែង ស្មើនឹង**២០%**។

## ក.២- ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

-អភិវឌ្ឍន៍បទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម÷ (១).បទដ្ឋានគតិយុត្តដែលបានសម្រេចជាផ្លូវការមានដូចជា ប្រកាសរបស់ក្រសួងចំនួន**០៣** និងប្រកាសអន្តរក្រសួងចំនួន**០១**(២).បទដ្ឋានគតិយុត្តដែលបានរៀបចំនិងកំពុងឆ្លងដំណើការពិនិត្យសម្រេចរួមមាន សេចក្តីព្រាងប្រកាសរបស់ក្រសួងចំនួន**០៣** និងសេចក្តីព្រាងប្រកាសរួមចំនួន**០១**

-ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានចូលជាធរមាន ព្រះរាជាណាចក្រកម្ពុជាត្រូវបានយល់ព្រមឲ្យចូលរួមជាសមាជិកទី**១៥១** នៃ**អនុសញ្ញារ៉ូថឺដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ**” នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣។ បច្ចុប្បន្ននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញតួនាទីជាអាជ្ញាធរជាតិនៅក្នុងការអនុវត្តអនុសញ្ញា ដោយបានបង្កើតលេខាធិការដ្ឋានអនុវត្តអនុសញ្ញានេះ តាមរយៈសេចក្តីសម្រេចលេខ០៥៦សសរ.កសក.ប ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពី **ការបង្កើតអាជ្ញាធរជាតិនិងលេខាធិការដ្ឋានអនុវត្តអនុសញ្ញារ៉ូថឺដាម**

-ការអនុវត្តកម្មវិធីនីតិកម្មឆ្នាំ២០១៣ របស់អង្គភាពផ្នែកនីតិកម្មកសិកម្ម ក៏បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍបទដ្ឋានគតិយុត្ត ដែលជាកម្មវិធីនីតិកម្មវិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងក្របខ័ណ្ឌសុវត្ថិភាពស្បៀងនិងការអភិវឌ្ឍផលិតកម្មកសិកម្ម រួមមាន÷ ច្បាប់ស្តីពីសហគមន៍កសិកម្ម សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងជីកសិកម្ម សេចក្តីព្រាងច្បាប់ស្តីពីគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ សេចក្តីព្រាងច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះព្រៃឈើ ព្រមទាំងបទដ្ឋានក្រោមច្បាប់រួមមានបណ្តាអនុក្រឹត្យ ប្រកាស ប្រកាសរួម និងបទបញ្ជាផ្សេងទៀត ព្រមទាំងបទដ្ឋានគតិយុត្តអន្តរក្រសួងពាក់ព័ន្ធមួយចំនួនក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិថែមទៀត។

## ក.៣- ការងារផ្សព្វផ្សាយអប់រំនិងលើកកម្ពស់ការយល់ដឹង

-ផ្នែកនីតិកម្មកសិកម្មបានអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹង ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនិងការប្រើប្រាស់សម្ភារកសិកម្ម នៅក្នុងខេត្តគោលដៅបានចំនួន១១ខេត្ត មានអាជីវករចូលរួមសរុបចំនួន៧១៩នាក់

-មន្ទីរកសិកម្មរាជធានី ខេត្ត បានសហការជាមួយថ្នាក់កណ្តាលអនុវត្តកម្មវិធីវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដល់អាជីវករសម្ភារកសិកម្មក្នុងឆ្នាំ២០១៣កន្លងមកបានចំនួន០៧ខេត្ត ត្រូវជា០៨វគ្គ បានផ្តល់វិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គដល់អាជីវករចំនួន៧៨៨នាក់។ សរុបពីឆ្នាំ២០១០ដល់២០១៣ បានបណ្តុះបណ្តាលអាជីវករសរុបចំនួន៦.២០៤នាក់

-ផ្នែកនីតិកម្មកសិកម្មរាជធានី ខេត្ត បានអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម និងការប្រើប្រាស់សម្ភារកសិកម្មបានចំនួន២១៣លើក គ្របដណ្តប់លើឃុំចំនួន២១៤ឃុំ និង១១៦ស្រុក ដោយមានអ្នកចូលរួមសរុប១០.៨៦៣នាក់។

## ក.៤- ការងារត្រួតពិនិត្យនិងអនុវត្តច្បាប់

-នីតិកម្មកសិកម្មបានត្រួតពិនិត្យការនាំចូលសម្ភារកសិកម្មចំនួន១៣៧ករណី ដែលអនុវត្តដោយ១០៩ក្រុមហ៊ុន ក្នុងនោះបានដាក់វិធានការចេញលិខិតព្រមានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះ១២ក្រុមហ៊ុន និង១៨ក្រុមហ៊ុនទៀតសម្រេចធ្វើការណែនាំ និងកែតម្រូវការអនុវត្តស្របតាមច្បាប់ជាធរមាន

-នីតិកម្មកសិកម្មនិងការិយាល័យនីតិកម្មកសិកម្មនៃមន្ទីរកសិកម្មរាជធានី ខេត្ត បានត្រួតពិនិត្យដេប៉ូលក់ដុំលក់រាយសម្ភារកសិកម្មចំនួន២.៣៦៥ដេប៉ូ និងបានចាត់វិធានការ ÷ (១).ចេញលិខិតព្រមានដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៧២ករណី និងចេញលិខិតព្រមានដោយមន្ទីរកសិកម្មចំនួន៨៥ករណី (២).កែតម្រូវផ្ទាល់មាត់ចំនួន១០៨ករណី និងធ្វើកិច្ចសន្យាកែតម្រូវ និងបញ្ឈប់បទល្មើសចំនួន៤៤៩ករណី (៣).ដកហូតលិខិតអនុញ្ញាតលក់ដុំលក់រាយចំនួន០១ករណី (៤).កសាងសំណុំរឿងបញ្ជូនទៅតុលាការចំនួន ២២ករណី។

## ក.៨- ចំណូលនិងចំណាយថវិការដ្ឋ និងគម្រោងសហប្រតិបត្តិការ

- ចំណូលថវិកាពីសេវាសាធារណៈក្នុងពាណិជ្ជកម្មសម្ភារកសិកម្មរួមមាន÷ ប្រមូលប្រាក់ចំណូលពីសេវាសាធារណៈក្នុងប្រតិបត្តិការពាណិជ្ជកម្មសម្ភារកសិកម្មសរុបចំនួន៣៧៦.៩៥០.០០០រៀល ក្នុងនោះ បានបង់ចូលថវិការដ្ឋបានចំនួន ២០៨.២៤៥.០០០រៀល ប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន១៦៤.៩៣៥.៥០០រៀល និងប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៣.៧៦៩.៥០០រៀល

- ចំណាយថវិការដ្ឋតាមកម្មវិធី P3-P4 រួមមាន÷ ផែនការចំណាយថវិកាចំនួន១២៩.០០០.០០០ រៀល ក្នុងនោះ បានចំណាយថវិកាជាក់ស្តែង ចំនួន៩៨.២១៨.០០០រៀល។

## ខ- វាយតម្លៃនិងសំណើ

-ការអនុវត្តច្បាប់ក្នុងសកម្មភាពពាណិជ្ជកម្មសម្ភារកសិកម្ម ត្រូវបានលើកកម្ពស់ និងមានការកើនឡើងនូវចំនួនក្រុមហ៊ុនដែលស្នើសុំចុះបញ្ជិកាប្រភេទសម្ភារកសិកម្ម និងស្នើសុំនាំចូលសម្ភារកសិកម្ម (ជីកសិកម្មនិងថ្នាំកសិកម្ម) ដែលមានបរិមាណកើនឡើងក្នុងកម្រិតពី២០%-៤០% ខ្ពស់ជាងឆ្នាំ២០១២

-ការអនុវត្តនីតិវិធីថ្មី និងការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅតាមបណ្តាស្រុក ក្រុង ខណ្ឌ នៅមិនទាន់មានសមត្ថភាពអនុវត្ត ដែលធានាភាពរលូនបន្តពីការធ្វើប្រតិភូកម្មរបស់ក្រសួងនិងមន្ទីរកសិកម្មឡើយ ដែលជាមូលហេតុធ្វើឲ្យអាជីវករមួយចំនួន មិនអាចស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយសម្ភារកសិកម្មបាន និងជាមូលហេតុធ្វើឲ្យដេប៉ូលក់ដុំលក់រាយសម្ភារកសិកម្មតាមបណ្តាខេត្ត រាជធានី ជួបបញ្ហាស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយ

-អង្គភាពនីតិកម្មកសិកម្មទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នៅខ្វះការពង្រឹងសមត្ថភាព ទាំងធនធានមនុស្ស គុណវុឌ្ឍិការងារ និងមធ្យោបាយសម្ភារ ថវិកា សម្រាប់បំពេញភារកិច្ច

-ការយល់ដឹងរបស់ពាណិជ្ជករ អាជីវករសម្ភារកសិកម្ម និងកសិករប្រើប្រាស់សម្ភារកសិកម្មនៅមានកម្រិត ដែលជាបញ្ហាលំបាកនៅក្នុងការគ្រប់គ្រង រួមជាមួយកង្វះការចូលរួមពីអាជ្ញាធរនិងសមត្ថកិច្ចពាក់ព័ន្ធគឺ ជាបញ្ហាប្រឈមខាងក្រៅ ដែលធ្វើឲ្យការអនុវត្តច្បាប់មិនទាន់មានប្រសិទ្ធភាព។

## គ- ទិសដៅការ

-បន្តសិក្សារៀបចំបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម សម្រាប់កម្មវិធីនីតិកម្មឆ្នាំ២០១៤ និងជំរុញការពិនិត្យសម្រេចនូវសេចក្តីព្រាងបទដ្ឋានគតិយុត្ត ដែលបានសិក្សារៀបចំរួចក្នុងឆ្នាំ២០១៣កន្លងមក

-ជំរុញការចូលរួមនិងការអភិវឌ្ឍបទដ្ឋានគតិយុត្តវិស័យកសិកម្ម ជាពិសេសសេចក្តីព្រាងច្បាប់សំខាន់ៗយចំនួនក្នុងក្របខណ្ឌសុវត្ថិភាពស្បៀង

-បន្តអនុវត្តនីតិវិធីនិងពង្រឹងសមត្ថភាពក្នុងការអនុវត្តអនុសញ្ញារ៉ូថឺដាមស្តីពី នីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ

-ពង្រឹងសមត្ថភាពរបស់មន្ត្រីអង្គភាពនីតិកម្មកសិកម្ម ក្នុងការបំពេញតួនាទីជាមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ ក្នុងការត្រួតពិនិត្យបទល្មើសនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន

-លើកកម្ពស់សមត្ថភាពអនុវត្តនីតិវិធីធ្វើអធិការកិច្ចនិងការអនុវត្តច្បាប់ ចំពោះសកម្មភាពពាណិជ្ជកម្មគ្រប់រូបភាពនៅរាជធានី ខេត្តទូទាំងប្រទេស លើកកម្ពស់ប្រសិទ្ធភាពក្នុងការត្រួតពិនិត្យដើមគ្រា លើសម្ភារកសិកម្មដែលធ្វើការនាំចូលនៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ និងយកចិត្តទុកដាក់ត្រួតពិនិត្យបទល្មើសនៅតាមបណ្តាខេត្ត ដែលមានច្រកព្រំដែន

-ត្រូវពង្រឹងការត្រួតពិនិត្យនិងការអនុវត្តច្បាប់ លើការនាំចូលថ្នាំកសិកម្មនិងជីកសិកម្ម សម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ការប្រើប្រាស់ផ្ទាល់នៅកសិដ្ឋានរដ្ឋឬឯកជន និងដីសម្បទានសេដ្ឋកិច្ចវិនិយោគដំណាំកសិឧស្សាហកម្ម

-បន្តអនុវត្តកម្មវិធីផ្សព្វផ្សាយថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាននូវច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដោយយកចិត្តទុកដាក់ចំពោះខេត្តគោលដៅ និងស្រុក ក្រុង ចំណុះខេត្តគោលដៅ

-ជំរុញការអនុវត្តនីតិវិធីក្នុងការផ្សាយពាណិជ្ជកម្មគ្រប់រូបភាពអំពី សម្ភារកសិកម្មរបស់ផ្នែកឯកជន ជាពិសេសការផ្សាយពាណិជ្ជកម្មថ្នាំកសិកម្មនិងជីកសិកម្ម ដែលត្រូវអនុវត្តតាមច្បាប់ជាធរមាន

-បន្តពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ ការងារគ្រប់គ្រងទិន្នន័យ រួមមានទិន្នន័យបច្ចេកទេសនៃប្រភេទសម្ភារកសិកម្មដែលបានចុះបញ្ជិកា ទិន្នន័យក្នុងសកម្មភាពពាណិជ្ជកម្មសម្ភារកសិកម្ម និងទិន្នន័យក្នុងប្រតិបត្តិការអនុវត្តច្បាប់។

### ៥.៤.៥-ការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង

### ក-ការងារអធិការកិច្ច

### ក.១. សកម្មភាពការងារ

- ចុះត្រួតពិនិត្យស្រាវជ្រាវការងារគ្រប់គ្រងរបស់ផ្នែករដ្ឋបាលជលផលអង្គរបុរី និងផ្នែករដ្ឋបាលជលផលបូរីជលសារ និងពិនិត្យការងារដឹកនាំ និងគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលជលផលព្រៃវែង

- ចុះត្រួតពិនិត្យស្រាវជ្រាវការងារគ្រប់គ្រងនិងការប្រើប្រាស់ថវិការដ្ឋនៅស្ថានីយផលិតពូជត្រីទី១និងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប ជាមួយការចុះត្រួតពិនិត្យលើការងារគ្រប់គ្រងវិស័យផលិតកម្ម និងបសុពេទ្យបាល ខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ

- ចុះអនុវត្តតាមខ្លឹមសារ នៃលិខិតលេខ០៦៧/១២ ទ.រ.ព.អ.ស.ជ.ណ ចុះថ្ងៃទី១៤ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី

- ចុះត្រួតពិនិត្យលើការងារគ្រប់គ្រងវិស័យផលិតកម្ម និងបសុពេទ្យបាល នៅខេត្តព្រៃវែង ស្វាយរៀង និងខេត្តតាកែវ

- ចុះពិនិត្យការអនុវត្តគម្រោងបង្កើនផលិតភាពស្បៀង សម្រាប់កសិករក្រីក្រតាមជនបទក្រោមជំនួយឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន(2KR 2011 ) នៅខេត្តបាត់ដំបង និងត្រួតពិនិត្យស្រាវជ្រាវការដឹកនាំគ្រប់គ្រង របស់មន្ទីរកសិកម្មរាជធានីភ្នំពេញនិងការិយាល័យចំណុះមន្ទីរកសិកម្ម

- ចូលរួមពិធីផ្សព្វផ្សាយសេចក្តីសម្រេចស្តីពី របៀបរបបការងារនិងបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាណត្តិទី ៥ និងចូលរួមប្រកាសចូលកាន់តំណែងជានាយខណ្ឌ និងនាយរងខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ

- ចុះត្រួតពិនិត្យការដឹកនាំគ្រប់គ្រង របស់មន្ទីរកសិកម្មខេត្តកំពង់ឆ្នាំងនិងការិយាល័យក្រោមឱវាទ និងចូលរួមក្នុងគណៈកម្មការសម្រាប់ប្រឡងប្រជែងជ្រើសរើស ចូលក្របខ័ណ្ឌក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការនាំចេញ និងកិច្ចព្រមព្រៀងស្តីពីកសិកម្ម និងកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ ( SPS ) ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ។

### ក.២- លទ្ធផលការងារ

**១-** ក្រសួងបានសម្រេចឱ្យរដ្ឋបាលជលផល រៀបចំបែបបទស្នើសុំស្ថាប័នមានសមត្ថកិច្ច ដើម្បីចុះបញ្ជីទីតាំងថ្មី និងសម្ភារករណីលិខិតអនាមិកប្តឹងស្ថានីយផលិតពូជត្រីទី១ ដែលរំលោភលើសេចក្តីទុកចិត្តចំពោះរឿងផ្ចិតមេដៃ ក្នុងការគាំទ្រនូវការដោះដូរទីតាំងស្ថានីយ ទាំងអស់ក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋស្របតាមច្បាប់ និងធ្វើប្លង់កម្មសិទ្ធិឱ្យបានច្បាស់លាស់ងាយស្រួលគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ជៀសវាងការចូលរំលោភកាន់កាប់ពីអ្នកផ្សេងទៅថ្ងៃក្រោយ

**២-** តាមរយៈលិខិតលេខ៩៤៩កសកចុះថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០១៣ ក្រសួងសម្រេចឱ្យរដ្ឋបាលជលផលអនុវត្តដូចខាងក្រោម÷

- រដ្ឋបាលជលផលនិងខណ្ឌរដ្ឋបាលជលផលព្រៃវែង ត្រូវយកចិត្តទុកដាក់ ជាពិសេសពង្រឹងសមត្ថភាពសហគមន៍នេសាទទាំងសហគមន៍នេសាទចាស់ និងសហគមន៍នេសាទដែលទើបបានបង្កើតថ្មីអំពីៈ ក្របខ័ណ្ឌច្បាប់ តួនាទីភារកិច្ច គោលការណ៍របស់សហគមន៍ ទិសដៅនិងបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលក្នុងការលុបឡូត៍នេសាទ ហើយបង្កើតជាសហគមន៍នេសាទឡើង

- ត្រូវចុះសិក្សាអំពីឧបករណ៍ទំហំ ប្រវែង និងទីតាំងឱ្យបានច្បាស់លាស់ នៅតាមអតីតឡូត៍នេសាទ ដែលស្ថិតនៅតាម

បណ្ដាខេត្តជាប់ព្រំដែនវៀតណាមដែលរាជរដ្ឋាភិបាលអនុញ្ញាតឱ្យដាក់របាំងធ្នស់ចាប់ត្រី និងត្រូវមានយន្តការតាមដានត្រួតពិនិត្យការអនុវត្តរបស់សហគមន៍ ដើម្បីធានាឱ្យបានថា សហគមន៍បានអនុវត្តន៍បោះរបាំងធ្នស់ចាប់ត្រីដោយខ្លួនឯង ហើយត្រឹមត្រូវតាមប្រភេទឧបករណ៍ ទំហំ ប្រវែង និងទីតាំង ដែលរដ្ឋបាលជលផលបានសិក្សា និងកំណត់ឱ្យប្រើប្រាស់

- ត្រូវត្រួតពិនិត្យឡើងវិញលើការធ្វើអាជីវកម្មអតីតឡូត៍នេសាទលេខ ៧ របស់សហព័ន្ធសហគមន៍នេសាទបាបោងអំពីបទដ្ឋានច្បាប់ បទដ្ឋានបច្ចេកទេស សកម្មភាពអាជីវកម្ម ការបែងចែកផលប្រយោជន៍ ការអនុវត្តកាតព្វកិច្ចក្នុងការកែលម្អ និងអភិវឌ្ឍន៍ តើបានត្រឹមត្រូវតាមកិច្ចសន្យាកែលម្អ និងអភិវឌ្ឍន៍ គោលការណ៍សហគមន៍ និងតាមខ្លឹមសារនៃសេចក្ដីសម្រេចរបស់ក្រសួង ពិសេសលិខិតលេខ ៧១១០ កសក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១ ដើម្បីក្រសួងមានមូលដ្ឋានច្បាស់លាស់សម្រាប់ពិនិត្យ និងសម្រេចបន្ត

- ត្រូវបន្តជំរុញ ពង្រឹង និងបង្កើនសមត្ថភាពការងារដឹកនាំ និងគ្រប់គ្រងដល់ខណ្ឌរដ្ឋបាលជលផលព្រៃវែងឱ្យកាន់តែមានប្រសិទ្ធភាពជាងនេះទៀត ជាពិសេសបន្តកិច្ចសហការល្អទាំងផ្ទៃក្នុងខណ្ឌក៏ដូចជាកិច្ចសហការល្អជាមួយអាជ្ញាធរដែនដី មានសមត្ថកិច្ចពាក់ព័ន្ធនានាក្នុងខេត្ត និងខិតខំប្រឹងប្រែងស្វែងរកដៃគូអង្គការក្រៅរដ្ឋាភិបាលជួយអភិវឌ្ឍន៍វិស័យជលផលបន្តទៀត។ ទន្ទឹមនឹងនោះ រដ្ឋបាលជលផលត្រូវធ្វើការអប់រំណែនាំផ្ទាល់បន្ថែមទៀតដល់នាយខណ្ឌ ឱ្យធ្វើការកែប្រែអត្តចរិតអាកប្បកិរិយា និងការប្រើពាក្យសំដីមិនសមរម្យដល់មន្ត្រីថ្នាក់ក្រោម

- ត្រូវបន្តជំរុញធ្វើលិខិតនិរាករណ៍លិខិតលេខ ២៤៩៩ ជផចុះថ្ងៃទី ៤ខែតុលា ឆ្នាំ២០១២ របស់រដ្ឋបាលជលផល ដែលបានអនុញ្ញាតឱ្យសហគមន៍នេសាទតេជោមេកឹង (អតីតឡូត៍នេសាទលេខ១៨) និងសហគមន៍នេសាទតេជោពោធិ៍ថ្មី (អតីតឡូត៍នេសាទលេខ១៩) បោះរបាំងធ្នស់ចាប់ត្រី ដោយមិនមានការអនុញ្ញាតជាគោលការណ៍ពីក្រសួង ហើយរដ្ឋបាលជលផលត្រូវយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាពនូវលិខិតលេខ ៧៩៥២ កសក ចុះថ្ងៃទី១២ ខែតុលាឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣- តាមរយៈលិខិតលេខ៩៥០ កសក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រសួងបានសម្រេចឱ្យរដ្ឋបាលជលផលអនុវត្តដូចខាងក្រោម÷

- ត្រូវចាត់វិធានការដល់ខណ្ឌរដ្ឋបាលជលផលខេត្តតាកែវ ឱ្យធ្វើការណែនាំដល់លោកនាយផ្នែករដ្ឋបាលជលផលអង្គរបូរី និងតាមផ្នែករដ្ឋបាលជលផលបូរីជលសារ ឱ្យមានរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំផ្នែកនីមួយៗ។ ដោយឡែកផ្នែករដ្ឋបាលជលផលបូរីជលសារ ត្រូវមានកិច្ចសហការល្អជាមួយអាជ្ញាធរស្រុក ឃុំ និងសមត្ថកិច្ចផ្សេងៗទៀតក្នុងស្រុក

- ធ្វើការណែនាំពង្រឹងបន្ថែមដល់នាយផ្នែករដ្ឋបាលជលផលអង្គរបូរី និងលោកនាយផ្នែករដ្ឋបាលជលផលបូរីជលសារ ក្នុងការទប់ស្កាត់ និងបង្រ្កាបបទល្មើសជលផល ដោយផ្អែកតាមមនសិការវិជ្ជាជីវៈរបស់ខ្លួន

- ត្រូវពង្រឹងសមត្ថភាពសហគមន៍នេសាទ ក្នុងខណ្ឌរដ្ឋបាលជលផលតាកែវទាំងមូលបន្ថែមទៀត ជាពិសេសសហគមន៍នេសាទតាមអតីតឡូត៍នេសាទ ដែលបានលុបចេញ ដើម្បីធ្វើឱ្យគាត់យល់ដឹងច្បាស់អំពី តួនាទី ភារកិច្ច ក្របខ័ណ្ឌច្បាប់បំណងប្រាថ្នា និងគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលុបឡូត៍នេសាទ និងដាក់ឱ្យសហគមន៍នេសាទ ថែរក្សា ការពារឡូត៍នេសាទ។ល។

- ត្រូវចាត់វិធានការជាបន្ទាន់ ដោយចុះសិក្សាកំណត់ឱ្យបានច្បាស់លាស់តាមអតីតឡូត៍នេសាទ ដែលស្ថិតក្នុងខេត្តជាប់ព្រំដែនប្រទេសវៀតណាម(ខេត្តកណ្ដាល ព្រៃវែង តាកែវ និងខេត្តកំពង់ចាម) ដែលអនុញ្ញាតឱ្យដាក់របាំងធ្នស់ ដើម្បីកុំឱ្យត្រីហូរចុះទៅប្រទេសវៀតណាម ដោយកំណត់ទីតាំង ទំហំឧបករណ៍នេសាទ ដែលត្រូវប្រើប្រាស់ដូចជា កន្លែងដែលត្រូវដាក់របាំងឬមិនដាក់របាំង ទំហំ ប្រវែងរបាំង ។ល។ ដែលទាមទារឱ្យមានការសិក្សាច្បាស់លាស់តាមលក្ខណៈបច្ចេកទេសខណៈ ដែលរដ្ឋបាលជលផលមិនទាន់បានកំណត់នៅឡើយក្រោយពីលុបឡូត៍នេសាទ

- បន្តតាមដាននិងត្រួតពិនិត្យការអនុវត្តន៍របស់សហគមន៍នេសាទ ឱ្យបានចំទិសដៅនិងគោលការណ៍របស់រាជរដ្ឋាភិបាល ដែលបានអនុញ្ញាតឱ្យសហគមន៍នេសាទបោះរបាំងធ្នស់លើទីតាំង ដែលរដ្ឋបាលជលផលសិក្សាថា ចាំបាច់ត្រូវបោះរបាំងធ្នស់ដោយសហគមន៍នេសាទត្រូវធ្វើធ្នស់ដោយខ្លួនឯង តែសព្វថ្ងៃសហគមន៍នេសាទក្រីក្រគ្មានទុន ការយល់ដឹងតិច និងមិនមាន

បច្ចេកទេសធ្វើផ្សស់ទៀតផង។

៤- តាមរយៈចំណារឯកភាពរបស់អតីតឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ លើរបាយការណ៍របស់ក្រុមការងារចុះទៅណែនាំ ដើម្បីកែលម្អចំណុចខ្វះខាតរបស់ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគីរី ដោយធ្វើលិខិតជម្រាបជូនទៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អំពីលទ្ធផលនៃការអនុវត្តលិខិតលេខ ០៦៧/១២ ទ.រ.ព.អ.ស.ជ.ណ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០១២ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ដោយចម្លងជូនរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ដើម្បីពង្រឹងបន្ថែម។

## ក.៣. សន្និដ្ឋាន

ទោះបីយើងបានជួបប្រទះនូវការលំបាកមួយចំនួនក្នុងអនុវត្តនៅតាមតំបន់នីមួយៗនៃរាជធានី ខេត្តក៏ដោយ ក៏យើងខិតខំប្រឹងប្រែងពីសំណាក់ថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់ផ្នែក អនុវត្តការងារសម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់ និងទទួលបានជោគជ័យ ។

## ក.៤. វិធានការ

- បន្តពង្រឹងសមត្ថភាពមន្ត្រីក្រោមឱវាទឲ្យខិតខំរៀនសូត្រនូវបទពិសោធន៍ល្អៗដើម្បីបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព
- ក្តាប់សភាពការណ៍ពាក់ព័ន្ធនឹងវិស័យកសិកម្មដើម្បីជាមូលដ្ឋានក្នុងការអនុវត្តការងារ
- ត្រួតពិនិត្យវាយតម្លៃ និងសន្និដ្ឋាន ក្នុងការតាមដានការអនុវត្តតាមស្មារតីនៃលិខិតណែនាំរបស់ក្រសួង ចំពោះអង្គភាពឬបុគ្គលដែលកន្លងមកមានការខុសឆ្គងឬមានការខ្វះខាត
- ខិតខំអនុវត្តការងារស្របតាមផែនការសកម្មភាពប្រចាំឆ្នាំ ២០១៤ ឲ្យបានជាអតិបរមាដូចជា:

### ១. វិស័យជលផល:

- ចុះត្រួតពិនិត្យលើការងារដឹកនាំ និងគ្រប់គ្រងវិស័យជលផល
- ចុះពិនិត្យការងារដឹកនាំនិងគ្រប់គ្រងរបស់អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល (ទឹកសាប និងសមុទ្រ)
- ចុះពិនិត្យការធ្វើអាជីវកម្មគន្លងដាយ និងការធ្វើអាជីវកម្មនេសាទរបស់សហគមន៍នៅតាមព្រំដែន
- ចុះត្រួតពិនិត្យលើការទប់ស្កាត់ការចិញ្ចឹម និងការនាំចូលត្រីរ៉ស់ ត្រីឆ្តោខុសច្បាប់និងត្រីហាមឃាត់នានា
- ចុះត្រួតពិនិត្យការគ្រប់គ្រង និងដំណើរការរបស់ស្ថានីយ និងមជ្ឈមណ្ឌលវារីវប្បកម្មទឹកសាប និសមុទ្រ។

### ២. វិស័យព្រៃឈើ:

- ចុះត្រួតពិនិត្យលើការងារដឹកនាំ និងគ្រប់គ្រងវិស័យព្រៃឈើ
- ចុះពិនិត្យការងារដឹកនាំនិងគ្រប់គ្រងរបស់អធិការដ្ឋាន ខណ្ឌ ផ្នែកនិងសង្កាត់រដ្ឋបាលព្រៃឈើ
- ចុះត្រួតពិនិត្យលើការងារដឹកនាំនិងគ្រប់គ្រងស្ថានីយដាំ និងស្តារព្រៃឈើរបស់រដ្ឋ

### ៣. វិស័យផលិតកម្មនិងបសុព្យាបាល:

- ចុះត្រួតពិនិត្យលើការងារដឹកនាំ និងគ្រប់គ្រងវិស័យផលិតកម្ម និងបសុព្យាបាល
- ចុះពិនិត្យការអនុវត្តរបស់មន្ត្រីលើការងារគ្រប់គ្រងវិស័យផលិតកម្ម និងបសុព្យាបាលខេត្តកំពង់ធំ សៀមរាប កំពង់ចាម ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ
- ចុះត្រួតពិនិត្យការគ្រប់គ្រងស្ថានីយចិញ្ចឹមជ្រូកពូជគោពូជ។

### ៤. វិស័យកៅស៊ូ:

- ចុះត្រួតពិនិត្យលើការងារដឹកនាំ និងគ្រប់គ្រងវិស័យកៅស៊ូ, ការកែច្នៃកៅស៊ូ និងការនាំចេញកៅស៊ូ។

### ៥. ការងារនីតិកម្មកសិកម្ម:

- ចុះត្រួតពិនិត្យលើការងារដឹកនាំ និងគ្រប់គ្រងសម្ភារបមាណីកសិកម្ម។

### ៦. អគ្គនាយកដ្ឋានកសិកម្ម:

- ចុះត្រួតពិនិត្យលើការងារដឹកនាំ និងគ្រប់គ្រងរបស់អគ្គនាយកដ្ឋានកសិកម្ម, ការងារដឹកនាំ និងគ្រប់គ្រងស្ថានីយពិសោធន៍ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម

- ចុះត្រួតពិនិត្យលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម ខេត្តរតនគីរី ក្រចេះ បាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ដើម្បីបង្ការទប់ស្កាត់លុបបំបាត់ភាពអសកម្មនិងកាត់បន្ថយបាតុភាពផ្សេងៗដែលកើតឡើងជាយថាហេតុ។

## ខ-សវនកម្មផ្ទៃក្នុង

### ខ.១. ការងារចុះធ្វើសវនកម្មផ្ទៃក្នុង

ក្នុងឆ្នាំ២០១៣នេះ ផ្នែកសវនកម្មផ្ទៃក្នុងបានចុះធ្វើសវនកម្ម តាមផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ ទទួលបានលទ្ធផលដូចខាងក្រោម ÷

- ***អង្គភាពថ្នាក់កណ្តាល :*** នាយកដ្ឋានកសិ-ឧស្សាហកម្ម នាយកដ្ឋានផលិតកម្មនិងបសុពេទ្យបាល នាយកដ្ឋាននីតិកម្មកសិកម្ម នាយកដ្ឋានផែនការនិងស្ថិតិ អគ្គនាយកដ្ឋានកសិកម្ម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកដ្ឋានកៅស៊ូ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ។

- ***គ្រឹះស្ថានសាធារណៈរដ្ឋបាល :*** វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាម។

- ***មន្ទីរកសិកម្មរាជធានី ខេត្ត:*** ខេត្តរតនគីរី មណ្ឌលគីរី កំពង់ចាម ព្រៃវែង ស្វាយរៀង ក្រចេះ ស្ទឹងត្រែង កណ្តាល កំពត ព្រះសីហនុ តាកែវ កែប កំពង់ស្ពឺ កោះកុង ឧត្តរមានជ័យ បន្ទាយមានជ័យ ព្រះវិហារ សៀមរាប បាត់ដំបង ពោធិ៍សាត់ ប៉ៃលិន កំពង់ធំ និងរាជធានីភ្នំពេញ ។

ក្នុងឆ្នាំ២០១៣ បានធ្វើសវនកម្មចំនួន៣៧សវនកម្មស្មើនឹង៨៦,០៥%នៃផែនការ៤៣សវនកម្មដ្ឋាន បានផ្តល់អនុសាសន៍ចំនួន២១០អនុសាសន៍ ជាមួយនោះសវនកម្មកំពុងខិតខំកែលម្អតាមអនុសាសនសវនកម្ម ដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុងនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដាក់ឲ្យអនុវត្ត។

### ខ.២.សន្និដ្ឋាន

ជារួមដោយមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួងនិងរាជរដ្ឋាភិបាលលើការងារសវនកម្មផ្ទៃក្នុង ផ្នែកសវនកម្មផ្ទៃក្នុង បានចុះធ្វើសវនកម្មសម្រេចបានលទ្ធផលល្អប្រសើរ ដោយអង្គភាពរងសវនកម្មភាគច្រើនបានយកចិត្តទុកដាក់ ធ្វើការកែលម្អរាល់ចំណុចខ្វះខាតកន្លងមកនិងនៅមានអង្គភាពមួយចំនួនតូចប៉ុណ្ណោះ ដែលការអនុវត្តកែលម្អតាមអនុសាសន៍នៃការធ្វើសវនកម្មមិនទាន់បានល្អ និងទាន់ពេលវេលា ។

### ខ.៣.ទិសដៅអនុវត្ត

-បន្តស្វែងយល់លិខិតបទដ្ឋានច្បាប់និងប្រមូលព័ត៌មានដែលពាក់ព័ន្ធការងារសវនកម្ម

-ពង្រឹងការអនុវត្តភារកិច្ចតាមច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រិត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា

-បន្តតាមដានកែលម្អសវនកម្មនិងធ្វើសវនកម្មឆ្នាំ២០១៤

-បន្តសហការជាមួយក្រុមជំនាញការធនាគារអភិវឌ្ឍន៍អាស៊ី ADB នៃគម្រោង PFMRDP Component 2 (Public Financial Management for Rural Development)។

## ៥.៤.៦- ការងារកសិ-ឧស្សាហកម្ម

### ក. លទ្ធផល

### ក.១-ការងារអនុវត្តគម្រោង

បានអនុវត្តថវិកាតាមកម្មវិធីទី២ ដែលមានអនុកម្មវិធីចំនួន០៣ គឺ÷ ទី១ ទី៤ និងទី៥ ចំណាយថវិកាសរុបចំនួន ៣២៧.១៤២.០០០រ០០ និងទទួលបានលទ្ធផលដូចខាងក្រោម÷

-អនុកម្មវិធីទី១ ចុះបណ្តុះបណ្តាលស្តីពី "បច្ចេកទេសកែច្នៃ និងផ្សំចំណីសត្វ" ក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៦០ នាក់ ដែលចំណាយថវិកាអស់ចំនួន ១១០.៨២៧.០០០រ០០

-អនុកម្មវិធីទី៤ ចុះបណ្តុះបណ្តាលស្តីពី"ការលើកកំពស់ស្តង់ដា គុណភាពសុវត្ថិភាពនៃផលិតផលកសិកម្ម" ក្នុង

ខេត្តចំនួន ០៣ សរុបចំនួន ៣៦០ នាក់ ដែលចំណាយថវិកាអស់ចំនួន ១០៩.៦២៨.០០០៛០០

-អនុកម្មវិធីទី៥ ចុះបណ្តុះបណ្តាលស្តីពី "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" ក្នុងខេត្តចំនួន ០៣ សរុបចំនួន ៣៩០ នាក់ ដែលចំណាយថវិកាអស់ចំនួន ១០៦.៦៨៧.០០០៛០០។

**ក.២-ការងារនីតិកម្ម**

-បានរៀបចំតាក់តែងសេចក្តីព្រាង និងកំពុងបន្តប្រជុំផ្ទៃក្នុងនាយកដ្ឋានជាច្រើនលើកលើសេចក្តីព្រាងសារាចរណែនាំស្តីពី និតិវិធីចុះកិច្ចសន្យាផលិតកម្មកសិកម្មតាមកិច្ចសន្យា និងទម្រង់គម្រូកិច្ចសន្យា នៃសារាចរណែនាំនេះផងដែរ

-បាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី "ការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម" ។

**ក.៣-ការងាររៀបចំសន្និបាតកសិករ**

-បានចូលរួមជាគណៈកម្មការ និងបានបង្កើតគណៈមេប្រយោគដើម្បីជ្រើសរើសកសិករឆ្នើមមកពីបណ្តាលខេត្តនានា ទូទាំងប្រទេសលើប្រធានបទ "ការកែច្នៃផលិតផលកសិកម្ម និង ជលផល" នាថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៣

-បានចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃដល់ទីតាំងជាក់ស្តែងរបស់កសិករឆ្នើមចំនួន០៥រូប នៅខេត្តព្រះសីហនុ កំពត មណ្ឌលគីរី និងកោះកុង ក្រោយពីគណៈមេប្រយោគបានជ្រើសរើស ក្នុងចំណោមកសិករ ១៣ រូប មកពីខេត្តនានា។

**ក.៤- ការងារដីសម្បទានសេដ្ឋកិច្ច**

បានទទួលរបាយការណ៍រៀងរាល់ពីរខែម្តងអំពី ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចរបស់មន្ទីរកសិកម្ម ខេត្តកំពង់ចាម ស្ទឹងត្រែង ឧត្តរមានជ័យ ពោធិសាត់ កំពង់ធំ និងក្រចេះ។

**ក.៥-ការងារសហប្រតិបត្តិការជាតិ និងអន្តជាតិ**

-បានសហការជាសមភាគីជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) និង AFD លើសកម្មភាពអនុវត្តគម្រោងសាកល្បងស្តីអំពី Contract Farming ក្នុងអាជីវកម្មស្រូវសម្រាប់នាំចេញ។

-បានសហការជាមួយអង្គការ AFD និង GIZ រៀបចំផែនការសកម្មភាពការងារស្តីអំពី"ផលិតកម្ម កសិកម្មតាមកិច្ចសន្យា និងភាពជាដៃគូ"

-បានសម្របសម្រួលដល់ក្រុមហ៊ុន CamAgra ដើម្បីទទួលបានថវិកាគាំទ្រក្នុងការសិក្សា ការពិនិត្យលទ្ធភាពនិងការអនុវត្តគម្រោងសាកល្បងស្តីអំពី "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" ពី AFD។

## ខ. វិធានការ

-បន្តខិតខំរៀបចំគោលនយោបាយ ផែនការ កម្មវិធី គម្រោង និងវិធានការណ៍ដើម្បីអភិវឌ្ឍវិស័យកសិឧស្សាហកម្ម

-បន្តពង្រឹងសកម្មភាពចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដោយសហការជាមួយស្ថាប័នពាក់ពន្ធ័ និងពង្រឹងការយល់ដឹងរបស់មន្ត្រីការិយាល័យកសិឧស្សាហកម្មខេត្ត ដើម្បីរាយការណ៍ជូនក្រសួងកសិកម្មអំពី "ដំណើរការអភិវឌ្ឍន៍វិស័យកសិឧស្សាហកម្ម"

-បន្តរៀបចំច្បាប់និងលិខិតបទដ្ឋាន បង្កើនការយល់ដឹងជាសាធារណៈអំពី ការអនុវត្តយន្តការអនុក្រឹត្យលេខ ៣៦ អនក្រ ស្តីពី"ផលិតកម្មកសិកម្មតាមកិច្ចសន្យា"

-បន្តបង្កើនការយល់ដឹងដល់ប្រជាកសិករតាមតំបន់ជនបទ អំពីបច្ចេកទេសក្រោយពេលប្រមូលផល ផលប្រយោជន៍ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ផលប្រយោជន៍នៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានិងភាពជាដៃគូ ក្របខ័ណ្ឌច្បាប់នានា ដែលទាក់ទងនិងការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម

-ជម្រុញឲ្យមន្ទីរកសិកម្មតាមបណ្តារាជធានីខេត្ត ដែលមិនទាន់មានមន្ត្រីទទួលបន្ទុកការិយាល័យកសិឧស្សាហកម្មធ្វើសំណើមកក្រសួងដើម្បីសុំគោលការណ៍តែងតាំងតួនាទី

-កែទម្រង់រចនាសម្ពន្ធ័ក្នុងនាយកដ្ឋាន ដោយបង្កើតការិយាល័យថ្មីមួយបន្ថែមទៀត ផ្តោតទៅលើបច្ចេកវិទ្យាក្រោយពេលប្រមូលផល វេចខ្ចប់ និងរក្សាទុក។ ជារួមស្វែងយល់សំណូមពររបស់វិស័យឯកជនក្នុងផ្នែកកសិកម្ម និងកសិឧស្សាហកម្ម

-លើកគម្រោងសុំថវិកាពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ រឺ ផ្នែកឯកជន ដើម្បីបង្កើតមន្ទីរពិសោធន៍ជាតិសម្រាប់

វិភាគផលិតផលកសិកម្ម និងកសិម្ហូបអាហារ ហើយខិតខំបង្កើនកិច្ចសហប្រតិបត្តិការជាមួយសប្បុរសជនអង្គការអន្តរជាតិ ស្ថាប័នឯកជន ដើម្បីស្វែងរកការគាំទ្រទាំងថវិកា និងបច្ចេកទេស ។

### ៥.៨.៧- ការងារយេនឌ័រ

#### ក. ស្ថានភាពនៃការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម

ក្រោយពីបានបង្កើតអង្គភាពយេនឌ័រ និងក្រុមការងារយេនឌ័ររួច ក្រុមការងារបានចុះធ្វើការសិក្សាស្រាវ ជ្រាវ ដើម្បីកសាងគោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។ គោលនយោបាយនិងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនោះ ជាលទ្ធផលទទួលបានដូចខាងក្រោម ÷

ទី១-បើកវគ្គបណ្តុះបណ្តាលពីចំណេះដឹងយេនឌ័រនិងអនុសញ្ញាស៊ី-ដ ជូនដល់មន្ត្រីរាជការគ្រប់អង្គភាពនាយកដ្ឋាន មន្ទីរកសិកម្មគ្រប់រាជធានី-ខេត្ត សរុបបានចំនួន១២១វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ៥.៨០០នាក់ ក្នុងនោះស្ត្រីចំនួន ២.៨៤២នាក់ ត្រូវជា៤៩% ស្មើនឹង៨០%នៃផែនការ។

ទី២ ÷ ក្រុមការងារបានសង្កេតឃើញថា មានគម្រោងប្រមាណជាង៨០% បានធ្វើការបែងចែកភេទនិងបានគិតគូរពីស្ត្រី នៅសល់ ប្រមាណជា២០% ទៀតនៅពុំទាន់អនុវត្តបាន។

ទី៣ ÷ បច្ចុប្បន្នចំនួនស្ត្រីជាថ្នាក់ដឹកនាំ ត្រូវបានកើនឡើង ជាលំដាប់ ជាពិសេសមានស្ត្រីចូលរួមដឹកនាំមន្ទីរមាន នចំនួន៧រូបដូចជាខេត្តសៀមរាប កែប ស្វាយរៀង តាកែវ មណ្ឌលគីរី កំពង់ឆ្នាំង និងព្រៃវែង។

ទី៤ ÷ ការបង្កើនលទ្ធភាពដល់ស្ត្រីជនបទក្នុងការទទួលបាន និងលទ្ធភាពគ្រប់គ្រងធនធាន និងសេវាកម្មកសិកម្ម។

ក្នុងន័យចង់ឱ្យកសិករទាំងពីរភេទចេះប្រើប្រាស់ធនធានធម្មជាតិ ដែលមានស្រាប់ឱ្យមានតុល្យភាព និងមាននិរន្តរភាព សំដៅធ្វើយ៉ាងណាឱ្យកសិករទាំងពីរភេទ ពិសេសកសិករជាស្ត្រីទទួលបានប្រាក់កម្រៃខ្ពស់។

#### ខ. ការងារបណ្តុះបណ្តាល

ជារួមបានបើកវគ្គបណ្តុះបណ្តាលចំណេះដឹងយេនឌ័រនិងផ្សព្វផ្សាយរបាយការណ៍ជាតិលើកទី៤ លើកទី៥ និងពិធីសារតាមជម្រើសរបស់អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងនារីភេទជូនដល់ភ្នាក់ងារ សុខភាពសត្វភូមិ បានចំនួន១៥វគ្គ ស្មើនឹង ៧៥០នាក់ ក្នុងនោះ មានស្ត្រីចំនួន២៨៤នាក់ ត្រូវជា ៤៨% នៃចំនួនសរុប។

#### គ. ការងារសហគមន៍

-សហគមន៍អភិវឌ្ឍន៍កសិកម្មមានចំនួន៤៨៣សហគមន៍ ដែលមានសមាជិកចូលរួមសរុបចំនួន៤៦.១៥២នាក់ ក្នុងនោះស្ត្រីមានចំនួន២២.៥៨៦នាក់ ស្មើនឹង ៤៩% នៃចំនួនសរុប

-សហគមន៍ព្រៃឈើមានចំនួន៤៥៧សហគមន៍ ដែលមានសមាជិកសរុបចំនួន១១៣.៥២៩គ្រួសារ (យោងស្ថិតិសហគមន៍ដែលបានរៀបចំនៅកម្ពុជា ខែមិថុនា ឆ្នាំ២០១៣)

-សហគមន៍នេសាទមានចំនួន ៥១៦សហគមន៍ ស្មើនឹង ១៥៦.៦២៨គ្រួសារ ដែលមានសមាជិកសរុបចំនួន ៣៣២.១៦៨នាក់ ក្នុងនោះស្ត្រីមានប្រមាណ ២៨% នៃចំនួនសរុប។

#### ឃ. វាយតម្លៃនិងសន្និដ្ឋាន

បច្ចុប្បន្នក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានដំណើរការអនុវត្តកិច្ចការឆ្ពោះទៅរកសមភាពយេនឌ័រ ដោយផ្តោតគោលដៅទៅលើស្ត្រីនិងបុរស ជាពិសេសលើស្ត្រី គឺធ្វើយ៉ាងណាឲ្យមានតុល្យភាពនៃការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងសង្គមជាតិប្រកបដោយសមធម៌ ក្នុងន័យចូលរួមបង្កើនផលិតភាពនិងពិពិធភាវូបនីយកម្មកសិកម្ម ដើម្បីចូលរួមក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមទិសដៅអភិវឌ្ឍសហវត្សរ៍នៅកម្ពុជា។

#### ង. វិធានការ

-បន្តអនុវត្តតាមអនុសាសន៍ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការផ្សព្វផ្សាយពីអនុសញ្ញាលុបបំបាត់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទ និងឯកសារដែលពាក់ព័ន្ធឲ្យ

បានទូលំទូលាយក្នុងវិស័យកសិកម្ម

-បន្តអនុវត្តន៍ទិសដៅទាំង៤នៃគោលនយោបាយនិងយុទ្ធសាស្ត្របញ្ញាបយេនឌ័រក្នុងវិស័យកសិកម្ម ឲ្យទទួលបាន លទ្ធផលល្អប្រសើរតាមផែនការកំណត់។

## ៥.៩- ធនធានមនុស្សនិងថវិកា

### ៥.៩.១ ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

### ក. លទ្ធផលៈ

ការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើន ប្រសិទ្ធិភាពការងារ ប្រកបដោយសមធមិ និងជាគោលដៅចម្បងក្នុងការលើកស្ទួយសមត្ថភាពធនធានមនុស្ស ស្របតាមជំនាញបច្ចេកទេស និង វិទ្យាសាស្ត្រ ដើម្បីរួមចំណែកលើកស្ទួយការអភិវឌ្ឍន៍ប្រទេស ដែលជាជ្រុង មួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ក្នុងតួនាទីជាសេនាធិការផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានបុគ្គលិក និអភិវឌ្ឍន៍ធនធានមនុស្ស បានខិតខំយកចិត្តទុកដាក់ក្នុងការ ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស មានជាអាទិ៍ ការងារគ្រប់គ្រងមន្ត្រីរាជការ ការងាររៀបចំមន្ត្រី កាន់មុខតំណែង ការងាររៀបចំស្នើសុំគ្រឿងឥស្សរិយយស ការងាររៀបចំរចនាសម្ព័ន្ធ ការងាររៀបចំបៀវត្ស ប្រាក់ធានារ៉ាប់រងសង្គម ការងាររៀបចំតម្លើងថ្នាក់ ការងាររៀបចំដាក់មន្ត្រីគ្រប់អាយុឱ្យចូលនិវត្តន៍ និងការងារអភិវឌ្ឍន៍ធនធានមនុស្ស ឱ្យស្របទៅតាមគោលការណ៍ ច្បាប់ និងលិខិតបទដ្ឋាននានា ។

បច្ចុប្បន្នដំណើរការផលិតកម្មកសិកម្ម បានកំពុងវិវឌ្ឍន៍តាមរបត់នៃទីផ្សារសេរី ដូចនេះ រចនាសម្ព័ន្ធតួនាទី និងភារកិច្ចនៃអង្គភាពនីមួយៗ ចាំបាច់ត្រូវតែកែលំអឱ្យសមស្របតាមសភាពការណ៍ជាក់ស្តែង ។ វិស័យកសិកម្មអាចអភិវឌ្ឍន៍ទៅបានគឺ តម្រូវឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ និងធនធានមនុស្សមានសមត្ថភាពសមស្រប នៅតាមបណ្តាលអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានក្របខណ្ឌ មន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន៦.៦០៥នាក់ ជានារីចំនួន១.២២៥នាក់ ស្មើនឹង១៨,៥៤% ក្នុងនោះ :

- អង្គភាពថ្នាក់កណ្តាលមានចំនួន៤.០២៤នាក់ជានារីមានចំនួន៧៦០នាក់ ស្មើនឹង១៧,៥៤%
- អង្គភាពថ្នាក់រាជធានី ខេត្ត មានចំនួន២.៥៨១នាក់ ជានារីមានចំនួន៥១៩នាក់ ស្មើនឹង២០,១០%
- បានតែងតាំងតម្លើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការ សរុបចំនួន៧៩នាក់ ជានារីចំនួន៣៧នាក់
- បានលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌ មានចំនួន៧១នាក់ ក្នុងនោះ បោះបង់ការងារមានចំនួន២៥នាក់ សុំលាឈប់ពីការងារ ចំនួន២៧នាក់ និងមរណភាព ចំនួន១៩នាក់
- បានផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួង០៥នាក់ ផ្ទេរចូលក្រសួង០៥នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួង មានចំនួន៨៦នាក់
- បានចេញលិខិតអនុញ្ញាតច្បាប់សម្រាកពីការងារមានចំនួន៤៣នាក់ ក្នុងនោះ ច្បាប់សម្រាកប្រចាំឆ្នាំមចំនួន៣០នាក់ ច្បាប់ព្យាបាលជំងឺមានចំនួន០១នាក់ និងច្បាប់សម្រាកលំហែមាតុភាព មានចំនួន១២នាក់
- ក្នុងឆ្នាំ២០១៣ ក្រសួងបានប្រឡងជ្រើសរើសក្របខណ្ឌថ្មីបានចំនួន១៦៨នាក់ តាមគោលការណ៍របស់រាជរដ្ឋាភិបាល និងបានបែងចែកមន្ត្រីក្របខណ្ឌថ្មី ឱ្យទៅបម្រើការងារនៅតាមអង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្ត
- បានពិនិត្យ កែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសារសម្រាប់ខែមករាដល់ខែធ្នូ ឆ្នាំ២០១២ របស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា
- បានចេញប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស មានចំនួន៤០នាក់
- បានចេញប្រកាសឱ្យមន្ត្រីរាជការ ចូលបម្រើការងារនៅអង្គភាពដើមវិញ ចំនួន១២នាក់
- បានចេញលិខិតផ្ទេរកូនកំព្រាចំនួន០២នាក់ ទៅក្រសួងសង្គមកិច្ចអតិតយុទ្ធជន និងយុវនីតិសម្បទា
- បានចេញប្រកាសដាក់មន្ត្រីឱ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន១៩៦នាក់

- បានចេញប្រកាសស្តីពីការអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាមានចំនួន១៩៤នាក់ និងពលករអណ្តែតមានចំនួន៨៧១នាក់

- បានចេញប្រកាសតម្លើងមួយថ្នាក់តាមកំរិតសញ្ញាបត្រដល់មន្ត្រីរាជការចំនួន៣៩នាក់

- បានចេញប្រកាសតម្លើងថ្នាក់ប្រចាំឆ្នាំ២០១៣ ជូនមន្ត្រីរាជការកសិកម្មចំនួន២.៣៤០នាក់

- ក្រសួងបានបញ្ជូនមន្ត្រីចូលរួមបណ្តុះបណ្តាលបានចំនួន២៨៩នាក់ ក្នុងនោះ ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី មានចំនួន៣៩នាក់ និងនៅក្រៅប្រទេសថ្នាក់បណ្ឌិតចំនួន០១នាក់ ថ្នាក់អនុបណ្ឌិតចំនួន០៨នាក់ និងរយៈពេលខ្លីចំនួន២៤១នាក់ ដោយឡែកមន្ត្រីរាជការជានារីមានចំនួន៥៧នាក់

- បានរៀបចំ និងធ្វើសំណើសុំផ្តល់គ្រឿងឥស្សរិយយសជូនដល់មន្ត្រីកសិកម្ម បានចំនួន១.៣៩៩នាក់ ក្នុងនោះស្រី១២៤នាក់ ចាប់ពីមេដាយការងារសំរិទ្ធ រហូតដល់មេដាយព្រះមហាក្សត្រត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្សកុសមៈនារីរ័ត្នថ្នាក់មហាសេរីវឌ្ឍន៍

- បានលើកសំណើសុំដំឡើងស្ថានីផលិតត្រីពូជទី១ ទៅជាវិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្ម **សម្តេចតេជោ ហ៊ុន សែន**

- បានលើកសំណើទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីសុំជួយពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀប ទៅជាវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- បានលើកសំណើសុំបំបែកប្តូរឈ្មោះបង្កើតមហាវិទ្យាល័យ និងដំឡើងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានជាផ្នែកថ្នាក់ឆ្នាំសិក្សាមូលដ្ឋានរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានចេញប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះវិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្ម **សម្តេចតេជោ ហ៊ុន សែន**

-បានចេញសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

ក្នុងឆ្នាំ២០១៣នេះដែរ មន្ត្រីក្រុមការងារអនុវត្តគម្រោងថវិកាតាមកម្មវិធីរបស់នាយកដ្ឋាន បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការដាក់ពង្រាយមន្ត្រីរាជការ" នៅក្នុងតំបន់គោលដៅចំនួន៤ គឺខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តព្រះសីហនុ និងនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាសកម្មភាពធ្វើឲ្យគម្រោងតាមកម្មវិធី ឆ្នាំ ២០១៣ ទទួលបានលទ្ធផលជោគជ័យ។

ទន្ទឹមនឹងសកម្មភាពទាំងអស់ដែលបានអនុវត្តខាងលើ នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្សបានកសាងផែនការសម្រាប់ឆ្នាំ២០១៤ ដែលក្នុងនោះមាន ផែនកាថវិកាតាមកម្មវិធី និងមិនមែនកម្មវិធី ផែនការជ្រើសរើសក្របខណ្ឌ និងផែនការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងពលករអណ្តែត ។

## ខ. វាយតម្លៃនិងសំណើរ

ថ្វីបើមានការខិតខំប្រឹងប្រែងរបស់មន្ត្រីនាយកដ្ឋាន និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួង យ៉ាងណាក៏ដោយក៏ការអនុវត្តន៍ភារកិច្ចទាំងនោះ តែងតែជួបប្រទះនូវការលំបាក ស្មុគស្មាញជាច្រើនទៀតដែលនឹងត្រូវមានវិធានការមួយចំនួនសម្រាប់កែលំអ និងដោះស្រាយបន្ថែមទៀត ដូចជា÷

- ការបញ្ជូនឯកសារសម្រាប់តាំងស៊ប់ពីអង្គភាពថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្តមួយចំនួនមានការយឺតយ៉ាវ

- ការបញ្ជូនសំណុំឯកសារអំពីស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការ សម្រាប់បញ្ចូលក្នុងតារាងបៀវត្សប្រចាំខែនៅតែយឺតនាំឱ្យការបញ្ជូនឯកសារទៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលមាន ភាពអូសបន្លាយដែលបានប៉ះពាល់ដល់ការបើកផ្តល់បៀវត្សប្រចាំខែរបស់អង្គភាពក្រោមឱវាទក្រសួង

- រាល់ការបញ្ជូនឯកសារចាត់មន្ត្រីឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស នៅតែមិនទាន់បានអនុវត្តត្រឹមត្រូវតាមការណែនាំរបស់ក្រសួង ពោលគឺឯកសារផ្ញើមកនៅពុំទាន់បានគ្រប់គ្រាន់ និងមានការយឺតយ៉ាវមក មិនទាន់ពេលវេលាកំណត់

- រាល់ការបញ្ជូនឯកសារស្នើសុំមេដាយការងារជូនមន្ត្រីរាជការ នៅតាមបណ្តាអង្គភាពនានាចំណុះក្រសួងគឺនៅមាន

ការយឺតយ៉ាវមិនទាន់ពេលវេលាកំណត់ ទោះបីមានការក្រើនរំលឹកក៏ដោយ ហើយក៏ពុំបានអនុវត្តទៅតាមគោលការណ៍១០% របស់រាជរដ្ឋាភិបាលជាហេតុនាំឱ្យមានការលំបាកក្នុងការអនុវត្តការងារ ។

**ឥ. វិធានការៈ**

- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងគោលការណ៍ លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំ អំពីការងារគ្រប់មន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តន៍ជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្ស ឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកំរិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង ដើម្បីជាឯកសារសម្រាប់ក្រសួងប្រើប្រាស់

- បន្តរៀបចំសម្របសម្រួលការងារកសាងគោលការណ៍ លិខិតបទដ្ឋាន សេចក្តីសម្រេចនិងប្រកាសជូនអង្គភាពពាក់ព័ន្ធសម្រាប់ពង្រឹងលើការងារបណ្តុះបណ្តាលធនធានមនុស្ស ដោយលើកគម្រោងបញ្ជូនមន្ត្រីរាជការទៅសិក្សារយះពេលវែង មធ្យម ខ្លីនៅក្នុង និងក្រៅប្រទេស តាមជំនាញឱ្យបានច្រើន

- រៀបចំឯកសារដាក់មន្ត្រីឱ្យចូលនិវត្តន៍ឱ្យបានទាន់ពេលវេលា និងបន្តការងារដែលនៅសេសសល់

- ពិនិត្យនិងកែលំអលើការងាររៀបចំរចនាសម្ព័ន្ធ សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់អង្គភាពក្រោមឱវាទក្រសួង

- ចុះត្រួតពិនិត្យជាក់ស្តែងការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការ បុគ្គលិកកិច្ចសន្យា និងពលករអណ្តែតនៅតាមអង្គភាពថ្នាក់កណ្តាល និងរាជធានី ខេត្ត

- រៀបចំកសាងផែនការសំខាន់ៗមានជាអាទិ៍ៈ ផែនការក្របខណ្ឌ ផែនការជ្រើសរើសពលករអណ្តែត ផែនការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងផែនការថវិកាតាមកម្មវិធី និងមិនមែនកម្មវិធី។

### ៥.៩.២- ការអភិវឌ្ឍន៍ធនធានមនុស្សនៅតាមគ្រឹះស្ថានអប់រំ

### ក. សាកលវិទ្យាល័យភូមិន្ទកសិកម្ម

#### ក.១. លទ្ធផល

#### ក.១.១ ស្ថិតិនិស្សិត

ដោយអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាកលវិទ្យាល័យឆ្នាំ២០១០-២០១៥ និងក្រោមការដឹកនាំតម្រង់ទិសរបស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៣និងអាណត្តិទី៤ សាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រេចបាននូវលទ្ធផលការងារសំខាន់ៗជាច្រើន ជាពិសេសការងារអប់រំបណ្តុះបណ្តាលធនធានមនុស្ស ការងារស្រាវជ្រាវវិទ្យាសាស្ត្រ ការងារផ្សព្វផ្សាយ និងការងារសហប្រតិបត្តិការជាតិនិងអន្តរជាតិ ។

នៅឆ្នាំ២០១៣កន្លងមកនេះ និស្សិតដែលចុះឈ្មោះសិក្សានៅសាកលវិទ្យាល័យភូមិន្ទកសិកម្មមានចំនួនសរុប១ ៤៤៨នាក់ ក្នុងនោះមាននារី៤២១នាក់។

ក្នុងឆ្នាំ២០១៣ មាននិស្សិតសរុបចំនួន ៥ ៩៧៣នាក់ ក្នុងនោះនារី ១ ៤០៣នាក់ (ស្មើនឹង ២៣% នៃនិស្សិតសរុប) កំពុងសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម លើមហាវិទ្យាល័យជំនាញ១០ គឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម វិទ្យាសាស្ត្រជលផលកសិឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ ដែលបណ្តុះបណ្តាលថ្នាក់បរិញ្ញា និងនៅសាលាក្រោយឧត្តមដែលទទួលបន្ទុកបណ្តុះបណ្តាលថ្នាក់បរិញ្ញារង បរិញ្ញាជាន់ខ្ពស់ និងបណ្ឌិត ។




ចាប់តាំងពីបើកទ្វារសារជាថ្មីនាឆ្នាំ១៩៨៥ មកដល់ឆ្នាំ២០១៣នេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានរួមចំណែកបណ្តុះបណ្តាលនិស្សិតឲ្យបញ្ចប់ការសិក្សាដោយជោគជ័យលើវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងវិស័យពាក់ព័ន្ធផ្សេងៗ សរុបបានចំនួន៦.៨៤៣នាក់ (នារី ១.០៦៥នាក់ស្មើនឹង ១៧%) ដែលបែងចែកជាថ្នាក់បណ្ឌិតចំនួន ៧នាក់ (នារី១នាក់) បរិញ្ញាជាន់ខ្ពស់ចំនួន ៦៦៨នាក់ (នារី៩៦នាក់) បរិញ្ញាចំនួន៥ ២៦២នាក់ (នារី ៩១០នាក់) និងថ្នាក់បរិញ្ញារងចំនួន ៥០៦នាក់ (នារី ៥៨នាក់) ។ ស្ថិតិនិស្សិតបញ្ចប់ការសិក្សាបែងចែកតាមជំនាញផ្សេងៗមានបង្ហាញជូនក្នុងក្រាហ្វិកខាងក្រោម ។




### ក.១.២ សហប្រតិបត្តិការជាតិនិងអន្តរជាតិ

ដើម្បីពង្រឹងសមត្ថភាពសាកលវិទ្យាល័យឲ្យកាន់តែរឹងមាំ និងជាពិសេសដើម្បីឈានទៅដល់បទដ្ឋានអន្តរជាតិ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានយកចិត្តទុកដាក់ខ្ពស់ជាចម្បងលើកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ។ ជារួមកិច្ចសហប្រតិបត្តិការអន្តរជាតិ បានផ្តល់ឱកាសដល់សាកលវិទ្យាល័យគៀងគរបានមូលនិធិផ្សេងៗ សម្រាប់ដំណើរការការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស ការផ្លាស់ប្តូរនិស្សិតនិងសាស្ត្រាចារ្យទៅវិញទៅមកជាមួយសាកលវិទ្យាល័យដៃគូ ការធ្វើកម្មសិក្សារបស់និស្សិតនិងសាស្ត្រាចារ្យក្នុងនិងក្រៅប្រទេស ការផ្តល់អាហារូបករណ៍ ការផ្សព្វផ្សាយបច្ចេកទេសដល់កសិករ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ក្នុងឆ្នាំ២០១៣នេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានបង្កើតកិច្ចសហប្រតិបត្តិការថ្មីបានចំនួន៩ដៃគូ ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម បន្ថែមពីលើដៃគូដែលមានស្រាប់នាពេលកន្លងមក ។

**បញ្ជីឈ្មោះដៃគូសហប្រតិបត្តិការអន្តរជាតិថ្មីក្នុងឆ្នាំ ២០១៣**

| ល.រ | ស្ថាប័ន | ប្រទេស | សកម្មភាពកំពុងអនុវត្ត |
|---|---|---|---|
| ១ | Nagoya University | ជប៉ុន | ផ្លាស់ប្តូរនិស្សិត បុគ្គលិក និងការងារស្រាវជ្រាវ |
| ២ | កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) | កម្ពុជា | សហការរៀបចំផ្នែកប្រែប្រួលអាកាសធាតុនៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៣ | Erasmus Mundus Action 2 | សហគមន៍អឺរ៉ុប | ផ្លាស់ប្តូរនិស្សិត បុគ្គលិក និងការងារស្រាវជ្រាវ |

| | | | |
|---|---|---|---|
| | Partnerships Lot 12 “Lotus Unlimited” | | |
| ៤ | Toto Kogyo Co. Ltd. និង NPO Communion | ជប៉ុន | សហការស្រាវជ្រាវ |
| ៥ | Sangmyung University | កូរ៉េ | ផ្លាស់ប្ដូរនិស្សិត បុគ្គលិក ការងារស្រាវជ្រាវ ឯកសារវិទ្យាសាស្ត្រ |
| ៦ | Republic Polytechnic | សឹង្ហបុរី | អភិវឌ្ឍនិងផ្សព្វផ្សាយចំណេះដឹង ផ្ដល់សេវាដល់សហគមន៍ និងជំរុញការផ្លាស់ប្ដូរវប្បធម៌តាមរយៈយុវជន |
| ៧ | GIZ | អាល្លឺម៉ង់ | សហការអភិវឌ្ឍចំណេះដឹង |
| ៨ | The University of Rome “Tor Vergata” | អ៊ីតាលី | សហការក្នុងការស្រាវជ្រាវនិងបង្រៀន |
| ៩ | ក្រុមហ៊ុន ខ្មែរ ប្រ៊ូវើរី លីមីធីត | កម្ពុជា | ចែករំលែកបទពិសោធន៍ ចំណេះដឹង និងធនធានកម្មសិក្សា ការស្រាវជ្រាវ និងឱកាសការងារ |

## ក.១.៣ អាហារូបករណ៍និស្សិត

ក្នុងនាមជាគ្រឹះស្ថានសាធារណរដ្ឋបាល សាកលវិទ្យាល័យភូមិន្ទកសិកម្មបានយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វែងរកអាហារូបករណ៍ផ្សេងៗ និងផ្ដល់អាហារូបករណ៍ទាំងនោះដល់និស្សិត ជាពិសេសនិស្សិតពូកែ និស្សិតក្រីក្រ និងនិស្សិតមកពីតំបន់ដាច់ស្រយាល ។ ដោយឡែក ក្នុងឆ្នាំសិក្សា២០១២-២០១៣នេះ បន្ថែមលើ អាហារូបករណ៍ផ្ដល់ឱ្យដោយរាជរដ្ឋាភិបាល អាហារូបករណ៍សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត អាហារូបករណ៍ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាហារូបករណ៍ធនាគារពិភពលោក អាហារូបករណ៍សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងដៃគូអភិវឌ្ឍន៍នានា និស្សិតបានទទួលអាហារូបករណ៍ RUA-JICF-JINNAI ជប៉ុន មានចំនួនសរុប ៥៥ នាក់ (និស្សិតម្នាក់ៗទទួលបាន ៤០០ ទៅ ៥០០ USD/ឆ្នាំ) និងអាហារូបករណ៍ Nagao Environment Scholarship ជប៉ុន ចំនួន ៨នាក់ (និស្សិតម្នាក់ៗទទួលបានថវិកា ២ ០០០យ៉េន/ខែ សម្រាប់ចំណាយលើការរស់នៅ)។

## ក.១.៤ ការស្រាវជ្រាវនិងផ្សព្វផ្សាយ

ដោយមានកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូជាតិនិងអន្តរជាតិ ក្នុងឆ្នាំ២០១៣កន្លងមកនេះ មន្ត្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មបានចូលរួមអនុវត្តគម្រោងស្រាវជ្រាវ និងគម្រោងអភិវឌ្ឍន៍ចំនួន២២គម្រោង ដែលមានប្រភេទគម្រោង ប្រភព និងថវិកាគម្រោងរួម ដូចខាងក្រោម:

| លរ | ប្រភេទគម្រោង | ប្រភព | ថវិការួម | លរ | ប្រភេទគម្រោង | ប្រភព | ថវិការួម |
|---|---|---|---|---|---|---|---|
| ១ | កសិកម្មសមស្រប | JICA | 67 669 298 ¥ | ១២ | វេទិកាស្រាវជ្រាវ | IDRC | 182 759$ |
| ២ | កែឆ្នៃអាហារ-ស្រា | JICA | 45 465 000¥ | ១៣ | អភិវឌ្ឍន៍ទីផ្សារគោ | ACIAR | 90 000$ |
| ៣ | សហការបណ្ដុះបណ្ដាល *MSc* | *Belgium* | 534 895 € | ១៤ | ស្មៅចង្រៃនិងទិន្នផលស្រូវ | ACIAR | 30 000$ |
| ៤ | ប៉ារ៉ាស៊ីតសត្វ | Belgium | 65 000 € | ១៥ | កសិកម្មចម្រុះសត្វនិងដំណាំ | ACIAR | 70 000$ |
| ៥ | *EURASIA II* | EC | n/a | ១៦ | ប៉ារាស៊ីតដំណាំ | CARF | 2 72 |
| ៦ | *Techno I, II* | EC | n/a | ១៧ | វារីវប្បកម្ម | CARF | 17 660 $ |
| ៧ | LOTUS III | n/a | n/a | ១៨ | ពង្រឹងសមត្ថភាពកសិករ -បម្រែបម្រួលអាកាសធាតុ | MoE, EC, UNDP, SIDA, Denmark | 300 000 $ |
| ៨ | ពង្រឹងសមត្ថភាពបសុពេទ្យ | USDA | 51 000 | ១៩ | បង្កើនសមត្ថភាព អប់រំកសិកម្ម | Czech | n/a |
| ៩ | គ្រប់គ្រងធនធានធម្មជាតិ | USAID | 106 000 $ | ២០ | ប្រព័ន្ធចិញ្ចឹមសត្វ | IFAD, CIAT | 65 000$ |
| ១០ | បន្លែសុវត្ថិភាព | USAID | 50 000 $ | ២១ | ការអនុវត្តន៍ទីវាល | LI | 3 800 $ |
| ១១ | ការប្រែប្រួលអាកាសធាតុនិងអភិបាលកិច្ចទឹកនៅកម្ពុជា | IDRC | 134 074,50 $ | ២២ | Agricultural Learning Exchange for Asian Regional Networking (AgLEARN) | USAID/Regional Development Mission | 42 000 $ |

### ក.១.៥ ការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស

នៅក្នុងឆ្នាំ២០១៣សាកលវិទ្យាល័យបានធ្វើការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក ដោយបានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលខ្លីក្រៅប្រទេសចំនួន៦លើក ចូលរួមសិក្ខាសាលា កិច្ចប្រជុំ សន្និសីទចំនួន២៥លើក។ មន្ត្រីនិងបុគ្គលិកចំនួន២១រូបកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបណ្ឌិតនៅក្រៅប្រទេស។ បន្ថែមពីលើនេះ សាកលវិទ្យាល័យបានបញ្ជូននិស្សិតចំនួន២៨រូបទៅចូលរួមវគ្គបណ្តុះបណ្តាលនិងកម្មសិក្សាក្រៅប្រទេស និងបញ្ជូននិស្សិតចំនួន៤០រូបទៅធ្វើកម្មសិក្សាទៅប្រទេសអ៊ីស្រាអែល។

### ក.១.៦ ការវាយតម្លៃរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា

ក្រោយពីទទួលបានការទទួលស្គាល់ពេញសិទ្ធិពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សម្រាប់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ក្នុងគោលបំណងបង្កើនគុណភាពអប់រំរបស់ខ្លួន សាកលវិទ្យាល័យភូមិន្ទកសិកម្មបានដាក់ពាក្យស្នើសុំទៅគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីមកធ្វើការវាយតម្លៃគុណភាពអប់រំរបស់សាកលវិទ្យាល័យទាំងមូល ហើយនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា បានទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ននៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលមានរយៈពេលបីឆ្នាំ។

### ក.២ សន្និដ្ឋាននិងការវាយតម្លៃ

ជារួមអាស្រ័យដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ថ្នាក់ដឹកនាំក្រសួង និងក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ និងជាពិសេសការខិតខំប្រឹងប្រែងផ្ទាល់របស់ថ្នាក់ដឹកនាំ មន្ត្រីសាស្ត្រាចារ្យ បុគ្គលិក និងកម្មករ ពេលនេះសាកលវិទ្យាល័យភូមិន្ទកសិកម្មបានទទួលនូវទំនុកចិត្តខ្ពស់ពីសំណាក់និស្សិតនិងអាណាព្យាបាលហើយដែលធ្វើឲ្យកំណើននិស្សិតចូលសិក្សាមានការកើនឡើងជាលំដាប់ ។ សាកលវិទ្យាល័យបានយកចិត្តទុកដាក់ជាសំខាន់លើការអប់រំប្រកបដោយគុណភាពនិងផ្សាភ្ជាប់ជាមួយសេចក្តីត្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននិងទៅអនាគត ដោយយកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិជាកត្តាចំបង ។

អ្វីដែលសាកលវិទ្យាល័យភូមិន្ទកសិកម្មសម្រេចបានមកដល់ពេលនេះ គ្រាន់តែជាភាពជោគជ័យមួយផ្នែកប៉ុណ្ណោះ បើប្រៀបធៀបនឹងសេចក្តីត្រូវការអភិវឌ្ឍន៍ដ៏ធំធេងរបស់សាកលវិទ្យាល័យ ។ ដូចនេះសាកលវិទ្យាល័យមានផែនការយុទ្ធសាស្ត្រ ក្នុងការកសាងធនធានសាស្ត្រាចារ្យឲ្យបានរឹងមាំនិងគ្រប់ចំនួន កសាងហេដ្ឋារចនាសម្ព័ន្ធអាគារសិក្សា មន្ទីរពិសោធន៍ សម្ភារៈពិសោធន៍ស្រាវជ្រាវ ស្ថានីយ៍អនុវត្តជាក់ស្តែង និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ជីវិតសិក្សារបស់និស្សិតចាំបាច់ជាច្រើនទៀត ដូចជា អាហារដ្ឋានទំនើប បណ្ណាល័យ បណ្ណាគារទំនើប ពហុកីឡដ្ឋាន អន្តេវាសិកដ្ឋាន និងមណ្ឌលសិល្បៈកំសាន្តជាដើម ។

## ខ. សាលាជាតិកសិកម្មព្រែកលៀប

### ខ.១. លទ្ធផល

### ខ.១.១-ការបង្កើនប្រសិទ្ធភាពការដឹកនាំនិងគ្រប់គ្រងអង្គភាព

#### ១.១ ការងារដឹកនាំ

ក្នុងឆ្នាំ២០១៣ ក្រុមប្រឹក្សាភិបាលសាលាជាតិកសិកម្មព្រែកលៀប អាណត្តិទី៣ បានបន្តដឹកនាំចង្អុលណែនាំ និងធ្វើការប្រជុំដោយពិភាក្សាការងារបានចំនួន០៣លើក ដើម្បីពិនិត្យលទ្ធផលការងារសាលាជាតិ (១)របាយការណ៍ស្តីពីវឌ្ឍនភាពការងារសាលាជាតិកសិកម្មព្រែកលៀប (២) ការងារហិរញ្ញវត្ថុ ឆ្នាំ២០១៣ (៣) សេចក្តីព្រាងអនុក្រឹតស្តីពីការប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀបទៅជាវិទ្យាស្ថានជាតិកសិកម្មមានលក្ខណៈជាគ្រឹះស្ថានសាធារណៈរដ្ឋបាល (៤) បទបញ្ជាផ្ទៃក្នុងសាលាជាតិកសិកម្មព្រែកលៀប (៥) កម្មវិធីសិក្សាថ្នាក់បន្ត និងបឋម។

## ១.២ ស្ថានភាពបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

ស្ថានភាពមន្ត្រីបុគ្គលិកសាលាជាតិគីនៅក្នុងឆ្នាំ២០១៣ មានចំនួន **១៣៣** នាក់ នារី **៣៧** នាក់ និងមាន កម្រិតសញ្ញាបត្រជំនាញដូចខាងក្រោម÷

- បណ្ឌិត ០១នាក់ ស្រី ០០ នាក់ - អនុបណ្ឌិត ៤៨នាក់ ស្រី ១០ នាក់
- បរិញ្ញាបត្រ ៧២ នាក់ ស្រី ២៣ នាក់ - បរិញ្ញាបត្ររង ០៤ នាក់ ស្រី ០០ នាក់
- កម្រិតបឋម ០២ នាក់ ស្រី ០១ នាក់ - គ្មានជំនាញ ០៦ នាក់ស្រី ០៣ នាក់

## ១.៣ ការងារកសាងហេដ្ឋារចនាសម្ព័ន្ធបម្រើការឲ្យការងារបណ្ដុះបណ្ដាល

ក្នុងឆ្នាំ២០១៣នេះ សាលាជាតិបានជួសជុលនិងកសាង អាគារ០១ខ្នងជាការិយាល័យដេប៉ាតឺម៉ង់កសិ-ឧស្សាហកម្ម រៀបចំសួនច្បារឡើងវិញដោយដាំដើមឈើលម្អតាមប្លង់ដែលបានសិក្សារួច រៀបចំកន្លែងស្នាក់នៅសម្រាប់និស្សិតបុរស-នារីប្រកបដោយលទ្ធផលល្អប្រសើរ រៀបចំតបណ្ដាញទឹកបូមពីទន្លេចូលទៅកន្លែងពិសោធន៍ដំណាំបន្លែគ្រប់ប្រភេទ ជីកស្រះតូចចំនួន០៥សម្រាប់និស្សិតវិទ្យាសាស្ត្រជលផលអនុវត្តចិញ្ចឹមត្រី សាងសង់ទ្រុងមាន់តូចៗចំនួន១០សម្រាប់និស្សិតវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វពិសោធន៍ចិញ្ចឹមមាន់ ជួសជុលបន្ទប់ទឹកអាគារ A និង B ជាន់ទី Eo និង $E_1$ និងរៀបចំទ្រុងចិញ្ចឹមជ្រូកសម្រាប់និស្សិតវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វអនុវត្ត។

## ១.៤ ការងារបណ្ដុះបណ្ដាល

ស្ថិតិនិស្សិតកំពុងសិក្សា ឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន **១៥៦២** នាក់ ស្រី **៥០២** នាក់ ក្នុងនោះ សរុបអាហារូបករណ៍ ១២០៥ នាក់ ស្រី ៤៣៨ នាក់ អាហារូបករណ៍ព្រឹទ្ធសភាថ្នាក់បរិញ្ញាបត្រ ចំនួន ០៣នាក់ អាហារូបករណ៍សម្ដេច ហ៊ុន សែន ថ្នាក់បរិញ្ញាបត្រ ចំនួន ៥៧ នាក់ ស្រី ២០ នាក់ អាហារូបករណ៍ឯកឧត្តម ច័ន្ទ សារុន សរុប ៧៦ នាក់ក្នុងនោះ ថ្នាក់បរិញ្ញាបត្ររង ចំនួន ០៥ នាក់ ស្រី ០៣ នាក់ និងថ្នាក់បរិញ្ញាបត្រ ចំនួន ៧១ នាក់ ស្រី ១៨ នាក់

## ១.៥ លទ្ធផលនៃការបញ្ចប់ការសិក្សារបស់និស្សិតក្នុងឆ្នាំ២០១៣

### ១.៥.១ លទ្ធផលនៃការបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាប័ត្រ

| ល.រ | ជំនាញ | អាហារូបករណ៍ | | បណ្ដុះបណ្ដាលបន្ត | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | បេក្ខជន | ស្រី | បេក្ខជន | ស្រី | ជាប់ជាស្ថាពរ | ស្រី | ខ្សោយ (ធ្លាក់) |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៣១ | ១៤ | ៣២ | ១៤ | ៦៣ | ២៨ | |
| ២ | វិទ្យាសាស្ត្រព្រៃឈើ | ៣០ | ០៤ | | | ៣០ | ០៤ | |
| ៣ | វិទ្យាសាស្ត្រជលផល | ២០ | ០២ | | | ២០ | ០២ | |
| ៤ | វិទ្យាសាស្ត្រ និង វេជ្ជសាស្ត្រសត្វ | ៣៨ | ០៩ | ១១ | ០ | ៤៩ | ០៩ | |
| ៥ | ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ជនបទ | ២២ | ០៤ | | | ២២ | ០៤ | |
| ៦ | សាកវប្បកម្ម | ២០ | ១០ | | | ២០ | ១០ | |
| ៧ | សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ១៩ | ១២ | | | ១៩ | ១២ | |
| ៨ | កសិ-ឧស្សាហកម្ម | ១២ | ០៥ | | | ១២ | ០៥ | |
| ៩ | សុវិយោដី | ២៤ | ០៤ | | | ២៤ | ០៤ | |
| | **សរុប** | **២១៦** | **៦៤** | **៤៣** | **១៤** | **២៥៩** | **៧៨** | |

### ១.៥.១ លទ្ធផលនៃការបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាប្រ័តរង

| ល.រ | ជំនាញ | អាហារូបករណ៍ | | បណ្តុះបណ្តាលបន្ត | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | បេក្ខជន | ស្រី | បេក្ខជន | ស្រី | ជាប់ជាស្ថាពរ | ស្រី | ខ្សោយ (ធ្លាក់) |
| ១ | ជំនាញ ក្សេត្រសាស្ត្រ | ២៦ | ០៧ | | | ២៦ | ០៧ | |
| ២ | ជំនាញ រុក្ខកម្ម | ០៤ | ០១ | | | ០៤ | ០១ | |
| ៣ | ជំនាញ ជលផល | ០៧ | ០១ | | | ០៧ | ០១ | |
| ៤ | ជំនាញ ផលិតកម្ម និងបសុព្យបាល | ៣២ | ០៤ | ៣១ | ០៦ | ៦២ | ០៩ | ០១ |
| ៥ | ជំនាញ ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ជនបទ | ១៥ | ០៧ | | | ១៥ | ០៧ | |
| ៦ | ជំនាញ សាកវប្បកម្ម | ១៤ | ០៥ | | | ១៤ | ០៥ | |
| ៧ | ជំនាញ សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ១២ | ០៦ | | | ១២ | ០៦ | |
| ៨ | ជំនាញ កសិ-ឧស្សាហកម្ម | ០៨ | ០៤ | | | ០៨ | ០៤ | |
| ៩ | ជំនាញ សុរិយោដី | ១០ | ០៤ | | | ០៩ | ០៤ | ០១ |
| | សរុប...................... | **១២៨** | **៣៩** | **៣១** | **០៦** | **១៥៧** | **៤៤** | ០២ |

### ១.៦ ការចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

ក្នុងឆ្នាំ២០១៣នេះ សាលាជាតិបានបញ្ជូនថ្នាក់ដឹកនាំ សាស្ត្រាចារ្យ និស្សិតចូលរួម និងរៀបចំសិក្ខាសាលាសំដៅធ្វើការស្វែងយល់នូវការងារមួយចំនួនទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គម្រោងអភិវឌ្ឍន៍ក្នុង វិស័យកសិកម្ម ច្បាប់ និងបទដ្ឋានគតិយុត្តិក្នុងវិស័យកសិកម្ម សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ផែនការថវិកា ផែនការអភិវឌ្ឍន៍ បានចំនួន៦៩លើក ព្រមទាំងបានរៀបចំវគ្គបណ្តុះបណ្តាលនិងការសិក្សាស្រាវជ្រាវនៅក្នុងសាលាបានចំនួន៣៧លើក។

### ១.៧ ការងារសហការជាមួយគម្រោងនានា

បានទទួលថវិកាមូលនិធិនិងថវិកាបដិភាគសរុបចំនួន១៧៥,១៣៦ ពីមូលនិធិរបស់អគ្គនាយកដ្ឋានឧត្តមសិក្សា សម្ពន្ធភាព បម្រែបម្រួលអាកាសធាតុកម្ពុជានៃក្រសួងបរិស្ថាន ព្រមទាំងថវិការបស់រាជរដ្ឋាភិបាលចំនួន១០២,២៥៩,៨៤ ដុល្លារ។ ក្រៅពីនេះ សាលាក៏បានសហការជាមួយក្រុមហ៊ុនកូរ៉េដើម្បីរៀបចំបង្រៀនភាសាកូរ៉េ និងបើករោងជាងជួសជុលគ្រឿងយន្តដល់និស្សិត។

## ២.២. សន្និដ្ឋាន

ក្នុងការបណ្តុះបណ្តាលធនធានមនុស្សបម្រើឱ្យវិស័យកសិកម្ម រុក្ខកម្ម ជលផល បរិស្ថាន និងអភិវឌ្ឍន៍ជនបទ ទោះបីធនធាននិងមធ្យោបាយការងារនៅមានកម្រិតមិនគ្រប់គ្រាន់តាមសំណូមពរចាំបាច់ការងារក្នុងឆ្នាំ២០១៣នេះ សាលាជាតិបានពុះពាររាល់ការលំបាកប្រឈមមុខជាច្រើន ដូចជាការគ្រប់គ្រងដីធ្លីសាលាជាតិដែលមានស្រាប់ ការរៀបចំជួសជុលអាគារសិក្សា អាគារធ្វើការ និងការបំពាក់សម្ភារៈឧបករណ៍ឱ្យមានលក្ខណៈទំនើបតាមបទដ្ឋានរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) ជាដើម ។

**ចំណុចខ្លាំងដែលសាលាជាតិមានគឺ:**

- ធ្វើការកសាងបាននូវលិខិតបទដ្ឋានជាច្រើនសម្រាប់ការងារបណ្តុះបណ្តាលតាមការកំណត់របស់គ.ទ.ក ដូចជាកម្មវិធីថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន កម្មវិធីថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររង រួមមានរចនាសម្ព័ន្ធ មុខវិជ្ជា និងប្លង់គោលមុខវិជ្ជា លិខិតបទដ្ឋានវាយតម្លៃការបង្រៀនរបស់សាស្ត្រាចារ្យ លិខិតបទដ្ឋានសម្រាប់ការសិក្សារបស់និស្សិត ។ ល ។
- កម្រិតសមត្ថភាពរបស់សាស្ត្រាចារ្យ បុគ្គលិក សាលាជាតិបានកើនឡើងជាលំដាប់ ធ្វើឱ្យការបណ្តុះបណ្តាល

មានលក្ខណៈរលូនជាប្រក្រតីក្នុងប្រព័ន្ធក្រឌីត។ ជាក់ស្តែងក្នុងឆ្នាំ២០១២-២០១៣នេះសាលាជាតិមាននិស្សិតកំពុងសិក្សាសរុប **១៩៩៨**នាក់ នារី **៦៩៨**នាក់ នៅចុងឆ្នាំ២០១៣ និស្សិតដែលបានប្រលងបញ្ចប់ការសិក្សាដោយជោគជ័យមានចំនួន **៤១៦**នាក់ (នារី**១២២**នាក់) មាន៩ជំនាញ បន្ទាប់ពីបានចុះសិក្សាស្រាវជ្រាវរយៈពេលបីខែ និងសរសេររបាយការណ៍រួចមក នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣ បានអនុញ្ញាតឱ្យចូលប្រលង។

- ទោះបីទុននិងមធ្យោបាយបម្រើការងារមានកម្រិត ប្រេងឥន្ធនៈជាដើម សាលាជាតិបានយកចិត្តទុកដាក់ចាត់ចែងឱ្យមានកម្មវិធីចុះទស្សនៈកិច្ចសិក្សារបស់និស្សិត សាស្ត្រាចារ្យក្នុងន័យពង្រីកទ្រឹស្តីបង្រៀន និងការសិក្សារបស់និស្សិតឱ្យមានការវិវត្តន៍សមស្រប និងកាងារជាក់ស្តែងក្នុងមូលដ្ឋានផលិតកម្ម និងអាជីវកម្ម។

- ការងារជួសជុលកសាងហេដ្ឋារចនាសម្ព័ន្ធ និងការងារកសាងសោភ័ណភាពសាលាបានផ្អែកលើភាពម្ចាស់ការច្នៃប្រឌិត ធ្វើការជួសជុលកែលំអតាមរយៈទំនាក់ទំនងជាមួយសប្បុរសជនជាតិ អន្តរជាតិ និងថវិការដ្ឋដោះស្រាយបានមួយចំនួននូវបញ្ហាប្រឈម មានដូចជាការខ្វះបន្ទប់រៀន សម្ភារបម្រើការបង្រៀន និងរៀន។

- ជួសជុលការរៀបចំការិយាល័យបំពេញការងាររបស់មន្ត្រី បុគ្គលិក សាស្ត្រាចារ្យ ហើយនិងកែលំអសោភ័ណភាពសាលាជាតិបានសមស្របជាបរិស្ថាន គរុកោសល្យជាបណ្តើរៗ។

**ការលំបាក**

- ឥណទានប្រចាំឆ្នាំ២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្តល់មកសាលាពុំបានគ្រប់គ្រាន់ធ្វើឱ្យតម្រូវការមួយចំនួនបានដោះស្រាយបានដូចជា ទូទាត់ថ្លៃប្រើប្រាស់អគ្គិសនី ជួសជុលថែទាំឧបករណ៍ផ្សេងៗមាន តុ កៅអី កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព Overhead Projector ម៉ាស៊ីនថតចម្លង ម៉ាស៊ីន LCD រថយន្តដឹកជញ្ជូននិស្សិតចុះកម្មសិក្សា

- ធនធានសម្ភារ ដូចជាកុំព្យូទ័រ ម៉ាស៊ីនថតចម្លងជាដើម មធ្យោបាយបម្រើការងាររដ្ឋបាល ក៏ដូចជាការងារបណ្តុះបណ្តាលមានការខ្វះខាតមិនគ្រប់គ្រាន់ និងចាស់ទ្រុឌទ្រោមហួសសម័យបណ្តាលឱ្យកិច្ចការបណ្តុះបណ្តាលពិបាកក្នុងការសម្រេចទិសដៅ

- ការទំនាក់ទំនងពីអង្គភាពមួយទៅអង្គភាពមួយទៀត មានការយឺតយ៉ាវពុំបានទទួលព័ត៌មានឱ្យបានទាន់ពេលវេលា

- ខ្វះធនធានមនុស្សដែលមានកម្រឹតសមត្ថភាព និងជំនាញគ្រប់គ្រាន់បំពេញតម្រូវការឱ្យសមស្របជាមួយការវិវត្តន៍និងសាកលភាវូនីយកម្ម

- នាមឈ្មោះជាសាលាជាតិ មានការយល់ច្រឡំពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិបង្កឱ្យមានការលំបាកក្នុងការរកដៃគូធ្វើការសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ វិទ្យាស្ថាន អង្គការជាតិ និងអន្តរជាតិនានា

- សាលាជាតិមានភារកិច្ចបណ្តុះបណ្តាលចំនួន១០ជំនាញ បរិមាណមន្ត្រី បុគ្គលិកតិច បរិមាណផ្ទៃដីធំនិងអាគារភាគច្រើនចាស់ទ្រុឌទ្រោម ។ ល ។ ប៉ុន្តែទទួលបានគម្រោងថវិកាសម្រាប់ការចំណាយពីរដ្ឋមានកម្រឹតទាប។

**បញ្ហាប្រឈម**

- បរិមាណធនធានមនុស្សនៃមន្ត្រីបុគ្គលិករបស់សាលាជាតិនៅមានកម្រឹត ហើយបានទទួលភារកិច្ចទទួលខុសត្រូវតាមបែបវិមជ្ឈការ និងសហវិមជ្ឈការ។ ប៉ុន្តែកម្រិតនៃការទទួលខុសត្រូវ ក៏ដូចជាការគ្រប់គ្រងដឹកនាំការងារតាមផ្នែកនិងជំនាញទទួលបន្ទុកមានកម្រឹត និងមានភាពធូររលុង។

- មិនទាន់បានការយកចិត្តទុកដាក់តាមដានការសិក្សារបស់និស្សិតឱ្យបានស៊ីជម្រៅ ពិសេសលើនិន្នេសលើ ការសិក្សា។ ផ្នែកព័ត៌មាននិងទីផ្សារការងាររបស់និស្សិតមិនទាន់បានយកចិត្តទុកដាក់បំពេញការងារឱ្យឆ្លើយតប ទៅនិងភារកិច្ចដែលបានប្រគល់ជូន

- មជ្ឈមណ្ឌលឯកសាររបស់សាលាជាតិ មិនទាន់មានឯកសារគ្រប់គ្រាន់ក្នុងការបង្កលក្ខណៈឱ្យនិស្សិត និងអ្នកស្រាវជ្រាវមានលទ្ធភាពស្វែងយល់ និងស្វែងរកឯកសារបានតាមសំណូមពរ ឬតម្រូវការ

- ការអប់រំនិស្សិតឱ្យស្រលាញ់ចូលចិត្ត និងចេះស្រាវជ្រាវតាមរយៈការអានសៀវភៅ ឯកសារ ការស្តាប់ ការតាមដាន ការវិវត្តន៍ផ្សេងៗក្នុងសង្គម ហើយចេះធ្វើការវិភាគវាយតម្លៃ និងសន្និដ្ឋានឱ្យបានស៊ីជម្រៅនៅមានកម្រឹត។

**ខ.៣. ទិសដៅ**

- ការពង្រឹងបទបញ្ជាផ្ទៃក្នុង
- កែលម្អកម្មវិធីសិក្សា និងខ្លឹមសាមេរៀន
- ការងារបណ្តុះបណ្តាលសមត្ថភាពគ្រូបង្រៀន
- ការងារទាក់ទង និងតភ្ជាប់កិច្ចសហការជាមួយអន្តរជាតិ ។
- អនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីរយៈពេលវែង ឬមធ្យម (៣ឆ្នាំ ឬ៥ឆ្នាំ) សម្រាប់ជាទិសដៅអនុវត្ត

**គ. សាលាជាតិកសិកម្មកំពង់ចាម**

គ.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០**១២**-២០១**៣** សរុប**មានចំនួន១.៥៥៩**នាក់ **(ស្រី៦០៨នាក់)**ក្នុងនោះ ÷

- និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់ (ស្រី៥៣៥នាក់) ក្នុងនោះ ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់ (ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់ (ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ។

**គ.២. ការងារពិសោធន៍ស្រាវជ្រាវ**

- ធ្វើការពិសោធន៍ដំណាំសណ្តែកសៀង
- ធ្វើការពិសោធន៍លើប្រសិទ្ធភាពជីអាសូត ផូស្វរ ប៉ូតាស្យូម លើការលូតលាស់ដំណាំម្ទេសដៃនាង
- ពិសោធន៍តាមដានការលូតលាស់ជ្រូកមេក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់ចំណីឧស្សាហកម្ម។

**គ.៣. ការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិជ្ជាកសិកម្ម**

- លើកគម្រោងចំនួន១១ស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទស្តីពីការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ
- បន្តការងារស្រាវជ្រាវផលិតកម្មដំណាំស្រូវ ដែលបានឧបត្ថម្ភជំនួយពី ACIAR-CARF
- បន្តការងារស្រាវជ្រាវលើបសុវប្បកម្ម ដែលបានឧបត្ថម្ភជំនួយពី DEL-phe(UK)
- ផ្សព្វផ្សាយពីការធ្វើឥណទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ-ក្របី នៅតាម មូលដ្ឋានឃុំ-ស្រុក ក្នុងខេត្តកំពង់ចាម
- ផ្តល់ជ្រូកពូជជូនដល់កសិករក្រីក្រនៅស្រុកត្រាំកក់ខេត្តតាកែវនិងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមបានចំនួន ១៨គ្រួសារ
- ធ្វើការប្រជុំកសិករណែនាំពីការប្រើប្រាស់ថ្នាំកសិកម្ម ជីគីមី និងជីសរីរាង្គ នៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

## ៥.៩.៣- ការងារគណនេយ្យ-ហិរញ្ញវត្ថុ

## ១. លទ្ធផល

### ក. ការងារចំណូល

ក្នុងឆ្នាំ២០១៣ ការប្រមូលចំណូលចូលថវិកាជាតិសម្រេចបានចំនួន៧២.៣៩៥.៤៦១.៥៧៦រៀល ដែលមានប្រមាណ២៤៣% នៃផែនការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ២៩ ៧២៤ ០០០ ០០០រៀលក្នុងនោះ :

-ចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋសម្រេចបានចំនួន៥៨ ០២៥ ១៤៥ ១៤៨ រៀល ដែលមានប្រមាណ២៣៦% នៃផែនការចំនួន២៤ ៥៤២ ០០០ ០០០ រៀល

-ចំណូលផលទុនលើការលក់ ដូលទ្រព្យសម្បត្តិ និងសេវា ប្រមូលបានចំនួន៤ ២៧៦ ៨៩៤ ៤៣០ រៀលស្មើនឹង ១០២% នៃផែនការដែលមានចំនួន៤ ១៨២ ០០០ ០០០រៀល ។

-ចំណូលបានមកពីការផាកពិន័យ និងដាក់ទណ្ឌកម្មចំនួន១០ ០៩៣ ៤២១ ៩៩៨ រៀលស្មើនឹង ១០០៩%នៃផែនការចំនួន១ ០០០ ០០០ ០០០រៀល។

## ខ. ការងារចំណាយ

ការអនុវត្តនិងគ្រប់គ្រងថវិកាប្រចាំឆ្នាំ២០១៣ សម្រេចបានប្រមាណ៩៣,២០% នៃថវិកាកែតម្រូវ។ ការចំណាយថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានញែកដាច់ពីគ្នារវាងថវិកាតាមកម្មវិធី និងថវិកាមិនមែនកម្មវិធី ដូច្នេះយើងអាចវិភាគខ្ទង់ចំណាយថវិកានីមួយៗដូចខាងក្រោម :

**១-ថវិកាមិនមែនកម្មវិធី**: ការចំណាយលើការងាររដ្ឋបាលប្រចាំថ្ងៃ និងការអនុវត្តប្រចាំឆ្នាំ អនុវត្តបានប្រមាណ៥៩ ៨៥៦ ៥០៣ ៤៨៩រៀល ស្មើនឹង ៩៣,៦០% នៃថវិកាកែតម្រូវចំនួន ៦៣ ៩៣៨ ១៦៦ ០០០ រៀល។ការចំណាយតាមជំពូកនិមួយៗមានដូចខាងក្រោម :

**ជំពូក ៦០**: ការទិញអនុវត្តជាក់ស្តែងបានចំនួន ១២ ២៧៦ ៧១៨ ៣៨៤រៀល ស្មើនឹង ៩៤,៤០% នៃថវិកាកែតម្រូវដែលមានត្រឹមតែចំនួន ១៣ ០០៥ ០០០ ០០០រៀល

**ជំពូក ៦១**: សេវាខាងក្រៅអនុវត្តជាក់ស្តែងបានចំនួន ១ ៦០៤ ២៨០ ៨៨៥រៀល ស្មើនឹង ៧៤,៥០%នៃថវិកាកែតម្រូវដែលមានចំនួន ២ ១៥៤ ០០០ ០០០រៀល

**ជំពូក ៦២**: សេវាក្រៅផ្សេងៗអនុវត្តជាក់ស្តែងបានចំនួន៤ ៤៦៨ ៤៦៣ ០២៣រៀលស្មើនឹង ៨៥,១០%នៃថវិកាកែតម្រូវដែលមានចំនួន៥ ២៥០ ២១៥ ០០០រៀល

**ជំពូក ៦៣**: ពន្ធ និងអាករ អនុវត្តជាក់ស្តែងបានចំនួន២០៥ ១១១ ០០០រៀល ស្មើនឹង ៨២,០០%នៃថវិកាកែតម្រូវដែលមានចំនួន ២៥០ ០០០ ០០០រៀល

**ជំពូក ៦៤**: បន្ទុកបុគ្គលិកអនុវត្តជាក់ស្តែងបានចំនួន៣៣ ៤៣០ ៦៧៥ ៣៨២ រៀល ស្មើនឹង ៩៧,៦០%នៃថវិកាកែតម្រូវដែលមានចំនួន៣៤ ២៦៣ ១៦៦ ០០០រៀល

**ជំពូក ៦៥**: ឧបត្ថម្ភធន និងជំនួយសង្គមអនុវត្តជាក់ស្តែងបានចំនួន៧ ៨៧១ ២៥៤ ៨៥៥រៀលស្មើនឹង ៨៧,៣០%នៃថវិកាកែតម្រូវដែលមានចំនួន៩ ០១៥ ៧៨៥ ០០០រៀល។

**២-ថវិកាតាមកម្មវិធី** :ការចំណាយថវិកាសំដៅសម្រេចឲ្យបានគោលបំណង គោលដៅ និងលទ្ធផលរំពឹងទុក របស់វិស័យនិមួយៗដែលបានកំណត់ពីដើមឆ្នាំ២០១៣នេះការប្រើប្រាស់ថវិកាតាមកម្មវិធីមានលក្ខណៈល្អប្រសើរ ច្រើនធៀបនឹងឆ្នាំ២០១២ ជាក់ស្តែងក្រសួងអនុវត្តបានចំនួន ២០ ២៣៩ ៦៣៦ ៣៥០រៀល ដែលមានប្រមាណ ៩២,២០% នៃថវិកាកែតម្រូវចំនួនប្រមាណ២១ ៩៥៧ ៤០០ ០០០រៀល។ការចំណាយតាមជំពូកនីមួយៗមានដូចខាងក្រោម:

**ជំពូក ៦០**: ការទិញអនុវត្តជាក់ស្តែងបានចំនួន៨ ៨៦២ ២៤៥ ៣៥០ រៀល ស្មើនឹង ៩៦,៥០%នៃថវិកាកែតម្រូវដែលមាន៩ ១៨២ ៤០០ ០០០រៀល

**ជំពូក ៦១**: សេវាខាងក្រៅអនុវត្តជាក់ស្តែងបានចំនួន៥ ៦៤០ ២២២ ៨០០ រៀល ស្មើនឹង ៨៣,២០%នៃថវិកាកែតម្រូវដែលមានចំនួន៦ ៧៧៧ ០០០ ០០០រៀល

**ជំពូក ៦២**: សេវាក្រៅផ្សេងៗអនុវត្តជាក់ស្តែងបានចំនួន៥ ៧០៧ ១៦៨ ២០០ រៀល ស្មើនឹង ៩៥,៦០%នៃថវិកាកែតម្រូវដែលមានចំនួន៥ ៩៦៨ ០០០ ០០០រៀល

**ជំពូក ៦៥**: ឧបត្ថម្ភធន និងជំនួយសង្គមអនុវត្តជាក់ស្តែងបានចំនួន៣០ ០០០ ០០០ រៀល ស្មើនឹង ១០០%នៃថវិកាកែតម្រូវដែលមានចំនួន៣០ ០០០ ០០០រៀល។




### គ. ការងារផ្គត់ផ្គង់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | | |
|---|---|---|
| ប្រេងឥន្ធនៈគិតជាទឹកប្រាក់សរុបចំនួន: | | ២ ១៩៩ ៩៨៧ ៥៥០៖០០ |
| +ប្រេងម៉ាស៊ូត | មានទឹកប្រាក់ ចំនួន | ១ ៨៥៤ ៩៩១ ៧០០៖០០ |
| +ប្រេងសាំង | មានទឹកប្រាក់ចំនួន: | ៣៤៤ ៩៩៥ ៨៥០៖០០ |
| សម្ភារការិយាល័យ | មានទឹកប្រាក់ចំនួន | ៤៥៦ ៩៨៥ ០០០៖០០ |
| សម្ភារបរិក្ខារនិងសង្ហារិម | មានទឹកប្រាក់ចំនួន | ៦៤៩ ៥៩០ ០០០៖០០ |
| ឯកសណ្ឋាន | មានទឹកប្រាក់ចំនួន | ២៥៧ ១៩៤ ០០០៖០០ |
| សម្ភារនិងបរិក្ខារពិសោធន៍ | មានទឹកប្រាក់ចំនួន | ៤ ៤៨៧ ៣៦២ ០០០៖០០ |

### ឃ. ការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចូលរួមបិទបញ្ជីចំណូលចំណាយ និងពិនិត្យបញ្ជីសារពើភណ្ឌឆ្នាំ២០១២នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសាកលវិទ្យាល័យភូមិន្ទកសិកម្មវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាសាលាជាតិកសិកម្មព្រែកលៀបនិងសាលាជាតិកសិកម្មកំពង់ចាម

-ចូលរួមពិនិត្យនិងផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះឆ្នាំ២០១២របស់មន្ទីរកសិកម្មខេត្តរតនគិរី ពោធិ៍សាត់ កំពង់ឆ្នាំង ព្រះសីហនុ កំពត កែប មណ្ឌលគិរី បាត់ដំបង កណ្តាល និងបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ស្នើសុំគោលការណ៍រៀបចំនីតិវិធីនិងចូលរួមដេញថ្លៃលក់នូវទ្រព្យសម្បត្តិចាស់ ខូចទ្រុឌទ្រោមប្រើប្រាស់លែងកើតដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរកសិកម្មខេត្តស្ទឹងត្រែង កំពង់ស្ពឺ មណ្ឌលគិរី កំពត រដ្ឋបាលជលផលនិងរបស់នាយកដ្ឋានកិច្ចការរដ្ឋបាល

- ចុះពិនិត្យនិងវាយតម្លៃជាក់ស្តែងគុណភាពបច្ចេកទេសនូវទ្រព្យសម្បត្តិ ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ខណ្ឌរដ្ឋបាលព្រៃឈើ កំពង់ចាម ក្រចេះ កំពង់ធំ ឧត្តរមានជ័យ កំពង់ឆ្នាំង បាត់ដំបង បន្ទាយមានជ័យ សៀមរាប កណ្តាល និងមន្ទីរកសិកម្មខេត្តកែប

- ចូលរួមប្រជុំឆ្លងកំណត់ហេតុកំណត់ទុនគ្រាដំបូងនិងរៀបចំធ្វើលិខិតជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើសុំពិនិត្យនិងចុះហត្ថលេខាលើតារាងតុល្យការចាប់ផ្តើមរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងសាលាជាតិកសិកម្មកំពង់ចាម

- រៀបចំធ្វើលិខិតជម្រាបជូនទៅប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ប្រធានអង្គភាពគ្រប់គ្រងគម្រោងទាំងអស់និងប្រធានមន្ទីរកសិកម្មរាជធានីខេត្តស្តីពី សំណើសុំបំពេញបែបបទប្រគល់ទទួលនិងផ្តល់ឯកសារពាក់ព័ន្ធពេលគម្រោងត្រូវបានបញ្ចប់ហើយផ្ទេរទ្រព្យសម្បត្តិទាំងនោះ ជូនក្រសួងស្ថាប័នរាជធានីខេត្តសម្រាប់កត់ត្រាក្នុងបញ្ជីសារពើភណ្ឌប្រើប្រាស់ជាទ្រព្យសម្បត្តិរដ្ឋ

- ចុះពិនិត្យស្រាវជ្រាវនិងវាយតម្លៃជាក់ស្តែងកំណត់ឲ្យបានច្បាស់លាស់ នូវផ្ទៃដីមានដើមកៅស៊ូធ្វើអាជីវកម្មផ្ទៃដីមិនទាន់ចៀរជ័រនិងផ្ទៃដីនៅទំនេរចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគិរី

- រៀបចំលិខិតជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនូវដីអតីតចម្ការម្រេចទំហំ៧,២០ហិកតាស្ថិតនៅភូមិទឹកប៉ោងឃុំបឹងព្រាវស្រុកស្រែអំបិលខេត្តកោះកុងរបស់មន្ទីរកសិកម្មខេត្តកោះកុង ដែលប្រជាពលរដ្ឋបានចូលកាន់កាប់តាំងទីលំនៅយូរមកហើយ

- រៀបចំធ្វើលិខិតជម្រាបជូនទៅអគ្គនាយដ្ឋានកៅស៊ូ ស្នើសុំផ្តល់ទិន្នន័យតម្លៃលក់មធ្យមភាគកៅស៊ូ (ជ័រក្រែប) គ្រប់ប្រភេទប្រចាំឆ្នាំ២០១២

- ចុះពិនិត្យនិងវាយតម្លៃជាក់ស្តែងគុណភាពបច្ចេកទេស នូវមធ្យោបាយដឹកជញ្ជូនបទល្មើសព្រៃឈើ ដែលតុលាការបានសម្រេចរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ តាមរយៈសាលក្រមឬសាលដិកាស្ថាពរគិតត្រឹមដំណាច់ឆ្នាំ២០១១ នៅតាមបណ្តាខណ្ឌនានារបស់រដ្ឋបាលព្រៃឈើ

- ចុះពិនិត្យនិងវាយតម្លៃការដោះដូរទីតាំងមន្ទីរកសិកម្មខេត្តស្វាយរៀងនិងកំពង់ចាម ដែលស្នើសុំផ្លាស់ប្តូរទៅទីតាំងថ្មី

- ពិនិត្យការសាងសង់អគារដែលជាថ្នូរនៃការដោះដូរទីតាំងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ស្ថិតនៅឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំខេត្តកំពង់ចាមទីតាំងអគ្គនាយកដ្ឋានកៅស៊ូនិងទីតាំងការិយាល័យអុីវីរបស់អគ្គនាយកដ្ឋានកសិកម្ម

- ចុះពិនិត្យពិភាក្សាជាមួយអភិបាលនៃគណៈអភិបាលខេត្តរតនគិរី លើករណីសំណើសុំដីសាងសង់ទីបញ្ជាការកងរាជអាវុធហត្ថក្រុងបានលុងនិងសាងសង់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរីនៅលើដីចម្ការកៅស៊ូឡាបានសៀក

-សហការជាមួយអគ្គាធិការដ្ឋានរដ្ឋបាលព្រៃឈើ ចុះអនុវត្តតាមខ្លឹមសារនៃលិខិតលេខ០៦៧/១២ទ.រ.ព.អ.ស.ជ.ណ ចុះថ្ងៃទី១៤ខែវិច្ឆិកាឆ្នាំ២០១២របស់ក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច នៅខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី

-រៀបចំលិខិតទៅអគ្គនាយកដ្ឋានកៅស៊ូស្តីពី សំណើសុំពិនិត្យនិងពិភាក្សាលើដីកាសម្រេចលេខ០៥ក្រ៥.ប/ដកស ចុះថ្ងៃទី២៩ខែមីនាឆ្នាំ២០១៣របស់សាលាឧទ្ធរណ៍

-រៀបចំលិខិតជំរុញឲ្យក្រុមហ៊ុនស៊ីហ្វ៊ារ៉ាប់ប៊ើរលីមីតធីតបង់ថ្លៃឈ្នួលចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគិរីប្រចាំឆ្នាំ២០១៣ ឲ្យបានឆាប់រហ័សនិងទាន់ពេលវេលា

-ចូលរួមពិនិត្យដំណើរការដេញថ្លៃដាយត្រីលេញនិងដាយបង្កង នៅខេត្តព្រៃវែងខេត្តកណ្តាលនិងរាជធានីភ្នំពេញ

- ចុះពិនិត្យទីតាំងដីការិយាល័យក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មនៃមន្ទីរកសិកម្មខេត្តស្វាយរៀង ដែលត្រូវផ្ទេរជូនខណ្ឌរដ្ឋបាលជលផលស្វាយរៀង

- ចូលរួមប្រជុំពិភាក្សារកវិធានការដោះស្រាយបំណុល របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ដែលបន្សល់ទុកតាំងពីឆ្នាំ១៩៨៦

- សហការជាមួយអគ្គាធិការដ្ឋាននិងនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ចុះត្រួតពិនិត្យស្រាវជ្រាវការដឹកនាំគ្រប់គ្រងរបស់មន្ទីរនិងការិយាល័យចំណុះមន្ទីរកសិកម្មរាជធានីភ្នំពេញ

- ចូលរួមប្រគល់ទទួលទ្រព្យសម្បត្តិរដ្ឋជាថ្នូរ នៃការដោះដូរទីតាំងដីពិសោធន៍កសិកម្ម នៅខាងលិចផ្លូវជាតិលេខ៦អា របស់សាលាជាតិកសិកម្មព្រែកលៀប

- ចុះពិនិត្យជាក់ស្តែងទីតាំងដីមន្ទីរកសិកម្មខេត្តរតនគិរី ដែលត្រូវប្រគល់ជូនខណ្ឌរដ្ឋបាលជលផលរតនគិរី សម្រាប់សាងសង់អគារខណ្ឌរដ្ឋបាលជលផលនិងការកត់ត្រាទីតាំងដីរបស់ខណ្ឌរដ្ឋបាលព្រៃឈើរតនគិរី ក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

- ចុះពិនិត្យទីតាំងដីចំនួន០៣កន្លែង តាមប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនិងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់សាលាជាតិកសិកម្មកំពង់ចាមស្ថិតនៅក្រុងកំពង់ចាម និងស្រុកត្បូងឃ្មុំ ដែលមានការលម្អៀងពីបញ្ជីសារពើភណ្ឌ

- ពិនិត្យនិងបិទបញ្ជីគណនេយ្យ ហិរញ្ញវត្ថុ សម្រាប់ការផ្ទេរនាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចាស់ដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍ និងបើកបញ្ជីសម្រាប់នាយកវិទ្យាស្ថានត្រូវចូលកាន់តំណែងថ្មី ។

## ង. ចំនួនលេខគណនីធនាគារ

ក្នុងឆ្នាំ២០១៣នេះ ចំនួនលេខគណនីធនាគារបានថយចុះពី ២៦ គណនីនៅឆ្នាំ២០១២មកត្រឹមចំនួន ២៥ គណនី នៅចុងឆ្នាំ២០១៣នេះ ក្នុងនោះ NBC: 7 , FTB: 10 ,ACLEDA: 6 ,ANZ :2។ ចំនួនគណនីដែលបានថយចុះនោះ យើងបានទទួលព័ត៌មានប្រចាំខែពីបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។បានផ្តល់របាយការណ៍រៀងរាល់ប្រចាំខែឆ្នាំ២០១៣ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិស្តីអំពី ស្ថានភាពប្រើប្រាស់គណនីរបស់បណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងគម្រោងនានានៅតាមប្រព័ន្ធធនាគារដែលបាន និងកំពុងបម្រើការងារក្នុងវិស័យកសិកម្ម ។

## ច. ប្រាក់កក់ និងថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច

ប្រាក់កក់ធានាអនុវត្តកិច្ចសន្យា: ក្នុងឆ្នាំ២០១៣ នេះនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុបានទទួលបង្កាន់ដៃប្រាក់កក់ ចំនួន ០៥ ពីក្រុមហ៊ុនចំនួន ០៤ បានបង់ប្រាក់កក់ចូលគណនីចំណូលលេខ០០០០០០០០០១៣៣៣ នៅធានាគារជាតិ នៃកម្ពុជា(NBC) សរុបទឹកប្រាក់ចំនួន 331 821,30$ និងបានជូនដំណឹងទៅនាយកដ្ឋានផែនការ និងស្ថិតិ និងលេខាធិការដ្ឋានសម្បទានដីសេដ្ឋកិច្ច ដើម្បីជ្រាបជាព័ត៌មាន ។

## ២. វាយតម្លៃនិងសំណើ

លទ្ធផលខាងលើគឺ បានកមកពីការខិតខំប្រឹងប្រែងរបស់មន្ត្រីនិងអង្គភាពពាក់ព័ន្ធទាំងអស់ ចូលរួមសហការជាមួយគ្នាក្នុងដំណើរការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់លើការអនុវត្តតាមសេចក្តីណែនាំនានារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឈានមុខគេអនុវត្តកម្មវិធីគណនេយ្យតាមកុំព្យូទ័រដែលក្រសួងដទៃពុំទាន់អនុវត្តនៅឡើយ។ ជាមួយនឹងលទ្ធផលសម្រេចបានខាងលើ ការអនុវត្តកន្លងមកក៏នៅមានការលំបាកជាពិសេសសមត្ថភាពមន្ត្រីដែលត្រូវប្រឈមនឹងរបស់ថ្មីៗនៃកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសារធារណៈ។

## ៣. ផែនការនិងទិសដៅ

- ត្រៀមលក្ខណៈរៀបចំថវិកានិងអនុវត្តថវិកាកម្មវិធីទាំងស្រុងនៅឆ្នាំ២០១៥ខាងមុខ ជាពិសេសការរៀបចំសាកល្បងបង្កើតអងគ្គភាពថវិកានៅតាមអង្គភាពធំៗមួយចំនួន
- បន្តពង្រឹងការគ្រប់គ្រងប្រព័ន្ធ SERVER កុំព្យូទ័ររបស់នាយកដ្ឋាន និងប្តូរកម្មវិធីគណនេយ្យកុំព្យូទ័រថ្មីក្រោមចំនួយរបស់គម្រោង ADB ឱ្យមានលក្ខណៈសាមញ្ញជាងក្នុងដំណើរការប្រចាំថ្ងៃ
- កែប្រែប្រព័ន្ធ Internet ADSL ទៅជាប្រព័ន្ធ Fiber Optics លឿនរហ័ស និងបន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូសដោយសាលក្រម ដីកាសម្រេចពិន័យអន្តរការណ៍ និងឈើអញ្ញាតិជន (ឈើគ្មានម្ចាស់) នៅខណ្ឌរដ្ឋបាលព្រៃឈើទូទាំងប្រទេស
- ត្រៀមចុះពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត និងបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រៀមសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យ និងបិទបញ្ជីគណនេយ្យការិយបរិច្ឆេទ ២០១៣ នៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងបួនស្ថិតក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្តចូលរួមពិនិត្យ និងជំរុញការរៀបចំឯកសារកំណត់ទុនគ្រាដំបូងឱ្យសាលាជាតិកសិកម្មព្រែកលៀបដែលនៅពុំទាន់បញ្ចប់នៅឡើយ
- សហការជាមួយផ្នែកពាក់ព័ន្ធរៀបចំផ្គត់ផ្គង់និងបែងចែកនូវប្រេងឥន្ធនៈ សម្ភារបរិក្ខារ ឯកសណ្ឋាន និងសម្ភារប្រើប្រាស់ឆ្នាំ២០១៤ ជូនដល់បណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រៀមចុះពិនិត្យតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើន-ថយចុះ ឆ្នាំ២០១៣ នៅតាមមន្ទីរកសិកម្មរាជធានី ខេត្ត និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ជួយរៀបចំឱដំណើរការនូវគម្រោងនានាដែលត្រូវការថវិកាបដិភាគតាមការណែនាំរបស់ថ្នាក់ដឹកនាំ

- បន្តសហការចូលរួមកិច្ចលទ្ធកម្មគម្រោងហិរញ្ញប្បទាន ដោយធនាគារអភិវឌ្ឍន៍អាស៊ីដែលកំពុងដំណើរការនិងគម្រោងផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំ

- បន្តចូលរួមអនុវត្តសកម្មភាព PFM/MAP ក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបន្តខិតខំគៀងគរចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០១៣។

## ៥.១០- កម្មវិធី និងគម្រោងជំនួយដោយដៃគូអភិវឌ្ឍន៍

### ៥.១០.១ គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាបក្រោមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលហ្វាំងឡង់ មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្មនិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅក្នុងស្រុកចំនួន២៨ ឃុំចំនួន១៩៦ ក្នុងខេត្តគោលដៅបួន មានខេត្តកំពង់ចាម (៦១ឃុំ) ខេត្តកំពង់ធំ (៤៥ឃុំ) ខេត្តសៀមរាប (៥៨ឃុំ) និងខេត្តបន្ទាយមានជ័យ (៣២ឃុំ) ដែលមានប្រជាជនទទួលផលប្រហែល ៦៣,០០០គ្រួសារ ។ ការអនុវត្តគម្រោងមានរយៈពេលអនុវត្ត៧ឆ្នាំដែលបានចាប់ផ្តើមអនុវត្តពីថ្ងៃទី៣១ខែមីនាឆ្នាំ២០១០ ដល់ថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០១៨និងមានថវិកាសរុបចំនួន៥៥.៣០១.២០០ដុល្លារអាមេរិក ដែលក្នុងនោះមានថវិកាកម្ចីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(Grant)ចំនួន ៣.៤០០.០០០ដុល្លារអាមេរិក ជំនួយហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(Loan) ចំនួន២៧.៣០០.០០០ដុល្លារអាមេរិក កម្ចីហិរញ្ញប្បទានរបស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្មចំនួន៦.៦៩០.០០០ដុល្លារអាមេរិក ជំនួយហិរញ្ញប្បទានរបស់មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (Grant) ចំនួន៦.៦៩០.០០០ដុល្លារអាមេរិក ជំនួយហិរញ្ញប្បទានរបស់រដ្ឋាភិបាលហ្វាំងឡង់ (Grant) ចំនួន ៥.៧៤៧.៩០០ដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៥.៤៧៣.២០០ ដុល្លារអាមេរិក។ គម្រោងមានភ្នាក់ងារប្រតិបត្តិ(Executing Agency) ចំនួនពីរគឺ(១)លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង(២)ភ្នាក់ងារប្រតិបត្តិរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដែលមានអង្គភាពសម្របសម្រួលការអភិវឌ្ឍ ជាអ្នកសម្របសម្រួលការអនុវត្តគម្រោងនៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ ភ្នាក់ងារអនុវត្ត (Implementing Agency) មានអគ្គនាយកដ្ឋានកសិកម្មនិងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានវិទ្យារបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទមានតួនាទីជាគណៈកម្មាធិការតម្រង់ទិសគម្រោង។

គោលដៅរបស់គម្រោងគឺជំរុញការអភិវឌ្ឍសកម្មភាពនៅសហគមន៍មូលដ្ឋានតាមរយៈការវិនិយោគកែលំអផលិតភាពហេដ្ឋារចនាសម្ព័ន្ធនៅជនបទនិងអភិវឌ្ឍន៍ធនធានមនុស្ស។គោលបំណងរបស់គម្រោងគឺបង្កើនជីវភាពរបស់កសិករក្រីក្រក្នុងតំបន់គោលដៅក្នុងអំឡុងឆ្នាំ២០២០។គម្រោងមានសមាសភាគបី (១) ការអភិវឌ្ឍឃុំ-សង្កាត់តាមរយៈការផ្តល់កញ្ចប់ថវិកា (Block Grant) (២) បង្កើនផលិតភាពកសិកម្ម និងពិពិធកម្ម (៣) ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាព។

អង្គភាពសម្របសម្រួលការអភិវឌ្ឍ (DCU) ជាភ្នាក់ងារប្រតិបត្តិនៃគម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានសម្របសម្រួលអនុវត្តសកម្មភាពនៅក្នុងឆ្នាំ២០១៣ និងបានសម្រេចលទ្ធផលតាមផែនការដែលបានគ្រោងទុក ។ ក្រុមហ៊ុនជំនាញការ SMEC International Pty Ltd បានអនុវត្តការងារពីថ្ងៃទី០៩ ខែកក្កដាឆ្នាំ២០១២ ហើយបាននិងកំពង់អនុវត្តគម្រោងបន្ត ។ ការចំណាយរបស់អង្គភាពសម្របសម្រួលការអភិវឌ្ឍន៍ក្នុងឆ្នាំ២០១៣ មានចំនួន ២.១៩៥.៤៧០ ដុល្លារអាមេរិក (៣៩%)។ ចាប់ពីគម្រោងចាប់ផ្តើមពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០មកដល់ថ្ងៃទី៣១ខែធ្នូឆ្នាំ ២០១៣ ការចំណាយសរុបរបស់អង្គភាពសម្របសម្រួលការអភិវឌ្ឍន៍មានចំនួន២.៩៩៣.៥១៧ ដុល្លារអាមេរិក (៥៣.០%) ក្នុងនោះមានថវិកាជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន២.៩៣៥.៦៧៦ ដុល្លារអាមេរិក(៥២.៨០%) និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ចំនួន៥៧.៨៤១ដុល្លារអាមេរិក (៦៤.០៧%)។ ការចំណាយសរុបរួមគម្រោង របស់ភ្នាក់ងារប្រតិបត្តិនិងភ្នាក់ងារអនុវត្ត មានចំនួន ៨.២៨៩.០៣២ដុល្លារអាមេរិក (១៥.៦%)។

នៅក្នុងឆ្នាំ២០១៣ ការអនុវត្តរបស់គម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានសម្រេចលទ្ធផលល្អ បន្ទាប់ពីផែនការរយៈពេល១២ខែរបស់គម្រោងបានអនុម័តនាថ្ងៃទី២២ខែកុម្ភៈឆ្នាំ២០១៣ ដោយធនាគារអភិវឌ្ឍន៍អាស៊ី។ មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ី បានខិតខំជួយសហការជាមួយភ្នាក់ងារប្រតិបត្តិ និងភ្នាក់ងារអនុវត្តគម្រោង ដោយសម្រេចលទ្ធផលបានគួរជាទីពេញចិត្ត ទោះបីជាជួបប្រទះបញ្ហាតិចតួច មានដូចជាទឹកជំនន់ ការជាប់រវល់របស់កសិករក្នុងការចូលរួមបោះឆ្នោតជាតិ និងលំហូថវិកា ។

### ៥.១០.២ គម្រោងជំនួយបច្ចេកទេស ADB-Grant . 0222-CAM/Component1: PFMRDs

គម្រោងបានផ្តល់នូវជំនួយបច្ចេកទេសដល់ក្រសួងតាមរយៈការកសាងសមត្ថភាពស្ថាប័ននិងមន្ត្រី លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ដែលផ្តោតលើការលើកកម្ពស់ និងការពង្រឹងសមត្ថភាពស្ថាប័នរបស់ក្រសួងដែលអភិវឌ្ឍន៍ក្នុងវិស័យជនបទក្នុងនោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៍ជាក្រសួងមួយអភិវឌ្ឍន៍សកម្មភាពក្នុងវិស័យជនបទ។

បានសហការនិងរៀបចំបើកសិក្ខាសាលាចំនួន០២លើកនៅខេត្តព្រះសីហនុ និងសៀមរាប ក្នុងគោលដៅលើកកំពស់និងពង្រឹងសមត្ថភាពមន្ត្រីតាមអង្គភាពជំនាញដែលពាក់ព័ន្ធ និងកែលំអប្រសិទ្ធភាពការងារ ជាពិសេសលើការងារអនុវត្តថវិកាតាមកម្មវិធី ការងាររៀបចំប្រព័ន្ធគណនេយ្យ ការងារសវនកម្មផ្ទៃក្នុង ការងារលទ្ធកម្ម និងការងារតាមដាននិងវាយតម្លៃ។

### ៥.១០.៣ គម្រោងកម្មវិធីខ្សែសង្វាក់ផលិតកម្មកសិកម្មកម្ពុជា

គម្រោងកម្មវិធីខ្សែសង្វាក់ផលិតកម្មសិកម្មកម្ពុជា(CAVAC)ជាកម្មវិធីអភិវឌ្ឍន៍កសិកម្មក្រោមការគាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី ដែលមានថវិកាសរុបប្រមាណ៤៣ លាន ដុល្លាអូស្ត្រាលី ក្នុងរយៈពេល៦ឆ្នាំ គឺពីឆ្នាំ ២០១០ ដល់ ឆ្នាំ ២០១៥ មានគោលដៅ ជួយកាត់បន្ថយភាពក្រីក្រនៅជនបទ ដោយការបង្កើនផលិតភាពនិងប្រាក់ចំណូលដល់កសិករខ្នាតតូច ដោយបានកំពុងអនុវត្តនៅក្នុងខេត្តចំនួន៣មានៈខេត្តតាកែវ ខេត្តកំពត និងខេត្តកំពង់ធំលើសមាសភាពចំនួន៤គឺ÷ ១).កសិពាណិជ្ជកម្ម ២). ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងធនធានទឹក ៣). ការស្រាវជ្រាវ និងផ្សព្វផ្សាយ និង៤). បរិយាកាសជំរុញអាជីវកម្ម ។

**ក. កសិពាណិជ្ជកម្ម និងផ្សព្វផ្សាយ** ( Agribusiness and Extension )

ផ្នែកកសិពាណិជ្ជកម្មផ្តោតលើការបង្កើត និងពង្រឹងភាពជាដៃគូ និងអន្តរាគមន៍នូវបច្ចេកទេសថ្មី និងទីផ្សារដែលផ្តល់ការគាំទ្រនូវធាតុចូល(សម្ភារកសិកម្ម)និងសេវាកម្មដល់កសិករ និងសហគមន៍កសិកម្ម។ សកម្មភាពនិងលទ្ធផលសំខាន់ដែលទទួលបានមាន÷

- ទីផ្សារពូជស្រូវៈ បានគាំទ្រ និងសហការដល់ទីផ្សារពូជស្រូវជាមួយក្រុមហ៊ុនពូជស្រូវមាស និងលោកសុគន្ធា ពីយុទ្ធសាស្ត្រទីផ្សារស្រូវ និងបង្កើតសហគមន៍ផលិតពូជស្រូវបី សហគមន៍កសិកម្មផលិតគ្រាប់ពូជចំប៉ីខេត្តតាកែវ សហគមន៍បឹងនិមលខេត្តកំពត និងសហគមន៍ខ្វែកមានឫទ្ធិ ខេត្តកំពង់ធំ។
- ទីផ្សារជីនិងថ្នាំកសិកម្មៈ បានសហការ និងគាំទ្រដល់ក្រុមហ៊ុនលក់និងផ្គត់ផ្គង់ជី និងថ្នាំកសិកម្ម តាមរយៈការបណ្តុះបណ្តាល អាជីវករលក់សម្ភារៈកសិកម្ម និងការធ្វើបង្ហាញដែលរួមមានៈ ក្រុមហ៊ុនលក់និងផ្គត់ផ្គង់ជីមាន ក្រុមហ៊ុន យី តាក់ ក្រុមហ៊ុនហេង ពេជ្រឆាយ ក្រុមហ៊ុន Malasan, Papaya និង Bayon Heritage និងក្រុមហ៊ុនលក់ថ្នាំកសិកម្មមាន ក្រុមហ៊ុននគរធំ និងក្រុមហ៊ុន SPK ដោយមានអគ្គនាយកដ្ឋានកសិកម្មត្រួតពិនិត្យបច្ចេកទេស។
- ទីផ្សារពូជបន្លែៈបានសហការជាមួយក្រុមហ៊ុន East West Seed International ធ្វើស្រែបង្ហាញចំនួន ១៤៨ កន្លែងនៅខេត្តកណ្តាល និងខេត្តកំពុងចាម។
- ទីផ្សារនាំអង្ករចេញៈ បានកំពុងគាំទ្រ និងកសាងសមត្ថភាពដល់បុគ្គលិក ក្រុមហ៊ុនបៃតងកម្ពុជា និងសមាគមរោងម៉ាស៊ីនកិនស្រូវកម្ពុជាពីការផលិតពូជស្រូវ និងផលិតកម្មស្រូវមានគុណភាពសម្រាប់ការនាំចេញ។

- លើប្រព័ន្ធផ្សព្វផ្សាយ÷ បានគាំទ្រជាមួយក្រុមហ៊ុន Delight Cambodia ផលិតឯកសារវីដេអូអប់រំខ្លីរយៈពេល ២០នាទីស្តីពី ដីបំណាស់ថ្មី។ បានសហការជាមួយក្រុមហ៊ុន Asia Master សម្រាប់ផ្តល់សារព័ត៌មានកសិកម្មតាមបណ្តាញទូរស័ព្ទ។
- សហការជាមួយមន្ទីរកសិកម្មខេត្តៈ បានធ្វើកិច្ចសន្យាជាមួយមន្ទីរកសិកម្មខេត្តកំពង់ធំ ខេត្តកំពត និងខេត្តតាកែវ ដើម្បីអនុវត្តគម្រោងប្រព័ន្ធព័ត៌មានកសិកម្ម ការរៀបចំចងក្រង និងពង្រឹងចរនាសម្ព័ន្ធសហគមន៍កសិកម្ម និងការធ្វើស្រែបង្ហាញ។
- គាំទ្រអគ្គនាយកដ្ឋានកសិកម្ម និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម លើការបោះពុម្ពឯកសារផ្សព្វផ្សាយ។

## ខ. ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងធនធានទឹក

ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និងធនធានទឹកគឺផ្តោតលើការស្តារ និងកសាងប្រព័ន្ធស្រោចស្រព ដោយចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៣ ដោយបានស្តារ និងកសាងរួច និងបន្តស្តារ និងកសាងប្រឡាយស្រោចស្រពចំនួន២០ប្រព័ន្ធ មាន៦ប្រព័ន្ធខេត្តតាកែវ ៩ប្រព័ន្ធនៅកំពត និង៥ ប្រព័ន្ធនៅខេត្តកំពង់ធំ ដែលអាចឲ្យកសិករប្រមាណ ២ម៉ឺនគ្រួសារអាចបង្កបង្កើនផលយ៉ាងតិចចំនួន២ដងក្នុងមួយឆ្នាំ។

## គ.ការស្រាវជ្រាវ

បានបង្កើតមូលនិធិ និងគាំទ្រសកម្មភាពស្រាវជ្រាវចំនួន២គឺ÷ការស្រាវជ្រាវអភិវឌ្ឍកសិកម្មពីថ្នាំកសិកម្មចំនួន ៤ និងស្រាវជ្រាវពីយេឌ័រចំនួន៦។

## ឃ.បរិយាកាសជំរុញអាជីវកម្ម

សកម្មភាពផ្តោចលើ បង្កលក្ខណៈងាយស្រួលបរិយាកាសដល់អាជីវកម្មនៅកម្ពុជាលើតម្លៃខ្សែចង្វាក់ផលិតកម្មកសិកម្ម ដែលរួមមានការគាំទ្រផ្នែកគោលនយោបាយ ច្បាប់ និងគោលការណ៍នានាទាក់ទងនឹងខ្សែសង្វាក់តម្លៃផលិតកម្មកសិកម្ម ព្រមទាំងការអង្កេតស្ថិតិកសិកម្ម។ សហការនិងគាំទ្រដល់អគ្គនាយកដ្ឋានកសិកម្ម (នាយកដ្ឋានដំណាំស្រូវ) និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា លើសកម្មភាពកែលំអខ្សែសង្វាក់ស្រូវអង្ករ និងមន្ទីរកសិកម្មខត្ត ក្នុងការផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងជី និងថ្នាំកសិកម្ម។

## ៥.១០.៤ គម្រោងអភិវឌ្ឍន៍ជនបទតំបន់ទំនាបទន្លេសាប

គម្រោងអភិវឌ្ឍន៍ជនបទតំបន់ទំនាបទន្លេសាប ក្រោមឥណទានធនាគារអភិវឌ្ឍន៍អាស៊ី [Loan 2376-CAM (SF) Grant 0092-CAM(SF)] លើសមាសភាគទី២ផ្នែកៈ ការលើកកម្ពស់ផលិតភាពកសិកម្ម ដើម្បីកែលម្អជីវភាពរស់នៅជនបទ ដែលបានអនុវត្តក្នុងខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់ នៅឆ្នាំ២០១៣ លើអនុគម្រោង និងសេវាគាំទ្រសំខាន់ៗដូចខាងក្រោម÷

- អនុគម្រោងកែលំអជីវភាពរស់នៅៈ ការរៀបចំចងក្រង និងពង្រឹងសមត្ថភាពក្រុមកសិករ និងសហគមន៍កសិកម្ម
- អនុគម្រោងការកែលំអប្រព័ន្ធកសិកម្មៈ ការសិក្សាវាយតម្លៃ និងការបណ្តុះបណ្តាលពីប្រព័ន្ធក្សេត្របរិស្ថានកសិកម្ម
- អនុគម្រោងការបង្ហាញកសិកម្មចំរុះ និងបច្ចេកវិទ្យាកសិកម្មៈ ការធ្វើស្រែបង្ហាញ និងទិវាស្រែ
- អនុគម្រោងបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងខ្សែចង្វាក់ផលិតកម្មកសិកម្ម
- អនុគម្រោងមុខរបរក្រៅកសិកម្មៈ ការកែច្នៃផលិតផលកសិកម្ម និងមុខរបរជំនួញពាក់ព័ន្ធនឹងការគាំទ្រផលិតកម្ម និងខ្សែសង្វាក់ផលិតកម្មកសិកម្ម
- ការគ្រប់គ្រងនិងសម្របសម្រួលគម្រោង និងកសាងសមត្ថភាពមន្ត្រីៈ ការបណ្តុះបណ្តាល ទស្សនកិច្ចសិក្សាកិច្ច។

**ក. លទ្ធផល ÷**

**១.ខេត្តកំពង់ឆ្នាំងៈ** បានអនុវត្តសកម្មភាពតាមអនុគម្រោងនិមួយៗដូចខាងក្រោម÷

-បានពង្រឹងសហគមន៍កសិកម្មក្នុងបានចំនួន ៣ សហគមន៍ដែលមានសមាជិកចូលរួម ចំនួន២៧១ នាក់ ក្នុងនោះស្ត្រីមាន ចំនួន ១៥១ នាក់ មានហ៊ុនសរុប៦៤១ហ៊ុន និងទុនសរុប ចំនួន៦.៤១០.០០០រៀល

-បានរៀបចំ និងពង្រឹងសមត្ថភាពក្រុមសន្សំចំនួន ២៤ក្រុម មានអ្នកចូលរួម ៧២៣ នាក់ មានស្ត្រី ៥៣៨នាក់

-ផ្តល់ទុកគាំទ្រដល់សន្សំប្រាក់ចំនួន ១៤ ដែលក្នុង១ក្រុមចំនួន៤០០ដុល្លាសហរដ្ឋអាមេរិក និងទុនគាំទ្រសរុបចំនួន ៥៦០០ដុល្លាអាមេរិក សម្រាប់សមាជិកក្រុមសន្សំទាំងអស់ ៤២៤នាក់ មានស្ត្រី ៣១២នាក់។

-បានបណ្តុះបណ្តាលនិងធ្វើបង្ហាញគំរូ ពីការចិញ្ចឹមត្រីអណ្តែងក្នុងស្រះថង់ផ្លាស្ទិកចំនួន៨ ដែលមានកសិករចូលរួម ចំនួន២៣០នាក់មានស្ត្រីចំនួន១៤០នាក់

-បានបណ្តុះបណ្តាល និងធ្វើស្រែបង្ហាញពីផលិតកម្មស្រូវគំរូចំនួន៦កន្លែង ដែលមានកសិករចូលរួមចំនួន១៧៣នាក់ មានស្ត្រីចំនួន ១២១នាក់

-ធ្វើបង្ហាញផលិតកម្មផលិតកម្មពូជស្រូវចំនួន១២កន្លែង ដែលមានកសិករចូលរួមចំនួន៣៦០នាក់ មានស្ត្រីចំនួន១៨២ នាក់

-បានបណ្តុះបណ្តាល និងធ្វើបង្ហាញការចិញ្ចឹមមាន់យកសាច់ ៤កន្លែង មានកសិករចូលរួម១៧៣ នាក់ មានស្ត្រី ១១០ នាក់

-បានធ្វើបង្ហាញនិងបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មមាន់ពូជចំនួន៤កន្លែងមានកសិករចូលរួម១៦៧ នាក់ មានស្ត្រី ១០១ នាក់

-បានធ្វើបង្ហាញនិងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកមេចំនួន៣កន្លែង មានកសិករចូលរួម១៣៩នាក់ មានស្ត្រី៩៤ នាក់

-បានរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេស ក្រោយពេលប្រមូលផលលើដំណាំស្រូវ៥៧វគ្គ មានកសិករចូលរួម២០៧នាក់ មាន ស្ត្រី១៥៤នាក់

-បានធ្វើបង្ហាញនិងបណ្តុះបណ្តាលបច្ចេកទេសដាំដំណាំបន្លែចំនួន៧កន្លែង មានកសិករចូលរួម២០៦នាក់ មានស្ត្រី៨៨ នាក់

-បណ្តុះបណ្តាលនិងធ្វើបង្ហាញគំរូភ្ញាស់កូនត្រី១ កន្លែងនៅកសិដ្ឋានកសិករ យោគ ស្លេស នៅភូមិកំពង់ ត្រឡាច ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលមានកសិករចូលរួម ៣០ នាក់។

**២.ខេត្តពោធិសាត់:** បានអនុវត្តសកម្មភាពតាមអនុគម្រោងនិមួយៗ ដូចខាងក្រោម÷

-បានបង្កើតសហគមន៍កសិកម្មថ្មីចំនួន២ សហគមន៍ និងពង្រឹងសហគមន៍កសិកម្មក្នុងបានចំនួន៦សហគមន៍ ដែលមានសមាជិកចូលរួមចំនួន២៨៩នាក់ ក្នុងនោះ ស្ត្រីមានចំនួន២០២នាក់ មានហ៊ុនសរុប៥៣៧ហ៊ុន និងទុនសរុបចំនួន ២៣.០៦០.០០០ រៀល

-បានពង្រឹងសមត្ថភាពក្រុមសន្សំចំនួន៧៨ក្រុម មានអ្នកចូលរួម ៤៥១ នាក់ មានស្ត្រី ៣០៩នាក់

-បានជ្រើសរើសនិងរៀបចំក្រុមផលិតពូជស្រូវចំនួន០៦ក្រុម មាន៣០គ្រួសារជាអ្នកដឹកនាំអនុវត្ត និងកសិករចំនួន ៣០៦នាក់ចូលរួម មានស្ត្រីចំនួន ១៩៧នាក់

-បានធ្វើស្រែបង្ហាញ និងទិវាស្រែពីការចិញ្ចឹមមាន់គំរូចំនួន១៥កន្លែង មានកសិករអនុវត្ត១៥គ្រួសារ និងមានកសិករ ចូលរួមចំនួន៧២៦ នាក់មានស្ត្រីចំនួន៤២៤នាក់

-បានបណ្តុះបណ្តាលនិងធ្វើស្រែបង្ហាញពីផលិតកម្មពូជស្រូវគំរូចំនួន៦កន្លែង ដែលមានកសិករចូលរួមចំនួន៣៩០ នាក់មានស្ត្រីចំនួន២៤៣នាក់

-បានបណ្តុះបណ្តាលពីបច្ចេកទេសផលិតពូជស្រូវនិងធ្វើបង្ហាញគំរូចំនួន៦កន្លែង ដែលមានកសិករចូលរួមចំនួន១៨០ នាក់មានស្ត្រីចំនួន១១៨នាក់

-បានធ្វើបង្ហាញនិងបណ្តុះបណ្តាលពីបច្ចេកទេសកៀរពង្រាបដីចំនួន១៣កន្លែង ដែលមានកសិករចូលរួមចំនួន៣៩០ នាក់មានស្ត្រីចំនួន ២៣៨ នាក់

-បានធ្វើបង្ហាញនិងបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ចំនួន១៣កន្លែង ដែលមានកសិករចូលរួមចំនួន៣៩១ នាក់មានស្ត្រីចំនួន ២៣៣ នាក់

-បានធ្វើបង្ហាញ និងបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមជ្រូកចំនួន៥កន្លែង ដែលមានកសិករចូលរួមចំនួន១៤៧ នាក់មានស្ត្រីចំនួន ១០១នាក់

-បានធ្វើបង្ហាញនិងបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រីចំនួន១៣កន្លែង ដែលមានកសិករចូលរួមចំនួន៣៨៥ នាក់មានស្ត្រីចំនួន ២១០នាក់

-បានធ្វើបង្ហាញ និងបណ្តុះបណ្តាលពីបច្ចេកទេសប្រព័ន្ធកសិកម្មចំរុះចំនួន០៦កន្លែង ដែលមានកសិករចូលរួមចំនួន១៧៤ នាក់មានស្ត្រីចំនួន ១០៣ នាក់

-បានបណ្តុះបណ្តាលពីបច្ចេកទេសទុកដាក់ស្រូវ មុននិងក្រោយពេលប្រមូលផលចំនួន១៣វគ្គ ដែលមានកសិករចូលរួមចំនួន៣៨៧នាក់មានស្ត្រីចំនួន២៤១នាក់

-បានរៀបចំទស្សនកិច្ចសិក្សាសម្រាប់មន្ត្រីកសិកម្ម និងកសិករគំរូចំនួន១លើក ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាបច្ចេកទេសផលិតកម្មកសិកម្ម និងការរៀបចំក្រុមកសិករ និងសហគមន៍កសិកម្ម នៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមចំនួន៣៨នាក់ ស្ត្រី០៤នាក់។

**៣. ខេត្តកំពង់ធំ:** បានអនុវត្តសកម្មភាពតាមអនុគម្រោងនិមួយៗដូចខាងក្រោម÷

-បានបង្កើតសហគមន៍កសិកម្មពង្រឹងសហគមន៍កសិកម្មក្នុងបានចំនួន៤សហគមន៍ ដែលមានសមាជិក ចូលរួមចំនួន ២៤០ នាក់ ក្នុងនោះស្ត្រីមានចំនួន ១៦៤ នាក់

-បានរៀបចំ និងពង្រឹងសមត្ថភាពក្រុមសន្សំចំនួន ១៦ ក្រុម មានអ្នកចូលរួម៤៦១ នាក់ មានស្ត្រី ២៧១ នាក់

-បានបណ្តុះបណ្តាល និងធ្វើស្រែបង្ហាញពីបច្ចេកទេសចិញ្ចឹមជ្រូកចំនួន៤កន្លែង មានកសិករអនុវត្ត៤គ្រួសារ និងមានកសិករចូលរួមចំនួន៦១នាក់ មានស្ត្រីចំនួន ៤៧នាក់

-បានបណ្តុះបណ្តាលនិងធ្វើស្រែបង្ហាញពី បច្ចេកទេសដាំដុះដំណាំដីខ្ពស់ចំនួន២កន្លែង មានកសិករអនុវត្ត២គ្រួសារ និងមានកសិករចូលរួមចំនួន៦ នាក់មានស្ត្រីចំនួន៤២នាក់

-បានធ្វើបង្ហាញពីបច្ចេកទេសចិញ្ចឹមមាន់ចំនួន៧កន្លែង មានកសិករអនុវត្ត៧គ្រួសារ និងមានកសិករចូលរួមចំនួន ២១០ នាក់មានស្ត្រីចំនួន ១៦៦នាក់

-បានបណ្តុះបណ្តាលនិងធ្វើកសិដ្ឋានបង្ហាញពី បច្ចេកទេសកសិកម្មចំរុះចំនួន៣កន្លែង មានកសិករអនុវត្ត៣គ្រួសារ និងមានកសិករចូលរួមចំនួន៧៥នាក់មានស្ត្រីចំនួន៤៨នាក់

-បានបណ្តុះបណ្តាលនិងធ្វើបង្ហាញពី បច្ចេកទេសផលិតកម្មមាន់ចំនួន២ កន្លែង មានកសិករអនុវត្ត២គ្រួសារ និងមានកសិករចូលរួមចំនួន៥០នាក់មានស្ត្រីចំនួន៤០នាក់

-បង្កើតក្រុមអាជីវកម្មផ្គត់ផ្គង់កូនជ្រូកចំនួន៣ក្រុម ដែលមានកសិករចូលរួមចំនួន៩៤នាក់មានស្ត្រីចំនួន៧២នាក់ និងបានបណ្តុះបណ្តាលនិងធ្វើបង្ហាញពីបច្ចេកទេសផលិតកម្មដំណាំស្រូវចំនួន២៦កន្លែង ដែលមានកសិករចូលរួមចំនួន ៦៦៦ នាក់មានស្ត្រីចំនួន៤៤៨ នាក់។

## ខ. ការលំបាកចម្បងក្នុងការអនុវត្តគម្រោង

- ថវិកាបដិភាគរាជរដ្ឋាភិបាល (RGC) មិនគ្រប់គ្រាន់ នាំឲ្យលំហូរថវិកាពី PMO ទៅខេត្តសម្រាប់អនុវត្តសកម្មភាពគម្រោងមានការយឺតយ៉ាវ និងមិនសម្រេចតាមផែនការ
- មន្ត្រីអនុវត្តគម្រោងនៅតាមខេត្តមួយចំនួនមានការផ្លាស់ប្តូរសមាសភាពនៅពេលកំពុងដំណើរការអនុវត្តគម្រោង
- សកម្មភាពធ្វើបង្ហាញមួយចំនួនទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិមានជំងឺ សត្វបំផ្លាញ ទឹកជំនន់ និងភាពរាំងស្ងួត។

## គ. ទិសដៅអនុវត្តបន្ត

- ចុះតាមដាន និងគាំទ្រក្រុមសន្សំ សហគមន៍កសិកម្ម និងកសិករគំរូធ្វើបង្ហាញ
- ត្រួតពិនិត្យឡើងវិញនិងតាមដានសកម្មភាពការងារឆ្នាំ ២០១៣ និង រៀបចំផែនការសកម្មភាពឆ្នាំ ២០១៤
- បន្តអនុវត្តផែនការសកម្មភាពឆ្នាំ ២០១៤ ដោយផ្តោតលើសកម្មភាព÷
    - បន្តចងក្រង គាំទ្រនិងពង្រឹងសមត្ថភាពក្រុមកសិករ និងសហគមន៍កសិកម្ម ពង្រឹងការគាំទ្រហេដ្ឋារចនាសម្ព័ន្ធសហគមន៍កសិកម្ម

- បន្តបង្ហាញកសិកម្មចំរុះ និងបច្ចេកវិទ្យាកសិកម្មៈ ការធ្វើស្រែបង្ហាញជាលក្ខណៈផលិតកម្មគំរូលក្ខណៈជំនួញកសិកម្ម (Agri-business)
- បន្តបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងអាជីវកម្មកសិកម្ម (Agri-business)
- អនុវត្តសកម្មភាពមុខរបរក្រៅកសិកម្មៈ ការកែច្នៃផលិតផលកសិកម្ម និងមុខរបរជំនួញពាក់ព័ន្ធនឹងការគាំទ្រ ផលិតកម្ម និងខ្សែសង្វាក់ផលិតកម្មកសិកម្ម
- សម្របសម្រួលគម្រោង និងការកសាងសមត្ថភាពមន្ត្រី។

### ៥.១០.៥ គម្រោងបន្សាំនឹងការប្រែប្រួលធាតុអាកាស និងពាណិជ្ជកម្មស្រូវ-អង្ករ

- គម្រោងនេះជាជំនួយនិងកម្ចីរបស់ ADB រួមជាមួយដៃគូអភិវឌ្ឍន៍មួយចំនួន និងរាជរដ្ឋាភិបាលកម្ពុជា
- គម្រោងគ្រោងទុនសរុបចំនួន ៨៧ លានដុល្លារអាមេរិក
- រយៈពេលអនុវត្តដំណាក់កាលទី ១ឆ្នាំ២០១៣-២០១៦ ដំណាក់កាលទី ២ ឆ្នាំ២០១៧-២០១៩
- គម្រោងកម្មវិធីនេះចែកជា២ផ្នែក÷
  - ផ្នែករៀបចំគោលនយោបាយលើកទឹកចិត្តសម្រាប់ផលិតកម្មស្រូវ និងនាំចេញអង្ករ មានថវិកា២៤ លានដុល្លារអាមេរិក
  - ផ្នែកវិនិយោគលើការធ្វើពាណិជ្ជកម្មស្រូវ-អង្ករ មានថវិកា ៥៧.១៧០.០០០ ដុល្លារអាមេរិក

- គម្រោងនេះបានចុះកិច្ចព្រមព្រៀងរវាង ADB និងរដ្ឋាភិបាលកម្ពុជា (តំណាងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) កាលពីខែមិថុនា ឆ្នាំ ២០១៣។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងរៀបចំដែនដី និងនគររូបនីយកម្ម និងខេត្តចំនួន ៣ គឺ÷ បាត់ដំបង កំពង់ធំ និងព្រៃវែង ជាអ្នកអនុវត្ត

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំការិយាល័យអនុវត្តថ្នាក់ជាតិ រួចហើយ

- គម្រោងមានភាពអសកម្មនៅក្នុងដំណាក់កាលនៃការអនុវត្តឆ្នាំ២០១៣ និងដើមឆ្នាំ២០១៤

- ការិយាល័យអនុវត្តថ្នាក់ជាតិ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងចាប់ផ្តើមរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៣-២០១៤ និងដំណាក់កាលទី១ ឆ្នាំ២០១៣-២០១៦។

# ជំពូក ៣
# វាយតម្លៃនិងសន្និដ្ឋាន

## ៦-វាយតម្លៃរួម

ផ្អែកលើលទ្ធផលទទួលបានក្នុងឆ្នាំ២០១៣-២០១៤ កន្លងមកនេះ យើងអាចវាយតម្លៃជារួមបានថា ទោះបីជាបានជួបប្រទះនូវគ្រោះធម្មជាតិដូចជាគ្រោះទឹកជំនន់ និងកង្វះទឹក ជាពិសេសជំនន់ទឹកភ្លៀងនារដូវវស្សា ភាពរាំងស្ងួតកង្វះខាតទឹកនារដូវវស្សា យ៉ាងខ្លាំងក្លាយ៉ាងណាក្តី ដោយសារមានការណែនាំនិងតម្រង់ទិស ដ៏ត្រឹមត្រូវនិងមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងមានការចូលរួមពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញការអនុវត្តការងារគ្រប់មុខសញ្ញាបានយ៉ាងសកម្ម និងបានដោះស្រាយទប់ទល់នូវគ្រោះធម្មជាតិ និងស្តារឡើងវិញនូវការខូចខាតទទួលបានប្រសិទ្ធភាពខ្ពស់ ហើយបានធ្វើឱ្យផលិតកម្មកសិកម្មក្នុងឆ្នាំ២០១៣-២០១៤ មិនធ្លាក់ចុះ ព្រមទាំងមានការវិវឌ្ឍរីកចម្រើនគួរជាទីមោទនៈ។

ជាក់ស្តែងការអនុវត្តដាំដុះដំណាំស្រូវ២០១៣-២០១៤នេះ យើងអាចនៅរក្សាបានកំណើនទាំងផ្ទៃដីដាំដុះ ទិន្នផល និងបរិមាណផល។ តុល្យភាពស្បៀងទូទាំងប្រទេសត្រូវបានប៉ាន់ស្មានថានៅសល់ប្រមាណ**៣,០៩០លានតោនអង្ករ** គិតជា**ស្រូវជាង៤,៨២៨លានតោន លើសឆ្នាំមុន ៩២.៨៦៨ តោន**។

ក្នុងការអនុវត្តឯកសារគោលនយោបាយជំរុញផលិតកម្មស្រូវនិងនាំចេញអង្ករបស់រាជរដ្ឋាភិបាលកម្ពុជា ក្រៅពីបាន និងកំពុងជំរុញផលិតកម្មស្រូវដែលសម្រេចបាននូវលទ្ធផលគួរជាពេញចិត្ត ជាមួយនឹងអតិរេកគិតជាអង្ករប្រមាណ៣,០៩ លានតោនក្នុងឆ្នាំ២០១៣-២០១៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន បានសម្រួចសកម្មភាពជំរុញអង្ករកម្ពុជាឲ្យឈានចូលទៅក្នុងទីផ្សារអន្តរជាតិ ហើយអង្ករនាំចេញផ្លូវការបានកើនជាង ២០៥ ពាន់តោន នាឆ្នាំ២០១២ រហូតដល់ជិត ៣៨០ ពាន់តោន នាឆ្នាំ២០១៣នេះ។ ជាពិសេសយើងមានមោទនៈភាពខ្ពស់ណាស់ ដោយសារអង្ករកម្ពុជាបានប្រកួតឈ្នះបានលេខ១ ពីរដងជាបន្តបន្ទាប់។

ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មសំខាន់ៗ ក៏មានការកើនឡើងលើសឆ្នាំមុន ចំពោះដំណាំអចិន្ត្រៃយ៍ ដូចជា កៅស៊ូ ស្វាយចន្ទី ដំណាំឈើហូបផ្លែនិងដំណាំចម្ការ។ល។ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ជាលក្ខណៈគ្រួសារ និងជាលក្ខណៈវិនិយោគខ្នាតតូច មធ្យម និងធំ។ គួរកត់សម្គាល់ថា នៅឆ្នាំ២០១៣ ផ្ទៃដីដាំដុះកៅស៊ូនៅកម្ពុជាបានកើនឡើង ១៧,៣% ធៀបនឹងឆ្នាំ២០១២ (២៨០.៣៥៥ហិកតា) ដែលរួមមាន÷ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) មានចំនួន៥៥.៩០៨ហិកតា (ស្មើនឹង១៧%) ផ្ទៃដីចម្ការកៅស៊ូសម្បទានសេដ្ឋកិច្ចមានចំនួន១៣៥.៤៤៦ហិកតា (ស្មើនឹង៤១,២%) និងផ្ទៃដីចម្ការកៅស៊ូគ្រួសារតូចតាចនិងឯកជនមានចំនួន១៣៧.៤១៧ហិកតា (ស្មើនឹង៤១,៨%) នៃផ្ទៃដីសរុប។ ផ្ទៃដីចៀរជ័រសរុបមានចំនួន៧៨.៤៩៣ហិកតា ដែលមានផលិតផលចំនួន៨៥.២៤៤តោន កើនឡើង៣២% ធៀបនឹងឆ្នាំ២០១២។ ជាសន្និដ្ឋានរួម ការងារបង្កបង្កើនផលផ្នែកដំណាំឆ្នាំ២០១៣-២០១៤នេះ ទទួលបានលទ្ធផលល្អប្រសើរ។

រីឯផលិតកម្មសត្វជាពិសេស ការចិញ្ចឹមគោ ជ្រូក និងមាន់ទាជាលក្ខណៈគ្រួសារមានការវិវឌ្ឍន៍ជាវិជ្ជមានគួរកត់សម្គាល់ទាំងចំនួនសត្វទាំងបែបផែនផលិតកម្ម ដោយផលិតកម្មនេះអាចធានាការផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក។ ដោយឡែក បើប្រៀបធៀបនឹងឆ្នាំ២០១២ ការចិញ្ចឹមគោបានកើនឡើងពី៣,៣៧លានក្បាល ទៅដល់៣,៤៣លានក្បាល កើនឡើងប្រមាណ ១,៦% រីឯក្របីសរុបមានចំនួនជាង៦១៩ពាន់ក្បាល ថយចុះ៥,៧៦% និងជ្រូកចិញ្ចឹមបានជាង២,៤៤លានក្បាល កើនប្រមាណ ១០,៣៣%។ ការកើនឡើងចំនួនគោ ជ្រូក និងបក្សី បណ្តាលមកពីប្រជាជនមានយល់ដឹងពីការចិញ្ចឹមសត្វ ការចាក់ថ្នាំការពារទប់ស្កាត់បានជំងឺឆ្លងសត្វ ជាពិសេសនៅរដូវវស្សានិងទឹកជំនន់ដោយទន្លេមេគង្គមិនមានជំងឺឆ្លងគោក្របីផ្ទុះឡើងឡើយ។ បន្ថែមលើសពីនេះ តម្លៃសត្វរស់កើនឡើង មានទីផ្សារ និងជាប្រភពចំណូលសម្រាប់កសិករ។ ចំពោះដំណាំអចិន្ត្រៃយ៍ ដូចជា កៅស៊ូ ស្វាយចន្ទី ដំណាំឈើហូបផ្លែនិងដំណាំចម្ការ។ល។ កំពុងមានការរីកចម្រើនជាបន្តបន្ទាប់ជាលក្ខណៈគ្រួសារ និងជាលក្ខណៈ

វិនិយោគខ្នាតតូច មធ្យម និងធំ។ គួរកត់សម្គាល់ថា នៅឆ្នាំ២០១៣ ផ្ទៃដីដាំដុះកៅស៊ូនៅកម្ពុជាបានកើនឡើង១៧,៣% ធៀបនឹងឆ្នាំ២០១២ (២៨០.៣៥៥ហិកតា) ដែលរួមមាន÷ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) មានចំនួន៥៥.៩០៨ហិកតា (ស្មើនឹង១៧%) ផ្ទៃដីចម្ការកៅស៊ូសម្បទានសេដ្ឋកិច្ចមានចំនួន១៣៥.៤៤៦ហិកតា (ស្មើនឹង ៤១,២%) និងផ្ទៃដីចម្ការកៅស៊ូគ្រួសារតូចតាចនិងឯកជនមានចំនួន១៣៧.៤១៧ហិកតា (ស្មើនឹង៤១,៨%) នៃផ្ទៃដីសរុប។ ផ្ទៃដីចៀរជ័រសរុបមានចំនួន៧៨.៤៩៣ហិកតា ដែលមានផលិតផលចំនួន៨៥.២៤៤តោន កើនឡើង៣២%ធៀបនឹងឆ្នាំ២០១២។

វិស័យព្រៃឈើកំពុងតែត្រូវបានយកចិត្តទុកដាក់ខ្ពស់ សំដៅធានាឱ្យមាននិរន្តរភាពសម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើដល់ប្រជាជនក្រីក្រ តាមរយៈកំណែទម្រង់ព្រៃឈើ។ ក្នុងរយៈពេល៦ឆ្នាំ២០០៨-២០១៣ លទ្ធផលនៃការងារដាំឈើទទួលបានសរុបចំនួន១០៤.៣៧៧ហត ក្នុងនោះ ដាំដោយរដ្ឋបាលព្រៃឈើចំនួន៤.១៨៨ហត កងយោធពលខេមរភូមិន្ទចំនួន៣០០ហត បុគ្គលជាលក្ខណៈគ្រួសារចំនួន៦.១២០ហត រុក្ខទិវាចំនួន៤០៩ហត និងក្រុមហ៊ុនឯកជនចំនួន៩៣.៣៦០ហត។

ចំណែកឯវិស័យជលផល ការធ្វើអាជីវកម្មនេសាទទឹកសាបបានកើនឡើង៣,៧% ធៀបនឹងឆ្នាំមុន និងមានកំណើនប្រមាណ៣៥% ធៀបក្នុងរយៈពេល៥ឆ្នាំ (ឆ្នាំ២០០៩-២០១៣)។ អាជីវកម្មនេសាទសមុទ្របានកើនប្រមាណ ១១% និងមានកំណើនប្រមាណ៤៧%ធៀបក្នុងរយៈពេល៥ឆ្នាំ (ឆ្នាំ២០០៩-២០១៣)។ ការអភិវឌ្ឍវារីវប្បកម្ម ដូចជាការចិញ្ចឹមត្រី បង្គា ការភ្ញាស់កូនត្រីពូជ ក្រពើ កំពុងត្រូវបានអនុវត្តយ៉ាងសកម្ម និងសហគមន៍នេសាទចំនួន៥១៦សហគមន៍ត្រូវបានបង្កើត និងពង្រឹងសមត្ថភាពគ្រប់គ្រង។ ឆ្នាំ២០១៣ ក៏ជាការកត់សម្គាល់នូវកំណែទម្រង់ផ្តាច់ព្រ័ត្រក្នុងវិស័យជលផលក្រោមការដឹកនាំដ៏មោះមុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលឡូតិ៍នេសាទមានប្រវត្តិជាង១០០ឆ្នាំ ត្រូវបានរំសាយចោលដោយមួយភាគធំជូនប្រជាពលរដ្ឋប្រើប្រាស់ និងគ្រប់គ្រងតាមរយៈសហគមន៍នេសាទ និងមួយផ្នែកតូចទុកសម្រាប់អភិរក្សនិងបង្កើនផលស្តុកឡើងវិញ។ កំណែទម្រង់នេះបានរួមចំណែកយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល កំពុងត្រូវបានយកចិត្តទុកដាក់ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវគ្រប់រូបភាពនៃបទល្មើសផ្សេងៗ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ទន្ទឹមនឹងអនុវិស័យខាងលើ (ផលិតកម្មដំណាំស្រូវ ផលិតកម្មនិងបសុព្យាបាល ផលិតកម្មដំណាំកៅស៊ូ រុក្ខកម្ម ជលផល) ផ្នែកសេវាកម្មនិងការគាំទ្រផ្សេងៗ ក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល ជាពិសេសការងារស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសបានជួយឲ្យផលិតកម្ម និងអាជីវកម្មមានសភាពប្រែប្រួលទាំងបរិមាណ និងគុណភាព ពោលបរិមាណផលិតផលកើនឡើង គុណភាពកាន់តែប្រសើរ ប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែខ្ពស់ជាមួយការប្រែប្រួលផ្នត់គំនិត និងសមត្ថភាពកសិករក្នុងការប្រកួតផលិតកម្មក្នុងទីផ្សារ។ ដោយឡែក ផ្នែកផ្សេងៗទៀត ដូចជាការងារវិនិយោគសាធារណៈ ការរៀបចំគម្រោងជាច្រើនសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ការងារវិនិយោគផ្នែកឯកជនលើវិស័យកសិកម្មមានការកើនឡើង ការងារស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ត្រូវបានអនុវត្តកាន់តែទូលំទូលាយ រួមនឹងកិច្ចការសហប្រតិបត្តិការអន្តរជាតិកាន់តែល្អប្រសើរឡើង និងការរៀបចំលិខិតបទដ្ឋានច្បាប់ លិខិតបទដ្ឋានក្រោមច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ត្រូវបានរៀបចំរួចរាល់បានកាន់តែច្រើនជាលំដាប់ផងដែរ។

ជារួមសមិទ្ធផល ដែលសម្រេចបានដូចក្នុងរបាយការណ៍លំអិតនេះ គឺជាផ្លែផ្កានៃកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍នានា និងការខិតខំយ៉ាងសស្រាក់សស្រាំរបស់ប្រជាកសិករ និងផ្នែកឯកជនក្រោមបរិការណ៍ស្រុកទេសមានសុខសន្តិភាព និងក្តីសង្ឃឹមចំពោះអនាគតសម្បូរណ៍រុងរឿង។

**៧-ទិសដៅរួម**

វិស័យកសិកម្មជាវិស័យអាទិភាព ដែលរាជរដ្ឋាភិបាលបានកំណត់ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ តាមរចនាសម្ព័ន្ធមុំបួននៃចតុកោណប្រទាក់ក្រឡាគ្នា ដែលជាមូលដ្ឋានគ្រឹះដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងរៀបចំកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០១៤-២០១៨) និងផែនការសកម្មភាពរបស់ខ្លួន ឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបានដាក់បញ្ចូលនូវសកម្មភាពអាទិភាពតាមផ្នែក នៅក្នុងគម្រោងវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិលសំដៅការស្វែងរកប្រភពទុន និងជំនួយពីដៃគូអភិវឌ្ឍន៍ ក្នុងការធ្វើឱ្យសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ។ ដោយឡែកសម្រាប់ឆ្នាំ២០១៣-២០១៤នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវទិសដៅរួមមួយចំនួនដូចខាងក្រោម÷

១. បន្តបង្កើនផលិតភាពស្រូវ និងដំណាំផ្សេងៗទៀត តាមរយៈការពង្រឹង ពង្រីកនិងធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេសដាំដុះ ថែទាំ និងការពារ និងព័ត៌មានទីផ្សារកសិកម្ម ដោយជំរុញសេវាទាំងនេះឲ្យមានរចនាសម្ព័ន្ធដល់មូលដ្ឋាន ហើយផ្សារភ្ជាប់ជាមួយនឹងបណ្តាញស្ម័គ្រចិត្ត និងដៃគូដែលមានការពាក់ព័ន្ធ ការលើកកម្ពស់ការស្រាវជ្រាវ ដើម្បីបង្កើនផលិតភាព និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការផលិត និងប្រើប្រាស់ពូជដែលមានគុណភាព និងឆ្លើយតបនឹងសេចក្តីត្រូវការទីផ្សារ ការកសាងនិងស្តារហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ការបន្តកែលម្អប្រព័ន្ធប្រមូលនិងទុកដាក់កសិផល ការរៀបចំនិងកែសម្រួលក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងការផលិតពូជ ការប្រើប្រាស់ធាតុចូលកសិកម្មតាមបច្ចេកទេស ការរៀបចំនិងពង្រឹងសហគមន៍កសិកម្ម ជំរុញការអនុវត្តប្រព័ន្ធផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការគ្រប់គ្រងដីធ្លីកសិកម្ម ព្រមទាំងការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យកសិកម្ម។

២. បន្តជំរុញពិពិធកម្មដំណាំកសិកម្មតាមរយៈ ការលើកកម្ពស់ការស្រាវជ្រាវ និងអភិវឌ្ឍ ការផ្សព្វផ្សាយមុខដំណាំថ្មីៗដែលមានសក្តានុពលសម្រាប់ដាំដុះនិងការនាំចេញ ទាក់ទាញវិនិយោគឯកជន ពិសេសការស្រាវជ្រាវ ការផលិត ការចែកចាយពូជ និងកែច្នៃកសិផល ការសហការជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់ក្នុងការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗដល់កសិករ និងជំរុញការប្រើប្រាស់ និងណែនាំការប្រើប្រាស់គ្រឿងយន្តកសិកម្មឲ្យប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច។

៣. បន្តលើកកម្ពស់ពាណិជ្ជូបនីយកម្ម តាមរយៈជំរុញការអនុវត្តច្បាប់ និងគោលនយោបាយ ការពង្រឹងយន្តការស្ថាប័នដើម្បីជំរុញការធ្វើពាណិជ្ជកម្ម និងការនាំចេញកសិផល រួមមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់សហគមន៍កសិកម្ម ការលើកម្ពស់សមត្ថភាពផលិត កែច្នៃបឋម និងកែច្នៃផលិតផលសម្រេច ការកែលំអនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមមានយន្តការច្រកចេញចូលតែមួយ ការលើកស្ទួយភាពជាដៃគូរវាងកសិករនិងពាណិជ្ជករ ក៏ដូចជាការលើកស្ទួយភាពជាដៃគូរវាងកសិ-ឧស្សាហកម្មខ្នាតធំ និងកសិកម្មជាលក្ខណៈគ្រួសារ។

៤. ពង្រឹងនិងពង្រីកភាពជាដៃគូរវាងផ្នែកសាធារណៈ និងផ្នែកឯកជនលើវិស័យកសិកម្ម ដើម្បីការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ក្នុងផ្នែកចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយផ្តោតលើការគាំទ្រក្នុងការចែកចាយធាតុចូលកសិកម្មដូចជាពូជ ជី ថ្នាំកសិកម្ម គ្រឿងយន្តកសិកម្ម ការផ្គត់ផ្គង់ទឹក។ល។ ព្រមទាំងសេវាគាំទ្របច្ចេកទេសកសិកម្ម និងបច្ចេកវិទ្យា ការផ្តល់ឥណទាន ការផលិតពូជ និងចំណីសត្វ បសុសត្វ និងធ្វើកសិធុរកិច្ចជាមួយកសិករ និងសហគមន៍កសិកម្ម តាមរយៈប្រព័ន្ធផលិតកម្មកសិកម្មតាមកិច្ចសន្យា។

៥. លើកកម្ពស់និងជំរុញការចិញ្ចឹមសត្វតាមគ្រប់រូបភាពឲ្យមានការអភិវឌ្ឍនិងមានប្រសិទ្ធភាពសេដ្ឋកិច្ច សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុកនិងការនាំចេញ ដោយគិតគូរដល់សុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការទីផ្សារ។ ដើម្បីសម្រេចបាននូវគោលដៅនេះ ក្រសួងត្រូវជំរុញអនុម័តផែនការយុទ្ធសាស្ត្រស្តីពីផលិតកម្មសត្វ ជាពិសេសជំរុញអនុម័តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វនាឆ្នាំ២០១៤នេះ។ បន្ថែមលើសពីនេះត្រូវរៀបចំកែលំអរចនាសម្ព័ន្ធអង្គភាពផលិតកម្មនិងបសុព្យាបាលឲ្យបានសមស្របដើម្បីគ្រប់គ្រងវិស័យនេះមានការរីកចំរើនមានប្រសិទ្ធភាពការងារខ្ពស់ ស្របតាមកំណែទម្រង់របស់រាជរដ្ឋាភិបាល មានសុខដុមនីយកម្មនិងអនុវត្តបាននូវកាតព្វកិច្ចអន្តរជាតិ ក្នុងគោលដៅបង្កើនផលិតកម្មសត្វ បង្ការ ទប់ស្កាត់ ការពារ

សុខភាពសត្វនិងសុខភាពសាធារណៈ សម្របសម្រួលពាណិជ្ជកម្មសត្វនិងផលិតផលមានដើមកំណើតពីសត្វ ជាមួយនឹងការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានអនាម័យនិងភូតគាមអនាម័យ។

៦. បន្តកិច្ចខិតខំជំរុញការចងក្រង និងពង្រឹងសមត្ថភាពសហគមន៍កសិកម្មនៅទូទាំងប្រទេស ដែលជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្ដុំក្នុងភាពជាដៃគូជាមួយផ្នែកឯកជន ក្រោមក្របខ័ណ្ឌផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការអនុវត្តកសិកម្មល្អ ដែលនឹងជួយឱ្យកសិករទទួលបានទាំងបច្ចេកវិទ្យាថ្មី ឥណទានគ្រប់គ្រាន់ធានាបានស្ថេរភាពនៃការផ្គត់ផ្គង់កសិផលទៅកាន់ទីផ្សារទាំងបរិមាណនិងគុណភាព និងពិសេសទទួលបាននូវចំណូលខ្ពស់ និងកម្រៃប្រកបដោយសមធម៌ដែលអាចនាំឱ្យគ្រួសារកសិករអាចចាកផុតពីភាពក្រីក្របានឆាប់រហ័ស។

៧. ត្រូវជំរុញការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ដោយបន្តជំរុញរៀបចំច្បាប់ស្ដីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ការងារអង្កេតសិក្សា វាយតម្លៃ និងការធ្វើសារពើភណ្ឌការប្រើប្រាស់ដីកសិកម្មឱ្យបាននៅទូទាំងប្រទេស ដើម្បីទទួលបាននូវទិន្នន័យជាក់លាក់ជាធាតុចូលបម្រើឱ្យការរៀបចំផែនការអភិវឌ្ឍន៍វិស័យកសិកម្ម ដែលអាចកំណត់បានតំបន់ដាំដុះច្បាស់លាស់ ដើម្បីតម្រង់ទិសដល់ការធ្វើប្រពលវប្បកម្ម និងពិពិធភាវូបនីយកម្មកសិកម្មប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងធានានិរន្តរភាពនៃការប្រើប្រាស់ដីកសិកម្ម។ ចូលរួមទប់ទល់និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការពារបរិស្ថានធម្មជាតិ។

៨. បន្តជំរុញការអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជាឆ្នាំ ២០១១-២០២០ និង បន្តជំរុញការចងក្រងសហគមន៍កៅស៊ូគ្រួសារឱ្យបានច្រើន ដោយបង្កើនការជួយគាំទ្រផ្នែកបច្ចេកទេស ពិសេសការជ្រើសរើសពូជ ការថែទាំ ការព្យាបាលជំងឺ ការប្រមូលផល និងការកែច្នៃ ដោយត្រូវជំរុញការអភិវឌ្ឍកៅស៊ូ កសិ-ឧស្សាហកម្មលើដីសម្បទានសេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាលបានផ្ដល់ឱ្យវិនិយោគិនក្នុងស្រុកនិងបរទេស សម្រាប់ការអភិវឌ្ឍដោយទ្រង់ទ្រាយធំ សម្រាប់ធ្វើជាស្នូលនៃការអភិវឌ្ឍកៅស៊ូគ្រួសារនៅក្នុងតំបន់ សំដៅបង្កើនខ្សែចង្វាក់តម្លៃឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ច ដោយរាប់ចាប់តាំងពីការកែលម្អគុណភាពចម្ការ ការកែច្នៃ និងការធ្វើពាណិជ្ជកម្មផលិតផលជ័រកៅស៊ូឱ្យសមស្របតាមស្តង់ដារអន្តរជាតិ។ ដើម្បីឱ្យចម្ការកៅស៊ូឈានទៅរកវិបុលកម្មទំនើប ហើយដើរឱ្យទាន់សម័យវិទ្យាសាស្ត្រផង និងក៏ជាឱកាសរបស់កម្ពុជាកំពុងតែមានសម្រាប់ការអភិវឌ្ឍចម្ការកៅស៊ូ ដែលរាជរដ្ឋាភិបាលបានផ្ដល់ដីសម្បទានសេដ្ឋកិច្ចផង ផ្ដល់កម្មសិទ្ធិដីជូនប្រជាពលរដ្ឋផងនោះ ដូច្នេះការដាំដុះថ្មី ចាំបាច់គឺត្រូវសម្រិតសម្រាំងពូជ ដើម្បីទទួលបានទិន្នផលខ្ពស់។ ចំណុចនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូនិងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) នឹងសហប្រតិបត្តិការជាមួយភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ អនុវត្តគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូ ធ្វើយ៉ាងណាឱ្យពូជកៅស៊ូមានគុណភាពនិងទិន្នផលខ្ពស់ និងអភិវឌ្ឍកៅស៊ូគ្រួសារ។ ទន្ទឹមនេះត្រូវពង្រីកទីតាំងមន្ទីរពិសោធន៍មូលដ្ឋាន និងពង្រឹងបច្ចេកទេស បច្ចេកវិទ្យាកៅស៊ូ និងបង្កើនសមត្ថភាពគ្រប់គ្រងច្បារពូជ សម្រាំងពូជ បង្កាត់ពូជ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

៩. ក្រោយការកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២ រាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទទាំងអស់ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារនិងធ្វើជាកន្លែងអភិរក្សជលផល ត្រូវបន្តអនុវត្តអនុសាសន៍ទាំង៧ចំណុចដែលរាជរដ្ឋាភិបាលបានកែទម្រង់វិស័យជលផលស៊ីជម្រៅកន្លងមក។ បន្តរៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សនិងកន្លែងនេសាទគ្រួសារឱ្យបានច្បាស់លាស់ ដោយសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធព្រមទាំងត្រូវពង្រឹងការបង្ក្រាបបទល្មើស និងការពារកន្លែងអភិរក្សជលផល។ បន្តពង្រឹងទំនាក់ទំនងសហការរវាងមន្ត្រីរដ្ឋបាលជលផលជាមួយគណៈបញ្ជាការឯកភាពខេត្ត ក្រុង ស្រុក និងកងកំលាំងប្រដាប់អាវុធ សហគមន៍នៅមូលដ្ឋាន ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល និងរក្សាធនធានជលផលឱ្យបានគង់វង្ស។ បន្តខិតខំពង្រឹងសមត្ថភាពរបស់សហគមន៍នេសាទដែលបានបង្កើតឡើងរួចហើយចំនួន៥១៦សហគមន៍ឱ្យបានរឹងមាំ ក្លាយជាសហគមន៍នេសាទគ្មានបទល្មើសជលផល ទាំងទឹកសាបនិងសមុទ្រ។ បន្តយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទដូចជា ការចិញ្ចឹមត្រីទាំងទឹកសាបនិងសមុទ្រជាពិសេស ក្នុងស្រះ ក្នុងបែ និងក្នុងស្រែទៅតាមស្ថានភាពជាក់ស្ដែង នៅតំបន់ដែលខ្សត់ទឹក ខ្វះខាតត្រី ដោយលើកទឹកចិត្តនិងជំរុញការចិញ្ចឹមត្រីខ្នាតតូចជាលក្ខណៈគ្រួសារ។ ជំរុញការបង្កើតស្ថានីយ៍ផលិតកូនត្រីពូជឱ្យបានច្រើនកន្លែងដើម្បីធានាតម្រូវការក្នុងស្រុក និងត្រូវជំរុញការរៀបចំបង្កើតសហគមន៍ស្រះជម្រកត្រីឱ្យបានច្រើនបន្ថែមទៀតនៅតាមឃុំទូទាំងប្រទេស ព្រោះ

នេះជាវិធីសាស្ត្រមួយចំណាយទុនតិចហើយធ្វើឱ្យត្រីសំបូរឡើងវិញ។ បន្តធ្វើការសិក្សាស្រាវជ្រាវពីផលស្តុកធម្មជាតិទាំងទឹកសាបនិងសមុទ្រ សំដៅធានាការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព។

១០. ចាត់វិធានការនានាសំដៅបញ្ឈប់ការកាប់រាន ដុត ហ៊ុមព័ទ្ធ រំលោភយកដីព្រៃឈើធ្វើជាកម្មសិទ្ធិ និងជំរុញឱ្យប្រជាពលរដ្ឋទាំងអស់ចូលរួមដាំដើមឈើនៅតាមមូលដ្ឋាន ដើម្បីចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងស្នើឱ្យអាជ្ញាធរមានសមត្ថកិច្ច ពិសេសមន្ត្រីរដ្ឋបាលព្រៃឈើទាំងអស់ សហការជាមួយក្រុមការងារថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អនុវត្តវិធានការទាំងនេះឱ្យមានប្រសិទ្ធភាព។ ដោយឡែកការពង្រឹងសហគមន៍ព្រៃឈើក៏ដូចជាសកម្មភាពអាទិភាព ដែលត្រូវតែអនុវត្តបន្តពិសេសបង្វែរជីវិតរបស់ប្រជាពលរដ្ឋដែលពឹងអាស្រ័យលើផលអនុផលព្រៃឈើឱ្យមកធ្វើកសិកម្មចម្រុះវិញ។ ទន្ទឹមនឹងនេះ ក៏ត្រូវបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវបទបញ្ជារបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញនាពេលថ្មីៗនេះ អំពីការបង្ក្រាបបទល្មើសព្រៃឈើ ពិសេស ឈើក្រញូងឱ្យមានប្រសិទ្ធភាពបំផុត។ លើសពីនេះទៀត ក្រសួងនឹងចាត់អង្គភាពជំនាញនីមួយៗដែលពាក់ព័ន្ធត្រូវបន្តចុះពិនិត្យផ្ទៀងផ្ទាត់ជាប្រចាំនូវសកម្មភាពវិនិយោគរបស់ក្រុមហ៊ុនទទួលដីសម្បទាននានា និងដែលបានចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល ដើម្បីធានាដល់កិច្ចដំណើរការនៃសកម្មភាពវិនិយោគផង ការបង់ថ្លៃសម្បទានដីជូនរដ្ឋតាមកាលកំណត់ផង និងការទប់ស្កាត់នូវភាពអសកម្មផ្សេងៗដែលអាចកើតមានទាក់ទងនឹងដីសម្បទានផង។ បន្ថែមលើនេះ បន្តជំរុញការកំណត់ព្រំប្រទល់ដែនព្រៃ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងការបន្តកំណត់តំបន់ព្រៃឈើរេចរិលដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសហការជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ បន្តអនុវត្តដោយយកចិត្តទុកដាក់ខ្ពស់ និងប្រកបដោយប្រសិទ្ធភាពលើកិច្ចការទាំងអស់នេះ ហើយសមិទ្ធិផលថ្មីៗដែលនឹងបង្កើតឡើងពិតជានឹងរួមចំណែកយ៉ាងសំខាន់ដល់កិច្ចអភិវឌ្ឍនិងវិបុលភាព នៅលើមូលដ្ឋានកាន់តែទូលាយជាងមុនប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈកាន់តែអំណោយផលដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិប្រកបដោយចិរភាព។

## ៨. ការវាយតម្លៃនិងសន្និដ្ឋាន

លទ្ធផលការងារក្នុងវិស័យកសិកម្មឆ្នាំ២០១៣-២០១៤ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជាប្រមុខ និងដោយការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីក្រសួងស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនិងការខិតខំតស៊ូមិនចេះនឿយហត់របស់ប្រជាពលរដ្ឋជាកសិករនោះ បានបង្ហាញឱ្យឃើញពីវឌ្ឍនភាពការងារផលិតកម្មអាជីវកម្មនិងសេវាកម្មកសិកម្ម ដោយទទួលបាននូវការរីកចម្រើនលើគ្រប់ផ្នែក ជាពិសេសលើការងារផលិតកម្មដំណាំ ដែលមានការកើនឡើងខ្ពស់លើសឆ្នាំមុនៗ។ ដោយសារឆ្នាំនេះ បានជួបប្រទះនូវគ្រោះធម្មជាតិ ទឹកជំនន់ធ្ងន់ធ្ងរ បានធ្វើឱ្យបរិមាណផលិតផលស្រូវមានកំណើនទាបជាងបណ្តាឆ្នាំកន្លងមក។

ការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ ដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ក៏មានវឌ្ឍនភាពគួរជាទីពេញចិត្តជាមួយនិន្នាការកើនឡើងជាលំដាប់។ ជាក់ស្តែងក្នុងនោះនៅឆ្នាំ២០១៣ កម្ពុជានាំអង្ករចេញផ្លូវការបានកើនជិតពីរដងប្រៀបធៀបនឹងឆ្នាំ២០១២ ក៏ប៉ុន្តែគោលដៅមួយលានតោននៅឆ្នាំ២០១៥ ជាវិញ្ញាសារដ៏តឹងតែងមួយ។

ទន្ទឹមនឹងការកើនឡើងខ្ពស់នូវបរិមាណផលស្រូវ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្ម ជាពិសេសដំណាំកៅស៊ូគ្រួសារនិងដំណាំកៅស៊ូឯកជន បានកើនឡើងគួរជាទីពេញចិត្ត។ កំណែទម្រង់វិស័យជលផល និងព្រៃឈើក៏កំពុងបានផលផ្លែផ្តារួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ ជាមួយនឹងសន្តិសុខនិងសុវត្ថិភាពជីផ្លែ ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ដែលជាបុរេលក្ខខណ្ឌដ៏សំខាន់មួយក្នុងការបង្កើតនូវវឌ្ឍនភាពនៃផលិតកម្មដំណាំនិងការចិញ្ចឹមសត្វនិយាយដោយឡែក និងការអភិវឌ្ឍវិស័យកសិកម្មនិយាយជារួម។ រីឯការងារសេវាកម្មផ្សេងៗ រួមមានការងារសេវាកម្មបច្ចេកទេស និងការងារសេវាកម្មរដ្ឋបាលគ្រប់គ្រងបុគ្គលិក បណ្តុះបណ្តាលអភិវឌ្ឍន៍ធនធានមនុស្ស ការងារគោលនយោបាយផែនការហិរញ្ញវត្ថុ ក៏ត្រូវបានពង្រឹងនិងកែលម្អ ឱ្យទទួលបានប្រសិទ្ធភាព ដើម្បីរត់តាមស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍជាសកល។

ទោះយ៉ាងណាក្តី ការគិតគូរលើទិដ្ឋភាពសេដ្ឋកិច្ចកំណើននៃវិស័យផលិតកម្មកសិកម្មនៅឆ្នាំ២០១៣ មានកម្រិតទាបពោលគឺ មានប្រមាណជិត ២ ភាគរយ ប្រៀបធៀបនឹងបណ្តាឆ្នាំកន្លងមកមាន ៤,៥ភាគរយ។ មូលហេតុបណ្តាលមកពីការធ្លាក់ចុះនៃកំណើនផលិតផលស្រូវ និងកំណើនផលិតផលដំណាំផ្សេងៗ ដោយសារគ្រោះធម្មជាតិធ្ងន់ធ្ងរ ពិសេសទឹកជំនន់។ សភាពការណ៍នេះ បានបង្ហាញអំពីភាពប្រឈមច្រើនឬរងឥទ្ធិពលច្រើនពីកត្តាធម្មជាតិ ហើយក៏មិនត្រូវភ្លេចពីបញ្ហាប្រឈមនិងការរងឥទ្ធិពលមិនល្អពីការគៀបសង្កត់លើផលិតផលនាំចូលពីបរទេសផងដែរ៕

រាជធានីភ្នំពេញ, ថ្ងៃទី ខែមីនា ឆ្នាំ២០១៤

# លទ្ធផលបញ្ចប់ស្រូវរដូវវស្សាឆ្នាំ ២០១៣

ឧបសម្ព័ន្ធទី ១

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហត) | ផ្ទៃដីភ្ជួររាស់ (ហត) | | ផ្ទៃដីសាប (ហត) | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហត) | | | | | | សរុបស្ទូង និង ព្រោះ បុកដាំ (ហត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ស្រូវស្រាល | | កណ្តាល | ធ្ងន់ | ចំការ | ឡើងទឹក | | |
| | | | សរុប | គោ-ក្របី | | សរុប | បង្កើនរដូវ | | | | | | |
| 01 | បន្ទាយមានជយ័ | 230,000 | 231,700 | 1,834 | 3,263 | 56,274 | 21,905 | 108,907 | 52,415 | - | 13,036 | 230,632 | 100.27 |
| 02 | បាត់ដំបង | 251,000 | 543,736 | 9,477 | 2,215 | 72,596 | 24,605 | 106,894 | 99,263 | 1,566 | 16,674 | 296,993 | 118.32 |
| 03 | កំពង់ចាម | 165,500 | 171,160 | 52,481 | 14,153 | 27,112 | 8,893 | 63,959 | 75,686 | 12 | 1,050 | 167,819 | 101.40 |
| 04 | កំពង់ឆ្នាំង | 108,550 | 207,706 | 82,353 | 18,161 | 8,696 | 1,424 | 89,290 | 21,055 | 110 | 1,500 | 120,651 | 111.15 |
| 05 | កំពង់ស្ពឺ | 113,600 | 258,013 | 195,131 | 15,349 | 21,636 | 1,623 | 71,623 | 22,032 | 338 | - | 115,629 | 101.79 |
| 06 | កំពង់ធំ | 210,000 | 215,191 | 93,455 | 9,465 | 35,554 | 11,167 | 100,583 | 60,875 | 4,479 | 13,700 | 215,191 | 102.47 |
| 07 | កំពត | 126,000 | 135,095 | 72,741 | 18,761 | 17,072 | 17,072 | 79,449 | 38,234 | 31 | 309 | 135,095 | 107.22 |
| 08 | កណ្តាល | 41,000 | 52,948 | 14,181 | 2,213 | 11,927 | 4,967 | 15,376 | 12,153 | 1,592 | 62 | 41,110 | 100.27 |
| 09 | កោះកុង | 10,150 | 9,752 | 3,779 | 829 | 2,993 | - | 4,959 | 1,142 | 1,280 | - | 10,374 | 102.21 |
| 10 | ក្រចេះ | 32,100 | 33,267 | 9,127 | 3,174 | 12,996 | 785 | 15,565 | 4,234 | 65 | - | 32,860 | 102.37 |
| 11 | មណ្ឌលគិរី | 20,000 | 22,296 | 2,783 | 2,374 | 3,354 | 199 | 10,988 | 4,706 | 3,872 | - | 22,920 | 114.60 |
| 12 | ភ្នំពេញ | 11,557 | 11,564 | 5,103 | 1,451 | 3,256 | 594 | 5,120 | 3,775 | - | - | 12,151 | 105.14 |
| 13 | ព្រះវិហារ | 72,800 | 72,773 | 8,451 | 5,469 | 13,072 | - | 34,783 | 26,645 | 3,122 | - | 77,622 | 106.62 |
| 14 | ព្រៃវែង | 250,000 | 281,711 | 51,161 | 7,017 | 87,518 | 31,668 | 157,877 | 34,454 | - | 45 | 279,894 | 111.96 |
| 15 | ពោធិសាត់ | 98,000 | 119,641 | 29,640 | 9,341 | 38,176 | 220 | 34,134 | 25,417 | 1,485 | 11,571 | 110,783 | 113.04 |
| 16 | រតនគិរី | 27,000 | 14,427 | 6,125 | 1,396 | 3,617 | - | 5,145 | 5,665 | 12,745 | - | 27,172 | 100.64 |
| 17 | សៀមរាប | 180,000 | 216,895 | 79,130 | 14,045 | 40,700 | - | 88,810 | 39,195 | 7,025 | 8,115 | 183,845 | 102.14 |
| 18 | ព្រះសីហនុ | 16,000 | 17,000 | 4,250 | 1,212 | 1,805 | - | 10,298 | 4,380 | - | - | 16,483 | 103.02 |
| 19 | ស្ទឹងត្រែង | 27,000 | 24,755 | 6,190 | 2,355 | 14,083 | - | 9,680 | 992 | 2,909 | - | 27,664 | 102.46 |
| 20 | ស្វាយរៀង | 165,500 | 167,527 | 68,345 | 8,271 | 67,372 | 9,608 | 91,876 | 7,301 | | | 166,549 | 100.63 |
| 21 | តាកែវ | 170,000 | 390,241 | 160,923 | 16,443 | 100,323 | 52,916 | 92,021 | 9,222 | | | 201,566 | 118.57 |
| 22 | ឧត្តរមានជ័យ | 67,000 | 66,985 | 1,215 | 1,376 | 17,935 | - | 33,452 | 6,493 | 6,825 | - | 64,705 | 96.57 |
| 23 | កែប | 3,080 | 3,530 | 2,451 | 570 | 978 | 450 | 2,184 | 368 | - | - | 3,530 | 114.61 |
| 24 | ប៉ៃលិន | 4,000 | 6,485 | - | 22 | 1,174 | - | 3,065 | 2,159 | 87 | - | 6,485 | 162.13 |
| សរុប | | **2,399,837** | **3,274,398** | **960,326** | **158,925** | **660,219** | **188,096** | **1,236,038** | **557,861** | **47,543** | **66,062** | **2,567,723** | **107.00** |
| តួលេខឆ្នាំមុន | | **2,369,730** | **3,148,244** | **1,117,343** | **177,005** | **679,036** | **242,113** | **1,183,723** | **528,795** | **51,478** | **69,006** | **2,512,038** | **106.01** |
| ប្រៀបធៀប | | **30,107** | **126,154** | **-157,017** | **-18,080** | **-18,817** | **-54,017** | **52,315** | **29,066** | **-3,935** | **-2,944** | **55,685** | **0.99** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣

ឧបសម្ព័ន្ធទី ២

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដី អនុវត្ដបាន | ប៉ះពាល់និងខូចខាតដោយប្រការផ្សេងៗ | | | | | | | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | ផ្ទៃដីនៅសល់អាចប្រមូលផលបាន (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | | |
| 01 | បន្ទាយមានជយ័ | 230,632 | - | - | 73,011 | **73,011** | - | - | 28,778 | **28,778** | 5,144 | 206,998 |
| 02 | បាត់ដំបង | 296,993 | | | 136,183 | **136,183** | | | 41,715 | **41,715** | 14,792 | 270,070 |
| 03 | កំពង់ចាម | 167,819 | - | - | 12,059 | **12,059** | - | - | 6,861 | **6,861** | 5,066 | 166,024 |
| 04 | កំពង់ឆ្នាំង | 120,651 | - | 51 | 2,301 | **2,352** | - | 51 | 1,683 | **1,734** | - | 118,917 |
| 05 | កំពង់ស្ពឺ | 115,629 | 2,239 | - | - | **2,239** | - | - | - | **-** | - | 115,629 |
| 06 | កំពង់ធំ | 215,191 | - | - | 20,969 | **20,969** | - | - | 7,281 | **7,281** | 2,180 | 210,090 |
| 07 | កំពត | 135,095 | 2,000 | | | **2,000** | - | - | - | **-** | - | 135,095 |
| 08 | កណ្ដាល | 41,110 | 595 | - | 4,854 | **5,449** | - | - | 873 | **873** | 624 | 40,861 |
| 09 | កោះកុង | 10,374 | | 37 | 62 | **99** | - | - | 21 | **21** | - | 10,353 |
| 10 | ក្រចេះ | 32,860 | - | - | 5,737 | **5,737** | - | - | 3,424 | **3,424** | 1,681 | 31,117 |
| 11 | មណ្ឌលគិរី | 22,920 | - | - | 480 | **480** | - | - | 27 | **27** | - | 22,893 |
| 12 | ភ្នំពេញ | 12,151 | | | 50 | **50** | | | 10 | **10** | - | 12,141 |
| 13 | ព្រះវិហារ | 77,622 | - | - | 5,767 | **5,767** | - | - | 3,229 | **3,229** | - | 74,394 |
| 14 | ព្រៃវែង | 279,894 | - | - | 55,840 | **55,840** | - | - | 14,125 | **14,125** | 13,122 | 278,891 |
| 15 | ពោធិសាត់ | 110,783 | - | - | 15,226 | **15,226** | - | - | 6,585 | **6,585** | 255 | 104,453 |
| 16 | រតនគិរី | 27,172 | - | - | 4,635 | **4,635** | - | - | 1,985 | **1,985** | 10 | 25,197 |
| 17 | សៀមរាប | 183,845 | - | - | 12,766 | **12,766** | - | - | 6,090 | **6,090** | 1,310 | 179,065 |
| 18 | ព្រះសីហនុ | 16,483 | - | 10 | 40 | **50** | - | - | - | **-** | - | 16,483 |
| 19 | ស្ទឹងត្រែង | 27,664 | - | - | 8,070 | **8,070** | - | - | 3,046 | **3,046** | 670 | 25,288 |
| 20 | ស្វាយរៀង | 166,549 | 1,152 | | 1,933 | **3,085** | 178 | 497 | | **675** | 439 | 166,313 |
| 21 | តាកែវ | 201,566 | 3,556 | - | 1,995 | **5,551** | - | - | 864 | **864** | 864 | 201,566 |
| 22 | ឧត្តរមានជ័យ | 64,705 | - | - | 6,956 | **6,956** | - | - | 784 | **784** | - | 63,921 |
| 23 | កែប | 3,530 | - | - | - | **-** | - | - | - | **-** | - | 3,530 |
| 24 | ប៉ៃលិន | 6,485 | - | - | 753 | **753** | - | - | 253 | **253** | - | 6,232 |
| សរុប | | **2,567,723** | **9,542** | **98** | **369,687** | **379,327** | **178** | **548** | **127,634** | **128,360** | **46,157** | **2,485,521** |
| ឆ្នាំមុន | | **2,512,038** | **167,819** | **275** | **58,098** | **226,192** | **19,420** | **95** | **16,510** | **36,025** | **8,819** | **2,484,832** |
| ប្រៀបធៀប | | **55,685** | **-158,277** | **-177** | **311,589** | **153,135** | **-19,242** | **453** | **111,124** | **92,335** | **37,338** | **689** |

# លទ្ធផលប៉ាន់ស្មានបណ្ដោះអាសន្ននៃផ្ទៃដីដាំដុះស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤

ឧបសម្ព័ន្ធទី ៣

| ល.រ | រាជធានី–ខេត្ត | ផែនការ (ហត) | ផ្ទៃដីដាំដុះ (ហត) | ផ្ទៃដីខូចខាតដោយ (ហត) | | | | ផ្ទៃដីប្រមូលផល (ហត) |
|---|---|---|---|---|---|---|---|---|
| | | | | ខ្វះទឹក | សត្វល្អិត | ទឹកជំនន់ដើមរដូវ | សរុប | |
| 01 | បន្ទាយមានជ័យ | 6,700 | 12,398 | 36 | - | 617 | 653 | 11,745 |
| 02 | បាត់ដំបង | 9,100 | 10,582 | 18 | - | - | 18 | 10,564 |
| 03 | កំពង់ចាម | 52,000 | 53,569 | - | - | - | - | 53,569 |
| 04 | កំពង់ឆ្នាំង | 24,200 | 35,566 | 120 | - | - | 120 | 35,446 |
| 05 | កំពង់ស្ពឺ | 870 | 645 | - | 5 | - | 5 | 640 |
| 06 | កំពង់ធំ | 15,000 | 41,540 | - | - | - | - | 41,540 |
| 07 | កំពត | 3,000 | 9,715 | - | - | - | - | 9,715 |
| 08 | កណ្ដាល | 62,000 | 65,058 | - | - | - | - | 65,058 |
| 09 | កោះកុង | - | - | - | - | - | - | - |
| 10 | ក្រចេះ | 14,000 | 14,116 | - | - | 363 | 363 | 14,083 |
| 11 | មណ្ឌលគិរី | - | - | - | - | - | - | - |
| 12 | ភ្នំពេញ | 1,440 | 1,440 | - | - | - | - | 1,440 |
| 13 | ព្រះវិហារ | 200 | 75 | - | - | - | - | 75 |
| 14 | ព្រៃវែង | 75,000 | 92,201 | - | - | - | - | 92,201 |
| 15 | ពោធិសាត់ | 8,270 | 9,963 | - | - | - | - | 9,963 |
| 16 | រតនៈគិរី | - | - | - | - | - | - | - |
| 17 | សៀមរាប | 16,200 | 18,440 | 400 | - | - | 400 | 18,040 |
| 18 | ព្រះសីហនុ | - | - | - | - | - | - | - |
| 19 | ស្ទឹងត្រែង | 130 | 141 | - | - | - | - | 141 |
| 20 | ស្វាយរៀង | 18,000 | 20,422 | 22 | | | 22 | 20,400 |
| 21 | តាកែវ | 75,000 | 96,532 | - | - | - | - | 96,532 |
| 22 | ឧត្តរមានជ័យ | 500 | 600 | - | - | - | - | 600 |
| 23 | កែប | 20 | 20 | - | - | - | - | 20 |
| 24 | ប៉ៃលិន | 2,000 | 1,674 | | | | - | 1,674 |
| **សរុប** | | **383,630** | **484,697** | **596** | **5** | **980** | **1,581** | **483,446** |

# បរិមាណផលស្រូវរដូវវស្សាឆ្នាំ២០១៣ និងរដូវប្រាំងឆ្នាំ ២០១៣-២០១៤

ឧបសម្ព័ន្ធទី ៤

| ល.រ | រាជធានី-ខេត្ត | រដូវវស្សាឆ្នាំ២០១៣ | | | | រដូវប្រាំងឆ្នាំ២០១៣-២០១៤ | | | | សរុបប្រចាំឆ្នាំ២០១៣-២០១៤ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) |
| 01 | បន្ទាយមានជ័យ | 230,632 | 206,998 | 2.821 | 584,007 | 12,398 | 11,745 | 3.820 | 44,862 | 243,030 | 218,743 | 2.875 | 628,869 |
| 02 | បាត់ដំបង | 296,993 | 270,070 | 2.794 | 754,700 | 10,582 | 10,564 | 3.873 | 40,911 | 307,575 | 280,634 | 2.835 | 795,611 |
| 03 | កំពង់ចាម | 167,819 | 166,024 | 3.330 | 552,860 | 53,569 | 53,569 | 4.245 | 227,422 | 221,388 | 219,593 | 3.553 | 780,282 |
| 04 | កំពង់ឆ្នាំង | 120,651 | 118,917 | 3.067 | 364,769 | 35,566 | 35,446 | 4.138 | 146,689 | 156,217 | 154,363 | 3.313 | 511,458 |
| 05 | កំពង់ស្ពឺ | 115,629 | 115,629 | 3.072 | 355,259 | 645 | 640 | 3.298 | 2,111 | 116,274 | 116,269 | 3.074 | 357,370 |
| 06 | កំពង់ធំ | 215,191 | 210,090 | 2.428 | 509,998 | 41,540 | 41,540 | 4.367 | 181,391 | 256,731 | 251,630 | 2.748 | 691,389 |
| 07 | កំពត | 135,095 | 135,095 | 3.065 | 414,115 | 9,715 | 9,715 | 4.131 | 40,130 | 144,810 | 144,810 | 3.137 | 454,245 |
| 08 | កណ្តាល | 41,110 | 40,861 | 3.097 | 126,541 | 65,058 | 65,058 | 4.178 | 271,835 | 106,168 | 105,919 | 3.761 | 398,376 |
| 09 | កោះកុង | 10,374 | 10,353 | 2.788 | 28,866 | - | - | - | | 10,374 | 10,353 | 2.788 | 28,866 |
| 10 | ក្រចេះ | 32,860 | 31,117 | 2.876 | 89,508 | 14,116 | 14,083 | 4.257 | 59,946 | 46,976 | 45,200 | 3.307 | 149,454 |
| 11 | មណ្ឌលគិរី | 22,920 | 22,893 | 2.481 | 56,798 | - | - | - | - | 22,920 | 22,893 | 2.481 | 56,798 |
| 12 | ភ្នំពេញ | 12,151 | 12,141 | 2.865 | 34,787 | 1,440 | 1,440 | 3.500 | 5,040 | 13,591 | 13,581 | 2.933 | 39,827 |
| 13 | ព្រះវិហារ | 77,622 | 74,394 | 2.870 | 213,540 | 75 | 75 | 2.907 | 218 | 77,697 | 74,469 | 2.870 | 213,758 |
| 14 | ព្រៃវែង | 279,894 | 278,891 | 2.985 | 832,545 | 92,201 | 92,201 | 4.646 | 428,366 | 372,095 | 371,092 | 3.398 | 1,260,911 |
| 15 | ពោធិសាត់ | 110,783 | 104,453 | 3.331 | 347,951 | 9,963 | 9,963 | 4.182 | 41,661 | 120,746 | 114,416 | 3.405 | 389,612 |
| 16 | រតនគិរី | 27,172 | 25,197 | 2.203 | 55,510 | - | - | - | - | 27,172 | 25,197 | 2.203 | 55,510 |
| 17 | សៀមរាប | 183,845 | 179,065 | 2.760 | 494,271 | 18,440 | 18,040 | 3.650 | 65,838 | 202,285 | 197,105 | 2.842 | 560,109 |
| 18 | ព្រះសីហនុ | 16,483 | 16,483 | 2.950 | 48,625 | - | - | - | - | 16,483 | 16,483 | 2.950 | 48,625 |
| 19 | ស្ទឹងត្រែង | 27,664 | 25,288 | 2.570 | 64,990 | 141 | 141 | 3.496 | 493 | 27,805 | 25,429 | 2.575 | 65,483 |
| 20 | ស្វាយរៀង | 166,549 | 166,313 | 2.726 | 453,338 | 20,422 | 20,400 | 4.209 | 85,864 | 186,971 | 186,713 | 2.888 | 539,202 |
| 21 | តាកែវ | 201,566 | 201,566 | 3.447 | 694,847 | 96,532 | 96,532 | 4.834 | 466,632 | 298,098 | 298,098 | 3.896 | 1,161,479 |
| 22 | ឧត្តរមានជ័យ | 64,705 | 63,921 | 2.524 | 161,311 | 600 | 600 | 4.500 | 2,700 | 65,305 | 64,521 | 2.542 | 164,011 |
| 23 | កែប | 3,530 | 3,530 | 3.213 | 11,342 | 20 | 20 | 3.609 | 72 | 3,550 | 3,550 | 3.215 | 11,414 |
| 24 | ប៉ៃលិន | 6,485 | 6,232 | 3.333 | 20,773 | 1,674 | 1,674 | 3.900 | 6,529 | 8,159 | 7,906 | 3.453 | 27,302 |
| **សរុប** | | **2,567,723** | **2,485,521** | **2.925** | **7,271,251** | **484,697** | **483,446** | **4.383** | **2,118,710** | **3,052,420** | **2,968,967** | **3.163** | **9,389,961** |
| **ឆ្នាំមុន** | | **2,512,038** | **2,484,832** | **2.872** | **7,136,139** | **495,507** | **495,465** | **4.349** | **2,154,801** | **3,007,545** | **2,980,297** | **3.117** | **9,290,940** |
| **ប្រៀបធៀប** | | **55,685** | **689** | **0.054** | **135,112** | **-10,810** | **-12,019** | **0.033** | **-36,091** | **44,875** | **-11,331** | **0.045** | **99,021** |

# តុល្យភាពស្បៀងតាមបណ្តារាជធានី-ខេត្តឆ្នាំ ២០១៤

ឧបសម្ព័ន្ធទី ៥

| ល.រ | រាជធានី-ខេត្ត | ចំនួនប្រជាជន (នាក់) | បរិមាណផល តោន | ទុកពូជ និងបាត់បង់ពេល ប្រមូលផល១៣% តោន | ស្រូវចំណីនៅសល់ (ក្រោយពីកាត់ចេញ១៣%) តោន | គិតជាអង្ករ ៦៤% តោន | តម្រូវការស្បៀង ជាអង្ករ តោន | តុល្យភាពស្បៀង (អង្ករ) តោន | តុល្យភាពស្បៀង (ស្រូវ) |
|---|---|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 740,294 | 628,869 | 81,753 | 547,116 | 350,154 | 105,862 | **244,292** | **381,707** |
| 02 | បាត់ដំបង | 1,141,085 | 795,611 | 103,429 | 692,181 | 442,996 | 163,175 | **279,821** | **437,220** |
| 03 | កំពង់ចាម | 1,773,038 | 780,282 | 101,437 | 678,845 | 434,461 | 253,544 | **180,917** | **282,682** |
| 04 | កំពង់ឆ្នាំង | 533,928 | 511,458 | 66,490 | 444,968 | 284,780 | 76,352 | **208,428** | **325,669** |
| 05 | កំពង់ស្ពឺ | 763,397 | 357,370 | 46,458 | 310,912 | 198,984 | 109,166 | **89,818** | **140,340** |
| 06 | កំពង់ធំ | 702,772 | 691,389 | 89,881 | 601,508 | 384,965 | 100,496 | **284,469** | **444,483** |
| 07 | កំពត | 616,816 | 454,245 | 59,052 | 395,193 | 252,924 | 88,205 | **164,719** | **257,373** |
| 08 | កណ្តាល | 1,120,987 | 398,376 | 51,789 | 346,587 | 221,816 | 160,301 | **61,515** | **96,117** |
| 09 | កោះកុង | 123,241 | 28,866 | 3,753 | 25,113 | 16,073 | 17,623 | **-1,551** | **-2,423** |
| 10 | ក្រចេះ | 349,392 | 149,454 | 19,429 | 130,025 | 83,216 | 49,963 | **33,253** | **51,958** |
| 11 | មណ្ឌលគិរី | 75,202 | 56,798 | 7,384 | 49,414 | 31,625 | 10,754 | **20,871** | **32,611** |
| 12 | ភ្នំពេញ | 1,727,544 | 39,827 | 5,178 | 34,649 | 22,176 | 247,039 | **-224,863** | **-351,349** |
| 13 | ព្រះវិហារ | 250,363 | 213,758 | 27,789 | 185,969 | 119,020 | 35,802 | **83,219** | **130,029** |
| 14 | ព្រៃវែង | 1,202,893 | 1,260,911 | 163,918 | 1,096,992 | 702,075 | 172,014 | **530,061** | **828,221** |
| 15 | ពោធិសាត់ | 443,655 | 389,612 | 50,650 | 338,963 | 216,936 | 63,443 | **153,494** | **239,834** |
| 16 | រតនគិរី | 191,029 | 55,510 | 7,216 | 48,294 | 30,908 | 27,317 | **3,591** | **5,611** |
| 17 | សៀមរាប | 928,335 | 560,109 | 72,814 | 487,295 | 311,869 | 132,752 | **179,117** | **279,870** |
| 18 | ព្រះសីហនុ | 256,284 | 48,625 | 6,321 | 42,304 | 27,074 | 36,649 | **-9,574** | **-14,960** |
| 19 | ស្ទឹងត្រែង | 125,124 | 65,483 | 8,513 | 56,970 | 36,461 | 17,893 | **18,568** | **29,013** |
| 20 | ស្វាយរៀង | 599,260 | 539,202 | 70,096 | 469,106 | 300,228 | 85,694 | **214,534** | **335,209** |
| 21 | តាកែវ | 939,809 | 1,161,479 | 150,992 | 1,010,487 | 646,712 | 134,393 | **512,319** | **800,498** |
| 22 | ឧត្តរមានជ័យ | 241,548 | 164,011 | 21,321 | 142,690 | 91,321 | 34,541 | **56,780** | **88,719** |
| 23 | កែប | 39,312 | 11,414 | 1,484 | 9,930 | 6,355 | 5,622 | **734** | **1,146** |
| 24 | ប៉ៃលិន | 64,887 | 27,302 | 3,549 | 23,753 | 15,202 | 9,279 | **5,923** | **9,255** |
| | សរុប | **14,950,196** | **9,389,961** | **1,220,695** | **8,169,266** | **5,228,330** | **2,137,878** | **3,090,452** | **4,828,832** |

**កំណត់សម្គាល់ ៖** យោងលើការធ្វើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ២០១៣ និងការធ្វើចំណោលឆ្នាំ២០១៤របស់ក្រសួងផែនការ

# តុល្យភាពស្បៀងផលិតផលស្រូវឆ្នាំ ២០១៤

ឧបសម្ព័ន្ធទី ៦

| កំរិតកំណត់ | ឯកត្តា | រដូវវស្សា | រដូវប្រាំង | សរុប |
|---|---|---|---|---|
| ផែនការដាំដុះ | ហ.ត | 2,399,837 | 383,630 | **2,783,467** |
| ផ្ទៃដីអនុវត្ត | ហ.ត | 2,567,723 | 484,697 | **3,052,420** |
| ផ្ទៃដីខូចខាត | ហ.ត | 128,360 | 1,581 | **129,941** |
| ផ្ទៃដីស្តារបាន | ហ.ត | 46,157 | 330 | **46,487** |
| ផ្ទៃដីប្រមូលផល | ហ.ត | 2,485,521 | 483,446 | **2,968,967** |
| ទិន្នផលមធ្យម | ត/ហ.ត | 2.925 | 4.383 | **3.163** |
| បរិមាណផល | តោន | 7,271,251 | 2,118,710 | **9,389,961** |

**កំណត់សម្គាល់**

| | | |
|---|---|---|
| - កាត់ចេញ ១៣ភាគរយ លើបរិមាណសរុបសំរាប់ទុកពូជ និងបាត់បង់ពេលប្រមូលផល | 1,220,695 | តោន |
| - ស្រូវចំណីនៅសល់ ក្រោយពីកាត់ចេញ ១៣%) | 8,169,266 | តោន |
| - សរុបស្បៀងដែលមាន គិតជាអង្ករ | 5,228,330 | តោន |
| - តម្រូវការស្បៀងមួយឆ្នាំ | 2,137,878 | តោន |
| - បរិមាណអង្ករលើស | **3,090,452** | តោន |
| - គិតជាស្រូវលើស | **4,828,832** | តោន |

# ផលិតកម្មដំណាំស្រូវរយៈពេល ១០ ឆ្នាំ ២០០៣-២០១២

ឧបសម្ព័ន្ធទី ៧

| ឆ្នាំកំរិតកំណត់ | ឯកតា | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | មធ្យមភាគ ១០ ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះប្រចាំឆ្នាំ | ហាត | **2,374,175** | **2,443,530** | **2,541,433** | **2,585,905** | **2,615,741** | **2,719,080** | **2,795,892** | **2,968,529** | **3,007,545** | **3,052,420** | **2,636,612** |
| - វស្សា | ហាត | *2,075,646* | *2,121,591* | *2,212,015* | *2,241,114* | *2,255,104* | *2,334,228* | *2,391,016* | *2,496,569* | *2,512,038* | *2,567,723* | *2,267,006* |
| - ប្រាំង | ហាត | *298,529* | *321,939* | *329,418* | *344,791* | *360,637* | *384,852* | *404,876* | *471,960* | *495,507* | *484,697* | *369,606* |
| ផ្ទៃដីប្រមូលផលប្រចាំឆ្នាំ | ហាត | **2,109,050** | **2,414,455** | **2,516,415** | **2,566,952** | **2,613,363** | **2,674,603** | **2,777,323** | **2,766,617** | **2,980,297** | **2,968,967** | **2,566,111** |
| - វស្សា | ហាត | *1,815,619* | *2,093,564* | *2,188,726* | *2,222,596* | *2,252,733* | *2,290,552* | *2,372,519* | *2,294,784* | *2,484,832* | *2,485,521* | *2,198,296* |
| - ប្រាំង | ហាត | *293,431* | *320,891* | *327,689* | *344,356* | *360,630* | *384,051* | *404,804* | *471,833* | *495,465* | *483,446* | *367,815* |
| ទិន្នផលប្រចាំឆ្នាំ | ត/ហាត | **1.977** | **2.479** | **2.489** | **2.621** | **2.746** | **2.836** | **2.970** | **3.173** | **3.117** | **3.163** | **2.651** |
| - វស្សា | ត/ហាត | *1.725* | *2.261* | *2.272* | *2.413* | *2.540* | *2.620* | *2.760* | *2.920* | *2.872* | *2.925* | *2.433* |
| - ប្រាំង | ត/ហាត | *3.536* | *3.901* | *3.938* | *3.959* | *4.030* | *4.126* | *4.201* | *4.406* | *4.349* | *4.383* | *3.962* |
| បរិមាណផលប្រចាំឆ្នាំ | តោន | **4,170,284** | **5,986,179** | **6,264,123** | **6,727,127** | **7,175,473** | **7,585,870** | **8,249,452** | **8,779,365** | **9,290,940** | **9,389,961** | **6,893,977** |
| - វស្សា | តោន | *3,132,581* | *4,734,300* | *4,973,694* | *5,363,690* | *5,722,142* | *6,001,385* | *6,548,709* | *6,700,439* | *7,136,139* | *7,271,251* | *5,415,104* |
| - ប្រាំង | តោន | *1,037,703* | *1,251,879* | *1,290,429* | *1,363,437* | *1,453,331* | *1,584,485* | *1,700,743* | *2,078,926* | *2,154,801* | *2,118,710* | *1,478,873* |
| សេចក្ដីត្រូវការស្បៀង | តោន | **1,905,896** | **2,013,533** | **2,053,983** | **2,096,025** | **1,970,270** | **1,979,214** | **2,076,542** | **2,108,022** | **2,142,178** | **2,137,878** | **2,028,223** |
| ស្បៀងសល់ ឬខ្វះ (អង្ករ) | តោន | **416,118** | **1,319,571** | **1,433,880** | **1,649,640** | **2,025,033** | **2,244,598** | **2,516,752** | **2,780,328** | **3,031,017** | **3,090,452** | **1,810,343** |
| ស្បៀងសល់ ឬខ្វះ (ស្រូវ) | តោន | ***650,184*** | ***2,061,830*** | ***2,240,438*** | ***2,577,562*** | ***3,164,114*** | ***3,507,185*** | ***3,932,425*** | ***4,344,263*** | ***4,735,964*** | ***4,828,832*** | ***2,828,662*** |

# ស្ថិតិផ្ទៃដីប្រមូលផល និង បរិមាណផល ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សាឆ្នាំ ២០១៣

ឧបសម្ព័ន្ធទី ៨ក

| ល.រ | រាជធានី-ខេត្ត | ពោតសរុប | | | ក្នុងនោះពោតក្រហម | | | ដំឡូងឈើ | | | ដំឡូងជ្វា | | | បន្លែគ្រប់មុខ | | | សណ្តែកបាយ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) | អនុវត្ត (ហ.ត) | ប្រមូលផល (ហ.ត) | បរិមាផល (ត) |
| 01 | បន្ទាយមានជ័យ | 4,881 | 4,766 | 19,226 | 4,349 | 4,234 | 12,681 | 47,727 | 40,325 | 808,868 | 120 | 120 | 942 | 1,338 | 1,338 | 10,194 | 350 | 350 | 359 |
| 02 | បាត់ដំបង | 118,087 | 99,213 | 503,422 | 117,533 | 98,682 | 510,295 | 61,507 | 46,969 | 1,692,895 | 99 | 99 | 532 | 806 | 690 | 3,547 | 16,118 | 15,602 | 13,924 |
| 03 | កំពង់ចាម | 22,124 | 22,124 | 54,762 | 7,685 | 7,685 | 39,961 | 67,566 | 67,387 | 1,326,626 | 381 | 381 | 3,151 | 6,112 | 6,112 | 100,985 | 7,053 | 7,044 | 7,169 |
| 04 | កំពង់ឆ្នាំង | 1,206 | 1,206 | 1,774 | - | - | - | 1,577 | 1,577 | 9,112 | 852 | 852 | 4,228 | 2,121 | 2,121 | 13,058 | 538 | 538 | 549 |
| 05 | កំពង់ស្ពឺ | 583 | 583 | 1,166 | - | - | - | 3,343 | 3,343 | 100,290 | 260 | 260 | 1,118 | 887 | 887 | 4,435 | 1,913 | 1,913 | 2,870 |
| 06 | កំពង់ធំ | 498 | 498 | 954 | - | - | - | 36,630 | 36,505 | 528,849 | 139 | 139 | 480 | 692 | 667 | 1,737 | 488 | 488 | 2,035 |
| 07 | កំពត | 1,487 | 1,487 | 3,209 | - | - | - | 754 | 754 | 1,603 | 544 | 544 | 2,441 | 1,483 | 1,483 | 5,466 | 762 | 762 | 1,406 |
| 08 | កណ្តាល | 12,443 | 12,357 | 62,631 | 10,697 | 10,697 | 54,407 | 8 | 8 | 64 | 30 | 30 | 180 | 5,034 | 4,481 | 20,573 | 71 | 71 | 57 |
| 09 | កោះកុង | 73 | 73 | 396 | - | - | - | 334 | 334 | 6,956 | 28 | 28 | 168 | 165 | 165 | 905 | - | - | - |
| 10 | ក្រចេះ | 2,463 | 2,463 | 6,172 | 2,085 | 2,085 | 5,292 | 46,810 | 46,810 | 1,042,378 | 66 | 66 | 533 | 498 | 498 | 3,976 | 171 | 171 | 148 |
| 11 | មណ្ឌលគិរី | 443 | 443 | 2,722 | - | - | - | 10,271 | 10,271 | 157,505 | - | - | - | 435 | 435 | 640 | 3,101 | 3,101 | 3,454 |
| 12 | ភ្នំពេញ | 128 | 128 | 640 | - | - | - | 35 | 35 | 350 | 33 | 33 | 82 | 447 | 447 | 3,129 | 24 | 24 | 24 |
| 13 | ព្រះវិហារ | 11,125 | 11,125 | 33,368 | 4,825 | 4,825 | 16,113 | 12,650 | 12,650 | 139,150 | 534 | 534 | 5,340 | 1,383 | 1,383 | 4,673 | 7,214 | 7,214 | 14,881 |
| 14 | ព្រៃវែង | 1,409 | 1,409 | 7,045 | 1,404 | 1,404 | 7,020 | 1,969 | 1,969 | 35,442 | - | - | - | 759 | 759 | 11,385 | 298 | 298 | 358 |
| 15 | ពោធិសាត់ | 6,445 | 5,536 | 20,218 | 5,412 | 5,412 | 19,765 | 5,342 | 5,342 | 160,260 | 87 | 87 | 479 | 495 | 495 | 2,970 | 1,831 | 1,831 | 2,380 |
| 16 | រតនគិរី | 119 | 119 | 742 | - | - | - | 13,590 | 13,356 | 273,794 | 34 | 34 | 173 | 48 | 48 | 223 | 539 | 539 | 488 |
| 17 | សៀមរាប | 535 | 530 | 1,545 | - | - | - | 9,855 | 8,860 | 135,260 | 375 | 370 | 2,006 | 1,895 | 2,322 | 20,096 | 630 | 630 | 757 |
| 18 | ក្រុងព្រះសីហនុ | 160 | 160 | 320 | - | - | - | 470 | 470 | 6,110 | 34 | 34 | 272 | 240 | 240 | 1,920 | - | - | - |
| 19 | ស្ទឹងត្រែង | 1,553 | 1,553 | 1,553 | 247 | 247 | 247 | 19,202 | 2,910 | 58,200 | 163 | 163 | 2,119 | 807 | 807 | 564 | 1,340 | 1,340 | 1,072 |
| 20 | ស្វាយរៀង | 13 | 13 | 65 | - | - | - | 10,571 | 10,326 | 174,910 | 459 | 459 | 4,591 | 1,817 | 1,817 | 18,324 | - | - | - |
| 21 | តាកែវ | 510 | 510 | 1,275 | | | | 1,189 | 1,189 | 10,701 | 255 | 255 | 1,454 | 1,696 | 1,696 | 25,440 | 514 | 514 | 411 |
| 22 | ឧត្តរមានជ័យ | 198 | 159 | 985 | 10 | 10 | 70 | 25,125 | 22,850 | 528,631 | 26 | 26 | 139 | 186 | 186 | 484 | 160 | 144 | 211 |
| 23 | ក្រុងកែប | 150 | 150 | 240 | - | - | - | 100 | 100 | 1,468 | 81 | 81 | 229 | 287 | 287 | 1,452 | - | - | - |
| 24 | ក្រុងប៉ៃលិន | 32,227 | 29,763 | 119,047 | 32,212 | 29,753 | 119,012 | 18,774 | 17,343 | 433,575 | - | - | - | 50 | 30 | 450 | 490 | 1 | 490 |
| សរុប | | **218,860** | **196,368** | **843,477** | **186,459** | **165,034** | **784,862** | **395,399** | **351,683** | **7,632,997** | **4,600** | **4,595** | **30,656** | **29,681** | **29,394** | **256,626** | **43,605** | **42,575** | **53,044** |
| ឆ្នាំមុន | | **182,004** | **181,264** | **820,348** | **160,672** | **159,373** | **756,085** | **332,740** | **308,686** | **6,773,041** | **4,972** | **4,972** | **29,619** | **36,506** | **36,506** | **257,605** | **49,961** | **49,823** | **54,883** |
| ប្រៀបធៀប | | **36,856** | **15,104** | **23,129** | **25,787** | **5,661** | **28,777** | **62,659** | **42,997** | **859,956** | **-372** | **-377** | **1,037** | **-6,825** | **-7,112** | **-979** | **-6,356** | **-7,248** | **-1,840** |

ឧបសម្ព័ន្ធទី ៨ខ

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី | | | សណ្តែកសៀង | | | ល្ង | | | អំពៅ | | | ក្រចៅ | | | ថ្នាំជក់ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
